អក្សរសិល្ប៍ខ្មែរ

គ្រប់គ្រងដោយគណៈកម្មាធិការ
COMMISSION DES MOEURS & COUTUMES

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ចោះពុម្ពដំបូង

អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ឃុនឥន្ទមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: លោកអាចារ្យ កៅ-សុីម. អ្នកគ្រូគណ្ឌ
សិស្សនៅសាលាបាលីជាន់ខ្ពស់

បញ្ជីក្រឹះ

ផ្នែកអក្សរសាស្ត្រ		ទំព័រ
លោក ហាន់-យេង	រឿងកំព្លឹងកំសត់	១
លោកគ្រូអាចារ្យ ពាង-សុខ..	និទានសុភាសិតទី ២.....	១៥
ឃុនឥន្ទមន្ត្រី ញ៉ុក-ថែម ...	ប្រជុំសុភាសិតខ្មែរ (តាមលំដាប់អក្សរ, តទៅ)	២២
.....	រឿងមាយើង (តាក្យកាព្យ, តទៅនឹងចប់)..	២៩
លោកឧកញ៉ាវង្សាសនោត្ថ តង.	លោកនេយ្យ (តាក្យកាព្យ, តទៅ)	៤៦
ផ្នែកសាសនា		
ព្រះគ្រូញាណសំវរៈ ញាណ-ឈិន	លោកធម្មសួត្រ (តទៅ).....	៥០

ឆ្នាំតំរង់ទី ១៦ — លេខ ១ ខែឃុំងអីរយោ ១៩៤៦ — ដំឡៃជាវ: ១ ឆ្នាំ ១៥ រៀល ។

KĂMPŬCHĔASŎRĬYA

Revue religieuse et littéraire éditée par l'Institut Bouddhique.
Rédacteur en chef de la partie littéraire : Khun Nibandhamantri Nhok-Thĕm, Pandit à l'Institut Bouddhique.
Rédacteur en chef de la partie religieuse : Vénérable Kao-Sim, Surveillant général de l'Ecole Supérieure de Pāli.

TABLE DES MATIÈRES

Partie littéraire:

		Pages
Monsieur Hăn-Yéng.....	Rûòng kămpul kămsăt (roman),..	1
Vénérable Achar Peang-Sŏk.	Nĭtean sŏp'easĕt (2)..	15
Monsieur Nhĭk-T'èm ...	Recueil de proverbes khmèrs par ordre alphabétique (suite)... .	22
.. ..	Meayŏng (en vers, suite et fin) ...	25
Feu l'Ŏknha vŏngsa sarpéch Nong	Lokanĕyy, poème (suite).....	46

Partie religieuse:

Vénérable Prĕah kru Nheanĕasăngvĕarĕa Nhean-Ch'ŭn..... ..	Lŏkăt'ĕammĕasâutr (suite)	50

16e année — N° 1. Janvier 1944 — Abonnement: un an 15$00.

រឿងកំប្លែងសង់

ហាន់-យេង តែងនឹងរៀបរៀង

បទទី ១

កំណើតសុភ័ន្ត

នៅមាត់ស្ទឹងស្រុកកំពង់ធំ មានភូមិមួយជាទីស្ងាត់គួរឲ្យរម្ងាប់កាយ សប្បាយចិត្ត សួនច្បារបរិបូណ៌ដោយផ្លាវឹកស្គុះស្គាយត្រអូបឈ្ងុយឈ្ងប់ ញាំងឥតាសឲ្យរីករាយ នៅចំពីមុខផ្ទះឈើដម្បូលប្រក់ក្បឿងយ៉ាងធំ ១ មានដើមឈើស្រោងចោលម្ល៉ប់ឲ្យឈឹងត្រជុំវិញធ្វើជារបង មានបក្សាបក្សីយំច្រៀងអឺងកងមិនដាច់រយៈ នៅខាងមុខមានស្ពានចុះទៅកន្លែងតិចថ្ងាត្រជាក់ ខាងម្ខាងផ្លូវកៅស៊ូត្រង់ដូចបន្ទាត់កាត់ទៅផ្សារនៅជិតទីនោះ ។

ភូមិនោះជាសម្បត្តិដ៏សុខុមរបស់នាយសោកិត កើយាឈ្មោះនាងវ៉ែន-នារី អ្នកពាំងពីរនៅជាមួយគ្នាមកជាសុខ ពុំដែលមានផ្ទុលរមាស់អ្វីនឹងគ្នាម្តងសោះ ស្រុកកំពង់ធំពាំងមូល តែងស្គាល់នាមអ្នកពាំងពីរឥតខ្វះដល់រូបអ្នកឯណាមួយ ព្រោះនាយសោកិតជាអ្នកសុភុតសុភម មានចិត្តមេត្តាករុណាដល់អ្នកជិតខាងពុំមានរើសមុខ មានអជ្ឈាស្រ័យទុខលំពោនមិនចេះឆ្អែតឆ្អន់ឡើយ ឯមេផ្ទះវិញក៏រឹតតែល្អជាងស្វាមីទៅទៀត រួមនឹ

ពោលតែពាក្យសុភាពពិរោះចាប់ចិត្តដល់ខ្ញុំក៏ជាទន្ទឹងអ្នកស្រីជានិច្ច មាន
ចិត្តសទ្ធាជ្រះថ្លាធ្វើបុណ្យឲ្យទានជារៀងរាល់ថ្ងៃ ជាអ្នកសង្រ្គោះដល់ជន
ទីពាល់ត្រជុនជាប ជាអ្នកពាក្យចាស់ថែរក្សាជម្ងឺអ្នកកំសត់ខ្ចត់ខ្ចោត ជាទេវ-
ធីតានៃស្រុកនោះឯង ។

តួនាយោស្វាម៉ានេះស្រឡាញ់គ្នាណាស់ មិនដែលខាស់អធ្យាស្រ័យ
គ្នាទេ បើតាយោជាដូចម្តេច អ្នកជាស្វាម៉ាក៏យល់ព្រមតាម បើប្តីគិតយ៉ាង
ណា នាងជាប្រពន្ធក៏តាំងចិត្តស្តាប់ តែងតែនាំគ្នាទៅត្រួតត្រា
ម៉ៅការកម្មករធ្វើស្រែចម្ការជាញឹយ ។ ឯដីស្រែនោះធំល្មមយកម៉ៅសុត
កន្ទុយក្អែក ចំរើនផលជាច្រើន បើគិតជាទឹកប្រាក់បានចំនួនជាងបីពាន់
រៀលក្នុងមួយឆ្នាំ ហើយនៅមុខផ្ទះញ៉ាំច្រើនដើមចេកផង ។

កាលបើប្រសព្វនឹងគ្នាបានពីរឆ្នាំមក នាងជាតាយោក៏មានផ្ទៃពោះ
ទើបស្វាម៉ាហាមមិនឲ្យធ្វើការអ្វីពាក់ព័ន្ធអស់ ឲ្យនៅតែផ្ទះទំរាំថ្ងៃខួនឲ្យល្អ លុះ
ដល់ខែចែត ព.ស. ២៤៦១ នាងក៏បានសម្រាលបុត្រនាយម៉ាថ្ងៃចូល
ឆ្នាំថ្មី នៅពេលដែលគេកំពុងតែធ្វើបុណ្យយ៉ាងធំធេងរាក់ អ្នកជិតខាងក៏
នាំគ្នាតឹកអង្ករចូលមកឲ្យសព្វសាធុការពារដល់តាកេនោះជាអនេកបរិយាយ
ពួកភ្ញៀវក៏ប្រគំមហោរីស៊ៅដែងសេចក្តីត្រេកអរ តគ្រឹកគ្រេងឡើងនាវេលា
ក្រៃពេះ សឹងណាន់មាត់សរសើរគ្រប់គ្នាថា "តួនេះ កើតឡើង
[illegible] ដែលជាទន្ទឹងមានសំណាងមិនសែងឡើយ

យើងកាល់គ្នានឹងបានដកកោនក្រោមម្ចាស់ក្តីដ៏មិនខាន;" ហើយ
ក៏នាំគ្នាច្រៀងរាំជាសប្បាយពេញភូមិ ។

មាតាបិតាក៏បានលោះពាលៀងមេនំ សម្រាប់បីពាច្រៀងចំពេលបុត្រ
បានត្រឡប់ទៅកាន់ផ្ទៃមេវិត ។ ចំណែកនាយសោតិត ខុកជាមានធុរៈច្រើន
យ៉ាងណាក៏ដោយ តែងតែទៀតមើលមុខកូនសំឡាញ់សិនទើបចេញ
ទៅ ម៉ោងនោះគាត់នៅតែកងផ្ទះ និយាយចន្ទរយ៉ាងមួយនឹងភរកញ្ញា
មេត្រី ក្បាណយកមកបីក្បាណយកមកពង្គាក់ថ្នមពន្លកចិត្តមិនចេះខ្សោយ
ណាយ ឯមាតាក៏ចំណួយបុត្រខ្លះលើសស្វាមី ១ យេគុណ មិនហ៊ាន
គាន់ឲ្យធ្ងន់ដៃភ្លាចក្រែងកូនឈឺ តែងតែបបោសអង្អែលមិនឲ្យឃ្លើស
ចិត្ត ខ្មីមិត្តតែពាក្យយំកំបញ្ចុកក្បាលថ្ងូរឲ្យអ៊ីមភ្លាម ។

លុះពាកចំរើនអាយុបាន ៣ ថ្ងៃ មាតាបិតាក៏ប្រជុំញាតិមិត្តបង្កក់
ឆ្នូបនឹងកោរសក់ដៃ ខ្មីមន្តកិច្ចសង្ឃមកសូត្រមន្តចំរើនមង្គលដល់ពាក
លុះដល់យាមល្អអាចារ្យក៏កោរសក់ ភ្លេងភ្លាត់ក៏ប្រគំឡើងមួយរំពេចជា
កំណត្តិយស ដល់កូនខ្លីនោះជាពន្លឹក ។ កាលបើសូរសព្ទធម៌ស្ងប់ស្ងាត់
ហើយ មេនំប្រគល់ពាកទៅមាតា មាតាក៏ប៉ប្រុងដោយសេចក្តីស្នេ-
ហា ព្រមទាំងស្វាមីនឹងញាតិសាច់សន្តានទាំងអស់ដើរប្រកួតក្បាណដើមឈើ
មង្គលដ៏ស័ក្តិសិទ្ធិបាន ៣ ដុំ តាមពិធីមានសញ្ញាថា ឲ្យកុមារបាន

ខ្ញុំលម្អិតសួរសួរអំពីធម្មជាតិកំពុងផ្លែផ្កា គឺថាឲ្យបានចំរើនវ័យវឌ្ឍនាការ
ជាសុខ ដ៏ដូចជាត្រីក្បាលតូចលាស់សន្ធឹកទៀវ្ញី ។

បុរសត្រាយបំផុតបានទាំគ្នាថ្វាយឲ្យឈ្មោះថារកនោះ លោកគ្រូ
ចៅអធិការជាប្រជានក្នុងដំខុំកំកុសង្ឃនៅទីនោះ មានពុទ្ធដីកាថា:

" កុមារនេះ កើតទៀងនៅវេលាចែតឆ្នាំ រៃសីយដូចទេវតាដែល
ស្តេចមកសណ្ឋិតក្នុងពិភពលោកយ៉ាងសង្ហាឥតក្តីក សមជាអ្នកមានវ-
សនាភ្លៀវភ្លៀកក្នុងប្រជុំជន ដូច្នោះអាចក្តីយល់ឃើញថា គួរឲ្យនាមជា
"សុភទ្ទ" វែប្រថា អ្នកមានទ្រង់ព្រះយសមមេឃឥតថាស់ជាអ្នកអង់អាច
មានអំណាចច្រើន តើញាមយល់ដូចម្តេច ?

អ្នកចាំងអស់គ្នាក៏យល់ព្រមតាម ទើបមាតាឪបឈ្មោះនោះជាក់
ស្តែកប្តូរមិត្តជាដង តមកញាតិសន្តានប្រកាសឈ្មោះនោះខ្លាំង ។ ជាដង
ទៀត ។ គួរឲ្យអស្ចារ្យណាស់ ពេលនោះស្រាប់តែបារកបើកភ្នែកឡើង
ញញឹមទទួលនាមរបស់ខ្លួន នាំឲ្យអ្នកចាំងពួងស្ងើចក្នុងចិត្តកាល់គ្នា ។

លុះផុតពីជីឲ្យឈ្មោះបានមួយស្រចក់ មេឃក៏ភ្លៅបុងមួយរំពេច
ពពកដ៏ៗក៏បិទបាំងព្រះចន្ទ្រដ៏ជិត នាំឲ្យងងឹតមើលទិសតំបន់ពុំយល់ផ្លូវ
បន្ទោរក៏ជាលច្រកត់ភ្លែតៗ ពេញផ្លែមេឃ ខ្ទេរអសនីបាញ់ផ្លាំងៗរន្ទាន់
ជាន់ ស្ទើរទីងក្រឡាប់ព្រះធរណី ជារកញាប់ញ័រស្រោនឥន្ទ្រិយ
ស្រឡាំងកាំកន្តក់ស្មារតី មាតាក៏លើកបក្ខាមទុបតែនឹងដើមទ្រូង

ដើម្បីការពារបុត្រតន្ទុកមិនឲ្យភ្ញាក់ផ្អើល ក្រែយោនោះមួយសន្ទុះមក ក៏យោបក់ចោកជាព្យុះព្យោហ៍តន្ទុត់ភ្លើងក្នុងផ្ទះឲ្យរលត់អស់គ្មានសល់ឃួរ ។ ផ្ទេកបន្ទោរចោលតន្ទីភ្លឺភ្លែតមកឃើញមុខគ្នាព្រិល ។ គួរឲ្យតក់ស្លុតឥតឧបមា ជានគុណព្រះកិត្តិសង្ឃ . មានភ្លើងឆេះឯងពីរបីចុចចំភ្លេង ។

- មាតាភ័យតក់ស្លុតជាខ្លាំង ក្រសាបបុត្រជាប់ទឹងដៃសម្រក់ទឹកភ្នែកពីរបីតក់ចុះមក អ្នកជវៃក៏នាំគ្នាចោមរោមដកដង្កាជុំវិញ សឹងលើកដៃប្រណម្យអញ្ជលីបួងសួងខេពនិកវរមរមេយ ឲ្យជួយសង្គ្រោះឲ្យផុតអំពីសេចក្តីអន្តរាយកាលរូប . ចាស់ៗ ញាក់អស់សរសៃសរសៃកពុំឮញាប់មាត់តែមិនហ៊ានសំដែងទឹកចិត្តរបស់ខ្លួន នៅវេលានោះចេញមកក្រៅឡើយ ទំរាំពីងគិតតែរូបខ្លួនមួយប៉ុណ្ណោះ ព្រោះនៅទុកាសជាអាកេនដូច្នេះ មានតែប្រតិបត្តិតាមពុទ្ធកាសិតត្រង់ចខ្លាថា “ អត្តាហិ អត្តនោ នាថោ ” ខ្លួនជាទីពឹងរបស់ខ្លួន ។

ខាងក្រៅសូវរលកតគ្រឹកតគ្រែង សោតម្ភកន្ធិចប្រាំងលាន់រំពងគួរឲ្យព្រឺកេម ព្រះពាយខេវបុត្រ ទ្រង់បង្គំឲ្យសេនាមាត្យរៀបផ្លូវស្អាតជាតដោយរួសរាន់ ព្រោះពលាហកខេវបុត្ត ទឹងចេញចាកវិមានយាងត្រសាលសមុទ្រសាគរ ក្នុងមិនយូរប៉ុន្មាន ដោយហេតុនេះឯង ជានជាពួកពលព្រិន្ទុបបួលគ្នាសង្កត់សង្កិន មែកព្រឹក្សាយោកយោលសន្ធឹកសន្ធប់

ម្ហូយសន្ទុះគ្រាយមក ព្រះពិរុណមានប្ញាទ័យមេត្តាពិភពលោក ជាន
យាងចុះមកជួយបង្ក្រាបសត្រូវឲ្យស្ងប់ស្ងាត់ ផែនពាសុធាក៏ជានត្រជាក់
ស្រួល ធម្មជាតិពាំនឡាយក៏ស្ងប់រម្ងាប់ដូចដើមវិញ ។

កាលបើស្ងប់ឈ្លក់ហើយ ពួកពាសាពាសីនាំគ្នាប្រញ៉ា រកឈើ
តូសអុចបង្កើងឲ្យភ្លឺព្រាងព្រាតឡើង គោមនេះឯងត្រូវពន្លត់ចុះ អ្នក
នៅកន្លែងនោះពាំងប៉ុន្មានក៏ជានជូរខ្លែង ញញឹមញញែមរកគ្នាជានដូច
ធម្មតា ដោយសង្ឃឹមថាផុតគ្រោះថ្នាក់ហើយ តែនៅពេលនោះស្រាប់តែ
សំឡេងខ្ទេងស្រាកលាន់ក្រៃ តាមក្រសែឈ្លក់ចូលមកកន្លែងជ្រុងជាសញ្ញា
អាត្រក់ដល់សម្បុកនោះ នាងត្នែនាវ៉ែសពួសតូវខ្មោចបន្ទំសំឡេងលាន់
រំពងដល់ត្រចៀកជូរញ្ជោះ ក៏ជ្រាក់ថ្ងៃមកក្តុកញ៉ាវន្ទត់ខួសពាក្តីកាយ តើត
សន្ធែងសន្ធៃស្រងូតស្រងាត់លើសលែង ទើបហាមាត់ខួលសួរហេតុ
នោះ ដល់លោកត្រូវមធិការពាំងខ្ពុំនិះឡឹកឡួលថា: " បពិត្រលោក
ម្ចាស់ លោកម្ចាស់មេត្តាពិនិត្យមើលតាមក្បួនកើនខ្លួវហេតុនេះឲ្យបានច្បាំ
ព្រះករុណាផង តើគ្រោះថ្នាក់នេះនឹងភ្ជាក់លើកូនសំឡាញ់របស់ច្បាំព្រះករុ-
ណាឬ? បើជាដូច្នោះមែន សូមលោកម្ចាស់កែជោគជតាខោះ ឲ្យត្រូវលើ
ខ្លួនច្បាំព្រះករុណាវិញ គ្នាមានពាន់ដងអ៊ីបើនៅតូចម្ល៉ះ ទុពុង្គោ! ពុង្គោ !!

ថាផុតពីមាត់ខឹកក្តែកក៏ហួរព្រោកមកលើមុខនាង ស្រក់តក់ៗ លើ
ដៃរៃយដូចគ្រាប់ភ្លៀងកំពុងភ្ជាក់លើជម្ងូលផ្ទះនោះឯង ។

លោកគ្រូទៅអធិការចាប់ដំសក្តារទៀនតាំងលេខសព្វគ្រប់រៀបរាយ
បីជាន់ផ្សេងគ្នាពីរថ្ងៃ បូកផ្សែគុណហារសងប៊ូកប៉ាំងហើយជាក់ដំសចុះ
ធើបព្រះកគ្រូឡើង ខៅវេលានោះ ក្មេងដែលធ្លាក់មកចំនួន ១៥នាក់
ជាប់គ្រាប់ស្លាប់ស្ងាត់ខៅហើយ ។ ចាវប្រុសនាយសោកតូចមកជំរាប
តាត់ថា "លោកប្រុស ដើមស្វាយល្អតខាងមុខបាក់មែកអស់ពីរខៅហើយ
ខ្ញុំបានរើសផ្លែបានពីរកញ្ជើ ខ្ញុំមួយកញ្ជើ ស្រគាលមួយកញ្ជើ មានស្វាយ
ខ្លះនោះធ្លាប់ផ្លែ ឯផ្លែស្រែចតែយាយម៉ុកតាត់ដែលឯក ឯស្រគាលនោះ
ពុកបន្ទុំជូនលោកស្រីពិសា ចំណែកខ្ញុំបានចិតផ្លែស្រគាលខួលមាន
អស់ពីរខៅហើយ ឃើញថាមេឃជូរអែមស្រួលណាស់មាន ខំរំបើពុំ
ផងមិនដឹងជាន់ឆ្ងាតជាក់ចិត្តបែបណាទេ" ។

លោកគ្រូទៅអធិការអត់ទ្រាំពុំបាន ភ្លាត់ព្រះឧស្ឋសួរខៅនោះថា
ស្វាយធំប៉ុណ្ណា ចំរើនពារ ?

ការុណាសូមទោស ធំប៉ុនក្តួនដើង មានប្រាស ។

អើ នេះបើបានត្រីសាបទឹកត្រីស្រួលណាស់ ចំរើនពារ គ្រាន់តែ
ទឹកស្ងើរតែនឹងលេចទឹកមាត់ ។

អ្នកពាល់គ្នាក៏ញញឹម ដោយគន់មើលឃើញចំពង់កលោកគ្រូឡើង
ប្លុះច្រែងដង ។

ព្រះគេជព្រះគុណជាច់អាចត្តិហើយ រួចក៏នាំគ្នាសើចគំលេងឡើង ក្មេងសេចក្តីរីមរែតតាំជាន់មុន សោកគ្រួចក៏ក្មេចក្បួនបាយ តែចិត្តមានតារែមធំហួងហែងបុគ្រងជាន់ច្បងជាន់ក្រោម មិនងាយក្មេចហេតុដែលជាក់ខឆំ-អោះលុតរបស់ខ្លួនឡើយ ទើបតឿនលោកឲ្យគាយ ។

-ចំរើនពរ ចាំតាគ្នាន៏កសំណេរភ្លាកម្តងទៀត អម្បាញ់មិញនេះវែលែតនិងស្ងាយល្អតក្មេចអស់ទៅហើយ" សញ្ញឹងមួយសន្ទុះទើបមានពុទ្ធដីកាតទៀត មិនអីទេញាម កុំបារម្ភអ្វី កូននេះមានសំណាងធំណាស់ ជល់ទៅថ្ងៃក្រោយ តែឲ្យអ្នកប្រសឯណោះប្រយ័ត្នកុំទៅរំលើងធំមេទាឲ្យសោះ ទើបបានសុខជល់អស់អាយុសង្ខារ ព្រោះជល់កុមារនេះអាយុបាន ១២ ឆ្នាំ ខឆំមានគ្រោះថ្នាក់ធ្ងន់ តាមទំនាយត្រូវតែធំព្រះពមពាជាតរចាលសិតា ដូច្នេះបន្តូ គាយថាខឆំកើតសោកសល្យ កូនប្រពន្ធញាតិសន្តានខឆំប្រាសចាកស្តាន !

អ្នកទាំងអស់គ្នាក៏ថែរមុខមើលមាយសោកតែត ដែលឲ្យធំអៀនខ្មួនបន្តិចហើយប្រតាសឡើងថា

-តានប្រាសកុំព្រួយព្រះទ័យពីរឿងនេះ ខ្ញុំតុណាស្រឡាញ់កូនស្ទើរខឆំដែរទៅហើយ ឯណាឲ្យខឆំនាំកូនមកឲ្យកូនទៅវិញ ។

*
* *

បទទី ២

សុភីត្រូវបំរើនរីយធំឡើង

- "យើចុះឯងពុតអានាងដល់ណាទៀត ខេះបានចំជាទុបក្រសោបតែម្នាក់ឯងហើយមែនហ្ន៎ ណ្ហើយឲ្យមកខ្ញុំបីម្នាងផង" សោកតនិយាយទៅកាន់ប្រពន្ធដែលកំពុងថ្នាក់ថ្នមសុភីត្រូ នាងមិនបានជាឮចេះតែពិចារណាមួយទំនឹកកូនស្រេចក្អាតក្អាយ សោកតមុខអន់ព្រោះច្រណែនខ្លាចនិយាយឡើងម្តងទៀតថា "មែនអានាងឲ្យកូនមកគ្នាលេងផងគ្នាទំនឹកអាលទៅមើលស្រែ ចិត្តអ្វីក៏អាក្រក់ម្ល៉េះ មិនយល់ដល់ចិត្តរបស់ប៉ាគាដែលស្រឡាញ់បុត្រផងសោះ" ។

- "ចុះអ្នកឋានមិនអាណិតដល់ចិត្តមាតាដែលហួងហែងកូនប្រុសផងទេឬ? អ្នកឋានមើល ថើដូចជាបណ្តាលចេកយ៉ាងហ្នឹងមិនឲ្យលេងឯណាក៏បាន ហើយចិត្តប្រុសស្រឡាញ់កូនមិនដល់ស្មើទេ ព្រោះប្រុសតែធ្វើការងារទៅក្រៅកូនចៅទៅហើយ អញ្ជើញទៅចុះចាំល្ងាចសឹមប៉ីកូន" ។

- "ឯងចង់ជាអាក្រក់ណាស់ ក្រែងតែប្រុសគេបានមិនរវល់ទំនឹងកូនចៅ ឯប្រុសឋានេះស្រឡាញ់ស្ទើរទំនឹងលេង បានជាស៊ូធ្វើការហត់ខ្ញើយ ចាំងថ្ងៃ ចាំងយប់ ចាំងភ្លៀង ចាំងផ្គរ មិនអាណិតតែគ្រឹមកូនទេ អាណិតដល់ម្តាយរបស់កូនថែមទៀតផង គឺឋានមិនឲ្យធ្វើការធ្ងន់ មិនឲ្យអាត់អន់ចិត្តម្ល៉ឹងហើយនៅមិនអាណិតគ្នាផង មិនឲ្យគ្នាពកូនបានបន្តិច" ។

- "អ្នកខានប្រសាសន៍នោះក៏ត្រូវហើយ តែខ្ញុំអាណិតអ្នកខ្លាំងណាស់ហើយ បានជាទុំម៉ាលកូនមិនឲ្យវាឈឺថ្កាត់ មិនឲ្យក់យ៉ា ចើខ្ញុំមិនថែវាតើអ្នកខំធ្វើការវាវដូចម្តេចកើត ។ មួយវិញទៀតខ្ញុំកំពុងតែប្រឡែងជាមួយនឹងកូន មិនគួរអ្នកមកផ្តាច់ពីដៃខ្ញុំសោះ អ្នកគិតមើលចើខ្ញុំកំពុងខ្ជិលខានចាយ ហើយអ្នកមកតាំងខានចាយចេញមិនឲ្យខ្ញុំខ្ជិលខានអ្នក ធ្វើយ៉ាងម្តេចគួរឬ ?

- "នេះបានចំជាកំពូលស្រែហើយ មកឲ្យមកគ្នាកុំប្រកែកច្រែនពេក ខាំតែខាតពេលទេ សោតិតនឹកខឹងចង់ជាណែ្តមយកកូនពីដៃប្រពន្ធតែនាងតុបជាប់មិនដឹងធ្វើម្តេច ក៏អង្គុយមើលមុខកូនធ្វើក្អែកលើងរលោងចំណែកសុតិខ្លួយើញដូចអង្គុយមើលមុខដូច្នោះ ដូចជាចេះអាណិតទើបញញឹមលូកដៃទៅរក រួចស្រែកហៅថា "ប៉ា ។" សោតិតក៏សប្បាយចិត្តហុចដៃទៅរកកូន "ហ៊ុះ! ឯងយើញទេ កូនមករកប៉ាវ តែឯងតើមិនព្រមឲ្យ" តែខាអាណិតប្តូកហុចកូនទៅឲ្យដោយសេចក្តីស្តាយថា "ទៅ! ទៅប៉ាឯងទៅ កុំមកអ្នកវិញ អ្នកលែងស្រឡាញ់ឯងហើយ ទៅទៅប៉ាឯងចុះ" ។

សោតិតបានកូនទៅដៃហើយ ក៏ថ្នាក់ថ្នមកូនតន្ទ្រក្លួនលោមថា "កូន! កូនកុំព្រួយអី បើម៉ាក់ឯងគេមិនឲ្យទៅចាំប៉ាបញ្ជូកបបរ ម៉ែចងឯងចេះញុំបបរទេ ?

សុភីន្ទូហាក់ដូចជាចេះស្តាប់ក៏ស្រែកអេះអះខ្លាំង នាំឲ្យសោកតំរែតែងសប្បាយចិត្តឥតឧបមា ។ ឧពុកម្តាយតាំងពីនាក់តែងឈ្លោះគ្នាពីរឿងកូន ស្ទើរតែរាល់ថ្ងៃរាល់ថ្ងៃ ដណ្តើមគ្នាស្រឡាញ់ ដណ្តើមប៉ាត ។

កាលបើសុភីន្ទូចេះដើរហើយ ក៏មានពស្លៀងមុខក្រោយតាមមើលមិនឲ្យដួល កុមារភីស្រួលខ្លួនឥតមានឈឺចាប់អ្វីដល់មួយគ្រាឡើយ ។

មានមួយថ្ងៃ សុភីន្ទូបានអាយុ ៥ ឆ្នាំពិសនៅមិនចេះស្ងៀម តែងតែរត់លេងជាសប្បាយក្នុងផ្ទះ លោតព័ទ្ធឆ្អែះទៅទាំងឆ្អែះ ស្រាប់តែជាន់លើដីសថ្មមួយកូនដុំ ក៏អិលដើងរូរទៅទាំងមុខគ្រាន់ចំណាប់ក៏ដួលចុះត្រង់ទីនោះ សុភីន្ទូខឹងណាស់ងើបឡើងចាប់ដីសដាច់នៅដៃ តែពុំដឹងគិតតែចេះដូចម្តេចនឹងសងសឹកបាន ក៏អង្គុយរាន់មួយសន្ទុះទើបចៃតគំនិតឡើងថា នឹងយកវាទៅដុះលើក្តារខៀនកុំឲ្យវាខ្ជាប់ ក្រោយៗឲ្យវាកន្ធាលកុំឆ្លើឲ្យកុមារដួលទៀត ហើយស្រែកថា: "ហាហាយហ៎ា! សប្បាយអីម្ល៉ះ! ឧទេវតាអើយ ស្តាប់មើលចុះ អាដែងនេះកំពុងស្រែកយំឮខ្លួស។ យីអើ! អានេះខ្ជិលណាស់ហ្ន៎ មិនដែលប្រទះទេក៏ខ្វក់អីម្ល៉ះ មើលចុះសុទ្ធតែក្អែលប្រឡាក់ក្តារអស់ ម្ទឹងៗ ចាន់ជាឯងដួល ម៉ែបាងទេកុំឲ្យខ្ជាប់ តែស្អីហ្ន៎នៅលើក្តារខៀន។ វង់បី វង់មួយធំ វង់ពីរទាង ក្រោមកូច ឧឡានទេហ្ន៎! ឡាន! ឡាន! ប៉ម! ប៉ម!!

សុភាស្ត្រីលើកក្តារឡើងដើរស្រែក "ប័ម! ប័ម! ចៀសបងចៀស តិចឡានកិន!" ។

រំលងនោះ រត្នានាំបានឮសំឡេងកូនស្រែក ក៏ដើរចូលមកឈរមើល សុភាស្ត្រីក៏ស្ទុះឡើងយកកូបនោះទៅបង្ហាញម្តាយថា "អ្នក! ឡានស្អប់អ្នក ដើមកពីស្រែកជាក់ឆ្កែ ។" ។

-"ស្អប់ហើយកូន អ្នកត្រែកអណោះបានកូនចេះតូរាស់ ចាំអ្នកបង្រៀនឯងឲ្យសរសេរ" ។

ប្រពន្ធនាំចាញ់ដំសក្តារចៀនពីដៃកូន គូរតំរូអក្សរ "ក" ឲ្យកូនសរសេរតាម សុភាស្ត្រីក៏ខំសរសេរតាម ខំមិត្តតែសរសេរហើយក៏ចាំបានតួអក្សរនោះលែងភ្លេច នាំឲ្យម្តាយអ្នកពេញចិត្តឥតឧបមា រំលងសោតត្រឡប់មកដល់ផ្ទះវិញ នាងក៏ថ្លែងរឿងនោះប្រាប់ សោតក៏ញញឹមលែងបិទមាត់ដឹងភ្លេចពេលចាយ ។ ចាប់ដើមតាំងពីថ្ងៃនោះមក រត្នានាក៏ចាប់បង្រៀនកូនៈដោយសេចក្តីព្យាយាមខុសធម្មតា ដោយសេចក្តីៈស្នេហាចិត្តខ្ពង់ខ្ពស់ ដែលមាតាអាចនឹងផ្សាយដល់បុត្រសំឡាញ់ ។

ភាពមាតាបង្រៀនបុត្រនោះគួរឲ្យគន់គំនំពេក ត្រូវមានចិត្តជ្ងន់ឱបរៀបរៀងសិស្សមិនមានងុញច្រាន់ សិស្សក៏រំរៀនសូត្រដោយសេចក្តីជ្រះថ្លា ដោយសេចក្តីចង់ចេះចង់ដឹង រៀនដោយសេចក្តីស្រឡាញ់មិនមែនដោយសេចក្តីបង្ខិំបង្ខុំដោយទ្វាចរំភាត់ ដែលជាហេតុនាំឲ្យចំរើនបាន

ឆាប់រួសពន់ពាន់ចិត្ត សុភីន្ទ្រទំយកចិត្តទុកដាក់មិនឲ្យអ្នកជាត់សេចក្តី
ទុក្ខព្រាហ៍ មិនយូរប៉ុន្មានកុមារក៏ចេះមើលសាស្ត្រាជាច់ ។ យើងមិនអាច
ទីន្ទិសន្ទិដ្ឋានបាន ចំពោះសេចក្តីត្រែកអរសោទរបស់សោភនទីន្ត្រនារី
ដែលញាញីមញាក្រែមស្តាប់ កូនមើលរឿងព័ត៌មានស្តាប់ សមប៉ំខ្លួនកុមារ
ថ្លាពាក្យផង ចំណែកសុភីន្ទ្រក៏សប្បាយចិត្តលើសអ្នកពាំនាំព័ត៌មាន ព្រោះ
អាចនឹងដឹងរឿងព័ត៌អំពីបុកណាត្រៃនាយ មួយថ្ងៃ ។ កុមារមិនដាច់ចិត្ត
ជាត់សាស្ត្រាពីដៃ ស្ទើរនឹងធ្វើរូបកាយរបស់ខ្លួនឲ្យវិបត្តិទៅផ្សេង ។ ព្រោះ
ខុសអំណាចបថសម្រាប់កូនក្មេង ។

ដល់កុមារបានអាយុ ៧ ខួប សោភនក៏នាំយកទៅចូលសាលាឲ្យ
រៀនសូត្រជាមួយនឹងកុមារឯទៀត។ សុភីន្ទ្រក៏ខិតខំរៀនសូត្រជាច់គេជាច់
ឯង តែនៅពេលចំនេះ សុភីន្ទ្រមិនបានលះបង់ពេលសាស្ត្រាស្ទឹកវិត
ឡើយ កាលបើកុមារមើលច្រែនទៅក៏បែកគំនិត ចេះប្រែខិតរឿងព័ត៌ប្លែក។
ឲ្យតេឲ្យឯងស្តាប់គ្រប់គ្នា ឯរឿងអស់នោះ ច្រែនតែរឿងយក្សនឹងរឿង
កូនស្តេចព្រាត់ក្តងវៃព្រៃ ។

ពេលព្រឹកសុភីន្ទ្រទៅសាលា មានតាម្នាក់ឈ្មោះតាព្រឹតឆ័កណ្តៀត
សៀវភៅទៅតាម ដល់ពេលចេញក៏ទៅទទួលកុមារចេញមកផ្ទះវិញ
សុភីន្ទ្រក៏ពប់អានតាព្រឹដាងអ្នកដទៃ ។

តាមផ្លូវដែលសុភន្ទៅសាលា ហើយមិនឆ្ងាយពីផ្ទះកុមារប៉ុន្មាន មានគ្រែស្ពានមួយធំទេវឡែះ គឺជាផ្ទះនាងសាលីក្មេងកំព្រាឪពុកតាំងពីតូចមក នៅតែជាមួយនឹងម្តាយ នាងអង្គុយពន់ពេកដោយគ្មានគ្នាលេង ហើយនាងចំតែប្រឹងរៀនជាមួយនឹងម្តាយរបស់នាង ដែលបេះអក្សរក្បួនបញ្ចប់ផ្លែវ៉ែដែរ ថ្ងៃមួយនាងអង្គុយលេងតណ្តាលស្ពានបានឃើញចាស់តូចមួយរមៀលចូលមកជិតនាង ក៏រើសឡើងយកមកលេង ដល់សុភន្ទជាម្ចាស់ចាស់ចូលទៅមានេះឯក៏ពុំព្រមឲ្យអង្អែឲ្យម្តុតនាងទេញ តែសុភន្ទមិនព្រមលក់ នាងក៏ជាប់ចិត្តហុចចាស់ទៅឲ្យសុភន្ទ ក្រោយដែលបានយកចាស់មកថុបនឹងដើមទ្រូងដោយសេចក្តីស្តាយ ទឹកភ្នែកក៏ហូរខ្លាយមកលើមុខនាង ព្រោះនាងនឹកស្មានថានឹងបានកូនចាស់នោះ ជាកូនកំដរអង្គុយ តទៅវិមានគេមកបម្រាស់ទៅទៀត ម្តេចក៏វេរនាម៉្លេះហ្ន៎! ឯសុភន្ទបានឃើញដូច្នោះ ក៏នឹកអាណិតហុចចាស់ទៅឲ្យនាងវិញ ហើយនិយាយសុំទោសថា:

"កុំអន់ចិត្តអ្វីអូនបង បានជាខ្ញុំមិនព្រមឲ្យនោះ ព្រោះខ្ញុំស្រឡាញ់ចាស់ខេះណាស់ ហើយទើបនឹងបានពីភ្នំពេញមកថ្មីៗ ផង តែបើអូនបងចង់បានយកទៅចុះ ខ្ញុំមិនថាអ្វីទេ តែអាណិតឲ្យខ្ញុំសុំលេងម្តងៗ ផងណា" ។

លោកគ្រូអាចារ្យ ពាង-សុខ ក្រុមជំនុំព្រះត្រៃបិដក

ប្រែនិងរៀបរៀង

១- សូកភក្ខំ អនុស្សុក្កំ ឯតំ អប្បាយុសក្ខណំ
គោលុលាយស្ស ខុស្សុក្កំ ឯតំ ទីឃាយុសក្ខណន្តិ។

ស្រណុកដូចសូកវ: (១) ជាសុក្ខណ:អាយុខ្លី (២)
ទឿយដូចគោក្រមើ ផែលសាមើប្រែថ្លុយប់ (៣) ។
តើប្រែឲ្យអូសនាំ ការ:មាំដោយសព្វគ្រប់ (៤)
ជាហេតុអាយុសិប់ (៥) តើចលំទប់ឲ្យយឺនយូរ ។

មួយឯទៀតថា:

ជ្រូកស៊ីដេកស្រណុក ខ្មាំឲ្យធុកអាយុខ្លី
ឯគោនឹងក្រមើ កន្ធឹកគ្រុ (៦) ខ្លីឯចិត (៧)
ម្ចាស់ប្រែឲ្យអូសនាំ ការ:មាំមហិមា
នាំឲ្យអាយុវែង បិតជាប់ជាយូរអង្វែង (៨) ។

---

១ វាហ "ជ្រូក" ។ ២ គ្រឿងកំណត់អភិញ្ញាណ "គ្រឿងសំគាល់ឲ្យដឹង" ។ ៣ អយើ "ម្ចាស់" ។ ៤ របស់នៃលេខនាំមើ, ខ្ទុក, ផ្ទុក (ចង្ករ) ។ ៥ គ្រឿងសាយភ្នា ឬ រួមញ្ញ របស់ពួកសត្វ ។ ៦ ពេលយប់ ។ ៧ ពេលថ្ងៃ ។ ៨ ឈរ: តាំងនៅ; ខ្ជាប់ខ្ជួល; ទើរ; ជិតជាប់លាប់ ឈប់ ។

២- ដើម្បីប្រែនិតបញ្ហាត់សុភាសិតនេះ(១) ខ្ញុំនឹងស្រង់សាលុកជាតក(២) យកមកដំណាលក្នុងទីនេះតទៅ សាលុកជាតកនោះមានក្នុងតិកនិបាតវណ្ណនា ត្រង់អត្ថុទ្ធារវគ្គវណ្ណនា នៃជាតកដ្ឋកថា ។

សាលុកជាតក

៣- កាលកាលដែលកន្លងរំលងទៅហើយ កាលព្រះបាទព្រហ្មទត្ត(៣) សោយរាជ្យក្នុងក្រុងពារាណសី ព្រះពោធិសត្វបានកើតជាគោឈ្មោះមហាសោហិត(៤) ។

ចំណែកខាងម្ចាស់សោកឈ្មោះបុល្លសោហិត(៥) ។ គោទាំងពីរនេះធ្វើការងារបស់ត្រកូលមួយក្នុងភូមិមួយ ។ ត្រកូលនោះមានកុមារីកាម្នាក់តេញក្រមុំ(៦) ។ ត្រកូលដទៃបានដណ្តឹងកុមារីកានោះ ។ គ្រានោះ ត្រកូលនោះបានបំបិនផ្ជក ១ ឈ្មោះសាលុកៈ ដោយបបនេះថា យ

---

១ បាលី បតិដ្ឋ សំស្រ្កឹត ប្រែតិដ្ឋ ។ ២ ជាតក (ជាតិ) ឬពាក្យដែលដំណាលរឿងកំរើតហើយ ។ រាងសំផ្លែកឈ្មោះសាលុកៈ ។ ៣ តាមថា "ព្រហ្មទត្ត" ប្រែថា "នៃលព្រហ្មឡៃហើយ" ជាតាមរាងសំស្តេច ប្រើនអង្គនៃលសោយរាជ្យ ។ ក្នុងក្រុងពារាណសី ក្រុងមានក្បាលស្មា ឬ មានថ្ម មានតាងកើដ្ឋបាងកើក្បាលស្មា ។ ៤ មហាសោហិត "គោក្រហមធំ" ។ ៥ ចូឡសោហិត "គោក្រហមតូច" ។ ៦ ពេលក្នុងកំណត់អាយុស្ត្រីមានដូច្នេះ តាំងពីរកើតដល់ ៨ ខួប ហៅ គោរី ឬ ទារិកា ពីនោះដល់ ១០ ខួប ហៅតញ្ញា (តញ្ញាប្រែថា ស្រ្តីក្រមុំ" កំពាន) ពីនោះដល់ ១២ ខួប ហៅ កុមារី ឬ កុមារិកា; ចូលទេត្តក្រមុំ ហៅ គរុណី ឬ យុវតី ឬកំ មាណវិកា ចូលទេត្តចាស់ ហៅថេរី ឬ មហល្លិកា ។

ហមង្គល(๑) ។ ផ្ទះនោះតែងតែដេកខាងក្រៅគ្រែ ។ ខណៈក្នុងថ្ងៃមួយ គោឈ្មោះបុល្លសោភិតៈបានឱយាយនឹងបងថា បងអើយ! យើងតែងធ្វើការងារក្នុងត្រកូលនេះ ត្រកូលនេះរស់នៅអស្រ័យនឹងយើងដល់ម្ល៉េះតែនឹងមនុស្សពាលនេះ ឲ្យត្រឹមតែស្មៅនឹងចំបើងដល់យើង បានតែចិញ្ចឹមផ្ទះនេះដោយយថាបានឯងបាយ ឲ្យវាដេកខាងក្រៅគ្រែ តើវាធ្វើអ្វីដល់មនុស្សពាលនោះ ។ គោឈ្មោះមហាសោភិតៈបាននិយាយថា ប្អូនអើយ! ឯងកុំបង់បានបថាយនឹងបាយរបស់ផ្ទះនេះ តែពួកមនុស្សបង់ធ្វើវាឲ្យជាសំឡាកវាក្នុងថ្ងៃធ្វើវាហមង្គលរបស់កុមារាតែនេះ បានជាគេចិញ្ចឹមវាដោយយថាបានឯងបាយដើម្បីធ្វើឲ្យមានសាច់ឆាត់ ព័ទ្ធថ្ងៃខ្លួនឯងនឹងយើញវាដែលពួកគេបញ្ជូញអំពីខាងក្រៅគ្រែ ហើយសំឡាប់កាត់ជាកំណាត់តូច-ធំធ្វើបាយខណៈក្បែរ រួចទើបពោលគាថា(២) ៤ នេះតទៅ

អាសាសុកាសច្ច បិហាយ អាតុរន្ទានិ កុជ្ឈតិ
អនេឡាសុន្ធោ កុសំខាន ឯតំ ទីឃាយុលក្ខណំ ។

ឯងកុំបង់ធ្វើ ឫកពាលលើ ដូចឫកវរៈ ដែលគេហៅថា ផ្ទះសាលុកៈ វាស៊ីអន្ទៈ(៣) សំឡាប់កាយ ។

---

๑ រៀបចំការងារក្នុងស្រុក ។ ๒ ឯងថាដែលពួកវរៈពោលកំណាត់នូវបទអក្ខរៈ ឬ គឺអក្ខរៈ (អក្សរ) ក្នុងបទបានដល់ថា ๑ (ឃ្លា) គឺវាថាពួកវរៈប្រព័ន្ធនោះដោយបន្ទូរ: ពាក្យដែលជាំងនូវទោស បានដល់ការកំណត់ដោយអក្ខរៈ ទំនុវត្តិកៈបានដោយត្រឿង ដែលសំគាល់នៃការកំណត់ដោយគុណ ទំងលហុ ឬ ដោយជន្ទូ: ក្ខណៈ (ការកំណត់នូវពួកអក្ខរៈ សូម្បីក្នុងឃ្លា ๑) ទំនុវត្តិលក្ខណៈ (ការកំណត់នូវគុណទំងលហុក្នុងឃ្លាទាំង ๔) ។ ๓ ត្រឿងស៊ីមានបាយជាដើម ។

ឯងកុំចង់ថ្កើង ចូរសុំចំបើង សម្រាប់អាត្មា ការសុំចំបើង អាច
ឡើងភាយា គឺអាចធ្វើអ. យុទ្ធយើនយូរ ។

ឥធាឯ សោ ឥធាគច្ឆា អតិថិ យុត្តសេវាគោ
អថ ឧក្ខុសិ សាលុកំ សយន្តំ មុសលន្តរំ ។

ប្រុសជាអ្នកការនោះ ទើបមកឆ្ពោះផ្ទះនេះឯង ឯងទើបយើញជាក់
ស្តែង ដោយខ្លួនឯងទូរសូកៈ ។ ជាសត្វជាក់ដុះនោះ ម្ចាស់ឲ្យឈ្មោះ
ថាសាលុកៈ ដែលគេធ្វើមណៈ ឲ្យមានៈដេកស្រួលឆាន (១) ។

៩- ទាន់ក្រោយអំពីថ្ងៃនោះមកបានពីរបីថ្ងៃ កាលដែលពួកអ្នក
ធ្វើរវៃហមន្តលមកហើយ ពួកអ្នកខ្លួលក្បៀកសំឡាប់ជ្រូកឈ្មោះសា-
លុកៈ ហើយធ្វើសំឡកាវ ។ គោចាំងពីរបានឃើញសេចក្តីថ្ងាស់ឆ្ងោយ
របស់ជ្រូកនោះហើយក៏ប្រឹក្សាគ្នាថា សូវស្តីចំបើងរបស់យើងគ្រាន់បើ
ជាង ។ ព្រះសត្វញាបមគ្រូរបស់ពួកយើង ជាបុគ្គលបានគ្រាស់ដឹងឯង
ស្រេចចាប់ហើយ ព្រះអង្គបានត្រាស់គាថាទី ៣ ទាំងពុទ្ធដែលបំភ្លឺនូវ
សេចក្តីនោះ គឺ:

៦- វិកាឡំ សូករំ ឯិស្សា សយន្តំ មុសលន្តរំ
ជារត្តិ អថន្តេសុំ វាម្ចាតំ កុសាមិវ ។

---

(១) ស្ងាប់, ងាប់, ស្ងាប់ហើយ, ងាប់ហើយ ។

គោចាស់ពាំងពីរបាន　　ឃើញលំអានជ្រូកអ្នកផ្ទះ

គេចាក់កាប់ពុះរះ　　គេពន្លះដេកស្រងាំ ។

ហើយគិតថាចំបើង　　រមស់យើងគ្រាន់បើជាង

ជ្រូកខ្លៀវដេកស្រងាំ　　យើងគួរពាក់កុំគ្រាប់ពាំ ។

ចប់សាលុកជាតក តែប៉ុណ្ណេះ ។

ធម្មសំវេគកថា

๗- ឧសូកវៈ ឈ្មោះសាលុកៈ ដេកចាំស៊ីស្រាប់ មិនមានគំនិត មិនគិតក្តីស្លាប់ ថ្ងៃស្អែកត់ចំណាប់ ព្រោះតែស្រណុក ។

ឯគោពាំងគូ ទំបំរើគេ រងរេបក្តីទុក្ខ ស៊ីតែចំបើង មិនថ្លើងថ្លានមុខ ប៉ុន្តែមិនធុក គឺអាយុវែង ។

សមុស្សាហនកថា

๘- ជនពាំងឡាយដែលដឹងហេតុពាំងពីរ គឺ ហេតុរមស់ជ្រូកទំនិង ហេតុរមស់គោ ដូចបានដំណាលកន្លងមកដើមហើយ កាលបើច្បាស់ច្បាន់រួលំអដើម្បីខ្លួន មិនត្រូវប្រព្រឹត្តតាមអាការៈរមស់ជ្រូកទេ ត្រូវតែប្រព្រឹត្តតាមអាការៈរមស់គោ បើមិនដូច្នេះទេ ឈ្មោះថាជាមនុស្សមិនល្អសម ដូចសុភាសិតនេះ គឺ:

អលសោ តំហី តាមភេ តី ន សាធុ

អសញ្ញាតោ បព្វជិតោ ន សាធុ

ភជ. ន សាធុ អនំសម្ផការី

យោ បណ្ឌិតោ តោធជោ តំ ន សាធុ ។

[គហស្ថប្រែតាម: (๑) អលសៈមិនប្រពៃ (๒)

បព្វជិតលះវិន័យ មិនប្រពៃគឺមិនសម ។

ស្តេចមិនបានពិនិត្យ ធ្វើតាមចិត្តមិនទុត្តម

បណ្ឌិតវិធីមិនសម មិនទុត្តមតាមជាតិប្រាជ្ញ ។

មើដូច្នោះ ឈ្មោះថាជាមនុស្សល្អ សមដូចសុភាសិតនេះ គឺ

๑๐.ឧក្កំ តហាបតំ សាធុ សំវិភជ្ជញ្ច កោដនំ

អមាសោ អត្ថលាភេសុ អត្តព្យាបត្តិ អព្យថោ ។

ក- សេចក្តីឈ្លាសវៃ ក្នុងការគិតលៃកេរគោន (๓)

នៃជនក្នុងលោក ដែលនៅគ្រប់គ្រងគឺជា (๔) ។

កំចូរនេះឯងឱវាទ ឲ្យភ្ញុកអ្នកប្រាជ្ញនានា (๕)

គោលថាសោភា នេះជាលំអប្រពៃ (๖) ។

---

๑ សភាពនៃលស្ងួតត្រជាក់ ឬ ស្រួលជាញឹក ឬ កំ ងប់ន ។ ๒ ទម្រន ប្រែអួលកាយ-ចិត្ត ។ ๓ ត្រង់ប្រែថ្លាស់ ។ ๔ ផ្ទុះសំលែង <ក្នុង ។ ๕ ផ្សេងៗ ដោយខ្លួនៗ ។ ๖ ដំបូង ទី ๑ ។

១ - ការចែកវិលក	តំបែងចំណែកឲ្យសម
ដល់ខ្លួនខ្ញុំ	ច្រើនជ្រែងស្មុះស្មែងជាងមក ។
ដល់ស្រមណ៍ទីឥព្រាហ្មណ៍ (១)	ដែលដើរចោកចាមមកកេ
កិច្ចនេះពន្លក	គឺជាលំអចន្លាប់ ។
៤ - ការជាងយល់គោត (៣)	មិនត្រែតអរជោកជាំជាប់
ញ៉ាំងចិត្តឲ្យជ្រាប់	មិនឲ្យសប្បាយក្លេចគុណ ។
គឺមិនឡើងជោរ	ទៅតាមដំនោរឲ្យស៊ុន
កិច្ចនេះជាគុណ	គឺជាលំអច័ប ។
ឃ - កាលយសខ្លួចហើយ	ព្រងើយកន្តើយធ្វើអ្វី
ធ្វើតាមច្រកតី	ដូចកាលដែលខ្លួនមានយស ។
កិច្ចនេះចាត់ជា	ល្អស្អុះសោភាយ៉ាងខ្ពស់
អ្នកច្បាជ្ញមានយស	ហៅថាលំអច័ប្ជួន ។

ចប់និទានសុភាសិតទី ២ តែប៉ុណ្ណោះ ។

---

១ អ្នកអ្វាប់ជ្រយ, អ្នកបន្សាត់បាប ។ ៣ ឥស្សរិយ "តំណែងឯការ" ភោគ "គ្រឿងប្រើប្រាស់" សម្ភោន "សេចក្តីភប់អាន" កិត្តិ "ឋាបនៃលេខថ្លែងសេចក្តីល្បីល្បាញ" វណ្ណកណាខ្លះ "សេចក្តីថ្លែងគុណ" ។

ប្រជុំសុភាសិតខ្មែរតាមលំដាប់អក្សរ

ឃុនធិពន្ធមន្ត្រីញ៉ាក ថៃម រួបរួមនឹងរៀបរៀង

(ត្រួត)

អក្សរ គ

១ គយដេតជាស់គយឲ្យអង្គរ ។

១ គាប់ធំនឹស្រា ជាន់ធំជ្រុយ ។

១ គិតច្រើនកំហ្មាត ដេកច្រើនកំកើតព្យាធ៍ ។

៤ គិតរួចសឹមគួរ ។

១ គុណមិនឈ្នះគាប់ ទ្រព្យមិនឈ្នះត្រូវ ។

១ គួរបូកខ្វាឲ្យគោខ្វាចប្តូ គួរបូកខ្វាបង្កើលគោ ។

៤ គេខុសកុំអាលអរ គេសាទរកុំអាលអួត ។

១ គេច្រាប់កុំអាលនោត គេបំភោតកុំអាលក្បាក់ ។

១ គេច្រើកុំអាលទៅ គេហៅកុំអាលមុខ គេឲ្យកុំអាលយក គេសង្ឃឹកកុំអាលថយ ។

១ គេស៊ីពង ឯងរើសំបុក (កាលណាកើតទុក្ខលុក វាវេរយោធ ដូចសម្តីតំណែ) ។

១ គេស្ងាប់កុំអាលយំ យល់គេធំកុំអាលត្រេក ។

១ គេឲ្យដើរមុខមិនចេះបង់ជើង គេឲ្យដើរក្រោយមិនចេះរៃ ។

១ គោគេមិនអួត អួតតែគោឯង ។

◎ គោដំបៅខ្នង ក្អែកហើរលេងរកាយកន្ទុយ ។

◎ គោផ្តើលមិនគិត ភៅគិតឯងទាស់គ្នា ។

◎ គោមួយក៏យប់ គោដប់ក៏ល្ងួច ។

◎ គោលៀនស៊ីកក ស្រែល្អស៊ីកគូថ ។

◎ គោសាងខ្ចាំងដល់ ។

◎ គោស្តមថ្នមជ្រៃ ។

◎ គំនិតលើខ្លួន ភៅពួនស៊ុងស្ងឹកថ្នឹង ។

◎ គំនុំពួន បំណងស្តេច[1] ។

អក្សរ ឃ

◎ ឃើញខ្លាធ្លាក់អណ្តូងហើយ ម្តេចឡើយយកដុំថ្មភៅបន្តក់លើគ្នាទៀត ។

◎ ឃើញឈើពុក កុំគាលជាក់គូថអង្គុយ ។

◎ ឃើញដំរីជុះ កុំជុះតាមដំរី ។

◎ ឃើញសេះថាជាលា ឃើញគជាថាកណ្តុរ ។

◎ ឃើញខុងហើរ កុំសរសើរថាខុងបេសង់ឯង ។

◎ ឃើញមនុស្សដួល កុំដើរកន្ត្រង ។

◎ ឃ្លានកុំអាលស៊ី ។

---

[1] មួយយ៉ាងទៀតថា គំនុំឯង បំណងស្តេច ។

១ ឃ្មោកលិចអម្បែងអណ្តែត (ឃ្មោកលិច ថ្នូរណ្តែត) ។

១ ឃ្មាលក្រែមដិះក្រែម ។

អក្សរ ង

១ ងប់ងឹងល្ងែងតែងហ៊ានហោច ។

១ ងាយមិនក្រែណាងឹងបាន មានប៉ុន្មានមិនក្រែងឹងអ្នកជំបានសុខ
ចេះក្តីមិនក្រែណាងឹងអ្នកម្ចាស់ស្រុក ។

១ ងើយក៏ស្តុក ខុនក៏ជាក់គ្រាប់ ។

១ ងាប់ដូចពស់ រស់ដូចកង្កែប ។

អក្សរ ប

១ បង់តាប់ប្រែស្មុះស្មែង រកៀនរិះសរតើក្តី ។

១ បង់ចេះឲ្យសម្ងាប់អាចារ្យ បង់បានផ្ទៃផ្ការីយកភ្លើងដុតគល់
បង់បានកុសលឲ្យបង្គត់បាយ ។

១ បង់ចេះឲ្យធ្វើល្ងង់ ។

១ បង់ទ្វាញ់ឲ្យកេរអន្ទក់ បង់ស្រណុកឲ្យខឿយព័ក្តេង[1] ។

១ បង់បុណ្យបានជាប បើបង់បង់លាភវែងជាត់ជនរៅ ។

១ បង់ផ្ទឹតចិត្តនៅមិនបាន, បង់ផ្ទឹតផ្ទះនៅបាន[2] ។

១ បាក់អង្គុយកអង្គាម ។ (មានត)

---

* ១ បង់ទ្វាញ់ឲ្យស្មោះអន្ទក់ បង់ស្រណុកឲ្យទំធ្វើការ ។ ២ ស្មុះបង្ខៀតផ្ទះកុំឲ្យបង្ខៀតចិត្ត ។

នេះបទគាថាតិ

ព្រះចុងក្សត្រថ្ងៃ ដល់ដើមព្រះថ្ងៃ បញ្ជាប់អស្សពាហ៍ ព្រាត់
មុខមន្ត្រី សេនីសេនា យល់តែចៅមា . ណាពនោះឯងហោង ។
ទើបក្សត្រចមចៅ ឈប់រង់ចូរចៅ តុំយល់មនុស្សជន ស្តេចយ៉ាង
ក្រយា ស្ងោយមហាក្សត្រហោង តែមាចកន្ធង តែនឹងមាណព ។
ទើបព្រះត្រហ្មចត្ត ជាតជមក្សត្រ លើសលើលោកា សន្ធតនាមនៃ
មាណពនោះណា ឲ្យហៅចៅមា. យើងយល់តំណាយ ។ ស្តេច
សព្វហ្វូរ៉ាយ ក្រសាលនៅនៃ កំឡុងព្រៃនាយ ស្តេចលីលាលេង
ព្រឹក្សាពណ្ណាយ សាន្តសុខសប្បាយ ខតព្រៃព្រឹក្សា ។ ស្តេចគ្រាច់
ដោយព្រៃ ឥតអ្នកណាំនៃ ឱដ៏ពាន់ក្សត្រា សឹងរកក្សត្រថ្ងៃ សព្វព្រៃ
ព្រឹក្សា ខ្ចាចខ្លួនក្តាត់ណា រកមិនឃើញឡើយ ។ រីឯព្រះចុង
ត្រហ្មចត្តនោះ លីលាឡើងហើយ បន្ទូលនឹងមា. យើងថាចៅ
អើយ ថ្ងៃលិនពេកហើយ អង្គអញឃ្លានចាយ ។ ខ្ញុំឯអស់គ្នា
មន្ត្រីយោធា ចតុរង្គពាំងឡាយ សឹងតែតុំយល់ រហ័ពលព្រាត់ព្រាយ
ចៃកផ្លូវខ្លាត់ខ្លាយ អស់ឥតតុំយល់ ។ មាះយើងទូលចៅ ចាត់ក្សត្រចមចៅ
លើសលើលោកា ជាយអញខ្ញុំមាន តីមោះខ្លួនា តុំគួរក្សត្រា ជាត-

ស្ងោយសល់ ។ ស្តេចស្តាប់ហើយណា ចៅយកមកកំ កុំគិតសល់
រឹល តោះល្អមិនល្អ ទៀសតាមកល អញឃ្វានណាស់សល់ អត់
ឯណាបាន ។ ទឹកតើញាំងចៅ បានសំបៃនៅ ឬមួយតុំបាន មាយើង
ខ្លួនៅ បពិត្រកូត្រកូត្រាន្ត ទឹកសោតមាន គឺមានតែថា ។ ដាក់
ទឹងបំពង់ តុំគួរព្រះអង្គ ស្តេចសោយឡើយណា ស្តេចស្តាប់ថាៅ
យើចៅកុំថា ច្នោះចៅម្ដាយ យកមកឆាប់។ ។ កូណាចៅមាយើង
ម្ដាយដោះឡើង ទៅយកប្រដាប់ ដាក់ទឹកបំពង់ សំណុំបាយស្រាប់
ស្រែចស្រាយផ្ដាប់ ថ្វាយមហាកូត្រា ។ ស្តេចសោយអាហារ មា
យើងត្រកាល មានសេពិសា បាយបរិសុទ្ធិស អង្គរនោះណា ដូច
ព្រះត្រយោ ស្តេចសោយបរិភោគ ។ អាហារពិសា តាប់ព្រះនុស្ដមហា-
កូត្រកូត្រាន្តចក្រី បន្ទូលសរសើរ ថានេះមែនស្រី ប្រដាប់ចំណី
តិសេសពិសា ។ ប្រពន្ធមាយើង ចេះរៀបចំប្លែង មុខចៅមែនណា
ចៅអើយអាហារ ត្រកាលពិសា សឹងជាតិនុជ្ជា- រសត្រកាលក្រៃ ។
ដួនលើតំណាន ឯណាមកមាន អាហារក្នុងក្រៃ ទឹងថាដូចគ្នាន
កូវពិសាក្រៃ មិនច្នោះឡើយនៃ ចំណីនេះជា ។ មាយើងបង្ខំ មហា-
កូត្រទត្តម ឥសូរសើរសោ លុះស្តេចសោយសល់ ស្តាប់មហាកូត្រា
ស្តេចសោយគង្ហាំ បំពង់នោះនៃ ។ ទឹកសោតពិសា អប់អស់ក្លិន
ផ្ការ ពិដោរប្រៃតែ ស្តេចថាទឹងចៅ រសពិសាក្រៃ ខុនាងតាប់ចៃ

ចេះរៀបឲ្យប្តី ។ មាំយើងនោះណា បង្គំក្សត្រា លើកដៃលមកធឺ
ឆ្អែចស្កប់ស្កល់ បរិបូណ៌អស់ក្តី ទើបព្រះបត្រី បន្ទូលទៅថា ។
ចៅមាយើងអើយ អញហូបចាយហើយ មិនចេះអត់ស្ងូ ចៅឲ្យថង់
ចៅ មកឯអាយ៉ា អញនឹងធឺស្ងូ ឥឡូវនេះនៃ ។ ចៅមាយើង
ថ្វាយ ក្សត្រថ្លៃពណ្ណាយ ដោយព្រះហ្ឫទ័យ ស្តេចសោយស្ងូចៅ
មាយើងនោះនៃ មានសព្វគ្រប់ថ្លៃ ឥតខ្វះឡើយណា ។ ពាំងទេព
តារូ ក្រាញក្បាំពួ ស្ងូខ្លួសោតណា ក្រមួនមាត់ផ្ងន់ ព្រះអង្គសោយ
ស្ងូ ហើយទើបត្រាស់ថា ស្ងូចៅនេះនៃ ។ សព្វគ្រប់មានមិញ
ដូចតស់ស្ងូអញ តែងធឺសព្វថ្ងៃ ត័ព្វអញឯងហើយ ចៅអើយតាប់
ឆៃ អញបានអាស្រ័យ ចៅសព្វគ្រប់ហោង ។ បើអញបានដល់
ទីហានមណ្ឌល ឯងាយហើយហោង អញឲ្យឃុសចៅ ជាធំតន្ទូង
ចៅតំសត់ផង អញគាស្ងូចៅ ។ បន្ទូលម្ចាស់ហើយ ក្សត្រគ្រាណា
ត្រែយ ប្រះផ្ងូលើក្បៀ មាយើងហើយថា ចៅអើយនៃចៅ ស្តាប់អញ
ទឹងនៅ ទិយាយមួយហោង ។ ស្តាប់ណាចៅអើយ ដំណើរទិយាយ
ត្រែងត្រឹទ្ធតន្ទូង អញនៅថ្ងៃថ្ងង ចំដែងចំនង ទិតានមួយហោង
ពីត្រែងអតីតា ។ តុំតន់ទិយាយ ដំណើរអតីតកុាយ សណ្តាប់ឯ
មា- យើងដូលន់លក់ សាន្តសុខក្សត្រា ត្រែមដើមនៃមហា- ទិត្រែតធ
នោះនៃ ។

រំពេលនោះណា មែនមានទេពតា ក្សត្រព្រះដែ ឮព្រះ
ត្រហ្មទត្ត មហាក្សត្រដៀស្តង់ជ័យ ស្តេចបន្ទូលនៃ ន៏ងមាយើងថា ។
ស្តេចនន៏ងនិយាយ ទេពតាគាំងឡាយ បបួលគ្នាគ្នា មកមើរលើដែ
ស្តាប់សព្ទក្សត្រា យល់ស្តេចនិត្រា តុំបន្ទូលទៅ ។ ទេពតាខ៏ងក្តាត់
ន៏ងព្រះត្រហ្មទត្ត ធ្វើជាចមទៅ ថាក្សត្រនេះណា មុសាតែក្រសែ
ពោលពាក្យគាសៅ តុំគាន់ពាក្យសត្យ ។ ខ្មោះយើងអត់ក្លៅ ស្តេច
ឆាលអប្រិយ កាច់មែកដែថ្នាត់ ចំលាក់ទៅលើ សង្កត់មហាក្សត្រ
ឲ្យស្តេចចង់ចាត់ ព្រះជន្មដ៏រៃ ។ ថាបើតុំពាន់ នៅនេះតែងខាន
ស្តេចទៅមុខ៏ រយើងកាច់ភ្លើងក្តារ សង្កត់ចក្រី ព្រហ្មទត្តតិរ៏យ៏ ឲ្យ
ក្សយជន្ម ។ ថាបើបាននៅ នោះស្តេចចូលទៅ ដល់លើក្រឡា
បន្ទុះមេ្យតែន៏ តែស្ងាត់ន៏ងា យើងដែប្រគាល់ ជាពស់ទៅទាំ ។
ស្តេចស្តេចកុហក ថាហើយដេកលក់ ឲ្យតែយើងចាំ, មាយើងនន៏ងុយ
អន្តិយតែចាំ ឮពាក្យឆ្កាំ ។ ដាំ ។ នោះណា ។ មាយើងជាស់ស្តេច
ឆាប់មួយរំពេច ទើបទូលទៅថា បពិត្រស្តេចឡើង ជវនៈអស្សា
ធាប់ ។ ម៉ែម្ចា ឥឡូវនេះនៃ ។ ដ្បិតមានទេពតា ន៏ង្សៅក្សា
លើដើមត្រែដែ ៗន៏ងថាស្តេចនន៏ង ន៏ងយាយហើយនៃ ដ្ឋូលតំរែងដែ
ស្ងៀមស្ងាត់គាសា ។ ខ្ញុំចាំរស្តេចផ្ទំ លើរទៅខ្ញុំ ឮពាក្យទេពតា ស្តេច
ស្តាប់មាយើង ស្ទុះឡើងអស្សតាប៏ ដាំដាយម៉ែម្ចា មាយើងដោយ

ដ៏ត ។ ក្សត្រាណមែកព្រះវៃជ ភ្ញាក់ផុតក្សត្រថ្ម ព្រះបាទព្រហ្មទត្ត
ស្តេចទៅមុង ពីព័យមរណ៍ថ្នាត់ ទើបមាយើងគិត ទូលទៅទៀតថា ។
បពិត្រព្រះភូ-ធរាជឥស្សរ នេះឯងមួយត្រា មួយទៀតខ្ញុំឮ ពាក្យអស់
ទេពតា ថាដល់សីមា ព្រះអង្គនាយនោះ ។ ទីឯកាច់ភ្នែងថ្នារ សង្កត់
ភូថ្មាល រំងវិញទៀតស្មោះ ថាបើកន្ទុង រមុងពីនោះ លុះព្រះអង្គគ្រោះ
ចូលក្នុងបន្ទុំ ។ ទីឯវែកាឡា ជាឥសីមហិមា ទាក្សត្រទទួល បពិត្រ
ក្សត្រា ទេពតាជំនុំ ដូច្នោះនេះខ្ញុំ ឮជាក់ជាមួង ។

នេះបទពំនោល

មហាក្សត្រព្រហ្មទត្តឮស្តាប់ច្បង់ ស្តេចស្តាប់ពន្ធង ពំនូលនៃទៅ
មាយើង ។ ទើបមហាក្សត្រាថ្កល់ថ្កើង ថាដូច្នោះមាយើង ចែបយ័ត្នទៅ
ភ្នែងថ្នារនោះ ។ ទៅតាន់ពោតរំងនោះ ដៀងជួយគឿនស្មោះ ឲ្យរួច
ពីព័យថ្នារធំ ។ ស្តេចមានឫទ្ធិយថារម្ភ ឋានសេះវែងទំ លុះទៀបនៃ
ភ្នែងថ្នារនោះ ។ ក្សត្រថ្កើងមាយើងរំងនោះ សេះសោតលោតផ្លោះ
ច្រៀវច្រែចក្រសួចមហិមា ។ ជាក់ភ្នែងថ្នារាជសីមា ផុតមហាក្សត្រា
ក៏រួចមុងពីព័យ ។ លុះដល់មណ្ឌលពិភពថ្ម ទៅមាយើងនៃ ត្រាបលា
ទៅថ្កានត្រែះហាន ។ ព្រះបាទព្រហ្មទត្តបែជាន បន្ទូលផ្តាំថ្កាន ថាបួរ
ទៅទៀវហោង៍ណា ។ ហើយទៅវិលវិនយាត្រា មកធាប់មីម្ចា ទៅចាំ
ដួចទៅឮហោង៍ ។ មាយើងត្រួតត្រាបន្ទូលស្នង បពិត្រនេះម្តង កុំព្រួយ

ព្រះពុទ្ធប្បូទ័យ ។ ចាមទៅទៅរិលវិលវៃ ចាំក្សត្រៃស្តេចយ ដ៏ជា
ម្ចាស់សោ ។ ខ្លួលស្រែចមាយើងម្ចាស់ មកផ្ទះអាត្មា ច្បាយច្បាប់
តរៃយអស់ក្តី ។ ដំណាលច្បាប់តាលចត្រឹ ព្រាត់មុខមន្ត្រី ទៅដុំក្រៃម
ដើមត្រឹក្សា ។ ច្បាប់តាស្តេចសោយក្រយា សរសើរនាងថា តរៃយានេះ
អញស្ងួនត្រង ។ ច្បាប់អស់ដំណើរខំនង នាងត្រេកអរផង ដ្បិតចាន
ដូចចិត្តចិន្តា ។ មាយើងនោះនឹងតរៃយា ហូបចាយហើយណា ក៏កាន់ដាវ
ទៀងទៅចាំ ។ អង្គុយជិតទៅតយឃ្លាំ ក្នងពុងពេងកំ ព្រះចាទសម្តេច
ព្រហ្មទត្ត ។ មន្ត្រីត្រាស់ថៃកេរច្រែនក្តាត់ ប្រុងច្បាណាច្បយ័ក្ត ក៏ពេញ
នៃកដកេងរម្យ ។ លុះដល់អត្រាត្រចាស់ខុំ ដេកស្ងាត់ជ្រងំ ពុំភ្ញាក់
ដល់ម្ចាក់ទៀយណា ។ កាលនោះឯងឯទេតា ច្បាណាថៃកាឡា
ជាតិជាតស់ពារទៅហោង ។ រំហ៌ាតស់ធំកន្ទង ប៉ុនដើមត្នោតផង ក៏
លើកពពារគ្រៃខ្លាច ។ មានក្បែកនោះជំត្រែជាច ចង្កូមសស្វាច ទឹងទាំ
នៃមហាក្សត្រា ។ មាយើងដោះទៀងម្ចាស់ លើកខាន់ថ្លៃថ្លា ក៏ជ័ងនៃសិរ-
សាស់ ។ ឈាមតស់ខ្លាត់ខ្លាយទៅដល់ ទេព័ទ័មិល ក៏ពេញនៃព្រះ
ឋនា ។ ទើចទៅមាយើងគិតថា តស់នេះមរណា អសារសោះសូន្យ
ដីវ ។ ឈាមដួចដល់ពពេក ព្រះតេន្ទក្សត្រ ច្នេះតើនឹងធ្វើម្តេចបាន ។
ជ្រះឈាមព័ទ្ធកល្យាណ ទឹងជាស់ក្សត្រក្សាន្ត យល់ក្តីពុំគួរក្តាត់
ណា ។ ទឹងយកដៃដួតទុក សោតសឹងពុំជា កើតក្តីពុំគួរពេកដៃក្រ ។

ទើបយកខ្មោចឥសនោះនៃ ដាក់នៅត្រែតាមឮ ក្រែឮបន្ទុំរមូរតែន ។
ស្រែចហើយទើបគាត់ហាមាត់ លិទ្ធឈាមដែលដិត នៅព្រះសុដន់
ក្សត្រី ។ នាងនាដក្ងាក្ងក់តន្ទ្រិយ ទើបដាស់ភូមី ដ៏ជាតម្ដែងក្រឡា ។
នាងឱ្យបង្គាយថ្ងាប់ថាមា - យើងយកជំរូ កំលិទ្ធនៃដោះខ្ញុំហោង ។
ស្ដេចស្ដាប់ត្រែតតែកន្ទង់ ត្រាស់ប្រែឥសផង ម្ចាស់ពេជ្យហោដម្ដង ។
ចូរឆាប់ចាប់ចងយកវា កំណាចមហិមា នេះនាំយកទៅសម្លាប់ ។
ក្សត្រីណោះពេជ្យហោដចូលចាប់ ចងមាយើងខ្លាប់ ក៏នាំយកទៅម្ដង ។
ហេតុស្ដេចឥតពិចារណា ពុំគិតគុណមា - យើងយកតែពាក្យទេព្រ ។
ពេជ្យហោដនាំចងកត្រី ទៅបូព៌ទិសទី កំថានចំអ្នកនាយទ្វារ ។ ឮ
បើកដង្ហែត្រពិះកូបាល មានព្រះទន្លាវ ឲ្យនាំអ្នកទោសទៅគាប់ ។ ក្សត្រី
ណោះនាយទ្វារស្ដែងហ្ពាប់ យល់ទុំសន្ធឹងច្បាប់ សម្លាប់អ្នកទោសចាំង
យប់ ។ ថាទោសនេះម្ដេចអ្នកឈប់ ប្រាយច្បាប់សព្វគ្រប់ ដំណើរ
ដំណាលសេចក្ដី ។ នាំអ្នកទោសចាំងកត្រី ពុំត្រូវច្បាប់ពី បុកណា
គន្ធងឡើយណា ។ ពេជ្យហោដឆ្ងាស់ឆ្លើយវិនថា អញដឹងឯណា ជា
ទោសធ្ងន់ស្រាលអ្វី ។ ។ ស្ដេចប្រែអញចាំងកត្រី ចៅមកវាកក្ដី
តែព្រះបំរើនោះបាន ។ អំណាចអ្វី ឯងមាន ក៏អញនឹងហ៊ាន នាំ
គេមកសម្លាប់លេង ។ អម្បាលចៅឯងអញឯង ម្ដេចពុំគោតក្រែង
ក៏ខាស់ព្រះពជ្រអាជ្ញា ។ នាយទ្វារសោតឆ្លើយវិនថា បើព្រះអាជ្ញា

លុះត្រែវនឹងប្លាប់ទើបបាន ។ ប៉ើទុសនឹងប្លាប់បុកណា យើងយាត់ទាំងទាន បានដូរតែយើងជានាយភូវ ។ បើយើងគ្រាបទូលនាកាលនោះព្រះកូថុាល នឹងធ្វើម្តេច ។ តាមកល ។

ទេះបីទុកាកតតិ

នាយភូវនោះណា បង្ហានអាជ្ញា ឈរឈប់បេល់ ទើបទាំនិងទាន មែនមានមនុស្សសល់ ច្រាយច្រាប់អស់កល នឹងពេជ្ឈយាជហោង ។

ទៅអើយនិយាយ កាលពីត្រែងនាយ ខុកជាចំនង មុនមានស្រីម្នាក់ មានកូនមួយហោង បិញ្ចឹមស្ការផង ស្រឡាញ់ក្សា ។ ស្រីនោះទៅផ្សារ ខុកប៉ុន្តែស្ការ ទៅកូននោះណា ផ្តេកកង់អង្រឹង ខុកទើបយាត្រា ក្រែយនោះពស់អា- សិរពិសយង់ឃ្មង់ ។ ក្សុណៈពស់លលាំ ក៏រមកនឹងទាំកូននោះមរណ៍ហោង ស្ការយល់ពស់ពិស ច្រុស្តច្រំសកន្ទង ស្ការប្រទាំផង នឹងពស់នោះណា ។ កាលនោះពស់ពាល ប្រទាំនឹងស្ការ ស្ការទាំមរណា ម្ចាស់មកព័ផ្សារ ក្សុណៈស្ការនោះក៏ រត់ដោយមាគ៌ា ទៅទទូលហោង ។ រីស្រែម្ចាស់ស្ការ បេល់ឈាមខ្ចាល ទៅខ្ជូននោះផង ប្រ-ទាំណាគិតថា ស្ការគោចកន្ទង ទាំកូនជាមួង មិនឈាមអ្វីឡើយ ។ ទឹនធុលធៀបនាប់ ក៏យស្ការសម្ងាប់ ចោះបង់សៀតហើយ ចូលទៅមើលកូន មិនសូន្យឥតត្រែយ ពិតពុំទេឡើយ យល់ពស់មរណា ។ ទើបគិតឯងយល់ ជាពស់កាចសល់ ទឹនទាំបុត្រក្សា ស្ការគាបុត្រនោះ

ប្រទាំសោះសា យល់ស្មាមជាក់ជា បង្ហាល់ខ្លួនក្តាត់ ។ ខើបតិត
ស្តាយស្តារ ស្តាយកូនសង្សារ សោះសូន្យគំនិត សោកឯងផ្សាឯង
ស្តាយអស់ព័ចិត្ត អញភូចមហាក្សត្រ ទឹងស្តាយព្នោះហោង ។ ហេតុ
អញពុំបើក បើចៅទឹងទំ ខុសច្បាប់កន្ទុង ចៅភៅភ្លាវខ្លែត រែអញ
នេះម្តង មិនបើកឡើយហោង និយាយសោតមាន ។ តេជ្ជយោជ
ស្តាប់ហើយ ទំពុំចានឡើយ ខើបនាំភៅភ្លាន នាយភ្លាវក្សត្រិណ ឲ្យ
បើកជ្រកតាន ព្រះបន្ទូលថ្លាណ ប្រែយើងនេះណា ។ នាំមនុស្ស
ភៅគាប់ ចៅបើកឆាប់ ។ ដូចព្រះអាជ្ញា នាយភ្លាវក្សត្រិណ នោះ
សោតឆ្លើយថា លោកវែលឯណា នាំពាំងកត្រែ ។ តេជ្ជយោជ
ឆ្លើយថា ព្រះអើយអញណា ប្រែកថាអ្វី បើកចៅឆាប់ ។ ទឹងគាប់
ម្ចាម្ចី នៅតាស់សេចក្តី លើព្រះអាជ្ញា ។ យើងនេះមិនព្រាង កុំ
ចៅអួតអាង ឃាត់ពាំងកំងក បើចៅមិនជឿ ចៅខ្លួលក្សត្រា យើង
ពុំមុសា- ក់ទៀបឡើយហោង ។ នាយភ្លាវឆ្លើយថា ជឿជាក្សត្រា
ប្រែជាក់មែនហោង នាំភៅសម្ងាប់ តែច្បាប់សព្វជង សម្ងាប់មនុស្ស
ជង សឹងនាំភៅថ្ងៃ ។ នេះនាំពាំងយប់ យើងទឹងឲ្យឈប់ លុះស្រាង
ខ្ចីយ បើចៅទឹងទំ យើងពុំបើកនៃ ច្បាប់យើងពីរៃ ចេះចាំ
ស្តុកនៅ ។ ហើយមានន័យយ អំពីត្រែងនាយ អញទឹងច្បាប់ចៅ
ចៅស្តាប់អញថ្លែង សំដែងសំដៅ ដោយនិទានៅ ដំណើរអតីតា ។

មុនមានសេដ្ឋី មានទ្រព្យជ្រុំបី កោដិឃ្លាំងសោះសា ចិញ្ចឹមក្តៃចាំ ក្តៃជ្រុំយេណា សឹងក្តៃជា ។ បានដូចនូវចិត្ត ។ គោះមនុស្សជាចោរ យើញតែស្រមោល ចះណ្តេញដោយជិត ព្រុសត្រមនឹងទាំ ប្រចាំគ្នាស្អាត់ រក្សាសម្បត្តិ នៃមហាសេដ្ឋី ។ សេដ្ឋីនោះណា សឹងឲ្យ រក្សា ក្តៃជាប្រក្រតី មានខ្ញុំដណ្តាំ ចាយឲ្យក្តៃធ្វើ សព្វទិនភក្តី ពុំលោះឡើយណា ។

មានកាលមួយថ្ងៃ ចោរជ្រុំរយៃ តិតគប់នឹងគ្នា រាជកមង្គ[1] ឡើងលួចទ្រព្យមហា- សេដ្ឋីនោះណា អស់ពីឃ្លាំងហោង ។ ក្តៃជ្រុំរយយល់ ក្រដូរដេញដល់ ព្រមព្រុសទឹងទាំ ដេញក្តងមង្គ ក្តងហានកំចាំង ទាំស្ងាប់ចោរចាំង ជ្រុំរយអស់នៃ ។ លុះព្រឹកសេដ្ឋីយល់ទ្រព្យបាត់ពី មណ្ឌលឃ្លាំងជ័យ ជ្រុំមួយកោដិគត់ សោះឥតសង្ស័យ សេដ្ឋីគ្រាជាក្រៃ ថាអះអាវ ។ ចិញ្ចឹមក្តៃអ្វី ឲ្យបាយរាស្ត្រ ដំណោកឥតការ ចោរលួចទ្រព្យអស់ ក្តៃពេញចាំងភ្លឺ ឥតសព្វឥតសារ ខឹងខ្លុតថ្លើម ។ សេដ្ឋីឲ្យចាប់ ក្តៃទៅសម្លាប់ ឥតសំណល់ណា លបំលុះខ្មោចកោរ ឆ្កួតក្លិនដល់មហា- សេដ្ឋីនោះណា ដ៏ជាម្ចាស់ទ្រព្យ ។ សេដ្ឋីថាយើ អស់កូនឯងតើ យកក្តៃទៅគាប់ ត្រង់ហានឯណា រាស្ត្រយាស្តីស្ងាប់ ទៅយកធាប់ ។ អូសចេញឲ្យឆ្ងាយ ។

---

១ ក្រុមគោនជា អង្គឌ្ឌិត ។

ខ្ញុំមហាសេដ្ឋី ប្តឹងច្បាប់រឹងខ្លឹ ថាឆ្កែពាំងឆ្ងាយ យើងខ្ញុំសម្លាប់ កណ្តាលព្រៃឆ្ងាយ មិនធុមដល់អាយ នេះខ្លែយម្ចាស់ថ្លៃ ។ ទើបមហាសេដ្ឋី ថាភ្នែះភ្នែចអ្វី ធុមស្អុយពេកក្រៃ អារកហិតមើល ក្លែកក្រៃវិស័យ ខ្ញុំនោះសោតនៃ ហិតរកហោងណា ។ ដល់មាត់រណ្តៅ នោះធុមស្អុយក្រៃ វិស័យសោះសា ខ្ញុំនោះរំលឹមក ច្បាប់សេដ្ឋីថា រណ្តៅម៉ួយណា ធុមស្អុយពេកសល់ ។ ទើបសេដ្ឋីថា បើភ្នែះអស់គ្នា ទៅដឹកឲ្យឃុល់ ក្បែរខ្ញុំសេដ្ឋ កាន់ចបចេល ដឹកទៅយង់យល់ ភ្នែចចោរមរណា ។ រួចសខៀងទេ សឹងចង្អុមឆ្កែ នោះគ្រប់អស់គ្នា ខ្លែឲ្យកងទមង្គ សឹងគង់ទៅជា អស់ខ្ញុំនោះ៎ មកច្បាប់សេដ្ឋី ។ សេដ្ឋីគន់គិត តែកង់គំនិត ថាអះអញភ្លែយ ឯងឲ្យសម្លាប់ ឆ្កែនោះពុំគាប់ខុសទេហោងណា ។

ទៅអើយមហាក្សត្រ ព្រះបាទព្រហ្មទត្ត លើសលើសោកា អញខ្លាចនឹងភ្លែយ ស្តាយក្រែយដូចមហា- សេដ្ឋីនោះណា មិនលែងឡើយ.ហាង ។ អញពុំបើកចៅ ចៅនាំយកទៅ ក្បាឯទៀតផង ក្បាអញមានច្បាប់ ចេះស្រាប់កន្ទុង អញពុំបើកហោង ចៅកុំខំអញ ។ ពេជ្ឈឃាជនោះស្តាប់ អស់អាថិសាសេក្ខ នោះទើបនាំចេញ ទៅក្បាបស្តីម តាលគ្រានោះវិញ អ្នកក្បានោះមិញ ពុំបើកឡើយហោង ។ ពេជ្ឈឃាជថាបើ ចៅពុំបើកតើ មានច្បាប់ខំនុង ដំណើរនោះម្តេច

ចូរទៅសាសន៍ ក្រៅឲ្យក្រាបអញហោង អស់អាថិសារសព្ទ ។ ទើប
អ្នកហ្វាទៅ លោកដែលឯណា តាំមនុស្សទៅតាប់ តាំងយប់ក្រែ
ខុសព័ន្ធចាប់ ទៅអើយទៅស្តាប់ ទំយ៉ាយអញទាន ។ មុនមាន
មហាក្សត្រែ សោយភជសម្បត្តិ សម្បូណ៌ធនធាន ចំញឹមសេកសត្វ
សេកវ័តន៍កល្យាណ ហើរទៅមាំមាន្ត រកគ័ស្តុចំណី ។ សេកមាន
សម្បុរ នោះល្អទីម៉ល កបបញ្ចូនខ្ទិយ កាលនោះស្តេចយល់ សម្បុរ
បក្សី សេកសួគ៌សោភ័ ល្អល្អះប្រៃពៃ ។ ស្តេចអរកន្ធឆ ចន្ទូល
ទៅផង សេកសួគ៌នោះនៃ សេកអើយសម្បុរ សេកយល់ល្អក្រែ ហេតុ
ដូច្នេះម្តេចនៃ ក្រាបក្រាប់អញ៎ ។ សេកសោតខ្ញើចខ្លួល បពិត្រ
ផសូរ ជាមគុជសិរសា សម្បុរខ្ញុំល្អ ដូច្នេះខ្ញុំភោក្តា ផ្ទៃស្វាយនៅខា
ព្រៃក្រែហោមភាន្ត ។ ស្វាយនោះណា បើចាស់ជក អាក្រែកប៉ុន្មាន
បើបានភោក្តា ផលនោះក្សត្ត កូណាណោះក្រែបូណា កំឡោះ
រឹតក្រែ ។ ស្តេចស្តាប់សារសព្ទ សេកសួគ៌ខ្លួលថ្នាត់ បន្ទូលថាហែ
សេកអើយម៉ែភ្នោះ សេកទៅធាប់ក្រែ តាំពាក្រែ ផ្ទៃយើងនឹងធី ។
សេកសោតខ្លួល ព្រះបន្ទូលស្រួល ស្រែស់ស្រែចអស់ក្តី ហើយហើរ
ផ្លែកផ្លោះ ស្មោះទៅឃ្លាតខ្លី រកគ័ស្តុចំណី ចំណង់ភោក្តា ។ លុះនឹង
ក្រែកាន ទើបសេកតាំបាន ស្វាយមួយនោះណា មកផ្ទៃមហាក្សត្រែ
ស្តេចអរភ្លាត់ណា ខ្លួលផសា ពាក្យសត្វ ។ ស្តេចតិតថាស្វាយ

នេះតិចអម្បាយ ចាន់ពីរបីម៉ាត់ បើអញនឹងធ្វើ ឲ្យល្អខ្លួនថ្លាត់ តែអញ
ឯងក្បត្រ នៅបុត្រកវ៉ៃយ ។ ព្រះញាតិពាំងឡាយ បើប្តេះយកស្វាយ
នេះទៅដាំនា ហានមួយបើដល់ ចាន់ផលត្រីក្សា សំមរើងយកគ្នា
ឆីឲ្យគ្រប់ហ្មាង ។ នឹងមានរូបរ៉ែក្ត ល្អប្រពៃថ្លាត់ ពេកពន់កន្ធង ទើប
ស្តេចបណ្តុះ ស្វាយនោះជាមួង ដុះដូចស្តេចបង្ង នៃចិត្តជ្រាថ្នា ។
ស្តេចឲ្យទៅដាំ មានអ្នកផងចាំ ពិភក្តិរក្សា លុះស្វាយនោះធំ ចាន
ផលផ្លែផ្កា មោតុដាំនោះណា លើរន្ធនាគនៃ ។ ពិសនាគសព្វសាយ
ជ្រួតជ្រាបផ្លែស្វាយ ពិសពន់វិស័យ លុះស្វាយនោះធំ ទើបក្បត្រ
ដៀស្តដ័យ ឲ្យបេះច្រើនវៃក យកមកហោង៍ណា ។ ស្តេចឲ្យអាមាត្យ
ជំនិតព្រះបាទ ធីមុនក្បត្រា អាមាត្យនោះធ្វើ ពុលពិសមរណា
នៅព្រៃកត្តែមហា- ក្បត្រក្សាន្តនោះនៃ ។ ស្តេចយល់អាមាត្យ
ពិសពុលសល់ខ្លាត ខែនំព្រះត្រែតវៃក ពុំពិចារណា ឡើយមហា-
ក្បត្រវៃថ្ល ថាសេកចវៃន ឧនឹងសម្ងាប់អញ ។ តែពុអញនេះម្តង
អញឲ្យឆីលង៍ មើលមុនមែនមិញ បើអញឆីឯង ឥតវែកង៍សមអញ
លុះជីវិតវិញ មិនលែង៍ឡើយណា ។ ស្តេចភ្ញាល់ឆុលធាប់ ភ័យសេក
សម្ងាប់ ឥតពិចារណា ដំណាពីនោះ ស្វាយនោះផ្លែផ្កា ឥតនរអ្នក
ណា ឧនឹងហ៊ានបេះឡើយ ។ លុះលង៍រ៉ែង៍ទៅ នាគនោះនឹង៍នៅ ពុំចាន
ថយពី លំនៅនោះចេញ ពិសគេញធរណី រៃជាសាបទ្វី ពុំពុល

ឡើយណា ។ លង់រែងៗណាស់ តាចាស់ដូនចាស់ ពិបាកវក្ស
ដ៏មហាក្សត្រ មកតិតគ្នាថា យើងនេះដក ចាស់ណាស់ហើយ ។
ខ្ទឹងតែស្ងាប់ ក៏មិនឆាប់ស្ងាប់ ដូចចិត្តនោះឡើយ . ហើញ្ចុះយើងរស់
ជាមនុស្សថ្វីឡើយ ពិបាកឥតត្រើយ មកយើងៗឯ ។ ស្វាយដែល
ស្ពេចដាំ ឲ្យស្វាប់នឹងចាំ សេរូបនៅថ្ងៃ ពិបាកអាត្មា វក្សដ៏រ គាត់តិត
ព្រមប្តី ប្រពន្ធហើយទៅ ។ ចេះបានមកធ្វើ ក្បាលណាណាឯប្តី ដែល
សក់ជាខ្មៅ សម្បុរជាខ្មោះ ឥតខ្ចះខ្ចាងសោះ ក្រែឡើកមើលទៅ ប្រពន្ធ
នោះណា ។ ដែលជាក្រមុំ សម្បុរគួរសម ដោះដូចបទុមា ប្តីថានាងល្អ
នាងមកពីឯណា ប្រពន្ធឆ្លើយថា យើងក្មេកអញ្ជើហើយ ។ ប្តីឮកវីយោ
ចាំតែពាក្យថា មុខមិនស្គាល់ឡើយ ទើបឆ្លើយទៅថា ឧណាកអញ
អើយ ពាក្យប្រហែលហើយ រូបកងឯណៃ ។ ប្រពន្ធឆ្លើយថា ព្រះ
អើយអញ្ជើ ខ្ញុំវង្សឯណៃ ក្រតើវង្សឯ រូបឯងសព្វថ្ងៃ នរណា
ឡើយនៃ អញឯងដូនចាស់ ។ ទៅឯងសក់ស ខ្លួនកោងមិនល្អ
ឥឡូវប្រែជ្វាស់ ជាសក់ខ្មៅញាប់ ចំណាប់ចំណាស់ មុខមិញក្រ-
ឡះ ប្រែជាកំខ្មោះ ។ ប្តីថាអើ។ ឲ្យស្វាប់មិញតើ មកធើស្វាយ
នោះ ម្តេចអញនឹងមេ ប្រែខ្មែរខ្មោះ មេអើយបើញ្ចុះ ជាគ័ព្ភ
យើងឯង ។ ដូនតាប្រែប្រាណ ស្រែចរិលរឹងប្លាន លំនៅឥតត្រែង
វក្សដ៏រ ដូចពីមុនត្រង់ ដោយជាតិអង្គឯង ពិតពុំឃ្លាតឃ្លា ។

កាលនោះស្តេចយល់ កំឡោះនិមិល រូបរាត្តិសោភា ស្តេចត្រាស់ដណ្តឹង ថាមនុស្សពីឯណា មកនៅក្បែរ ជំរំអញហោង ។ ទើបតាកំឡោះ ទូលថៅដោយស្មោះ បពិត្រចៅស៊ង ខ្ញុំឯងតាចាស់ នៅនេះសត្វជង ដូរតែស្វាយផង ប្រែថ្លាណាច្នេះណា ។ ស្តេចស្តាប់ថាយើស្វាយពុលមិញតើ ម្តេចប្រែជា ? ភ្នែរចូរអ្នកផង ទៅបេះម្ន័ញ យកមកឆាប់ ! អញនឹងឲ្យធ ។ អាមាត្យក្រាបលា ទៅបេះផលា មកថ្វាយភូមី ទើបស្តេចឲ្យអា- មាត្យមុនមន្ត្រី ធ្មុនចក្រី ចង់ជង អក្ខរ ។ អាមាត្យ១ធ ល្អអស់ពន្លឺយ ប្រពៃសោភា ស្តេចយល់ភ្នែរនៃ ព្រះច័យសង្កា ត្រាស់ប្រើឲ្យមហា- មាត្យមួយធ្មេក ។ រៃឯល្អនិមិល សួរសមសម្បុរ ឡើងដូចរមៀត ស្តេចត្រាស់ឲ្យគៈ-មាត្យមួយធ្មេក ទើបស្តេចបានចៀត ខ្លែនឯងព្រះហស្ត ។ ឯងឲ្យបុត្រ បុត្រាមហេសី សឹងសោយតាំងអស់ សឹងមានព្រះអង្គ នោះប្រែថ្លាណាស់ ចាកចោលឯចាស់ តែឡះដាពាល ។ ស្តេចយល់ភ្នែរហើយ ទើបក្សត្រត្រាណត្រើយ សោយផលអាហារ ល្អអស់ព្រះអង្គ រុងរឿងត្រកាល សម្តេចកូចាល ថ្លៃកន្ទឹងសព្វគ្រា ។ ទើបក្សត្រជៀសជ័យ តតក្នុងព្រះច័យ អង្គឹក្តីណា ហេតុអ្វីស្វាយពុលថ្លាណាប្រែជា ? ស្តេចត្រាស់ឲ្យអា- មាត្យមើលអស់ក្តី ។ អាមាត្យទៅមើល រណ្តៅនោះឃើញ នាគខៅអំពី មុនមានដូរភ្នែរ ទើបទូលចក្រី

ស្តេចមានព្រះតម្រិះ- ថាណាយើងយំយល់ ។ ជាតិសន្ទានា ផ្តួតផ្តាច
ព្រឹក្សា ពិសពុលអស់កល ឥឡូវនោតមិញ ពិសពេញសព្វសល់
អញទើងជាលជល់ សម្លាប់សេកសត្វ ។ ស្តេចសែនទឹកស្តាយ សេក
សួគ៌ពណ្តោយ អស្សាបង់ចាត់ នៃចៅពេជ្ឈឃាដ ព្រះបាទត្រាស់ត្តុ
អញខ្លាចមហាកប្បតែ ទើងស្តាយគ្រោយតែ ។ ហេតុនោះឯងអញ
ពុំបើកចៅចេញ ទៅចាំងយប់នៃ មើលទោសភ្លាំងសល់ ចៅចាំជល់ថ្ងៃ
ឆ្លាប់មានកប្បតែថ្ងៃ ទើងភ្ញាល់ពុំបាន ។

ពេជ្ឈឃាដស្តាប់ស្តេច នាយគ្វាសំដែង ដំណាលនិទាន ទើប
ទៅឯគ្វារ ទុត្តរើហាន ពេជ្ឈឃាដហៅហាន ស្រែកថ្កាប់ទៅថា ។
ប្រើយអស់នាយគ្វារ ក្បាសត្វកាល បើកអញម្តងមា តាស់ប្រើអញនាំ
អ្នកទោសសន្ធិយោ ទៅគាប់សោះសោ ចៅបើកអញឆាប់ ។ នាយ
គ្វារធ្វើយទៅ ថាចៅប្រើយចៅ មិនដែលមានឆ្លាប់ នាំអ្នកទោសទៅ
សម្លាប់ចាំងយប់ អញយល់ពុំគាប់ ទុសព្រះមាគ្គា ។ ពេជ្ឈឃាដទើងខំ
ថាម្តេចក៏ពុំ បើកព្រះអាជ្ញា ជើមអញដើមគាន ឆ្លើមានមាគ្គា ឃាត់
ចាំដំកំឆក លើព្រះបំរែ ។ នាយគ្វារធ្វើយទៅ ថាពេជ្ឈឃាដចៅ
ឯងអញឯងបើ អញហោតម្លើះទុស ឆ្លាប់ដូច្នោះតើ ចៅទើងខំប្រែ
ឲ្យបើកទៅបាន ។ អញជានាយគ្វារ តិរមតិចា រឿងតិបុកណា
មិនដែលតុថា ដូច្នោះទើងមាន បើទោសប៉ុន្មាន កប្បតែថ្ងៃមានបុណ្យ ។

ប្រែនាំទៅផ្តន ចៅនៅនេះហោន ទំព័ត្រកឡើន សំមនាំចេញទៅ
យើនយាត់បើគ្គន ទោសយើនឯនហោន សឹនមានគ្រប់គ្នា ។ យល់
តែស្តេចប្រែ យើនបើកហើយតើ មិនខុសមាត្រា ដំណនឹនឃ្លឿន
ឃ្លាតស្លឿនច្បាប់ច្បា- កដកើតអនា ទរដៃគ្រែមកែ ។ ស្រដីកដការ
ដោយមុខភ្នាក់ងារ កាន់ខ្លាប់ទីតែ យល់តែអំណាច លួមភ្ជាប់ៗកែ
បើពុំលួមនែ ពាស់ក្បាលដោយច្បាប់ ។ មុខមន្ត្រីធំ បើបានដំនុំ
ព្រមប្រែសម្ងាប់ ឬតែក្បត្រា ពុះពារប្រែកាប់ គ្រែតកែទុនោប់
ឧនព្រះអំណាច ។ ចៅអើយច្បាប់មាន ក្បត្រតាំបុកណា ចារមរៀងពត
បើពុំទ្រង់ធមិ សម្ងាឯងអាច អានព្រះអំណាច ខុសច្បាប់ហើយណា ។
មុខមន្ត្រីធំ អ្នកប្តឹងដំនុំ តតព្រមគ្នីគ្នា បណ្តេញស្តេចចង់ ឥព្រះខតក
ដ្បិតស្តេចពុះពារ បំពាក់បំពាន ។ បើកស្តួមន្ត្រី ពុំដោយច្បាប់តា
ចារមបុកណា លួមលក់លួមលៃ លួមក្រយក៏ចាន នោរបុំខ្នាន អញ
តុំបើកឡើយ ។

ទេះបទព្រហ្មគីត ។

កាលនោះឯមហាក្សត្រ ព្រះព្រហ្មទត្តកើនឡើងហើយ ហ្លួ-
ច័យសោតពុំស្បើយ តតទៅដល់មាយើងថា ។ មាយើងមានគុណ
កែ កាលនៅព្រៃមានតែមា- យើងឯងឥតនឹណា កែកអំពីមាយើង
ឡើយ ។ ឥឡូវនេះអញប្រែ ឲ្យគេធ្វើឥតគាត់ហើយ គេកាប់ឬ

នៅឡើយ អ៊ុះអញស្តាយពាន់ពេកណាស់ ។ ស្តេចត្រាស់ឲ្យអាមាត្យ
រត់ទៅយកនូវសម្ដីមា នៅតាមយកចៅអា- យើងមកវិញពុំពាក់ ។
កាលនោះឯអាមាត្យ ក្រែញក្រែចប្រាថ្នាតែសង្ឃឹត តាមនៅពាន់ពេជ្ឈ-
ឃាដ នៅនាក្នុងទុត្តរនោះ ។ ទើបនាំមាយើងយក រៀងដំមកថ្វាយ
ក្សត្រស្នោះ ទើបស្តេចបន្ទូលឆ្ពោះ ដល់ណាំងចៅមាយើងថា ។ ម៉ៃ
មាយើងអើយចៅ កាលអញនៅលេងត្រីក្បា អញយល់មាឯងជា
មានគំនិតគំនួរក្រែ ។ ឥឡូវម្តេចចៅគិត ក្រែងណាវៃបចិត្តនៅលីម៉ៃ
ចូរចៅចែងសម័យ ចរចាមកឥឡូវកុំ ។ មាយើងទូលគំនិត ថា
បពិត្រព្រះពជា កាលក្នុងយប់មិញណា ពស់វាមកទាំក្សត្រៃថ្ងៃ ។
ខ្ញុំកាប់ពស់អន្តរាយ លោហិតក្តាយពីក្រោមក្រែ ពេញព្រះថនាង
វាទៅពីសេសសល់ ។ ខ្ញុំពុំហានច្រមាច ដាស់ព្រះបាទឲ្យអំពល់ ខ្លឹង
យកដៃដិតជល់ សោតពុំគួរទើបខ្ញុំខំ ។ យកអណ្តាតលិទ្ធឈាម
ក្លែកក្តែតគ្នាមពិតពុំសម ដាបជល់ព្រះអង្គអ- ម្ចាស់ឲ្យបង់យកចៅកាប់ ។
ខ្ញុំខ្លឹងខ្លួលក្សត្រក្សាន្ត ថាស់ពុំហានក្រែងខុសគាប់ អំពល់ប៉ើខ្លឹងស្លាប់
តាមវៀកអំតើកម្ម ។ តែជះហេតុអំតើ ត្រង់ពុំធ្លើវៀចម្ន ទើបមានយូរ
បញ្ជាំ ឲ្យគេស់ពាល់ពុំឲ្យទៅ ។ យកមកពិចារណា អង្គឹអសារ
សូន្យសៅ ក្បាលក្បាយជីតែនៅ នាងណាំនាយឥតការ ។ ស្តេច
ស្តាប់ដល្អាំងឆ្ពោះ បើដូច្នោះខ្លាចពស់ពាល ចៅទុកឯណាកាល

ឥឡូវចៅប្រាប់អញហោង ។ មារយើងទូលថា ខ្ញុំពុកនាគ្រាម
នៃផង គាំង ៣ កំណាត់ហោង គ្រាមចន្ទំនិទ្ធភូបាល ។ ទើប
ស្តេចឲ្យ.ទៅយក ទៅចំពស់មកមែនដូចសារ សព្វចៅមារយើងគាល
នោះព្រះអង្គដឿជាក់ស្តែង ។ ក្សត្រៃថ្ងៃបុណ្យឱ្ងន់ឱ្ងស់ យល់ទៅច
ពស់រៃឯស្ងប់ស្ងៀង ព្រឺព្រួចច្រឹងគ្រវែង ព្រះសិរីសោមទូលថា ។
តព្វជាមារយើងអើយ កុំអីឡើយលុះមណា ឧមារយើងមហា- គុណ
អនេកអនន្តកៃ ។ អ្នកផងសឹងស្ងប់ស្ងៀង ព្រឺគ្រែវែងខ្លួនទីកៃ យល់
គុណមារយើងកៃ គ្រាស់តតទឹងចូងថ្ងូរថ្ងៃ ។ ស្តេចឲ្យស្រែយចំណង
មារយើងហោងប្រាសលះលែង ទៅសទុក្ខបង់រៃ ហើយបន្ទូលដោះ
សារថា ។ ចៅអើយហេតុអញខ្លៅ ធ្លើទោសចៅឥតកុណា កុំចៅ
យកទោសា អញទូលជាខុសហើយ ។ ទើបស្តេចតិតគុណកៃ
ឲ្យយសថ្ងៃឥតស្មើឡើយ នៃមារយើងជាគ្រែយ ជាមន្ត្រីធំកន្ធង ។
ទឹងអ្នកសឹងចុះឡើង ចៅមារយើងឥតជ្ងឹមផង ហេតុបានកំរោគ្រង
កបន្ទរលំភូណ៌សួគ៌សល់ស្រី ។

នេះបទកំពតតី

ទឹងទិពនថ្លើង យសចៅមារយើង សាន្តសំខ្ញើ នេះទើបនៅថ្ងៃ
សំដែងស្រដី ដំណើរអំពី អ្នកនាយកេតា ។ ជាន់មេកវញ្ជើ ទ្តុះអរ
លលើ ទៅជាកំរោ តុំដែលមានទ្រព្យ ប្រជាប់ប្រជា លុះជួនហើយក

ឆ្លើងឆ្លើងដាំកែ ។ ស្ងៀកខៀនស្ងៀកកែ ស្លាដ៏ខ្លួនបង្ហែ ផ្លុំតផ្លុំ
សព្វថ្ងៃ អាងប្តីមានទ្រព្យ ប្រែជាច់ច្រែនកែ ថាអញនេះនៃ ឥត
តេផ្ទឹមផង ។ ហើយពុំស្រដី ទ្រព្យធនអ្វីៗ សំពៃស្លួនត្រង់ ស៊ី
ចាក់ស៊ីចោល ចាបសាបជាម្តង់ មានកូនមួយផង ទិងនាយនោះ
នៃ ។ បើកូននោះផ្ទុះ មេកញ្ជើផ្ទុះ ពុំលាងវិស័យ ដូចអ្នកចាំង-
ឡាយ អាងទ្រព្យច្រែនកែ ហែកកែពាក់ថ្ងៃ ។ ជួតតាបម៉ាចាលទៅ ។
លង់លុះវែងឆ្ងាយ ក្បាលខ្យត់អន្តរាយ ទ្រព្យចាំងសំពៅ ប្រែជា
អ្នកខ្យាត់ ខុតតអាសៅ លក់ចាំងសំពៅ ស៊ីចាយអស់ហោង ។
ហេតុស្រីវាតលំក្ខណ៍ ពុំខេះខុតជាក់ រក្សាស្លួនត្រង់ ឲ្យអាប់យស
ប្តី អប្រិយកន្ធង់ សព្វថ្ងៃនេះហោង សូមមានតេស៊ី ។ កំសោយ
កំសត់ ហ៊ានហោចខុតត ដើរដោយទិសទី ស្ងែងកេសូមមាន សព្វ
ហានទីកែ ចិញ្ចឹមជីវី ជីវិតសព្វថ្ងៃ ។ សូមមានរៀងទៅ ជួចដល់
លំនៅ ផ្ទះមាយើងនៃ នាងយល់អ្នកខ្យាត់ ខុតតក្រែកែ ស្មានអ្នក
ដទៃ ហើយឲ្យតាទៅ ។ លុះតន់ជាក់លាក់ នាងស្គាល់ជាអ្នក
ចៅនាយសំពៅ ប្តីដើមនៃនាង ទើបនាងថាចៅ តុនាយសំពៅ
ម្តេចដើរសុំទាន ។ ប្តីផ្តាច់ប្តោះបង់ អញឥតមានស. ធ្វើយអញ
ស្មោះស្មាន ទិងកំតាបស់ សំក្តីយសធនធាន ឥឡូវម្តេចច្បាណ
ប្រែជាខ្វះនេះ ។ ស្តីពោកមុខចៅ ចៅនាយសំពៅ ដើរសូមមានតេ

ស្រឡាញ់ចែកទ្រព្យ ល្អពេកមុខរមេ កញ្ជើដុះខេ ល្អពេកច្រើនជ ។ នេះហេតុលំគូណាស្រែ ចំរើនឲ្យប្តី ចរិយូណាច្រានបង ស្រីយើងចង់ចែកពេកតែច្រើនជ នៅនឹងអ្នកខ្សត់ ក្រែជាអ្នកមាន ។ កំសត់ចាន់ពីរក្នុងហើយរមិល មើលនាងកល្យាណ ស្គាល់ជាក់ហើយក្នុងស អាស្រីរកាសភាន ចេញសេចញ្ចៀមហាន លំនៅអាត្មា ។ ចៅមាយើងយស ទុត្តមក្តីដំខ្ពស់ ជ្រួតច្រានតរិយោ យសយីនពណ្ណាយ ក្តៅត្រួយសោះសា ច្រើនជច្រុសច្រ- កបក្តៅវែងត្រួយ ។ រីឯសារសំពួ ដំណើរក្តៅ-កាព្យ មានតាត្រែងនាយ ចរមបុកណ ខុតជានិយាយ អស់អាចម៍-រិយាយ ចែងចប់ម្ល៉ះហោន ។

ចប់រឿងមាយើងតែប៉ុណ្ណោះ ។

អ្នកទកញ៉ាវែងព្រួសារពេជ្រ ឆង រៀបរៀង

(តមក)

តិតថាស្រីក្នុង ក្នុមិតពកំឡុង ជម្ពូទ្វីបា ស៊ើសកេជ្ញាល់ផ្ទឹម ព្យាត្រីមជ្ឈា នាងនេះដាក់ជា កន្ធងលែងស្រី ។ មើលមុខមាន យស សក្តិសម្រស់ស្រឡះ ហាក់ចន្ទូបូណ៌ម៉ែ ត្រចង់ត្រចះ ស្រឡះពីស្បែ កបកល្យាណ៌ មានប្តីឪ្យនៅ ។ តិតគួរលេលង ដណ្តើងជាល្បង ទុបាយកលទៅ ម៉ែនាងនេះចេះ ចំណេះពុំខ្វៅ ច្បាប់ជ្ញាជាបណ្តៅ សមដឹងមិនខេ ។ តន់តិតស្រាប់ស្រេច ពន្ធកសតេជ្ញ ទៅខៀបមានតែ ៧ ដំខែន ចាយខែងច្បាប់ប្រែ ប្រស្នាថាមេ មាសមកពីណា ។ ដើរតែម្នាក់ឯង អាចច្បាសលះលែង តែម៉ែប្អូនភ្លា អំពាល់តិតភ័យ សង្ស័យចិត្តា ចូរចៅចរចា ច្បាំយច្បាប់ដោយត្រង់ ។ ឯនាងកល្យា . ណីនោះបរចបាន សាងនិងព្រះអង្គ មុនមកច្រើនជាតិ ច្រើសច្បាប្តាត្រង់ ពន្ធកពូជពង្ស សាតិជ្ញដូនស្រី នាងដឹងកងចិត្ត ភូជពង្សព្រួទ្ធតែន ឯងអស់ឥតប៉ា សន្ទុះសង្កា ប្រស្នាខ្លីវ សុះសព្វសេចក្តី មិនមានពីការ ។ នាងឆ្លើយថាអ- ម្ចាស់អើយខ្ញុនុ៎ះ មកមិនខើសការ ពាស់ខែងទោសខុត្ត សាន្តសុខក្រសាល អង្គឥតពីការ តាតើយសម្ងួយ ។ ឯអាថិប្រស្នា ចំណោ

ព្រះមហា- បុរសប្រុងប្រយ័ចែងចាត់នារី ស្រស់ស្អើគោមនាយ
ជាហេតុទុប្រយ័- ឥសកិច្ចខ្មែរឡាត់ ។ បើនាងថាមាន ការភ័យព្រួយ
ប្រាណ ប្រាកដដឿងជាក់ នោះនាងមានប្តី ស្វាមីរួមក្បែ កែនប្តី
អន់អាក់ ប្រចណាសង្ស័យ ។ បើនាងថាពុំ មានមោះអង្គអំ- ពល់ពី
ការភ័យ នោះនាងមិនមាន ប្រាសប្រាណដរៃ ដួចចាប់ប្រស័យ
ជាគូកាន់កួច ។ ពង្សពុទ្ធចមច័ក្រ ស្តេងស្តាប់ដឿងជាក់ ចូលចិត្តព្រឹ
ព្រួច ព្រឹសព្រះហ្ឫទ័យ អរកែលនលួច ក្រឡាប់កាន់កួច ជួប
ចាប់ប្រតិព័ទ្ធ ។ ទើបយាងព្រះបាទ ទៅទៀបនាងនាដ នារីរូប
រ័តន៍ ប្រប់ប្រាណបានថែរ រួសរេដល់ដីត ថាមេមាសមិត្ត នាមនាង
ឈ្មោះអ្វី ។ នាងស្តាប់ពាក្យ តន់តិតថែថា អ្នកនេះពីស័ ល្អល្អះ
អស់អង្គ ប្រុសក្នុងលោកិយ បិតហាននែនដី មិនមានដូតដល់ ។
បើល្អតែកាង រូបឆោមស្អាតស្អាង អាប់ឥតយោបល់ ល្ងង់ល្ងីកំឡៅ
ខ្លួនខ្លៅឆ្ងាយឆ្ងល់ តន់តិតពុំយល់ ការកិច្ចប្រស្នា ។ បើចិត្តចង់បាន
អង្គអញមិនមាន ចិត្តចាប់ចេតនា តិតគូរលលង ប្រាប់ល្បួងថាជា
កិច្ចកល់ប្រស្នា ចង់ដឹងសេចក្តី ។ នាងនាដតន់តិត ស្រាប់ស្រែច
ស្រីរ័តន៍ ឆ្ងាស់ឆ្ងើយទៅខ្ញុំ ថាអ្នកប្រុសអើយ អ្នកអើយមានអ្វី ប្រ-
សើរឯស្រី នោះឯងឈ្មោះខ្ញុំ ។ ព្រះពង្សពុទ្ធរ័តន៍ បញ្ជាបរមេត្ត
ចារមីបរម សាស្តាស្តេងស្តាប់ សារសពួកចិច្ចក់- ចាំងបានដឹងដំ- ណើរ

នោះវៀងជាក់ ។ តែតពុំឆ្ងាយឆ្ងល់ ទឹងព្រះយោបល់ ច្រើបច្រើស
ច្រើតក្សត្រ មិនមានទើសខាល់ សានសល់ជំពាក់ មិនមានថ្នាំងថ្នាក់
ក្នុងព្រះចិត្តា ។ ទើបអ្នកឆ្លើយទៅ ថាលៃហួនទៅ ពាលតេញ
តំណា ឈ្មោះកល្យាណី ឬអ្វីហួនភ្លា នាមនេះជាក់ជា ប្រសើរ
ឯស្រី ។ នាងឆ្លើយថាអើ ឯអម្ចាស់តើ នាមហៅឈ្មោះអ្វី អ្នក
អើយថាលៃ មាសថ្លៃប្រឹមប្រិយ ចូរហួនតិស៍ ស្តាប់បងបរាថ ។
បងនឹងច្រើយច្រាប់ អ្វីមួយពុំគាប់ ព្រះទ័យក្សត្រា ជាឈ្មោះបងប្អូ
ចូរទៅពុំជា មាសមានច្រើជ្ញា ឯងអធ្យាស្រ័យ ។ នាងនាងនិមិល
ច្រើជ្រប៉ែតតែល ជាន់ឥតឯណា យលអាថ៌ជាក់ច្បាស់ តើហៅឈ្មោះជ័យ
ដ្បិតជ័យនោះនៃ ចាន្ទូថាឈ្មោះ ។ ធម្មតាមហាក្សត្រ សោយភាគ-
សម្បត្តិ ព្រះទ័យមានៈ ច្រកចាន្ទូ ចារមើតេជះ ឮតេថាឈ្មោះ ពុំ
ក្បាន្តចិត្តា ។ ទើបអ្នកឆ្លើយស្តង នាឆ្លើយឈ្មោះបង តែតដួចហួនថា
អឡូវបងទៅ សូរទៅពំនាំ មាសមកតែឯណា ដួចដល់ហានអាយ ។
ហួនឧឹងទៅតែ ហានេះទៅទី ខ្ញើតខ្ញៀបឬទ្ធាយ ចូរហួនតិស៍ ច្រើម
ច្រើយច្រាប់ច្រាយ ចរចាចែងចាយ ចង់ដឹងសេចក្តី ។ នាងនាង
ទ្វាស់ឆ្លើយ ថាម្ចាស់ខ្ញុំអើយ ខ្ញុំមកអំពី នោះមកដល់ណោះ ឈប់
ស្នេះនៅទី ទើបទៅខ្ញើតតែ នេះទៅឯណោះ ។ ទើបអ្នកឆ្លើយទៅ
ថាម្តេចដូច្នោះ នាងប៉ាខ្ញុំឆ្លើយ ចម្លើយដោយដោះ សាសង៌ចំពោះ

តាមពាក្យអ្នកថា ។ គោធិសត្វឆ្លើយ ថាប្អូនដឹងហើយ ប្តូរអ្វីប្អូនក្មួ
ថាមើប្អូនដឹង ដំណឹងច្រើនច្រើន- កដោយច្រើនថ្ងៃ ចូរទៅសា-
ស្រាយ ។ នាងថាខ្ញុំដឹង ខ្ញុំមានដំណឹង អស់អាថអព្ភូតច្រើនយ អ្នក
ដណ្តឹងខ្ញុំ តាមកំណើតនាយ ឫតមកអាយ តើតនៅនេះមិញ ។
ហើយដណ្តឹងថា ខ្ញុំនឹងយាត្រា ទៅឯណាវិញ នៅចុងកំណើត
ខ្ញុំកើតខ្មៃតមិញ ពាំនេះអត្តអញ ពុំដឹងដៀងជាក់ ។ ហេតុដូច្នេ
កំណើត ទៅមុខខ្មៃតកើត កន្ទុកភូមិកពេក ចំណេរទៅបាន និញ្ចាន
ដៀងជាក់ ផ្តិលផ្តាច់អស់អ- កុសលច្បាបចង់ ។ ព្រះពង្សពោធិ ស្តាប់
នាងនារី ឆ្លាស់ឆ្លើយត្រូវត្រង់ ដោយធម៌សុចរិត ពេកពិតពុំលង់
ខ្មៃនទើបព្រះអង្គ សើរសួរទៅថា ឥឡូវប្អូនស្រី យកចុាយចំណី
ទៅជូននរណា ដើរតែឯកអង្គ គ្រាចំកន្លែងព្រឹក្ស ចូរទៅចរចា បង់ចង់
ដឹងជាន ។ នាងនាងឆ្លាស់ឆ្លើយ ថាម្ចាស់ខ្ញុំអើយ ចិត្តខ្ញុំស្មោះស្មាន
យកចុាយចំណី អំពីគ្រែស្មាន ទៅជូនអ្នកមាន គុណមួយអនន្ត ។ ព្រះ
មហាបុរស យង់យល់អាថអស់ កំចុងារមិនម- ន្ទិលថាស់ដល់តិច ស្រាប់
ស្រែចបើកថ- ន្ទុលថាប្អូនតន់ ទៅរកបិតា ។ បទមានគុណធ្ងន់ ជាក់
ជាអនន្ត បង្កើតអាត្មា បិតាប្អូនទៅ តើទៅឋានណា មានបើច្រើន
ប្រយោជន៍រកអ្វី ។ នាងនារីរតន៍ ឆ្លាស់ឆ្លើយទៅថ្លាត់ ច្រើនព្រះពោធិ
អាពុកខ្ញុំកូវ តែងទៅជួរចិ រកបេះផលពី ព្រៃធម្មអម្ពរ ។

(មានត)

(តទៅ)

សេលោ យថា បព្ពតោ ឯកគ្ឃនោ ភវេយ្យ ន សមីរតិ

ឯវំ និន្ទា បសំសាសុ ន សមិញ្ជន្តិ បណ្ឌិតា(១) ។

(បែលថា) ភ្នំជាវិការនៃថ្មសុទ្ធមិនរំកើបញាប់ញ័រដោយខ្យល់ទាំង ៤ ទិស មានទំសបូពិជាដើម (ដែលបក់មកត្រូវ) យ៉ាងណាមិញ, អ្នកប្រាជ្ញទាំងឡាយ លោកមិនរំកើបញាប់ញ័រក្នុងលោកធម៌ទាំង ៨ ប្រការ គឺមានលាភឥតលាភជាដើមយ៉ាងនោះដែរ ។

ក្នុងបទគាថានេះ បើតាមវេជ្ជកុដ្ឋកថាលើមានតែត្រឹមលោកធម៌ពីរប្រការ គឺនិន្ទានិងបសំសា ក៏ពិតមែន តែក្នុងអដ្ឋកថាមានសេចក្តីពន្យល់ថា ត្រូវដាក់បន្ថែមដល់លោកធម៌ទាំង ៨ ប្រការនោះដែរចុះ ។

មិនតែប៉ុណ្ណោះសោត ព្រះអដ្ឋកថាលោកសំដែងផ្ទួនថែមទៀតថា:

សេលោ យថា បព្ពតោ ឯកគ្ឃនោ ភវេយ្យ ន សមីរតិ

ឯវំ រូបា រសា គន្ធា សទ្ទា ផស្សា ច កេវលា

ឥដ្ឋា ធម្មា អនិដ្ឋា ច ន រេវេន្តិ តាទិនោ

ឋិតំ ចិត្តំ វិប្បមុត្តំ វយញ្ចស្ស ឧបសន្តោ(២) ។

(បែលថា) ភ្នំជាវិការនៃថ្មសុទ្ធមិនរំកើបញាប់ញ័រដោយខ្យល់ទាំង ៤ ទិសមានទំសបូពិជាដើម (ដែលបក់មកត្រូវ) យ៉ាងណាមិញ, រូប

---

១ — ធម្មបទ បណ្ឌិតវគ្គ លក្ខណគាថា ។ ២ ឥដ្ឋារម្មណ្ឌវគ្គ ទុតិយបណ្ណាសក. ឧបរិមវគ្គ. ធម្មបទដ្ឋកថា មហាវគ្គ. សោណវត្ថុ ។

សំឡេង-កូន-រស-ផស្សៈ នឹងធម្មារម្មណ៍ទាំងអស់ ដែលជាទីតាប់ចិត្តក៏មិនជាទីតាប់ចិត្តក៏ នឹងញុំាងចិត្តរបស់កិកុជាតាទិបុគ្គល (១) ឲ្យញាប់ញ័រមិនបានយ៉ាងនោះដែរ, ចិត្តរបស់កិកុនោះជាចិត្តនៅឋិតប់ឋិន ជាចិត្តយាងចុះសិង្កត់ក្នុងព្រះនិព្វានជាអារម្មណ៍, លោកពិចារណាឃ្លាសេចក្តីកើតនឹងសេចក្តីរលត់នៃចិត្តនោះ ។

គាថាទាំង ២ បទដែលកាប់ថាជាមង្គលនេះ គាថាទី ១ ខ្ញុំប្រាប្តនឹងលកុណ្ឌកភទ្ទិយត្ថេរដែលលោកមិនរំភើបញាប់ញ័រ អាក់អន់ស្រពន់ចិត្តក្នុងពាក្យចំអកចំអន់ឡកឡឺយជាពាក្យឥតប្រយោជន៍, ដែលតិកុកំណើរនឹងសាមណេរទាំងឡាយឃើញព្រះថេរៈនោះលោកគឿ ក៏នាំគ្នានឹកស្មានថាសាមណេរតូច ខ្លះចាប់ចុងដៃ ខ្លះចាប់ចុងស្បា - ខ្លះហៅលោកពូ ខ្លះហៅលោកតា ហើយសួរថា លោកមិនអផ្សុកទេឬអ្វី ? លោកក៏មិនរំភើបញាប់ញ័រក្នុងពាក្យចំអកចំអន់នោះ ។ ទើបព្រះដ៏ខ្ញុំទាំងឃសខ្ញុំទាំងឯងសរសើរថាចិត្តនេះហើយជាមង្គល ។

គាថាទី ២ ខ្ញុំប្រាប្តនឹងព្រះសោណត្ថេរ កាលដែលលោកបានសម្រេចអរហត្តផលរួចហើយ ទើបប្រកាសសេចក្តីប្រាប្តចំពោះភាក្ខឯងថ្វាយព្រះដ៏មានព្រះភាគថា ចំនែកព្រះទីណាស្រពដែលមានចិត្ត

---

១ បុគ្គលដែលមិនញាប់ញ័រដោយសេចក្តីត្រេកអរ នឹងសេចក្តីអាក់អន់ចិត្តក្នុងអារម្មណ៍ជាទីគាប់ចិត្ត នឹងអារម្មណ៍មិនជាទីគាប់ចិត្ត ។

ដុតចាប ពត: គោស: មោហ: ហើយ លោភតាំងនោះមិនចាន់រកែប
ញាប់ញ័រដោយអារម្មណ៍តាំង៦ មានរូបារម្មណ៍ជាដើម មានធម្មារម្មណ៍
ជាទីបំផុតសោះឡើយ ។

ទើបព្រះអដ្ឋកថាចារ្យនិតន្ទគាថានេះទុកថា "សេលោ យថា
ឯកឃនោ" ប៉ុណ្ណោះជាដើម តាមនំនងព្រះពុទ្ធដីកាដូចខ្ញុំធ្លាប់សំដែង
ហើយនោះ, សភាពចិត្តនេះជាមង្គល ។ សុភាសិតតាំង៦នេះ មូល
សេចក្តីទៅលើចិត្តបេស់ព្រះខីណាស្រពតាំងអស់ ។

ចប់ សេចក្តីក្នុងមង្គលសូត្រប៉ុណ្ណោះ ។

ដំណាពីនេះ ខ្ញុំនរៀបរៀងសេចក្តីជាបកិណ្ណក:ដែលជាប់ទាក់ទង
ដោយលោកធម៌បេស់បុថុជ្ជននិងព្រះខីណាស្រព ដើម្បីជាគ្រឿងប្រ-
ជាប់បញ្ញាបេស់សិក្ខាតាមកុល់បុត្រអ្នកត្រូវការនិងយកជាវត្តប្រតិបត្តិបាន
ដោយងាយ ដូចនិងមានតទៅនេះ ។

មិលិន្ទប្បញ្ហា. ណាវុលតាវគ្គ.

១ រឿងជាស់តឿនបំពោះលោកធម៌.

ដំណាលសេចក្តីថា: ព្រះចាមមិលិន្ទខ្ញុំនិងចោទដណ្តើនសួរតអង្គ
បេស់យុថ្លាថាមានប៉ុន្មាន? ព្រះនាគសេនត្នេតបថា មានអង្គ ២ ដោយ
បរិយាយថា បតិត្រមហារាជ ធម្មតាយុថ្លាវមែងតែងនិងលិចចុះកន្លែង
ខ្លះលន់នាក់មិនឲ្យរំកើបញាប់ញ័រដោយលេក -ឲ្យលំព្រះដែលបក់បោក

មកត្រូវ, ហើយរក្សានាវាមិនឲ្យសាត់អណ្តែតទៅកាន់ទិសផ្សេង ។ ជាន
ដូចម្តេចមិញ; ចតិត្តមហាភដ'' ព្រះយោគាវចរលោកកំណត់ចិត្តរបស់
លោកមិនឲ្យចិត្តសាត់អណ្តែតទៅកាន់អារម្មណ៍ផ្សេង ។ ដោយលក្ខគ
ណៈ: ទោសៈ: ទោហៈ: មកច្រហារខ្លួយ, ដូចយុថ្កាដែលចង់ចល់នាវា
ឲ្យទន្ទឹងនៅកណ្តាលមហាសមុទ្រដូច្នោះដែរ នេះជាអង្គទី ១ ។

មួយទៀតមហាភដ ធម្មតាយុថ្កាមិនឃ្លងឃ្លាងលិចនៅតែកណ្តាលទឹក
ជំរៅ ១០០ ហត្ថខ្លះ (២០០ ហត្ថខ្លះ) ចង់ចល់នាវាឲ្យទន្ទឹងនៅ ដូចម្តេច
មិញ; ព្រះយោគាវចរមិនឃ្លងឃ្លាងកណ្តាលក-យស-សក្ការៈ-ពាក់អាន-
ថ្វាយបង្គំ-កោតក្រែងខ្លួយ, លោកដំកល់ចិត្តរបស់លោកឲ្យទន្ទឹងនៅកណ្តាល
បច្ចុយ ៤ គ្រាន់តែល្មមនឹងចិញ្ចឹមជីវិតប៉ុណ្ណោះ; ដូចជាយុថ្កាដែលចង់ចល់
នាវាឲ្យទន្ទឹងនៅកណ្តាលមហាសមុទ្រ ដូច្នោះដែរ នេះជាអង្គទី ២ ។

សមដូចគាថាសិតរបស់ព្រះសារីបុត្តថា:

យថា សមុទ្ទេ លកគំ[1] ន បលវតិ បសីទតិ[2]
តថេវ លាភសក្ការេ មា បលវថ បសីទថ ។

អធិប្បាយថា: ធម្មតាយុថ្កាមិនឃ្លងឃ្លាង តែងទន្ទឹងលិចចុះកណ្តាលទឹក
សមុទ្រ យ៉ាងណាមិញ; អ្នកចាំងឆ្លាយកុំឃ្លងឃ្លាងលិចចុះកណ្តាលលាភ
ទន្ទឹងសក្ការៈខ្លួយ ដូចជាយុថ្កាដូច្នោះឯង ។

ចប់រឿងគាថាសិតទៀតចំពោះលោភធម៌តែប៉ុណ្ណោះ ។

---

១ ប្បាប់ខ្លះថា " លង្គទភា " ។ ២ ប្បាប់ខ្លះថា " វិសីទតិ " ផ្លូវច្រេះកំមាន ។

ធម្មបទ កោធវគ្គ

២_ រឿងអតុលឧបាសក(១)

មានសេចក្តីដំណាលថា: គ្រាកាលព្រះបរមគ្រូទ្រង់គង់ធ៌មានៅឡើយនោះ, សម័យមួយស្តេចទ្រង់ប្រថាប់នៅកន្លែងវត្តជេតវ័ន កាលនោះមានឧបាសកម្នាក់ឈ្មោះអតុល:នៅកន្លែងក្រុងសាវត្ថី, ថ្ងៃមួយគាត់នាំគ្នាប្រហែលជា ៥០០ នាក់ទៅវត្ត បម្រុងនឹងស្តាប់ធម៌កន្លែងសំណាក់ព្រះវេតត្តេរ លុះទៅដល់ហើយក៏នាំគ្នាថ្វាយបង្គំអង្គុយចុះកន្លែងដ៏សមគួរ ។

ឯព្រះវេតត្តេរលោកជាអ្នកត្រេកអរតែកន្លែងស្ងាត់ ប្រៀបគួរនឹងដូចជាសត្វស៊ីហ:ចូលចិត្តគ្រាច់ទៅតែឯកឯង; ជាន់ជាលោកមិនធ្លាប់ដំណាក់តិចតួចជាមួយនឹងឧបាសកនោះឡើយ គេក៏ខឹងអន់ចិត្តថាព្រះថេរៈនេះលោកមិននិយាយនឹងឯងមួយម៉ាត់សោះ; ក៏ក្រោកឡើងដើរទៅកាន់សំណាក់ព្រះសារីបុត្តត្តេរ។ លោកសួរថាអ្នកមកត្រូវការអ្វី? គេក៏ពិតថេរៈថាថា លោកម្ចាស់ខ្ញុំនាំឧបាសកទាំងនេះមកកាន់សំណាក់ព្រះវេតត្តេរបម្រុងស្តាប់ធម៌លោក។ មិនអើពើនឹងយើងខ្ញុំសោះ ទើបយើងខ្ញុំអន់ចិត្តត្រឡប់មកកាន់សំណាក់លោកម្ចាស់វិញ សូមលោកម្ចាស់សំដែងធម៌ឲ្យពួកយើងខ្ញុំ ។

---

១ អ្នកមិនចេះប្លឹងលោកធម៌ ។

គ្រានោះ ព្រះសារីបុត្តលោកតបថា បើដូច្នោះចូរអ្នកនាំគ្នាអង្គុយ ប្រុងចាំស្តាប់ចុះ អាត្មានឹងសំដែងដូន, លោកក៏សំដែងព្រះអភិធម្មឲ្យ ស្តាប់ គេក៏ខឹងអន់ចិត្តទៀតថា ព្រះអភិធម្មនេះជាធម៌ល្អិតណាស់ ហួត ចត់ណាស់ ព្រះថេរៈលោកសំដែងព្រះអភិធម្មយើងនឹងស្តាប់យកជា ប្រយោជន៍ម្តេចបាន ហើយក៏គ្រាកឡើងនាំបរិស័ទរបស់ខ្លួនទៅកាន់ សំណាក់ព្រះអានន្ទត្ថេរ។ លោកក៏សួរពាក់ខាត់ គេក៏ដំណាលរឿងតាម ហ្មូរហែ ហើយសូមទិមន្តព្រះអានន្ទសំដែងធម៌ឲ្យស្តាប់ ព្រះអានន្ទក៏ ឧទ្ទលថា បើដូច្នោះចូរអ្នកនាំគ្នាអង្គុយប្រុងចាំស្តាប់ចុះ, ហើយលោក សំដែងធម៌ខ្លី។ មានប្រមាណតិច គួរនឹងស្តាប់បានដោយងាយ ។

ឯទុជ្ជាសតពាន់នោះ ក៏ខឹងអន់ចិត្តទៀត នាំគ្នាគ្រាកឡើងដើរទៅ កាន់សំណាក់ព្រះបរមសាស្តាវិញ, ទើបព្រះបរមសាស្តាទ្រង់ត្រាស់សួរ ថា អ្នកពាន់អស់គ្នាមកនេះដោយតែវត្ថុអ្វី? គេក៏គ្រាបបង្គំទូលថា ខ្ញុំ ព្រះអង្គពាន់អស់គ្នាមកនេះត្រូវការនឹងស្តាប់ធម៌! ព្រះអង្គទ្រង់ត្រាស់សួរ ទៀតថា ចុះអ្នកបានស្តាប់ហើយឬនៅទេ? គេក៏គ្រាបបង្គំទូលរៀបរាប់តាំង អំពីរឿងដើមមកថា ខ្ញុំព្រះអង្គពាន់អស់គ្នានេះទៅកាន់សំណាក់ព្រះវេតត្ថេរ។ លោកមិនអើពើនឹងយើងខ្ញុំព្រះអង្គសោះ យើងខ្ញុំក៏ខឹងអន់ចិត្តនាំ គ្នាទៅកាន់សំណាក់ព្រះសារីបុត្តត្ថេរ។ លោកសំដែងព្រះអភិធម្មច្រើន ពេកយើងខ្ញុំចាំធម៌នោះមិនបាន ក៏ខឹងអន់ចិត្តត្រឡប់មកកាន់សំណាក់

ព្រះអានន្ទត្ថេរ។ លោកសំដែងធម៌តិចពេក យើងខ្ញុំអន់ចិត្តគ្រប់មក
កាន់សំណាក់ព្រះអង្គនេះ ។

ព្រះបរមគ្រូបានទ្រង់សណ្តាប់ពាក្យរបស់អតុលៈថាសភនោះហើយ,
ទើបទ្រង់មានព្រះតម្រាស់ថា អតុល!! និន្ទានឹងសរសើរនេះជារបស់មាន
មកហើយតាំងពីបុរាណនាយម្ល៉ះ; ជនចំពួកខ្លះតិះដៀលអ្នកនៅស្ងៀម,
ខ្លះតិះដៀលអ្នកនិយាយច្រើន, ខ្លះតិះដៀលអ្នកនិយាយតិច គ្មានឹងអ្នក
ដែលគួរគេនិន្ទាសុទ្ធ ឬគួរគេសរសើរសុទ្ធតែចំណែកមួយឥតមានសោះ
ឡើយ; ជនចំពួកខ្លះតិះដៀលព្រះមហាក្សត្រ, ខ្លះសរសើរព្រះមហាក្សត្រ
ខ្លះតិះដៀលមហាប្រជាពី, ខ្លះសរសើរមហាប្រជាពី; ខ្លះតិះដៀលព្រះចន្ទ
ព្រះអាទិត្យ, ខ្លះសរសើរព្រះចន្ទព្រះអាទិត្យ; ខ្លះតិះដៀលអាកាស, ខ្លះ
សរសើរអាកាស; ជនចំពួកខ្លះនិន្ទាព្រះសម្មាសម្ពុទ្ធដែលគង់ក្នុងកណ្តាល
បរិសទ្យទាំង ៤ ហើយសំដែងធម៌, ខ្លះសរសើរព្រះអង្គវិញ; ព្រោះហេតុ
ហ្នឹងហើយ ពាក្យនិន្ទាក្តី ពាក្យសរសើរក្តី របស់ពួកជនពាលនឹងយកជា
ប្រមាណពុំបានទេ; ឯចំណែកអ្នកប្រាជ្ញបើលោកនិន្ទាហើយ ឈ្មោះថា
និន្ទាមែន, បើលោកសរសើរហើយ, ឈ្មោះថាសរសើរមែនឥតប្រែប្រួល
ឡើយ, លុះទ្រង់មានព្រះតម្រាស់ដូច្នេះហើយ ទើបទ្រង់សំដែងកាសិត
នេះតទៅទៀតថា:

(មានត)

អង្គុជសុទិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ជោះពុទ្ធផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ឃុនឥន្ទមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: លោកអាចារ្យ ភៅ-សុីម អ្នកត្រួតត្រា
សិស្សនៅសាលាថាសីជាន់ខ្ពស់

មាតិកា

ផ្នែកអក្សរសាស្ត្រ		ទំព័រ
ឃុនឥន្ទមន្ត្រី ញ៉ុក-ថែម ...	រឿងអង្គារ ក្នុងសតវត្សរ៍ទី ១៣ តាមសេចក្តី កត់ត្រារបស់អ្នកដំណើរជាតិចិនម្នាក់ ...	៥៣
» »	ប្រជុំសុភាសិតខ្មែរ រៀបរៀងតាមលំដាប់អក្សរ (តទៅ)	៦៩
លោក ហេង-យេង	រឿងកំព្លុងកំសត់ (តទៅ)	៧៣
.....	រឿងព្រៃងខ្មែរ: "រឿងចៅកាំបិតបន្ទោះ"..	៨៨
លោកឧកញ៉ាវង្សាធិបតី ខង.	លោកនេយ្យ ភាក្យភាក្យ (តទៅ)	៩៤
ផ្នែកសាសនា		
ព្រះត្រៃញាណសំរ៉ែ: ញាណ-ឈីន	លោកធម្មស្វាគ្រ (តទៅតទៀតបន្ត)	៥៥
	អំពីតាំងចេញអធិការនៃគណៈមន្ត្រីសង្ឃ	១០៩

ឆ្នាំទំរង់ទី ១៦ — លេខ ៦ ខែហេមរិរយោ ១៩៦៤ — ជំនៃឆ្នាំ: ១ ឆ្នាំ ១៥ រៀល ។

KĂMPŬCHĔASŎRĬYA

Revue religieuse et littéraire éditée par l'Institut Bouddhique.
Rédacteur en chef de la partie littéraire : Khun Nibandhamantri Nhok-Thĕm, Pandit à l'Institut Bouddhique.
Rédacteur en chef de la partie religieuse : Vénérable Kao-Sim, Surveillant général de l'Ecole Supérieure de Pāli.

TABLE DES MATIÈRES

Partie littéraire:

		Pages
K'ŭn nĭpŏnmŏntrei Nhŏk-T'ĕm	Angkor au XIII[e] siècle d'après un voyageur chinois.	57
— —	Recueil de proverbes khmèrs classés par ordre alphabétique (suite) .	68
Monsieur Hăn-Yéng.....	Rŭtong kămpul kămsăt "roman" (suite)	75
. . . . .	Conte populaire cambodgien inédit: "lŭtong chau kămbĕt bintŏh".	88
Feu l'Okuha vŏngsa sarpéch Nong	Lokaněyy, poème (suite).....	94

Partie religieuse:

Vénérable Prŏah kru Nheaněasăngvĕarĕa Nhean-Ch'um.	Lŏkăt'ĕammĕasâutr (suite et fin)..	99
Communiqué du département des Cultes	Nominations de Chan At'ikar et Mŏntrei săng	109

12e année — N° 2. Février 1941 — Abonnement: un an 1$00.

រឿងអង្គរក្នុងសតវត្សទី ១៣

តាមសេចក្តីកត់ត្រាបស់អ្នកដំណើរជាតិចិនម្នាក់

ឃុនធិតន្លួមត្រីញ៉ុក-ថៃម

ស្រង់និងប្រែរៀបរៀងពីសៀវភៅកាយការរបស់សាលាបារាំងសែសភាគទី ២ ឆ្នាំ ១៩០២

(BEFEO, II, P. 135)

កាលបើយើងស្រាវជ្រាវរកវរកឿងរ៉ាវសម័យបុរាណរបស់ប្រទេសកម្ពុជាយើងនេះ ពុកជាដៃរឿងខាងពន្យាតាក្តី ទាងំនៀមទំលាប់របស់ស្រុកក្តី កាលពីសម័យតាំងពីជាន់នៅក្រុងនគរធំ ឬមុនសម័យនោះទៀងទៅ នោះយើងក្នុងសម័យនេះ មិនអាចនឹងដឹងរឿងរ៉ាវឲ្យបានពិស្តារទូលាយ ឲ្យសមនឹងពីជាអាណាចក្រដ៏ថ្កុំថ្កើងរុងរឿង របស់យើងក្នុងសម័យត្រង់នាយនោះឡើយ ។ គួរឲ្យនឹកស្តាយណាស់ ដែលរឿងរ៉ាវខាងពន្យាតាក្តី ខាងទំនៀមទំលាប់របស់ស្រុកក្តី មិនមានសេសសល់ដល់មកយើងសម័យនេះសោះ ពុកជាមានប្រាសាទពីជាន់នគរធំនឹងទីក្រុងចាស់ដទៃទៀតជាច្រើនអនេក្តី ព្រមទាំងក្បាច់ចម្លាក់នានាប្រការ. នឹងសិលាចារឹកជាភាសាបាលី-សំស្ក្រឹត-ខ្មែរជាច្រើនប្រភេទរួមជាមួយគ្នាទៅ នៅតែមិនល្មមគ្រប់គ្រាន់ឲ្យយើងបានដឹងពន្យាតារ

ន៍ដ៏ទំនៀមទម្លាប់របស់ស្រុកជាន់សព្វគ្រប់ ឬគ្រាន់តែល្មមសមន៍ដ
សេចក្តីចំរើនខុងជឿន របស់អាណាចក្រសម័យនោះបានឡើយ ។

ក្រៅអំពីសិលាចារឹកនន៍ដ៏បុរាណដ្ឋាន រឿងរ៉ាវសម័យបុរាណដែល
យើងបានដឹងខ្លះនោះ ដោយសារតែពួកអ្នកប្រាជ្ញចិនសម័យបុរាណ
បានកត់ត្រានន៍ដរៀបរៀងទុកមកខ្លះដោយអន្លើ។ ជាសេចក្តីខ្វល់ សង្ឃឹម
ទាន់អស់ ទើបនាំឲ្យយើងបានដឹងរឿងរ៉ាវខ្លះ ក្នុងរជ្ជសម័យរបស់ស្តេច
ខ្លះប៉ុណ្ណោះ គឺសេចក្តីពណ៌នារបស់លោកចៀវ-តា-កួន ដែលបាន
ពោលពណ៌នាអំពីទំនៀមទម្លាប់របស់ប្រទេសកម្ពុជា ក្នុងសម័យនគរធំ
ជាពុជាន៍ កាលពីរវាងគ្រិស្តសករាជ ១២៩៥ - ១២៩៧ ឬរវាងពុទ្ធ-
សករាជ ១៧៣៨ - ១៧៤០ ដែលយើងបានស្រង់នន៍ដ៏ប្រែចេញមកជា
ខេមរភាសា អំពីសៀវភៅពណ៌នារបស់សាលាចាក់ដ៏សែស នៅបុន
បួពាក្រប្រទេស ភាគ ២ ទំព័រ ១៣៩ (BEFEO., II, p. 135) នោះនាំឲ្យ
យើងបានដឹងរឿងរ៉ាវផ្សេងៗ ជាច្រើនគ្រាន់បើ ក្នុងសម័យពេលព្រះ
ចាវគ្រិន្ទ្រវរ៉ាន ព្រោះស្តេចនេះគង់ជាសម្តេចក្នុងរវាងគ្រិស្តសករាជ
១២៩៥-៦ ដល់ ១៣០៧ ។

ម្ល៉ោះក្រៅទៀត សេចក្តីពណ៌នារបស់លោកចៀវ-តា-កួននេះ សូម
អស់លោក-អ្នកមើលខុសឡូនៅដ្ឋានរបស់យើង តប្បីជ្រាបថា ច្បាប់ដើម
នោះជាអក្សរចិន លោកប៉ែលីយោត អ្នកប្រាជ្ញនៅសាលាចាក់ដ៏សែស

ចុងបូតាប្រទេស ចានប្រែចេញមកជាភាសាចាំងវែស ចោះពុម្ព
ផ្សាយក្នុងទស្សនាវដ្តីរបស់សាលា ។ យើងចានស្រង់នីងប្រែចេញមក
ជាខេមរភាសា ដោយមានសង្ឃឹមថា អស់លោក-អ្នកមើលទស្សនាវដ្តី
កម្ពុជសុរិយាតនឹងជាបរឿនក៏រំខៀមខ្ញាប់ជាន់ដើមខ្លះ តែសម័យ
អង្គរ ដែលអ្នកប្រទេសគ្រាចានរៀបរៀនពុកមក ពុកជាមិនតិស្តារ
ក៏ល្មមឲ្យបើងចានដឹងរឿងក៏ប្រែកេខ្លះ ដូចជាសេចក្តីចំណេះនឹងរឿង
ក្នុងរាជសំណាក់ជាដើម តាលពី ៦'សតវត្សក្រោយមកនេះ ត្រាតែ
សេចក្តីកត់ត្រារបស់លោកចៀវ-តា-កួន យើងមិនអាចចានដឹងបែបផែន
ខំខៀមខ្ញាប់ក្នុងសម័យនោះចានឡើយ ។ ប៉ុន្តែគួរឲ្យនឹកស្តាយពន់ពេក
ចំពោះសំដីភាសាខ្មែរដែលលោកចៀវ-តា-កួន ចានកត់ត្រាពុកមកជា
អក្សរចិននោះ មានសំខៀងឃ្លៀងឃ្លាតពីសំដីខ្មែរយើងពៅច្រើនដូច
ជាសើកុមន្ត្រីថ្នាក់ខ្ពស់ប្រែកូសដងមាសហៅថា "ចាំ-ខិង-ចាំ-ពា ឬ
ង៉ាន-ខិង-ចាំ-ពា" ថ្នាក់ប្រែកូសដងប្រាក់ហៅថា "សឺ-ឡា-ខឺ" ពួក
ខ្សែត្រែហៅថា "ចាំ-តឺ" លោកសង្ឃហៅថា "ជូ-តូ" មួយពួកទៀត
ហៅថា "ចាំ-សឺ-វ៉ុ" ដូច្នេះជាដើម សឹងលំបាកនឹងតម្រៀតាមពាក្យ
ខ្មែរកងសម័យបច្ចុប្បន្ននេះពន់ពេក ។

យើងសូមដាក់ថា : អស់លោក-អ្នកមើលទស្សនាវដ្តីនេះ តប្រាជ្រាប
ថា ការប្រែសេចក្តីពិភាររបស់លោកចៀវ-តា-កួននេះ យើងមិនចាន

ប្រែចប់សព្វគ្រប់ទេ គ្រាន់តែស្រង់យកមកប្រែដោយអក្ខរៗ តែនំណាដែលជាប់តាក្យចំនេះច្រើនពេកក៏រម្ងាប់ដៅ ប្តូតែនំណាដែលមិនសមហេតុសមផលក៏កាត់ចេញខ្លះដែរ ។ មួយវិញទៀត សេចក្តីប្រែនេះគង់មានត្រូវនឹងភ្នាត់ខ្លះពុំខាន ដោយហេតុអ្នកប្រែមានសេចក្តីចេះដឹងតិចក្នុងភាសាបាលីនៅស្រស ដូច្នេះ យើងសូមអភ័យទោសអំពីសំណាក់អ្នកមើលទស្សនាវដ្តីនេះ តួនតុភាសានេះផង ។

មុននឹងបញ្ចប់សេចក្តីបូជាខ្លួនេះ យើងសូមឲ្យប្រែជាជនជាតិខ្មែរត្រមាំងដ៏មហាជនក្នុងសហរដ្ឋអណ្តូស៊ុន តបប្រមានចិត្តលើកនឹកគុណចំពោះដល់លោកអ្នកបូជ្ជ នៅសាលាបាលីនៅស្រសបុរីបួតាប្រទេសមានលោកស៊ីវេសាចារ្យហ្វាន់ដាំដើម ដែលលោកខំខ្ចីខ្ចែវស្វែងរកឬកាំរាំងនានាពីព្រៃវែង ចាំងនានិមន្តមកបូជ្ជ តួមចាំងបានតាក់តែងបុកណាវត្តផ្ទៃ ក្នុងតួមដង្គ ដែលបាត់ដៃពាខ្លួនហើយកប់នៅព្រៃជ្រាយរួមមកហើយនោះ ឲ្យបានច្បាស់ជាតស្តែងឡើងវិញ ចាំងរឿងរាំងដែលយើងមិនច្បាស់ផងនោះ តួនសម័យព្រឹនាយរបស់យើងនោះ ក៏យើងបានដឹងខ្លះៗ តួនសម័យសព្វថ្ងៃនេះ ដោយសារកំឡាំងសតិបញ្ញានៃពួកអ្នកបូជ្ជាចាំងនោះ ។

ឃុនឧត្តមត្តិ ញ៉ុក-ថែម

ជណ្តិត នៅក្រសួងព្រឹទ្ធសភានៃណ្តិត្ត

ថ្ងៃ ២៨ មីរ្យ ១៩៤៣

សេចក្តីរាយការអំពីទំនៀមទម្លាប់នៅស្រុកខ្មែរ

ដែលលោកចៀវ-តា-កួនបានកត់ត្រាយកមក

ជាអ្នកស្រុកវ៉ែន-ចៀរជាខេរៀបរៀងឡុកមក

កាលអំពីដើមនោះ ស្រុកកម្ពុជាជាប្រទេសមួយតូច នៅសមុទ្រ ខាងត្បូង ជាចំណុះស្រុកហ្វូ-ណន ។ កម្ពុជាវិតដំបន្តិចម្តងៗ ឡើង ហើយមានរឿងប្រាកដជាដំបូងក្នុងសៀវភៅរបស់ពួក-ស្នី នៅកងចំ-ណោមសេចក្តីកត់ហេតុផ្សេងៗ របស់នានាប្រទេស ។ ពង្សាវតារ របស់ពួកតាងទាំងពួកសុំងក៏ចេញឈ្មោះជា ៦ តាំងអស់តែត្រឹមបណ្តា-គារមិនមានមកហូរហែទេ តាំងការពណ៌នាអំពីទំនៀមទម្លាប់ នឹងផល ប្រយោជន៍ក្នុងស្រុកក៏មិនសូវច្បាស់ដែរ ។ ក្នុងឆ្នាំខែ ១ ឃួន-ចេង នៃព្រះពុទ្ធជាធិរាជចេង-ផុង (1295) ទ្រង់ឲ្យបញ្ជូនពាជកូត ១ ក្រុមទៅ ប្រទេសនេះ ថ្វែងអំពាំព្រះពុទ្ធប្រកាសរបស់ព្រះពុទ្ធជាធិពុជ ។ លោក ចៀវ-តា-កួនក៏បានទៅជាមួយផង ។ ឆ្នាំខែ ១ នៃសម័យ តា-តូ (1297) ទើបលោកត្រឡប់មកវិញក្នុងរវាង ៣ ឆ្នាំដែលលោកបាននៅបានកត់ត្រា សូត្រច្បាស់អំពីទំនៀមទម្លាប់របស់ប្រទេស តិសុទ្ធតែជារឿងដែលលោក បានឃើញទាំងអស់ទាំងអស់ តែងជាសៀវភៅ ១ មាន ៤០ ចប់ ។

កាលណាលោកចៀវ-តា-កួនបានតែងរឿងនេះស្រេចលោកក៏យកទៅឲ្យប៉ូ-គៀវ-យេន។ ក៏ចាប់យកផ្ទៃរឿងនេះតែងជាពាក្យកាព្យដែលមានសេចក្តីពិពេះស្តាប់ណាស់ ។ មើលរឿង ជូ-ស៊ូ-ចាន-ហ្វាង-រេ-ឈីរេស៊ុ-គៀវ-យេន ដែលតែងសេចក្តីសរសើរដល់ប្រជារេស៊ុមហាបណ្ឌិតចៀវ-តា-កួន ។

* * *

អំពីទីក្រុងព័ទ្ធជុំវិញដោយកំពែង(១)— កំពែងព័ទ្ធជុំវិញប្រវែង ២០០ លី ។ ទីក្រុងនេះមានទ្វារ ៥ ទ្វារនិមួយៗមានទ្វារព័រជាប់គ្នានៅសងខាង ។ នៅផ្នែងទិសខាងកើតគេបើកចំហទ្វារតែរ ឯទ្វារឯទៀតៗ បើកតែមួយទេ ។ ក្រៅពីកំពែងនៅមានស៊ុនធំ តពីស៊ុនទៅមានចិញ្ចើមផ្លូវក្លាប់ទៅទឹងស្ពានធ្ងន់ធំ នៅបង្គន់ដែលស្ពានតាំងសងខាងមានរូបអសុរថ្មចំនួន ៥៤ រូប ខ្ពាតធំសំបើម ។ ទ្វារតាំង ៥ នោះមានសណ្ឋានដូចគ្នាតាំងអស់ ។ នៅក្បាលស្ពានជាដុំថ្ម ដែលគេឆ្លាក់ជារូបតស់ក្បាល ៩ ។ ឯរូបអសុរ (ឬទេវតា) នាំគ្នាយកដៃចាប់តស់ហើយប្រឹងតាញមិនឲ្យរូបបក់ទៅ ។ នៅលើខ្នងទ្វារកំពែងមានរូប

---

១ កម្ពុជា ឬឈ្មោះបុរៈ ជាទីក្រុងដែលព្រះចាទយសោប្បទេ ទ្រង់កសាងកាលពីឆ្នាំត្រីស័ក្ករាជ ៨០០ (ទីបរិវេណជុំវិញ ១៤,០០ ម) ។

ព្រះពុទ្ធព្រះសិរ ៩ ធ្វើពីថ្ម ព្រះកន្ត្រៃសំឡឹងទៅទិសខាងលិច នៅត្រង់កណ្តាលមានចេតាដោយមាស ។ នៅសងខាងគ្នា គេឆ្លាក់ថ្មធ្វើជារូបដំរី ។ តួកំពែងចាំងអស់ គេយកថ្មចាំងផ្ទាំងៗ ឆាក់ដម្អែកបន្ទប់លីគ្នា មានកំពស់ ២ ជាន ។ ថ្មចាំងនោះជាថ្មយ៉ាន់រ៉ែមិនមានស្មៅផ្តេសផ្តាសដុះឡើយ មិនមានន្លួចហោងទេ ។ នៅលើកំពែងប៉មខ្លះគេបានព្រែះសាបក្លាង-ឡាង ។ ពីរយៈ ១ ទៅរយៈ ១ មានផ្ទះតូចៗ ទេ ។ នៅខាងកន្ត្រៃកំពែងប៉ម មានជណ្តើរចោតមួយកំពស់ជាង ១០ ជាន នៅជាន់លើមានគ្រាំធំៗ បិទរោលយ៉ាប់ បើតរោលព្រឹក ។ តួកំពែងមានសណ្ឋាន ៤ ជ្រុង នៅជ្រុងនីមួយៗ. មានប្រាសាទថ្មមួយៗ គ្រប់ទាំង ៤ ទិស ។ ពួកអ្នកចេសវែលកាត់ព្រាមដើងហើយដើរបួលតាមគ្រាអស់នោះពុំបានឡើយ ។ នៅត្រង់កណ្តាលក្រង់មានប្រាសាទមាស ១ នៅកែ្សរខាងតៗ គ្នាទៅ មានប្រាសាទថ្មច្រែនជាងម្ភៃ ហើយមានបន្ទប់ថ្មតូចៗ រាប់រយ ។ នៅចុងខាងកើតមានស្ពានមាស មានរូបសិង្ហមាសពីរ នៅជ្រុងស្ពានទាំងសងខាងហើយមានព្រះពុទ្ធរូបមាស ៨ អង្គ គេជាក់នៅក្រោមបន្ទប់ថ្ម ។ បម្លាយ ១ លីទៅទិសខាងដើងប្រាសាទមាស មានប្រាសាទស្ពាន់មួយមានកំពស់ខ្ពស់ជាងប្រាសាទមាសដែលមើលទៅគួរឲ្យស្រប់ស្រួលណាស់ ។ នៅដើង (ប្រាសាទនេះ) មានប្រាសាទថ្មតូចៗ ចំនួនច្រែនជាង ១០ ឡើងទៅ ។ បម្លាយជាងមួយ

លីតានោះទៅទៀត ជាព្រៃរកដងខ្លែរបស់ព្រះមហាក្សត្រ ខៅក្នុងថ្នាក់តំណាក់របស់ក្សត្រ មានច្រាសាខមាស ១ ទៀត ។ បណ្តាច្រាសាខពរដំណាក់អស់នេះ យើងគិតថាគួរបានខន្ធលសេចក្តីសរសើរអំពីស្រុកវែនស្រុកស្តុកនឹងថ្កុំថ្កែង ដែលពួកឈ្មួញបានធ្វើឲ្យចំរើនឡើងជល់ប្រទេសនេះ ។

បើចេញទៅតាមទ្វារខាងត្បូង ទីនេះយើញមានច្រាសាខថ្ម ១ បម្លាយ ១ លីកន្លះ គេថាច្រាសាខនេះ ល្អ-ប៉ាំនបានកសាងឡើងក្នុងរវោ ១ យប់ប៉ុណ្ណោះ ។ បម្លាយចេញពីទ្វារខាងត្បូងទៅ យើញមានផ្ទះ ល្អ-ប៉ាំន ចំហាំជុំញាដែត ១០ លី ។ មានផ្ទះឥដ្ឋបួនជាន់ច្រើនរយខ្នង ។

ចំងាយតើត បម្លាយពីកំពែង ១.២ លី មានចំហាំជុំវិញប្រហែល ១០០ លី ។ មានច្រាសាខថ្មចំនួនផ្ទះឥដ្ឋបួនធ្វើពីថ្ម ។ ខៅក្នុងច្រាសាខមានព្រះពុទ្ធរូបដុំធ្វើពីសម្រិទ្ធ មានផ្ចិតបញ្ចេញខ្សែពន្លឺរឿងៗផង ។

ចំងាយដងផង បម្លាយ ៥ លីពីក្រុង មានច្រាសាខមាស ៤ ផ្ទួន មានផ្ទះឥដ្ឋបួន ៤-៥ ខ្នង ហាទ្បារសិង្ហមាស ព្រះពុទ្ធរូបមាស ជើរសម្រិទ្ធ គោសម្រិទ្ធ សេះសម្រិទ្ធ មិនមានខ្សែអ្វីទេ ។

អំពីលំនៅ- ព្រៃរកដងកំផង ខ្លែរកដងការ ទីនេះផ្ទះដែលល្អ ៗ សុទ្ធតែខៅខាងទិសខាងកើតទាំងអស់ ។ ព្រៃរកដងកំផង ខៅទិសខាងដងផង

ប្រាសាទមាសនឹងស្ពានមាស ។ កប់ពីក្នុងទាងរែកៗ ប្រមាណ ៥-
៦ លី ពីប្រាសាទ ។ គេឮថាប្រកបផ្ទះជាប់ខ្នងសុទ្ធតែជាសំណ ហើយ
មានផ្ទះឯទៀតៗ ធ្វើពីដីមានព័ណ៌លឿង ។ សសរស្ពានខ្លះធំៗ មាន
ព្រះពុទ្ធរូបឆ្លាក់នឹងលាបថ្នាំ ។ តួផ្ទះនោះមានសណ្ឋានល្អៗ មានថែវរាងៗ
មានភ្នាតចំហាមិនដូចគ្នា ។ ឯទីប្រជុំកុន្រ្តីយ៍នោះគ្របបង្អួចធ្វើពីមាស
តាំងភាងធ្វេង តាំងភាងស្តាំ មានសសរជ្រុងៗចែកតាក់តាំងពី ៤០
ដល់ ៥០ តាំងទៅភាងៗ បង្អួចតាំងនោះ ។ ចុះមកគ្រាមមានរូបដំរី ។
ខ្ញុំបានឮគេនិយាយថា នៅភាងក្តីព្រះរាជវាំងនោះ មានតន្ទៃល្អម៉ែល
ជារែនប៉ុន្តែការហាមឃាត់ មិនឲ្យចូលទៅក្នុងនោះទេ ។ នៅ
ក្នុងវាំងនោះមានប្រាសាទមាស ១(១) គ្រងំកំពូលជាខ័ដ្ឋនៃមហាកឫត្រ ។
ពួកអ្នកស្រុកអាយតាំងអស់តែនឹងដំណាលថា នៅក្នុងប្រាសាទនោះមាន
ប៊ិសាចពស់កន្ទុយ ៩ ជារៀហ្វាយដីនៃភជាន់ ។ កាល់ៗ យប់ពស់
នោះដំណើងជារូបស្ត្រីម្នាក់ ចូលមកដេកជាមួយនឹងស្តេចជាដំបូងបង្អស់
ពួកអគ្គមហេសីរបស់ស្តេចក៏មិនហ៊ានចូលទៅដែរ ។ ដល់យាមគំរប់ពីរ
ទើបពស់នោះចេញទៅ ហើយស្តេចក៏យាងទៅផ្ទំជាមួយនឹងអគ្គមហេសី
ឬស្រីព្រះស្តុំបាន ។ ប្រសិនបើយប់ណាមួយ មិនមានប៊ិសាចពស់នោះ

---

១ ពិតមានអាកាស ។

មកវិញ នោះដាក់ពេលដែលស្តេចគង់ទំនេរ ។ ប្រសិនបើយប់ណា ស្តេចមិនមកផ្ទះស្តេចនឹងមានគ្រោះថ្នាក់អ្វីមួយមិនខាន ។

ឯលំនៅរបស់ពួកក្សត្រនឹងមន្ត្រីធំៗ មានរបៀបនឹងចំហាស្រឡះពីផ្ទះរបស់បណ្តាពស្ត្រី ។ បណ្តាពស្ត្រីខ្លះៗមានលំនៅមានកំណត់គោនប្រកស្បូវ រៀវលែងតែគួរឱ្យការរបស់គ្រកូលនឹងលំនៅរាជការទើបប្រកក្បឿងបាន ។ ឯថ្នាក់របស់អ្នករាជការនោះកំណត់តាមឋានលំនៅ ។

បណ្តាពស្ត្រីខ្លះៗនៅផ្ទះប្រកស្បូវមិនហ៊ានប្រើក្បឿងទេ ឯឋានចំហាលំនៅតាមជនជាតរបស់ខ្លួន ។ ប៉ុន្តែពួកពស្ត្រីមិនហ៊ានធ្វើឱ្យធំលើសជាងលំនៅរបស់នាហ្លួនមន្ត្រីទេ ។

អំពីគ្រឿងតាក់តែងកាយ.— ពាក់អស់ តាំងពីស្តេច ពាក់ប្រែស ពាក់ស្រី សុទ្ធតែទុកសក់ ចំហាស្មា ។ ស្លៀកសំពត់ព័ទ្ធជុំវិញចង្កេះ ។ កាលណាគេចេញដើរ ទើបថែមក្រមាធំមួយគ្របឃ្លុំពីខាងលើបន្ថែម ។ ឯសំពត់នោះមានច្រើនបែប ។ ក្សត្រនឹងព្រះពស្ត្រដែលមានដំឡៃ ៦ ឬ ៣ ដំឡឹងមាស គឺជាសំពត់ល្អបំផុត មានព័ណ៌នឹងសរសៃឆ្មារ ។ សំពត់អំបោះនោះ ច្រើនតែមកពីស្រុកសៀមនឹងស្រុកចម្ប៉ា ដែលគេនិយមច្រើនបំផុតនោះ ជាសំពត់មកពីសមុទ្រខាងលិច ។

មានតែក្បត្តែមួយព្រះអង្គទេ ដែលទ្រង់ព្រះពស្ត្រមានសាច់ញឹកល្អិតបាន ទ្រង់មកុដមាសដាំពេជ្រ ។ កាលដែលមិនមានមកុដមាស ទ្រង់ផ្កាកឆ្នាមានកូនត្រអូបលើផ្នត់សក់ដូចជាផ្កាម្ទិះ ។ ព្រះសូរង ទ្រង់តួនដៃមុខ កព្រះហស្តកព្រះបាទខាងមានព្រះហស្ត ទ្រង់កងខាងបំពាក់មាសដាំពេជ្រត្នែកឆ្នា ទ្រង់ដំណើរព្រះបាទទេ បាតព្រះបាទខាងបាតព្រះហស្តលាបឥណ្ឌិកហម កាលណាយាងចេញព្រះហស្តទ្រង់ព្រះខាន់មាស ។

កងចំណោមបណ្តាកស្ត្រីមានតែពួកស្រី ទើបមានអំណាចលាបបាតដៃបាតជើងបាន ។ ពួកប្រុសៗមិនហ៊ានទេ ។ ពួកមន្ត្រីធំៗខាងពួកក្បត្តែប្រើសំពត់សាច់រង្វើលបាន ។ ពួកអ្នកកងរាំងអាចប្រើសំពត់ចាំងពីរជុនបាន ។ ឯបណ្តាកស្ត្រីចំពោះស្រីៗក៏អនុញ្ញាតឲ្យប្រើបានដែរ ។ មានជនជាតិចិនម្នាក់ ទើបមកដល់ថ្មីប្រើសំពត់ចាំងពីរជុនដោះ តែគេមិនបានចាប់ទេ ដ្បិតគាត់មិនទាន់ស្គាល់ទំនៀមទម្លាប់គេ ។

(មានត)

ឃុនធិពន្ធមន្ត្រី ញ៉ុក-ថែម រួបរួមនឹងរៀបរៀង

(ត ទ ក)

អក្សរ ប

១ ចាញ់ចត្តង្គអស់ប្រាជ្ញ ចាញ់តណ្ហាអស់កុសល ចាញ់រោគអស់ទន្លាន ។

២ ចាញ់ប្លាន់ជាព្រៃ ឈ្នះប្លាន់ជាមារ ។

៣ ចាញ់លែ្បងអស់ទ្រព្យធន ចាញ់ប្រពន្ធអស់សិរី ចាញ់ក្តីអស់គំនិត ។

៤ ចានមួយកាលែងអ្វីណ្តើគ្នា ។

៥ ចាប់នេះចាប់នោះមិនឆ្ពោះត្រង់ណា ។

៦ ចាប់ច្រវាក់ឡើងជ្រុយ[1] ។

៧ ចាប់រលំមួយ ក៏រញ្ជួយរលំដើម ។

៨ ចាស់អាងស្ងាប់ តាលអាងតាប់ ក្មេងអាងយំ ។

៩ ចិត្តឆ័ត្តុសាលស៊ី, ជ្រលែងស្រែកុំសាលចន់ ។

១០ ចិត្តជាវេរវត្ត មាត់ជាវេរតា ។

១១ ចិត្តងាប់ទៅស្រី ។

---

១ មើលត្រង់ភាសាអក្សរយោ. ថាដូច្នេះ: ហុតទឹកសំរឹងកាត ចាប់ច្រវាក់ក្រាកសម្បឹងជ្រុយ ។

៥ ចំញឹមមនុស្សឲ្យមើលចិត្ត ចំញឹមសត្វឲ្យមើលបង្ហួមក ។

១ ចិត្តល្អត្រូវខ្លួន ។

១ បាស់ថាសូវបង់ទ្រព្យខូចក៏ហ៊ី ខូចសំដីបង់គំនិតពិបាកស្រាយ ។

១ ចុះទឹកប្រទះត្រូវត្នោ, ឡើងលើប្រទះខ្លា ។

១ ចូលស្ទឹងតាមបត់ ចូលខ្លុកតាមកំពង់ ចូលស្រុកតាមប្រទេស ។

១ ចូលព្រៃសត្វសាហាវ, រកអំពាវគ្នាមុកដុំ, ដល់ឃានស្ពានខ្មែក ឃុំ ពួនក្នុងផ្ទះស៊ីម្ចាស់ឯង ។

១ ចេះគេថាកាប ក្រែងគេថាត្រើល ។

១ ចេះល្បាប់មិនខ្វាចក្តី ចេះវិន័យមិនខ្វាចតំបត្តិ ។

១ ចេះមកពីរៀន, មានមកពីកេ ។

១ ចោលសាច់ស្រែកឆ្កែន ចំពោះពីរដែរទៅកេសាច់វិញ ។

១ ចៅហ្វាយមានបុណ្យ, ខុនមានសក្តិ, ចៅហ្វាយអប្បលក្ខណ៍, ខុនឆ្លាក់អណ្តូង ។

១ ចំជាប់លោតសង្ឃ, ខ្លាចអ្នកត្រង់ព្រះសិរ ។

១ ចំណីត្រែនមុខត្រែនពិសា, កូនត្រែនជាត្រែនតែល្អ ។

១ ចំណីឆ្មាញ៉ាំកុំខុកដល់ថ្ងៃស្អែក, ប្រពន្ធគាប់ក្នែកកុំឲ្យដើរគ្រោយ ។

១ ចំណេះដើរកឯង ។

១ ចាំក្បួនចាំឲ្យស្ទាត់, កុំអៀនជ្រែនផ្សំពាក្យពោល ។

១ ចែវដាប់ខ្លួនគល់, មិនយល់ខ្លួនសក់ ។

១ ខ្ចែននចេះរវេះក្បាច់ ។

អក្សរ ឆ

១ ឆ្កែទាំឲ្យរកម្ចាស់, គោឆ្កេះឲ្យរកនាយ ។

១ ឆ្កែព្រុសមិនដែលទាំ, ផ្លុំលានមិនដែលក្ងៀន ។

១ ឆ្កែខាល់ចែក, លេកខាល់ចាំង ។

១ ឆ្នាំមិននៅ, កណ្តុរឡើងកផ្ទះ ។

១ ឆ្នូនវែស្រែក វែស្បែកហោ ។

អក្សរ ជ

១ ជាងទងស៊ុវងកំបែក, ជាងដែកហែកនឹងដៃ ។

១ ជាងមិនកើត, បង្ខោសដែក ។

១ ជួញដិតជាជាងជួញធ្វាយ, ជួញស្បែរៀនអាយរក្សាប្អូនស្រី ។

១ ដើងគ្រាយដោយតាមដើងមុខ ។

១ ដើងទេញឆ្នេញល្អិត, ស្ងឹកត្រចៀកកំប៉ិត, តំនិតរបិញរបុញ ។

១ ដើងបួនគង់មានភ្លាត់ ប្រាជ្ញចេះស្ងាត់គង់មានភ្លាំង ។

១ ដើងបួនគង់មានជ្រុល, អ្នកចេះពេញជ្រុលគង់មានជ្រួស ។

១ ដំពប់ដើងគង់ប្លាក់, ដំពប់មាត់បង់ប្រាក់ ។

១ ដៃជ្រលោមស្រឡៃ ត្រាវលោមចិន ។

អក្សរ ឈ

១ ឈើដើងធាត់, ឈើមាត់ស្តួម ។

២ ឈើគោងវល្ងិច្ខ, មនុស្សខ្លាត់ក្លាត់កុំឲ្យយកខ្លួនចៀត ។

៣ ឈើធំរលំឮខ្លាំង ។

៤ ឈើផ្លែចាញ់សន្ធឹក, គ្រឹះច្រែនទឹកល្អក់ពុំជា, ទ្រព្យច្រែនត្រួយ
រក្សា ទ្រព្យតិចណាត្រួយរិះគិត ។

៥ ឈើស្អាប់ពីចុង, ជំរើងាប់ពីពុង, មនុស្សស្អាប់ពីដើង ។

៦ ឈ្មួញទឹកពិតពីងខ្លួក ឈ្មួញគោតពីងរេះ សំណាងពីង
ចំណេះ ក្រែងជួញជួយបេះពីងគម្លឹ ។ ព្រះសង្ឃពីងវិន័យ សត្វកតវៃតែពីង
ឆរណី សេនាពីងឫទ្ធិ ឯអ្នកជីពិតពីងវត្ត ។ រមែលពីងក្រឡឹង រីឯត្រែងពីង
បខ្លាត់ កិរិយាពីងសំពត់ ឯបរិសុទ្ធពិតពីងសីល ។ សត្វគ្នាតពិតពីងរុយ
សាច់សត្វស្អុយពីងអំបិល មង្គលឈរពីងតពិល រក្សាសីលពិតពីងទាន ។

អក្សរ ដ

១ ដល់កំពង់លង់ខ្លួក ។

២ ដង្កូវចេញពីសាច់, ច្រែះចេញពីដែក ។

៣ ដប់នាក់អន្សមខ្លោច, គ្នាដូចស្រមោចអន្សមផៅ ។

៤ ដាក់ខ្លួឲ្យស្រែះបន្ទា, ការសាច់ដូនខ្លាខើបនៅស្រុកចាន ។

៥ ដឹកគោញី, ចន់ស៊ីគោឈ្មោល ។

១ ដឹងច្បាននឹងបង់, ដឹងច្បាត់នឹងគង់, ដឹងគួរដើរគាប់, ដឹងខ្ពស់ដឹងទាប ។

១ ដឹងដប់ផ្លូវឈើមួយ ។

១ ដឹងតាមសាប់, ច្បាប់តាមពាក្យ ។

១ ដឹងគ្នានៅគ្រាគ្រែ, សំបុរណ្ណនៅទៃតគ្គិក ។

១ ដឹងឆ្លើយពីគ្រោះដង, កូនគ្គងពីគ្រោះមេថា ។

១ ដឹងរង្គោះបោះបង្ហោយ ។

១ ដុតឲ្យខ្ញោច, ក្រេចឲ្យនៅ, ឬ ដុតទៅក៏ខ្ញោចក្រេចទៅក៏នៅ ។

១ ដូចគ្រែពីរត្នើងបាំង ។

១ ដូចខ្លាក់ជាន់ដែ ។

១ ដូចរតិញ្ចឹមកូនខ្លា ។

១ ដូចចាប់ក្តាមជាក់ចន្ទ្រែ ។

១ ដូចចាប់ស្វាមកបំបួស ។

១ ដូចជាគេយកអន្ទង់ ទៅចំហុងនឹងតក់ ។

១ ដូចជាគេអូសឫស្សីពីបុង ។

១ ដូចជាគេអូសឆ្កែឲ្យចុះទឹក ។

១ ដូចជាគេប្រដៅគ្រែតោឲ្យហែលទឹក ។

១ ដូចជាទឹកកន្ទុះភ្លុម ។

(មានត)

លោកបាង - យើង តែងនឹងរៀបរៀង

(ត្រួត)

នាងសាលីក៏មានសេចក្តីត្រេកអរ ឥតឧបមា សំដែងសេចក្តីអរគុណចំពោះសុភនិន្ទជាអនេកបរិយាយ ហើយក្មេងពាំងពីរនាក់នោះតែងទៅមកវាក្នុគ្នា តែងលេងជាមួយទំនងគ្នាជាកបរៀងមក ។

ចំណែកខាងសុភនិន្ទក៏កាន់តែសុភាពកបសា កាន់តែល្អរបណ្តូកងរៀងពាល់ថ្ងៃ មានចិត្តខ្នល់ខោនដល់មនុស្សម្នាក្នុងផ្ទះគ្រប់គ្នាមិនបានរ៉ៃសម្ទះ ។ អ្នកពាំងទុះក៏គោរពចំពោះសុភនិន្ទស្មោះអស់ពីចិត្តពីថ្លើម ។

បទទី ៣

សុវណ្ណបុប្ផា

បណ្តាមនុស្សក្នុងផ្ទះពាំងប៉ុន្មាន មានកុមារីម្នាក់ឈ្មោះសុវណ្ណបុប្ផា រូបកាងស្រឡះក្អែកធំ មានអំណាចលើពួកទាសាទាសិងខ្លួន ព្រោះនាងជាអ្នកចាត់ចែងខាងការផ្ទះ មើលត្រួតត្រាទុសត្រូវបន់ខ្លួនក្នុងផ្ទះពាំងប៉ុន្មាន អ្នកឯទៀតក៏កបន់នាងដូចចៅហ្វាយនាយ នាងមានអាយុច្រើនជាងសុភនិន្ទ ៨ ឆ្នាំ ហើយនាងទំនួយមើលថែរក្សាកុមារដោយ

យកចិត្តទុកដាក់ដូចជាប្អូនខាងបង្កើត ចំណែកសោភិតទំនងគ្មានក៏គេញ
ចិត្តទំនងខាងកើនលើសដើម ។

ដើមឡើយនាងសុវណ្ណបុប្ផាជាកូនអ្នកឧទ្ទាល់ក្រ កាលនាងអាយុ
បាន ៥ ឆ្នាំក៏បង្កើតមានជម្ងឺអាសន្នពេក ប៉ុះចាប់កន្លះភូមិស្ទាប់គោក្រមិនធ្វើ
អ្នកស្រុកអស់ជាច្រើន អ្នកនៅក្នុងភូមិនោះក៏នាំគ្នារត់ចោលផ្ទះសម្បែងទៅ
នៅទីដទៃទៅ នៅសល់តែតូចសុវណ្ណបុប្ផា ព្រោះឪពុកម្តាយ
នាងចាប់មានជម្ងឺដើរពុំរួច ។ ដោយគ្មានគេថែរក្សា គ្មានថ្នាំនៃរោគ
អ្នកជំងឺពីក៏ដល់ទូវមរណភាពចោលកូនស្រីឲ្យនៅតែម្នាក់ឯង ។

កុមារីកំព្រានោះ ក៏នៅហ្នឹងហូដំម៉ងមោះកណ្តាលភូមិស្ទាត់ឈឺង
មិនដឹងជានឹងរត់ទៅនៅទីណាក៏តែងតែសោយសោកសង្រេងកណ្តាលទី
រហោឋាន គ្មាននរណាឮ ដល់ពេលថ្ងៃយ ខាងឃ្លានខ្លាំងក៏ចូល
ទៅដើងគ្រានថ្ងៃយ រកតែអ្វីនឹងសង្កត់ពោះគ្មាន ឃ្លានពេកវៀសកហៅ
ខ្លាយក្តែង។ "ម៉ែអើយ កុំសម្លាប់យកពោកកូនស្រែកឃ្លានណាស់ ម៉ែ
ធើបរឡើងរកដណ្តាំថ្ងៃយឲ្យកូនញ៉ាំ" ។

មិនឮម្លាយធ្វើយនាងក៏ចូលទៅជាស់ ជាស់មិនគ្រាកនាងក៏ទុប
ភ្នែចខ្លាយយំ ឪពុកអើ! ពុកភ្លេអើយ! មនុស្សដែលច្រាសចាកវិញ្ញាណ
បៅយ បីដូចជាកំណាត់ឈើដែលនៅលើដែនដី មិនចេះស្តីនិយាយ
មានត្រចៀកក៏ដូចជាថ្នង់ ស្តាប់ពាក្យដំអូញកូនមិនឮ មានជង្ហើមចេញ

ចូលក៏នៅស្ងាត់ឈឹងកូន ដល់ស្ងាប់ទៅក៏ធ្វើព្រងើយកន្តើយ លែងអាណិតអាសូរដល់កូនដែលយំខ្លាចម្ល៉េះ ។

សុវណ្ណបុប្ផាមូលគោះខ្លាំង ក៏ខ្សឹងស្ងាំងសាច់ឈាមមួយរំពេច ស្រពោនស្រពន់អស់ដើងដៃ សំឡេងភ្លេចលែងតើតក៏ធ្លាក់ក្អែមម៉ក់ ។ យូរ។ ឮនស្រែកយំម្តង ។ ដោយមានចំណងថាខ្លាំងឲ្យអ្នកមេឮបានឮរហូតដល់ពេលល្ងាច ស្រាប់តែយើញនាងកុមារីម្នាក់ខ្សឹងទៅពនាងចុះពីលើផ្ទះ នាំយកទៅឯភូមិមួយឆ្ងាយពីភូមិរបស់នាង ហើយគេយកបបរមកបញ្ចុកនាង ដល់ញុំាបបរឆ្អែតហើយ នាងក៏យំរកម្តាយម្តងទៀត អ្នកដែលជួយដឹកនាំនោះ ក៏លួងលោមនាងដោយពាក្យពិរោះថាដូច្នេះ "អូនស្រីចង៏អើយអូនកុំយំ ម្តាយឯងគាត់មិននៅទេ គាត់ទៅស្រុកទេសឆ្ងាយហើយ គាត់បានផ្តាំឲ្យចង៏មើលឯងផង ចាំចង៏ថែទាំឯងឲ្យដូចម្តាយឯង ឯងមើលចុះចំណីចំណុកមិនខ្វះទេ" ។ ហើយអ្នកនោះក៏ថ្នាក់ថ្នមបីបម្រនាងឲ្យថ្នាត់មាត់ នាងក៏នេងលក់ភ្លេងដៃអ្នកចិត្តបុណ្យនោះទៅ ។

ឯនាងកុមារីនោះ មិនតឹងរណាក្រៅពីភ្នែនារីឡើយ ជាបុត្រីអ្នកមានស្តុកស្តម្ភមួយ ឪពុកម្តាយនាងមានតែក្រមង៏ដ៏រិះសះ ទំនិរស្រែចម្ការជាច្រើន មានចារស្រែជ្រូកសំរែចនាក់ ហើយអ្នកទាំងពីរស្រឡាញ់សុវណ្ណបុប្ផាដូចកូនបង្កើត ព្រោះនាងមិនដែលធ្វើខុសបុកម្នាក់ឲ្យឮរណា

ពិបាកចិត្តដោយសារនាងទៀយ ។ ឮនដូច្នោះតែនាវ៉ៅបិសុណ្ណបុថ្លាយកមកឮនោះ ព្រោះនាងឮនសាកសួរអ្នកស្រែចដែលរត់មកជែកក្នុងភូមិរបស់នាងថា ៅក្នុងភូមិនោះតើមានសល់អ្នកឯណា ដែលរត់មកមិនកើតដែរឬអ្វី? ដល់ដឹងសេចក្តីថា មានជនពីរនាក់តំពូនឈឺជាបហើយមានកូនស្រីមួយផង នាងក៏អង្វរនឹពុកម្តាយនាងឲ្យៅនាំ អ្នកតំសត់ចាំងបីនោះមក តែនឹពុកម្តាយនាងធ្វើយទៀងថា: "កូន! កូនឲ្យយើងធ្វើដូចម្តេច បើយើងយកអ្នកចាំងនោះមក ហាក់ដូចជាយកគ្រឿងមកដុតភូមិរបស់យើង ព្រោះជម្ងឺអាសន្នកេតជាជម្ងឺធ្ងន" ។

"បើដូច្នោះមានតែប្រែអ្នកឯណាមួយ ឲ្យយកថាំសង្ហរនឹងមួយអាហារៅឲ្យគ្នាផង សមគ្នាវេទនាខ្លាំងណាស់ហើយមើលៅ" នាងតែនាវ៉ៃយាយបង្ខិចិត្តនឹពុកម្តាយរបស់នាង ។

តែគ្មាននណាមួយហ៊ានដើរកាត់ភូមិចង្រៃនោះទៀយ ដោយខ្លាចឆ្លង ទើបនាងកាត់ចិត្តសូមអនុញ្ញាតនឹពុកម្តាយ ខំដៅទីនោះដោយខ្លួនឯង តែនឹពុកម្តាយនាងមិនព្រមបើតឲ្យៅ នាងក៏កើតទុក្ខលែងញុំាបាយទឹក ព្រោះនាងនឹកឃើញថា មិនគួរបើបណ្តោយឲ្យមនុស្សផងគ្នាស្លាប់អសារតែតការសោះ ដោយនាងអាចនឹងជួយសង្គ្រោះបាននឹពុកម្តាយឃើញនាងព្រួយចិត្តខ្លាចនាងឈឺក៏បណ្តោយឲ្យនាងៅ នាងក៏សប្បាយចិត្តយ៉ាងថាំនឹងបាយទឹកដើរដំរង់ៅទីនោះ ។ តែនាងមិនអាច

សុំគាល់ថាផ្ទះណាមួយដែលមាននៅគ្រោះ ក៏ចេះតែដើរកត្រប់គេហដ្ឋាន ចួនជាឮមាត់កូនក្មេងយំក៏ចូលទៅ ឃើញខ្មុកម្តាយក្មេងនោះស្លាប់ ហើយឃើញក្មេងនោះ កំពុងតែនុបខ្ទោចម្តាយយំ នាងក៏ធ្វើសង្វែនអនិច្ចាខ្ទោចចិត្ត លួកដៃទៅបីកូននោះមក ។

តាំងពីសុំណែបុជ្ជាមកនៅក្នុងត្រកូលវ័ត្តនារីរៀលាណា ដែលចម្ការក៏ពុំបានផល ជំនួញដូញជាក់ក៏ចេះតែខាត សម្បត្តិទៀតក៏កាន់តែរលាយបន្តិចម្តងៗ ត្រាំតមក ត្រកូលវ័ត្តនារីក៏ចុះក្រដូនជាចង្រៃ ប្រុសៗស្រីតាំងប៉ុន្មាន ក៏ចេញលែងនៅម្នាក់ម្តងៗ ទាល់តែគ្មានសល់ម្នាក់ចំណែកគោក្របីដីរាសេះក៏ត្រូវលក់ដូរអស់ នៅសល់តែផ្ទះទេខ្មុកម្តាយវ័ត្តនារីព្រួយចិត្តខ្លាំងស្តាំងស្តួមអង្គុយចុះដក ហើយឪពុកក៏ចូលមកបៀតបៀនបាន នាំឱ្យអ្នកខាងតីរាន់ចេញទៅរកបររកស៊ីនៅតែលើផ្ទះ ដល់ខែទាល់ក្រណាស់ក៏លក់ផ្ទះសំបែងកូមិករកស៊ីរួមមួយផង ។

ចំណែកវ័ត្តនារី ក៏ស៊ូដាំបាយទំនុបថ្ងាយកទៅលក់ដូរយកលុយមកចិញ្ចឹមជីវិត ខុកជានាងមិនធ្លាប់ខ្វៃយល់ថាកដូចម្តេច នាងក៏ខំប្រឹងថែរក្សាមាតាបិតានឹងប្អូនចិញ្ចឹមដោយសេចក្តីព្យាយាម មិនបានបណ្តោយឱ្យសេចក្តីជូតសង្រឹម ចូលមកដែកចិត្តនាងបានឡើយ នាងខំបំពេញកិច្ចជាម៉ែផ្ទះដោយយកចិត្តទុកដាក់ រហូតដល់ថ្ងៃអាក្រក់ ដែលត្រូវគ្រាត់ប្រាសចាកអ្នកដ៏មានគុណចាស់ពីរ. នៅគ្រាលនោះនាងកើតទុក្ខសល់ឆ្ងាត

ស្ងើចនឹងសម្ងាប់ខ្លួនដែរ តែមកនឹកអាណិតដល់សុវណ្ណបុប្ផា ទើបអត់សង្កត់ចិត្តទាំមាត់តស៊ូដល់ដីតែតទៅទៀត ទើបលះមកតែលនាងបានស្លួនទុកដើម្បីនឹងសម្រែចកិច្ចធ្វើបុណ្យរំលាយសពមាតាបិតា រួចនាងក៏គាន់មណាសញ្ញាដាក់ក្មេងម្នាក់ឲ្យមើលផ្ទះ ។

តាំងពីថ្ងៃនោះមក នាងក៏ចាប់ធ្វើការលើសមុន ថ្នមសុវណ្ណបុប្ផាមិនឲ្យធ្វើអ្វីបាំងអស់ កាលបើនាងមកពីផ្សារវិញក៏ចូលទៅស្ងួដណ្តាំបាយធ្វើមុខ ពេលណាអត់ នាងក៏លេចទឹកមាត់ជិតទឹកភ្នែង ទុកម្ហូបចំណីបន្តិចបន្តួចឲ្យប្អូនចិញ្ចឹម ព្រោះគ្នានៅកន្លែងភូមិត្រែងខ្សាច់ចាប់ នាងទំនៃរដើរទៅមានតែបីបួននោះ អស់ចំនួនមួយឆ្នាំគត់ ។

ល្ងាចមួយ នាងអង្គុយលេងជែបលែងជាមួយនឹងសុវណ្ណបុប្ផា ស្រាប់តែមានសេះមួយមានឧយ៉ាងមាំពេមស្អាត រត់ចូលមកក្នុងភូមិរបស់នាង ហើយក៏ឈប់រេពៅមុខស្ងួនចន្លៃរបស់នាង ហាតស្ទឹកទៀរខ្លួហើយក៏ស៊ីចន្លៃនាងតែម្តង នាងស្ទុះចុះទៅយកដំបងដេញសេះនោះ ក៏តែជាន់បន្លៃរបស់នាងខ្លួចអស់ ហើយទៅឈប់ឯម្ខាងឯណោះស៊ីចន្លៃទៀត នាងយើញដូច្នោះហើយក៏ស្ទុតចិត្តលុតដង្កង់ចុះ គក់ទ្រូងជែទ្រហោយំ_“ខុសេះអើយសេះ! សេះឯងម្តេចក៏មកបង្កិនចង្ហោចដំណាំផងខ្ញុំដូច្នេះ ម្តេចក៏មកឆ្លាចអាហារបស់យើង ដំណាំប៉ុណ្ណេះហើយដែលជួយឲ្យយើងរស់ដីតៗ ឥឡូវបើឯងមកស៊ីមកជាន់យ៉ាងហ្នឹង .....” ។

ខណៈនោះ មានបុរសកំឡោះម្នាក់រូបឆង្គស្អាតជាត រត់មកដល់ទីនោះដែរ ហើយសែងសួរអ្នកផ្ទះថា "អ្នកអើយ! អ្នកបានឃើញសេះខ្ញុំរួចមកទីនេះដែរឬអ្វី ?

សុវណ្ណបុប្ផាទីឆ្ងល់ក៏ឆ្លើយឡើង "សេះពូឯងអ្នកណាស់ ចូលមកស៊ីដំណាំមេសបងខ្ញុំអស់គ្មានសល់ ធ្វើឲ្យបងខ្ញុំយំសោក ពូឯងក៏ឥតមានយោគអីម្ល៉េះ មិនចេះថែសេះឲ្យវាមកចូលកូមិគេ" ។

សោកិតឮដូច្នោះក៏ភ្ញាក់ខ្លួន ហើយដើរចូលទៅជិតវត្ថានាទិយាយលួងលោមនាងថា: "អ្នកអើយកុំយំសោកថ្មី ចាំខ្ញុំសងថ្លៃដំណាំអ្នក ធ្វើម្តេចសេះខ្ញុំវាកាចវាលួចរត់មក ខ្ញុំតាមមិនទាន់តាមតែអ្នកមេគ្គាអត់ទោសទៅចុះ" ។

រួចសោកិតក៏លូកយកថ្លុក១០រៀ១០ហុចឲ្យនាង ហើយក៏ដឹកសេះត្រឡប់ទៅផ្ទះវិញ តែនឹកនឹករលឹកដល់វត្ថានាមិនភ្លេច ព្រោះសោកិតចាប់ចិត្តនឹងរូបនាង ទើបទុស្សាហ៍មកសេនផ្ទះនាងញយៗ រួចបានឲ្យគេមកដណ្តឹងនាងៗក៏ព្រម តែថាបើសោកិតអនុញ្ញាតឲ្យមួយឲ្យនាង គឺថាឲ្យស្មោះនឹងនាងរហូតដល់ផុតដីវិតហើយមិនក្បត់ចិត្តនាង សោកិតក៏ខ្លួលព្រមចុះខ្សន្យា ទើបរៀបការជាមួយនឹងនាងយ៉ាងអឺកៈធឺក ។

ចំណែកនាងសុវណ្ណបុប្ផាក៏បានសេចក្តីសុខរៀងមក រហូតដល់នាងធំពេញវ័យពេញកង ល្មុះដល់នាងពេញក្រមុំហើយឪពុកពានាងថ្លែកបន្តិច

ម្ដងៗហាក់ដូចជាផ្កាដែលរីកពេញទំនឹងនាងចេះតាក់តែងកាយស្បែកសំពត់អាវស្អាតៗ ហើយលាបប្រែងម្សៅទឹកអប់ផង រូបនាងហាក់ដូចជាស្រីខេតអប្សរ ។ មួយវិញទៀត នាងតែងចំរើរសោកិតរជាយយកចិត្តទុកជាក់ចំផុត ចំណែករសោកិតក៏ចូលចិត្តតែប្រែនាង ទាល់តែរត្នានាងចំអន់ថា "អ្នកបងប្រយ័ត្ន តិចក្លាតរបស់សុវណ្ណបុប្ផា" ។

"ត្រែល! ឯងនំយោយមើចយ៉ាងហ្នឹង ឯងក្លេចនំនាយលោកគ្រូទៅអធិការហើយឬ?

តើគួរឲ្យជឿពាក្យប្រុសបានទេហ:?

បទទី ៤

ការប្រព្រឹត្តកន្លងចិត្តភរិយា

លុះសុកន្ទែចំរើនវ័យបានធំឡើង មាតាបិតាក៏រីនរឹតតែថ្នាក់ថ្នមបុត្រ ស្រឡាញ់មិនឲ្យឃ្លៀសឃ្លាងចិត្តម្ដងឡើយ ព្រោះតាំងពីកូនខោះកើតឡើង ជំនួញគ្រប់មុខក៏ចំរើនជាងអស់ បើកូនចង់បានអ្វីក៏រកឲ្យភាល់តែបាន ត្រែវអំពីផ្ការយនឹងព្រះអាទិត្យត្រះចន្ទ្រចេញ ដែលហួសវិស័យខ្លួនទើងយកមកឲ្យពុំបាន ជីវិតកូនសម្បុកនោះ ក៏ឆ្លងការកៅ

ដោយសេចក្តីចំរើនគ្រប់ប្រការ គ្មានអ្នកណាមួយនឹកនាថា នឹងមានហេតុអាក្រក់ចូលមកលុកលុយបានទេ ។

តែកាលជាអនាគត ជាសភាវៈបិទបាំងអស្ចារ្យណាស់ យើងមិនអាចនឹងមើលឲ្យឆ្លុះជាក់ច្បាស់នឹងមំសចក្ខុបានទេ ព្រោះដូចជាខ្ចាវសូត្រដែលពួកកុមារកំពុងវាវ នឹងសន្មតថាចេះតែចេញឯងមកឥតអាក់ក៏ពុំបាន ព្រោះចួនលោជាមានអ្វីមកខ្ទប់ទាស់ នាំឲ្យផុយបុនក៏សឹងមាន ពុំនោះសោតដូចត្រីចក្រយាន ដែលយើងកំពុងជិះដោយស្រួលលោតែថែកកៅស៊ូឥតស្រណោះ ក៏ដូចជាជីវិតរបស់សុភិន្ទ ដែលកំពុងតែត្រេកត្រអាលទៅដោយល្បែងផ្សេងៗ ក៏ថែរជាកន្ទបែទៅតាមទំយមបែរបាកវិញ ។

កាលបើកុមារបានអាយុ ១២ ឆ្នាំហើយ មាតាមានជម្ងឺឈឺជាខ្លាំងបានខំរកគ្រូពេទ្យហូមកព្យាបាលពេតជាខ្លាំង ប្រុងប្រយ័ត្នថែរក្សាដោយល្អ ទើបបានជូរជម្ងឺបន្ថយមួយៗជាលំជាប់ ឯសុភិន្ទមិនហ៊ានឃ្លាតឡាយពីមាតាឡើយ មានចិត្តស្រណោនស្រពន់ពុំសប្បាយ តែងអង្គុយជិតគ្រែអ្នកម្តាយច្រើនតាក់តែងមិនឈប់ដៃ ខុតជាអ្នកបណ្តេញឲ្យទៅលេងយ៉ាងណាក៏ពុំព្រមទៅ ស៊ូតែទាំនៅមើលថែទាំខ្ចីកន្តៅខ្ចីកត្រជាក់ ។

ចំណែកខាងនាយសោភិតវិញ តាលបើតរំយោលឈឺពុំរៃដោយរួចថ្លៃពេក ក៏កើតអផ្សុកចិត្តសោកស្តាយ ដោយភ្លើងកាត់ជុតជាលកលល

កន៏សន្តាន ថ្ងៃមួយអត់គ្រាំពុំបាន ក៏ហៅនាង៏សុវណ្ណបុប្ផាឲ្យចូលមកតគត់ ប្រចាប់ឲ្យកន៏ចន្ទប់ស្អាតបេះ ខ្លួន ឯនាង៏នោះមានរូបឆោមលោមឆ័ណ្ឌ ជាអ្នកថ្លៃថ្លា ព្រោះនាង៏នោះប្រកបដោយសម្ផស្សសោភ័ខ្ចី ហើយត្រអូបប្រហើរផង គ្រាន់តែដើរដិតក៏ជាប់ភ្នែនគួរចាប់ចិត្ត ម្ល៉ោះហើយនាយសោកិត ក៏ក្តើនក្តៅចង់ប្រពន្ធភ្លូន ក្តៅចាំង៏ទំនាយលោកគ្រូហៅ អធិការក្តាន់ខ្លួនលួង៏លោមចំអែចំអន់មេខានោះ ។

មុនដំបូង៏នាង៏នោះ បានហាមគ្រាមហៅហ្វាយនាយបេះ ខ្លួនដោយអាង៏ថាជាការពុំគប្បី ព្រោះម្ចាស់ស្រីកំពុង៏មានផម្ងឹមិនស្រួល តែកន្ត័ចិត្តរំដួលញាប់ញ័រព្រឺព្រួចឥតឧបមា ដោយមិនធ្លាប់មាននរណាប្រលោមដល់ម្ត៎ង៏សោះ ទើបធ្វើឫកអៀនអន់ខុនជាក់មុខ តែនាយសោកិតដ៏ឆ័ណ្ឌលក៏បង្ខំចិត្តនាង៏ឲ្យស្ម័គ្រជាមួយ សុវណ្ណបុប្ផាពុំដឹង៏ច្បិតនយ៉ាង៏ណាដោយចាប់ចិត្តចេតនាឱ្យង៏ហ្វាយនាយស្រាប់ផង ក៏ព្រមប្រគល់កាយថ្លាយខ្លួនឫាណជូនចាំង៏អស់ ឥតមានខាចាំង៏អ្វីបន្តិចឡះវេលាកត្រីនោះឯង ។

កន៏ពេលដែលអ្នកចាំង៏ពីរ កំពុង៏តែក្តើតក្តើនដោយពិសព្ទញ្ញបេះកាមទេព ក៏កើតភ្យុះខ្យល់លេកចំកគ្រឹកគគ្រែង៏ ម្ែកឈើក៏យោកយោលខង់ឫាញចុះឡើង៏ ហាក់ឱ្យង៏ប្រែភ្លាយព្រះធរណី មេឃមីវង៏ងឹតខ្លួចំមានផ្ទលោន់គគ្រឹម ។ ភ្លុសន្ទោចវែងផ្លាយ ភ្លៀង៏ក៏បង្អុរចុះមកស្រោចស្រប់ប្រឋពី ព្រាយលំអង៏ចំកហើរដេរដាសប្រែជាចុះអ័ព្ទ

ប៉ាំងភាពអ្នកចាំងពីរបាត់ តែអ្នកចាំងពីរនោះ មិនបានតក់ស្លុតដល់អ-
ណាចក្ខៀងផ្តរនោះឡើយ ក្មេងអស់ហេតុការណ៍ចាំងពួង ហាក់ដូចជា
មិនមែនបិតនៅពិភពលោក នាយសោកិតក្មេងកំសោយ សុវណ្ណបុប្ផា
ក្មេងចៅហ្វាយស្រី ថមថយកំឡាំងខន់ដៃជើងល្វើយលក់ចាំងពីនោក
រហូតដល់ភ្លឺ ។

ការប្រព្រឹត្តិក្បត់ចិត្តនេះ ក៏ប៉ះប៉ាំងជិតមិនមានឮខ្លះភ្លាយសាយ
ដល់គេដល់ឯង ចំណែកមេផ្ទះបានគ្រាន់តែមើមែនទែនគាចដើរចេញមក
ខាងក្រៅកើត អង្គុយនិយាយលេងជាមួយអ្នកស្រុកនឹងអ្នកជិតខាងដែល
តែងនាំគ្នាមកសាកសួរដំណឹងតែពលល់ៗ ថ្ងៃ ។ កន្ទុងមកបានវែមួយ
ក៏បានជាស្រឡះស្រួលបួលមានកំឡាំងកំហែងដូរដើម ចាប់ធ្វើការងារ
ពេញដៃពេញជើង ឯសុកន្ធ្រក៏មានចិត្តត្រេកអរសោទរឥតឧបមា ហ៊ាន
ឃ្លាតឆ្ងាយពីមាតាចេញទៅគេលេងជាមួយនឹងក្មេងឯទៀតៗ ។

មានយប់មួយនាពេលអធ្រាត្រស្ងាត់ រត្នានាំបុកពោះឈឺទៀបៗ
ក៏នាំគ្នាភ្ញាក់ឡើងយកដៃសង្កត់ពោះគ្រាន់បានអន់បន្តិច ទើបសំដីដេកទៅ
វិញ បន្តិចមកក៏ចុកភ្ញាំងលើសដើម តើតឡើងត្រង់ចុងជង្គើមឈឺផ្សាដូច
មុតបង្ខា ហាក់ដូចជារមួលពោះវៀនជាខ្លុសាហ៍ស ឈឺភ្ញាំងណាស់
គ្រាមិនបានទើបពាក្យតែប្តី ពាក្យតមិនឃើញនាងក៏ភាញឈើគូសមកអុជ
ចង្កៀងបំភ្លឺឡើង យកដៃញាត់ពោះអង្គុយចាំគេត្រឡប់មកវិញ ព្រោះ

ទឹកស្នានថា សោកិតទៅបន្ទោបង់ លុះកន្ទុំមួយមោង៉តមកទៀត
នាឡិកាវយមោង៉ ៧ ក៏ភ្ញាយើញ គ្រឡប់ម៉កវិញ ទឹកធ្លល់ណាស់ទើប
នាង៎ាំដេញបំបាក់សេចក្តីឈឺដោយមាននេះ ដើរកាត់ផ្ទះទៅឯបន្ទប់កូន
សំឡាញ់ឃើញចង្កើងព្រឹមៗនៅលើតុ នាង៎យកដៃវែកមុង៎ឡើងឃើញ
កូនប្រុសដេកលក់ស្រួមកខ្ចៅ មានសៀវភៅនៅលើដើមទ្រូង ព្រោះ
សុតិន្តូត្រូវប្រឡង៎យកសញ្ញាបំត្រជាកំង-ខ្វែកង៎ឆ្នាំនេះផង ជានជា
ខិតខំស្វាធ្យាយណាស់ ។

មានានុនថើបបុត្រហើយ ក៏ឆ្ពោះទៅបន្ទប់នាង៎សុវណ្ណបុប្ផាដើម្បី
ខ្ចីជាស់នាង៎ឲ្យជួយរតែពោះឲ្យ លុះដល់ឆណៈគ្នាវស្រាប់តែឮសូរសំ-
ឡេង៎ខ្សឹបខ្សៀវគ្នា រ័ត្នានាទឹកស្នានជានាង៎សុវណ្ណបុប្ផានាំសហាយឡើង
ដេកលើផ្ទះ ដល់ប្រុង៎ស្តាប់មែនទែនទៅ កំចាំឮស្តាប់ជាមាត់ស្វាមី
និយាយលួង៎លោមមេខាថាដូច្នេះ "អូនអើយ! បង៎ឮស្តាប់ជាមិនចោល
ប្អូនទេ កុំមាសមេនាង៎ព្រួយចិត្តថ្នូ បង៎អាណិតប្អូនណាស់តែវាតើស៊ី បង៎
មានប្រពន្ធកូន៎ក៏ពិតមែនហើយ តែអូនកុំអាក់អន់តូចចិត្ត ការណ៍នេះ
ស្រែចតែខឹង៎ចិត្តបង៎ទេតើ! ។

— "ចាះ! ខ្ញុំដឿចិត្តលោកប្អូសហើយ តែថាប្រសិនបើជាការ
នេះបែកសារឡើង ; លោកស្រីមុខរាប់ណ្តាញ់ខ្ញុំឲ្យចុះចេញពីលើផ្ទះមិន
ហានទេ ខ្ញុំនឹង៎ទៅជាស្រីអនាថាឥតទីពំនឹង៎ ទៅជាកេរ្តិ៍ដំខៀលអ្នកផង

ចាំងពួង តើឲ្យខ្ញុំយកមុខទៅខុកឯណា មួយវិញទៀតជាតិស្តួចដូចជ្រូក កាលបើតមកគ្រែបង្កកលំអងគេសរហើយរួចហើរចេញទៅ មុខជាទឹងស្រពោនជ្រុះចាកខន្ធ កាលបើខ្លាក់ដល់ដីមុខជាទឹងស្ងួតអស្ចារ្យតាមអ្នកណា ទឹងមេត្តាជួយសង្គ្រោះ សូមលោកប្រសិតមើលផ្លូវនេះផងចុះ ។

"កែវកុំថប់អ្វីព្រលឹងបង ស្រួចទឹងបងចុះ បងការពារមិនឲ្យវេទនាឧដល់ថ្លៃគ្រាយ" ។

រត្នានីកាលបើបានឮពាក្យអស់នោះចុកត្រចៀកហើយ នាងក៏ទឹកដល់ទំនាយ ដែលលោកគ្រូបានទាយពុកអំពីថ្ងៃមុន ក៏តូចចិត្តណាស់ បាត់ឈឺពោះ ភ្លាត់ដៃខ្លាក់ចន្ត្រៃដែកភ្លាយ រួចនាងគត់ខ្លួនជាពុក គួរឲ្យស្រណោះនាពេលកត្រីកាលនោះពេក ទឹកសង្វេគដល់រូបខ្លួនដែលដួលដេកត្រង់ទីនោះ ស្វាមីក្លាក់ខ្លួនក៏ស្ទុះចេញមកចាំរុងទឹងត្រកងបី នាងឃើញមុខទឹកភ្នាញ់មិនបង់ឲ្យមកបំពាល់ខ្លួន ទំក្រែកឡើងគេចពេញតែរលីងផ្ទះ ប្រដេញគ្នាដូចគេលេងបិទពួន ផ្តើលដល់អ្នកផ្ទះចេញមកលាន់ ។ រត្នានីក៏បើកទ្វារស្ទុះចុះដណ្តើរវត់ដំរង់ទៅមុខទៅ តុំដឹងជាទឹងមានចំណងទៅទីណា ដល់មាត់ទឹកឃើញដើងអស់កំឡុងដួលសន្ធប់បាត់មាត់ទៅទីនោះ ។

សោភ័តទឹងខ្ញុំស្រាច្រែនបានតាមមកទាន់ ទើបលើកនាងយកវិលមកផ្ទះវិញ នាំគ្នាតែត្រួតន្ធគ្រសៃសង្វាយដៃគ្រប់គ្នា ខ្លះទៅរកជាំទឹក

ខ្លះតត់ទៅអញ្ជើញគ្រូ ដើម្បីដល់អ្នកដឹតខាងភ្ញាក់ពុះមកម៉ាម្នាក្មេងតាំងស្លាចុារ ដោយតំយណាស់ហាក់ដូចជាមាតារបស់ខ្លួនបង្កើតមានជម្ងឺឈឺនាំគ្នាអង្គុយជុំៗ មានទឹកមុខសូតស្រពោន ស្រីៗ ខ្លះក្អែកទន់ក៏អត់យំពុំបាន ។

ចំណែកសុតិន្ទ្រភ្ញាក់ម្ល៉ឺងកាលណាក៏ស្ទុះចេញមក ឃើញម្តាយសម្លាប់ចាត់មាត់ចាត់ក ក៏ស្រែកច្រលន់ឡើងថា "អ្នកអើយអ្នក! ខុអ្នកផងកូន!" រួចក៏ស្ទុះទៅឧបម្តាយយំរឭកខ្លួចទន់អស់តាំងខ្លួនច្បាណាគាឮសូរមាត់កូនក៏ភ្ញាឡើងបើកភ្នែកមើលបានមួយភ្លែត ក៏ប្រែទៅវិញលែងតំរែតើងដែរ ។

ពេលនោះគាគ្រូក៏មកដល់ អង្គុយបត់ជើងស្រួលបួលតាញ ឈើគួសអុជខ្ទៀនធូបមួយសំណុំធំ ដែលឆេះភ្លាឡើងបានរងើកក្រហាមឆ្ងិនរមួលចុះឡើង ពួកគាស៊ីក៏លើកទឹកអប់ផ្សែងខ្ទៀនមួយផ្តិលទាត់មកជាក់ជំកល់ពីមុខ គ្រូក៏គោះកំទេចធូបសំរែកគង់ទឹកលាន់ឆេវៀ ចង្ក្រុយផ្សែងឲ្យហុយច្រលោមទៅលើអ្នកជម្ងឺ រួចសែកមន្តអាគមខ្សឹបៗ ផ្តុំពុះទៅកង់ទឹកក្អែកសំឡឹងពុះមានមុខសម្លឹមភ្ញៀវដោយរងើកភ្លើង លុះសូត្រអាគមចប់ហើយក៏ផ្តែលក់ធូបតាំងអស់ទៅក្នុងផ្តិល យកដៃរលាស់ទឹកទៅលើរ័ត្តនារី ដែលបានត្រជាក់បន្តិចម្តងៗ បើកភ្នែកឡើងមានកំឡាំងសន្សឹមៗដាលំដាប់ ។

ចំនួន ១៥ នាទីតមក អ្នកជម្ងឺនោះក៏ដើរអង្គុយឡើងបានដោយអំណាចអានុភាពដ៏សក្តិសិទ្ធ រកគ្រូមាស្ងាស់សំពត់ឲ្យគ្រូស្រោចទឹក ដើម្បីឲ្យរោងរគ្រោះថ្នាក់ លុះស្រោចស្រប់គ្រប់សពាង្គកាយហើយ នាងក៏បានស្រឡះមុខមាត់មានកម្សាន្តតំហែង លើកដៃសំពះគ្រូ "លោកគាមានគុណធំធ្ងន់ណាស់ ជួយស្រោចស្រង់ជីវិតខ្ញុំម្ចាស់នេះ ហាក់ដូចជាប្រសិទ្ធឲ្យខ្ញុំរស់ឡើងវិញម្តងទៀត ខ្ញុំនឹងជូនរង្វាន់ទាន់ទៅលោកគាឲ្យពេញចិត្ត" ហើយនាងចូលទៅក្នុងផ្ទាស់សំលៀកបំពាក់ ពុងបំផុតបានចេញម៉ែកយករង្វាន់ជូនគ្រូជាចំនួនច្រើន ។

ចំណែកសុកន្ធ្រកុមារ ត្រេកអរណាស់ស្ទុះទៅទុបគាគ្រូដោយសេចក្តីដឹងគុណ គាគ្រូស្ទុតចិត្តអាណិតស្ទើរលួយថ្នើម ទើបដកដង្ហើមមិនស្តីថាអ្វី យកដៃអង្អែលក្បាលសុកន្ធ្រយ៉ាងថ្នម បន្តិចមកគាត់និយាយថា "ឲ្យចៅឯងបានសេចក្តីសុខមានអាយុយឺនដល់រយឆ្នាំ កុំឲ្យតម្អូញតម្អែរបៀតបៀនបាន គាអាណិតចៅណាស់ បើជាមានទុក្ខធុរៈទៅរកគាចុះគានឹងជួយ" ។

រួចគាត់ក៏លាម្ចាស់ផ្ទះវិលទៅលំនៅគាត់វិញ ។

(ម.ឧត)

* * *

និទានរឿងព្រៃឯ

ចៅតាំមិតមភ្នោះ

កាលពីដើមមានបុរសពីរនាក់បងទំនងប្អូន លំនៅមិនជ្រាកដជា
នៅឯណា ម្តាយអាពុកស្លាប់អស់ទៅ នៅតែ ២ នាក់ប្អូនទំនងបង នាថ្ងៃ
មួយក៏បបួលបងប្អូនទៅនៅវត្ត រៀនអក្សរធម៌អាថ៌ សាស្តាចាល់តាម
ចំនៀម ក៏បុរសបងប្អូនទៅនៅទំនងលោកគ្រូសង្ឃរាជ (ចៅអធិការ)
លោកក៏តែងអាណិតមេត្តាយកចិត្តទុកដាក់ បង្រៀនប្រដៅឲ្យរៀនស្ទាត់
ឯក្មេងពាំងពីរនាក់ទំនងមានអស់ក្មេងណារៀនឲ្យស្ទើរគ្នាន លុះរៀន
ចេះចប់ លោកគ្រូក៏បបួលជាទេន ឯទេនពាំងពីរពុំមានខ្ជិលច្រអូស
តែងតែចំរៀនស្ទាត់ បន្តើគ្រូមិនឲ្យអាក់អន់ព្រះទ័យពីអ្វីឡើយ ។
ថ្ងៃមួយទេនពាំងពីរចេញទៅដាំលាគ្រូសឹក គ្រូក៏ពុំមានឃាត់ ព្រមឲ្យ
ទេនពាំងពីរសឹក, សឹកហួច លោកគ្រូផ្តាំប្អូនសេបងថា ឲ្យទៅនៅកេសុី
ឯស្រុកចិន ទំនងជាទៅស្ថិតក្នុងស្រុកចិន; ឯបុរសប្អូនគ្រូមើល
ឲ្យថា ទំនងប៉ាន់ជាស្រុកសោយភព្វនគរពីរ ហើយលោកគ្រូក៏ផ្តាំថា
"ម៉ែនឯ្យណាស់កុំដេក យកប្រតន្ទទៀមើលម្តាយក្មេក ចូលដំណេក
កុំនិយាយទំនងប្រតន្ទ" ភាក្យពាំង ៣ ម៉ាត់នេះ ដង្ហែនគរពីរ បើឯង
រក្សាបានស្ទើរដូចជាទេនគរពីរ អញគ្មានអ្វីឲ្យឯងទេ មានតែពាក្យបណ្តាំ

ប៉ុណ្ណោះ ។ ឯបុរសខាងពីរនោះបងប្អូន លាគ្នាដើរទៅ ឯបងគ្នាំ
ឲ្យទៅរកស៊ីឯស្រុកចិន គេក៏ទៅរកស៊ីតាមភាក្យគ្នាំ ក៏បានជាទៅសួរ
ធំមែន ។ បុរសប្អូន មិនដឹងបើនឹងរកស៊ីអ្វី ក៏ទៅនៅនឹងបងប្អូនញាតិ
សន្តានទាំងគេក៏អាណិត ជណ្តើងប្រពន្ធរៀបការធ្វើផ្ទះឲ្យទៅ បុរសនោះ
ក៏រង្វើងក្តេចពាក្យដែលគ្នាំ ក៏ទៅរកស៊ីនឹងប្រពន្ធ ប្អូនបានស៊ី ប្អូន
អត់ រកស៊ីបានត្រឹមបាត់ល្ងាច បានល្ងាចបាត់ត្រឹម រកសំពត់នឹងស្បៀក
គ្មាន មានតែទោតញ្ចាស់មួយពាក់តណ្តាលក្តៅ ដាចលេចមុខលេចក្រោយ
បុរសនោះគិតដើរទៅតំពង់ទឹក ក្រែងមានគេមកពីស្រុកចិន
នឹងបានសួរដំណឹងគេពីបង ។

គាប់ដួងជាថ្ងៃនោះ មានសំពៅគេបើកមកពីស្រុកចិន បុរសនោះ
ក៏ប្តូរទៅសួរគេថា អ្នកនាយសំពៅអើយ អ្នកបានប្រទះខ្ញុំម្នាក់ផង
ទៅរកស៊ីស្រុកចិន ៥ ឆ្នាំនេះហើយដែរឬ? ឯនាយសំពៅឆ្លើយថា ខ្ញុំ
ឃើញខ្ញុំម្នាក់ដែរ ឥឡូវគេបានជាទៅសួរធំ មានឯារសក្តិធំក្នុងស្រុក
ចិន គ្មានអ្នកណាមានស្មើគេទេ បុរសនោះសួរទៅនាយសំពៅវិញថា
អ្នកនាយសំពៅ អ្នកអញ្ជើញទៅវិញថ្ងៃណា នាយសំពៅថា ៣ ថ្ងៃ
ទៀតខ្ញុំវិលទៅវិញ បើអ្នកអញ្ជើញមេត្តាឲ្យខ្ញុំសុំដោយសារទៅផង ។
បានអញ្ជើញទៅចុះ ។ បុរសនោះក៏លានាយសំពៅមកផ្ទះវិញ ចាំយ
និយាយនឹងប្រពន្ធថា នាងអើយ យើងសព្វថ្ងៃនេះ ក្រពាំបាកណាស់

ឥឡូវក្មួងដំណើរជាបងអញដែលទៅនៅកេស៊ុស្រុកចិន គេបានជាចៅស្ងួ
ជំកូនស្រុកចិន បងបងទៅកគាត់ ក្រែងគាត់អាណិតឲ្យធ្វើកាស
ចាយសំពត់អាវស្លៀកខាក់ខ្លះ ឯប្រពន្ធឮប្តីស្រដីដូច្នោះសួរថាបុះអ្នកទៅ
ទីឯអ្នកណា? បងទៅដោយសារសំពៅទីឯគេ។ ព្រមឲ្យទៅហើយ នៅ
៣ ថ្ងៃទៀតទើបគេចេញសំពៅទៅ ។ អើអ្នកទៅក៏ទៅកុះលុះដល់
៣ ថ្ងៃ បុរសនោះក៏ចុះសំពៅជាមួយទីឯគេទៅ ហើយជួយមើលថែទាំ
រក្សាបស់ទ្រព្យនាយសំពៅហាក់ដូចជាទ្រព្យបស់ខ្លួន ឯនាយសំពៅ
ឃើញចៅបុរសនោះមានគំនិតមានយោបល្អ ក៏ស្រឡាញ់ពាក់អានអាណិត
ឲ្យជាយចំកស៊ីតែសព្វថ្ងៃរៀងទៅ ។

ឯយោយតាប្រពន្ធចៅបុរសនោះ ក្រែយដែលចៅបុរសទៅស្រុក
ចិន ក៏លួចមានសហាយ យកមកដេកជាមួយរាល់ៗយប់ ។

បុរសនោះលុះដល់ស្រុកចិន ក៏សួរនាយសំពៅថា អ្នកនាយ
សំពៅលែទៅស្រុកខ្មែរវិញថ្ងៃណា ប្រាប់ខ្ញុំផង ។ នាយសំពៅថា ៣
ថ្ងៃទៀតទីឯចេញសំពៅទៅ ចៅបុរសនោះក៏ឡើងទៅសួរកេបង ដើរ
ទៅដល់មាត់ទ្វារផ្ទះបង ឃើញមនុស្សនៅចាំទ្វារសួរថា អ្នក នេះហើយ
ឬផ្ទះលោកចៅស្ងួខ្មែរ អ្នកចាំទ្វារប្រាប់ថាហ្នឹងហើយ ផ្ទះលោកចៅ
ស្ងួ ។ បុះអ្នកឯងមកពីណាមកសួរកេផ្ទះលោកចៅស្ងួ? ខ្ញុំមកពីស្រុកខ្មែរ
ឯលោកចៅស្ងួនេះលោកជាបងខ្ញុំបង្កើត ។ មនុស្សអ្នកចាំទ្វារ មើល

ទៅរួចទៅបុរសនោះ មិនសមជាបងប្អូនទេ ឯលោកទៅសួរសោះ ។ ហើយ
ក៏អ្នកចាំទ្វារនោះទៅដាក់បទបន្ទូលទៅសួ (រៀលនោះលោកទៅសួមិនទៅ
ទៅតាល់ស្តេច) ថា អ្នកទៅហ្វាយស្រី មានមនុស្សកំសត់ម្នាក់មកពីស្រុក
ខ្មែរ រូបក៏តូចក្រៃ ស្បែកខៀវខាត់ភ្លាត់ភ្លាស ដាច់ជាងលេចមុះលេច
ក្រែយ គេបានថ្កាប់ខ្ញុំថាគ្រែវជាប្អូនលោកទៅហ្វាយប្រុសបង្កើត
ឥឡូវខ្ញុំបាទឲ្យវាចាំនៅមាត់ទ្វារ ។

ឯបទបន្ទូលទៅសួនោះនឹកតបចិត្តថា អាដែងមនុស្សកំសត់ខ្មែតនេះវ
មកពីណាក៏ហ៊ានបង្អាប់ក្មេងថាប្តីអញជាបងវាបង្កើត នាងវិងក៏ប្រើម-
នុស្សឲ្យទៅចាប់បុរសនោះមកដាក់ច្រវាក់ ខុកនៅពេនសេះ រៀចាំប្តីមក
ទើបឲ្យយកទៅសម្លាប់ ។

ឯទៅបុរសនោះ គ្រាវគេដាក់ច្រវាក់ក៏នឹកថា តុអញអើយសង្ឃឹត
មកពីស្រុកខ្មែរដល់ស្រុកចិន ព្រោះតែបង ឥឡូវគេមាន គេពុំគិតអា-
ណិតឈាមដែលកើតមករួមផ្ទៃជាមួយគ្នា គេះធ្មេងមាន គេហ៊ានចាប់ឯង
មកដាក់ច្រវាក់គិតទើបសម្លាប់ផង តុអញអើយបើនៅស្រុកខ្មែរកេស៊ីតាម
ខ្លួនក្រ ក៏គ្មានទេណាហ៊ានធ្វើបាបខ្លួន ឯទៅបុរសនោះពុំដឹងជាបងទៅ
តាល់ស្តេច ដែលនិយាយដូច្នេះ (ដោយសំគាល់ថាបងធ្វើបាបខ្លួន) ។

លុះទៅសួជាបងវិលមកដល់ផ្ទះ បទបន្ទូលថ្កាប់ថា លោក មាន
មនុស្សខ្មែរម្នាក់មកពីស្រុកខ្មែរ មកនិយាយថា លោកជាបងបង្កើត តែ

រួចនោះគាត់ ស្ងៀកខោពាក់តណ្តាលភ្លៅ ជាបលេចមុខលេចក្រោយ
អង្គរខ្ញុំឲ្យដាក់ច្រវាក់ខ្នុកនៅពេនសេះ ចាំលោកអញ្ជើញមកសម្រេចឲ្យនាំ
ទៅសម្លាប់ ។

ឯចៅស្លូជាបងឮហើយនិយាយថា ចៅយកវាមកមើល តែកូនជា
ប្អូនបង្កើតរបស់យើងនៃមែន ហើយចៅស្លូឲ្យដោះច្រវាក់ចៅប្រុសនោះមក
ដល់ស្គាល់ជាប្អូនច្បាស់ជាមែន ក៏រៀបចាយឲ្យស៊ីផឹមើលចៅប្អូនក្រ
ណាស់ ស្ងៀតខោពាក់តណ្តាលភ្លៅ ចៅស្លូក៏ឲ្យខោមួយស្ងៀក ទើប
សួរប្អូនថា ប្អូននៅឯនាយសព្វថ្ងៃរកស៊ីអ្វីនឹងគេ ។ ចៅប្រុសជាប្អូនជ្រាប
បងថា ខ្ញុំនៅឯនាយមិនដឹងរកស៊ីអីទេក្រណាស់ ហើយមានប្រពន្ធ
ជន ឯបងឮប្អូនឱ្យដូច្នោះក៏ទឹកអាណិតប្អូនមិនចេញស្តី ។ ចៅស្លូ
ជាបងក៏សួរទៀតថា ប្អូនមកដោយអ្នកណា ។ ឯចៅប្រុសជាប្អូន
ដាក់បថា ខ្ញុំមកនឹងនាយសំពៅគេឲ្យដោយសារមក ។ ចុះគេទៅវិញថ្ងៃ
ណា ។ ចាខ, នៅ ៣ ថ្ងៃទៀត គេនឹងចេញសំពៅទៅវិញ ។

ចៅស្លូជាបងដឹងដូច្នោះក៏ស្ងៀមទៅឲ្យលើកចាយមក ហៅចៅ
ប្រុសជាប្អូនស៊ីជាមួយគ្នា លុះស៊ីផឹច្រាប់ថា ប្អូននៅផ្ទះនេះសិនចុះ
បងទៅលេងផ្ទះចិនសៃ ចៅស្លូជាបងទៅដល់ផ្ទះចិនសៃ
ឯចិនសៃគ្រេរត្អូកយើញចៅស្លូទៅដល់ក៏យកកៅអី ថ្នាំចិន ខ្យៀ ទឹក
តែទូល ហើយចៅស្លូនិយាយទៅចិនសៃថា ខ្ញុំមកគេលោកមើលឲ្យ

ប្អូនខ្ញុំបន្តិច តើវាទំនងចេះតែត្រដូចច្នេះទៅ ឬវាទំនងគ្រាន់បើទំនងតែដើរ ចំនែកញាសៀវភៅមកមើលសព្វៗ ទៅតាយថា ប្អូនលោកមិនជាអ្នកស្រលាញ់ចាកទេ ដល់ ៧ ឆ្នាំទៀត ទំនងបានសោយពរជ្យជាស្តេចនគរើ លោកទំនងបានជាធំសម្រាប់ពរជ្យដោយសារប្អូន ប៉ុន្តែឥឡូវលំបាកណាស់ ដល់វិលទៅស្រុកវិញពាក់កណ្តាលផ្លូវ ទំនងបានត្រូវមានដំរីមួយនគរើជាសម្រាប់ខ្លួន តែថាឃ្លាតទៅវិញ ត្រូវនោះដល់កំណត់បានសោយពរជ្យ ទំនងបានមកជាសម្រាប់បុណ្យវិញទាំងអស់ ។ ឯចៅស្តេចបានដឹងដំណើរប្អូនដូច្នោះ ក៏លាចិនសែតឡប់ទៅផ្ទះវិញ ។

ដល់ ៣ ថ្ងៃ នាយសំពៅគេផ្តួតសំពៅចេស្រែចាំ ចៅបុរសក៏និយាយថ្កាប់ថ្កឹងថា អ្នកបងខ្ញុំចង់លាអ្នកបងទៅ ដ្បិតសំពៅគេទំនងចេញទៅថ្ងៃនេះហើយ ។

ឯចៅស្តេចាបងយកផាឱបមកបែកមួយត្បូង ហុចឲ្យទៅចៅបុរសជាប្អូន ឯចៅបុរសជាប្អូន ក៏ទទួលយកផាឱបមួយត្បូង លាបងចុះដើរទៅបណ្តើរ គិតបណ្តើរនឹកតូចចិត្តស្តីរមិនចង់កាន់យកផាឱបនោះសោះ ចៅបុរសចេះតែនឹកតូចចិត្តថា ។ បងប្អូនទំនងគ្នាឥតពីអាពុកម្តាយស្លាប់ចោលទៅនៅតំណែតែបងទំនងប្អូនពីរនាក់ កាលវេលាត្រចេះស្រឡាញ់គ្នាពាក់អានគ្នា ដល់វេលាមានខាតគ្នាចោល ធ្វើមិនពាក់អានគ្នាមាសប្រាក់

អ្នកទកញ៉ាវិងព្រួសារពេជ្ជ ឆង រៀបរៀង

(តទៅ)

ពន្ធុត្តរច្ឆវ ពន្ធុកបណ្ដុល សពៀជ្ជសាទរ ថានាងប្អូនស្រី ប្រឹមប្រិយ
បវរ បិតានាងបវរ ទៅបេះកប្បាស ។ បើះប្អូនទៅ បងអ្នកនឹងទៅ
តាមប្អូនមិត្រមាស ចូរជួយចោមបេះ ប្រឡេះកប្បាស ប្ដូមួយប្អូន
ភ្លាស ជ្រែតនាងក្រមុំ ។ នាងឆ្លើយទៅប្អាន ថាម្ចាស់ទៅបាន កុំគិត
បារម្ភ តែមោះកុំដើរ ដំណើរខ្ញៀចខ្ញុំ ជាស្រីក្រមុំ ក្រែងអាពុករវ ។
នោងសួថា ប្អូនមាសបវរចា តាប់ណាស់ណោះមេ តិតក្រែងបិតា
លោកថាលោកវេរ បងនឹងទៅឯ ក្រែយប្អូនតុំងា ។ ព្រះពន្ធុនោងី
ន្ធូនាងនារី រូបរ៉ែនសោក ដួបចាប់ចងចិត្ត ស្ងាលស្ងិទ្ធនឹងគ្នា ដួប
កល់កំយោ ព្រាត់យូរខើបយល់ ។ នាងនាងនារី លាព្រះនោងី
ពួងពន្ធុទេសតល យោងយាត្រាត្រេច បន្ដិចទៅដល់ ដួបជួនយង់
យល់ បិតានាងនាង ។ ឯអង្គអម្ចាស ពួងពន្ធុវស្សូ ត្រីត្រៃតពាក្យ
តាមនាងទូន្មត ដល់ចំការគាល- ខោះអ្នកត្រអាល ចូលបតសម្ងាត់ ។
ក្រែមដើមៈពាធ៌ចាយ ក្ងមែកត្រសាយ ត្រសុំក្បែមក្បាខ្ពស់ ឯនាងនារី
ស្រស់ស្រីកល្យាណ បេះកប្បាសបាន ច្រើនជ្រលង់ ។ ព្រះពន្ធុ
នោងី ហូតយកប៊ុតី បង្ហុះមកដុំ ជ្រុំនឹងបម្រើង នាងច្រើនរង់

ព័ពេះសូវសម ឮសេចលើសលន់ ។ ឯកុលគោសី លុះឮសពួប្តី ពីពេះពេកពន់ ចិត្តចង់ស្លាប់ប្តី ចេញពីតម្បន់ ដើរដេលមនម- ណ្ឌល ខៀបភាល់ធី ។ ពោធីសត្វយល់ អាពុកនាងដល់ មកមិនផ្តុំប្តី ស្ងៀមស្ងាត់ស័ពួសល់ ទើបកុលគោសី ស្រាក់ស្រួលស្រដី អង្វរ លោមថា ។ ចៅអើយខំធ្វើត ផ្តុំបានម្តងទៀត ឲ្យយើងស្លាប់ក៏ ពោធីស្លាប់ហើយ ធ្វាស់ធ្វើយទៅថា មាឲ្យកូនមា ប្រែងទើបខ្ញុំផ្តុំ ។ កុលគោបីថា កូនអញនេះវ៉ា ជាស្រីតែមុំ វ៉ាភ្លាសអៀនប្រែន មិនហ៊ានប្រែងផ្សំ ចូរចៅឯងផ្តុំ តែឯងទៅវ៉ា ។ ពោធីសត្វធ្វើយ ខ្ញុំមិនផ្តុំឡើយ ខ្ញុំខ្លាសកូនមា មាមិនឲ្យប្រែង ចម្រែងផងគ្នា ខ្លួនខ្ញុំនេះជា ក្មេះខ្លាសតែមុំ ។ នាងកល្យាណី ស្តាប់ពាក្យពោធី- សត្វថ្លៃឧត្តម នាងធ្វើយទៅថា អ្នកអាសូវផ្តុំ ខ្ញុំនឹងប្រែងផ្សំ ឲ្យអាពុកស្តាប់ ។ ពោធីសត្វសើច អរអស់សំណើច ញញឹមហើយចាប់ ប៉ុយកមកផ្តុំ រងើសូវស័ពួ នាងនាងស្មែងស្តាប់ ប្រែងជួចឡើងវ៉ូ ។ ស័ពួប្រែង ទឹងប្តី ដួចដូរឫទ្ធិ រៃតែតឹងស្មុគស្មាម សំពួសូវក្សត្រក្សាច់ ឮសេច រងើ គក្រែកគៃពេច- ការកាលគ្រានោះ ។ ឯកុលគោសី ស្តាប់ប្រែងទឹងប្តី សូវសេមពីពេះ ទល់ទប់ប្រុងថ្កាណ តុំបានចំពោះ ថាចៅកំឡោះ ល្អល្អះប្រឹមប្រិយ ។ អញសូមសួរថា មកពីឋានណា ចង់ដឹងសេចក្តី សុះសពួសរពើ ចៅតើឈ្មោះអ្វី ចូរចៅស្រដី ប្រាយប្រាប់

អញ្ជាំ ។ បើចៅស្រឡាញ់ ចង់បានកូនអញ ជាតិជាកំណើ អញ
ផ្សំឲ្យចៅ ឥឡូវនេះណា កុំចៅសង្ឃឹ តិតវែងពុំបាន ។ ពោធិសត្វ
ថ្លែ ថាខ្ញុំឈ្មោះដ៏ឃ ខិត្យនៅនាឋាន ឥន្ទ្រជគ្គនគរ ចេញចរមកជ្ឈាន
ស្រុកនេះចង់បាន តូគួរស្នេហ៍ស្និទ្ធ ។ ឥឡូវអ្នកមា អាសូរកុណា
ឲ្យមានដូចចិត្ត វែងកូនវេះវោ ច្រាសប្រែតំនិត ពុំត្រមតាមចិត្ត អា-
ពុកម្តាយនោះ ។ កុលកោសីថា កូនយើងនេះវ៉ា ពុំដែលដួងខ្ញុះ
មិនមានវែងវ្រែស ច្រលូស្តប្រឈ្មោះ ពោលពាក្យទ្រគោះ ឲ្យម្តាយអា-
ពុក ។ កូនគេខ្លះ។ ចិត្តចោរមានៈ ចណ្ឌាលវែងមុខ ពោលពាក្យ
តាយងាយ ដេរម្តាយអាពុក បង្កើតគោសខ្ពុក ទាស់ខែងអ្វី ។ ។
កូនយើងនេះវ៉ា តែងតាមពាក្យអា- ពុកម្តាយស្រដី ដ្បិតវ៉ាដឹងអាថ៌ បេះ
ធម៌សេរ៉ៃ ក្រិត្យក្រមច្បាប់ស្រែ ឥតឯពីតាល់ ។ ព្រះពោធិសត្វ
តន្ទុកតុន្ទុតែន ឆ្លាស់ឆ្លើយសង៌សារ ថាបូរអ្នកថ្លែង សំដែងអស់អាថ៌
សេរ៉ៃធម្មា ឲ្យខ្ញុំដឹងជាន ។ កុលកោសិឆ្លើយ ថាវៃចៅអើយ វ័ធមិ
នេះមាន ពិស្តារនិងថ្លែង សំដែងពុំបាន រង៌ៅដល់ឋាន សន្យឹម
ចរចា ។ ព្រះពង្សពោធិ ស្តែងស្តាប់ពាក្យពិ អាពុកនាង៌ថា ខ្ញុះ
ទើបព្រះអង្គ ពូជពង្សាស្តា ចរចូលចម្ការ ជួយបេះកប្បាស ។
លុះល្ងាចត្រជាក់ ចានកប្បាសជាក់ ដោយដំដេរជាស ច្រមូលផ្តុតផ្តុំ
ជួបជុំពេញតាស ច្រមាណកប្បាស ១ដឹករវេះ ។ ឯកុលកោសិ ច្រាប់

ព្រះពោធិ៍ ថាកប្បាសថេរៈ ច្រើនពាន់ប្រមាណ ទុកខាន់នៅនេះ ស្អែក
យកវានេះ មកដុតដីតទៅ ។ ព្រះពោធិសត្វ ឮសំឡេងវែងថ្លាត់ ថាកុំ
ទុកនៅ ខ្ញុំនឹងខ្លួល រៀបយួរយកទៅ ដូចដល់លំនៅ កុំអ្នកព្រួយចិត្ត ។
ទើបព្រះអង្គវៀប កប្បាសស្រាប់ស្រេច ចាប់ចងរួតរឹត យួរយកដៃ ១
ស្តាំស្តួយធាប់ពិត យល់ហាក់ស្រាលក្តាត់ ពុំធ្ងន់ដល់តិច ។ កបកាយ-
ពល ដូចដំរីសារ យាងយាត្រាត្រេច ចរចូលដាក់ដល់ មណ្ឌល
ស្រាប់ស្រេច ពួកពង្សសេពិដ្ឋ ទៅស្រង់គង្គា ។ ឯនាងនិត្តិនី យល់
ព្រះពោធិ- សត្វសួរប្តីថា អ្នកនេះឈ្មោះអ្វី មកពីឋានណា ប៉ុនប៉ង
ធ្វើថ្នាថ្នា ប្រយោជន៍រកអ្វី ។ កុលកោសីថា អ្នកនេះនាមា ដ៏យឧមកពី
ឥន្ទបត្ថនគរ ចរវាងទី ចង់ជ្រាបកូនស្រី យើងដាកវិហេ ។ នាងនិត្តិនី
ស្តាប់ពាក្យស្វាមី ត្រេកអរសោមនស្ស- ខរខើបប្រហប្រាប រួសរៀប
អស់អា- ហារហៅព្រះមហា- សត្វសោយស្កប់ស្កល់ ។ សោយ
បរិបូណ៌ស្រេច ពង្សពុទ្ធសេពិដ្ឋ ពន្ធកខសពល សំណេះសំណាល
ត្រអាលសុខសល់ សាកសួរគារកល់ ពីធម៌សង្គីយ៍ ។ អាពុកនាងថា
កូនអើយប្រើប្រា ចង់ដឹងសេចក្តី ចូរកូនទ័មិល ច្រើតល្បាណ៌ ឲ្យ
ពស្រដី ចាយចែងចរចា ។ ព្រះពោធិវ- ង្សាសក្តិទុដ្ឋ ទុក្ខម
ទុក្ខលា ថាមែហប្អូនស្រី ប្រឹមប្រិយតំងា ចូរចាំចរចា បងចង់ដឹង
ជាន ។ នាងនាងឆ្លាស់ឆ្លើយ ថាម្ចាស់ខ្ញុំអើយ ធម៌នេះមាន តាំងពីរ

ប្រការ ពិស្តារនិទាន មួយ ។ បែកបាន ជា ១០ ប្រការ ។ មួយ
តីចំណេរ ចំណង់ចង់ចេរ ថាប្រុសអនុញាល មួយថាសាមាន្យ សន្ដាន
បណ្ដាល មួយថាស្រើបស្រាល ចិត្តចោរចង់ធំ ។ មួយថាខ្លៅខ្លួន
អាក្រែត់ពុំស្លូន ពុំស្ងើសក្ដិសម មួយថាចាវគេ មួយដេរគេរ- លើក
ទ្បើងថាខ្ញុំ ព្រះសង្ឃចៅកូរ ។ មួយថាធុំក្លាស់ ឆ្អែនឆ្អាបក្អែលណាស់
មួយថាចែចូរ មួយជាពាសោ ស្នែស្នោពុំត្រែរ អំបាលនេះកូរ ពោល
ពាក្យផ្ដាលផ្ដាញ ។ មួយសោតដំណាំ ទះពាត់ដោយដំ ដល់ ១០
ប្រការ ១ សង្កត់ត មួយក្រចៅខ្វារ មួយសង្កត់ស្មា អង្រែង់សិសោ ។
មួយក្ដិចមុះមាត់ មួយតប់ទះពាត់ មួយខាំកក្លា មួយទំង់ចោចសក់
មួយគក់អង្គា មួយជាកំសិសោ មួយជាកំចណ្ដាញ ។ បើទំង់ណាស់
កូរ មួយ។ ត្រូត្រែរ ជាជ្រាំវិញ្ញវិញ ពាំង់ពីប្រការ ដល់ជាលចែង់ចេញ
ជាមួយពាន់វិញ អត់បានប្លុះ ។ ពង្សពុទ្ធស្នែង់ស្ដាប់ សើចសង
សារសើពូ ថាវៃមាសមេ ស្រែងង់ទេទំង់ កំហឹង់ចាល់តែ ពាត់ទះ
ហោះដេរ ពោលពាក្យខ្លីខ្លា ។ កុំថាសេនី មួយពាន់ទោះបី ច្រើន
វៃក្រមហិមា លើសលែង់ទោះវិញ អង្គអញ់ជានា អាចអត់អស់ច្បា-
កដកុំថាម្ដេ ។ រីសេនីអញ តិចតែមួយមិញ តើប្អូនឧត្តម អាចអត់
ប្លុះទ មាសមេរ៉ៃរ- ពិង់ពិតដោយដំ- ណើរនោះចង់ជាត់ ។

(មានត)

ព្រះគ្រូញាណសំវរៈ ញាណ-ឈឺទ

(តទៅទំព័រ ៦)

ទោភណមេតំ អតុល នេតំ អច្ឆតាមិវ
ឯន្ទ្ធិ តុណ្ហីមាសីនំ ឯន្ទ្ធិ ពហុកាណិនំ
មិតភាណីបិ ឯន្ទ្ធិ ឧត្ថំ លោកេ អនិន្ទិតោ
ន ចាហុ ន ច កវិស្សតិ ន ចេតរហិ វិជ្ជតិ
ឯកន្តំ និន្ទិតោ ទោសោ ឯកន្តំ ក បសំសិតោ
យញ្ចេ វិញ្ញូ បសំសន្តិ អនុវិច្ច សុវេ សុវេ
អច្ឆិទ្ទវុត្តិំ(១) មេធាវឹ បញ្ញាសីលសមាហិតំ
និក្កំ ជម្ពោនទស្សេវ កោ តំ និន្ទិតុមរហតិ
ទេវាបិ នំ បសំសន្តិ ព្រហ្មុនាបិ បសំសិតោ ។

សេចក្តីថា: អតុលៈ និន្ទានឹងសរសើរនេះជារបស់មានមកហើយតាំងពីមុនណានាយម៉្លេះ និន្ទានឹងសរសើរនេះមិនមែនទើបតែនឹងមានកន្លងមកក្នុងថ្ងៃនេះទេ; ជនដំពូកខ្លះតិះដៀលអ្នកនៅស្ងៀមថាអើហ្ន៎! អ្នកនេះអង្គុយនៅតែស្ងៀមដូចមនុស្សគ ដូចមនុស្សថ្លង់ ដូចមនុស្សមិនដឹងអ្វីសោះ; ខ្លះតិះដៀលអ្នកនិយាយច្រើនថាអើហ្ន៎! អ្នកនេះនិយាយមិនចេះចប់ ច្រហែល

---

១ ប្បាឋខ្លះថា "អច្ឆិទ្ទវុត្តិំ" ក្នុងប្រែកំមានដែរ ។

ដូចជាឮសំលេងប្រហារស្នឹកត្នោតឮសូរច្បាប់ៗមុំរ; ខ្លះគិះដៀលអ្នកនិយាយ
តិចថា អើហ្ន៎! អ្នកនេះស្មានថាពាក្យសំដីរបស់ខ្លួនថ្លៃប្រហែលគ្នានឹង
មាសប្រាក់ ទើបនិយាយតែ ១ ម៉ាត់ ២ ម៉ាត់ក៏ស្ទើរមៅ; មនុស្សយើង
កន់លោកនេះដែលថាគេមិនគិះដៀលនោះមិនមានសោះឡើយ, ម្យ៉ាងទៀត
មនុស្សដែលគេនិន្ទាតែ ១ ចំណែកសុទ្ធ ឬដែលគេសរសើរតែ ១
ចំណែកសុទ្ធ មិនមែនមានហើយតែក្នុងអតីតមិនមែននឹងមានតែក្នុងអនា-
គត មិនមែនទើបតែនឹងមានក្នុងបច្ចុប្បន្ននេះទេ ។

ឯចំណែកបណ្ឌិតវិញ លោកតែងពិចារណាឮៗ ថ្លឹងស្គាល់
ច្បាស់នូវពាក្យនិន្ទានឹងពាក្យសរសើរ ហើយទើបលោកសរសើរនូវគ្នុ
ណាដែលជាអ្នកប្រតិបត្តិមិនជាប់ ព្រោះខ្លាចខ្លួនក្នុងសិក្ខាបទ ក្នុងកិច្ច
ចិញ្ចឹមជីវិតផង ជាអ្នកមានបញ្ញាព្រោះបរិបូណ៌ដោយបញ្ញាដែលកើត
តាមផ្លូវធម៌[1](ផង) ជាអ្នកនឹងនូនក្នុងសីលនឹងបញ្ញា ព្រោះបរិបូណ៌ដោយ
លោកិយបញ្ញា នឹងលោកុត្តរបញ្ញាផង; ដោយចតុប្បារិសុទ្ធិសីលផង,
អ្នកណាមួយនឹងគិះដៀលនូវគ្នុកនោះ ដូចមនុស្សអ្នកគិះដៀលនូវមាស
ជម្ពូនទ[2] ដែលគេដំដុសខាត់ហើយ ជាមាសឥតមានមន្ទិលដូច្នោះបាន
សូម្បីទេវតានឹងមនុស្សជាបណ្ឌិតចាំឆ្លាយក៏គន់សរសើរនូវគ្នុកនោះដែរ

---

១ ឆ្លូវ ២ យ៉ាងគឺតគឺលោក ១ គតិធម៌ ១ ក្នុងទីនេះសំដៅយកប្រាជ្ញាដែលចេះដឹងតាមធម៌
អាចផ្តាច់ផ្តាលសឹកសត្រូវគឺកិលេសបាន (មតិ) ។ ២ មាសដែលកើតមកអំពីផ្លែត្រឹង ឬដើម
ត្រឹង (អភិធាន) ។

មិនមែនត្រឹមតែទេវតានឹងមនុស្សប៉ុណ្ណោះ ទាំងមហាព្រហ្មក៏ម៉ឺនចក្រវាឡក៏តង់សរសើរដែរ ។

លុះព្រះកតវន្តមុនីទ្រង់ត្រាស់ភាសិតនេះចប់ហើយ ទើបឧបាសកចំនួន ៥០០ នាក់ មានអគុលឧបាសកជាដើមនោះ (បានស្តាប់ហើយ) ក៏បានតាំងនៅក្នុងគុណតីសោតាបត្តិផលទាំងអស់គ្នា (កន្លះកាលនោះឯង) ។

ចប់រឿងអគុលឧបាសកតែប៉ុណ្ណោះ ។

ធម្មបទ យមកវគ្គ

៣ រឿងព្រះនន្ទ (សំដៅឯសេចក្តីសរសើរ)

សេចក្តីដំណាលថា: កាលនៅក្នុងបឋមពោធិកាលគឺកាលដែលព្រះពុទ្ធអគ្គទើបនឹងបានត្រាស់ដឹងថ្មីៗ ក្នុងលោក ។

សម័យមួយទ្រង់ពុទ្ធដំណើរចូលទៅក្នុងក្រុងកបិលពស្តុ ទ្រង់បានបំបួសសក្យត្រកូលពីរអង្គគឺព្រះនន្ទ១ ១ ព្រះរាហុល ១; លុះទ្រង់ប្រថាប់នៅក្នុងក្រុងនោះតាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ទើបទ្រង់គមនាការត្រឡប់មកកាន់ក្រុងសាវត្ថីវិញ សម្រេចឥរិយាបថទៅក្នុងក្រុងនោះ ។

ឯចំណែកនន្ទកុមារក៏តាំងធ្វើព្យាយាមចំរើនសមាធិធម៌ ដរាបដល់បានសម្រេចព្រះអរហត្តផលបានជាអរហន្តអគ្គ ១ ដែរ, ទើបលោកចូលទៅគាល់ព្រះសុគតជាម្ចាស់ ហើយក្រាបបង្គំទូលតាមរឿងដើមត្រង់ប្រការ ។

ព្រះលោកនាថជាម្ចាស់ បានទ្រង់ព្រះសណ្តាប់ពាក្យព្រះធម្មវត្តា
នោះហើយ ទើបទ្រង់មានភ្នក្ខតម្រាស់ថា តថាគតក៏បានដឹងហើយដែរ
តំណទេវតាតំណខ្លាយក៏នាំសេចក្តីនោះមកប្តឹងតថាគតទៀតថា "អា-
យស្មា ភន្តេ ធម្មោ អាសភំ ឧយ្យា អជាសរំ ចេតោ-
វិមុត្តិ បញ្ញាវិមុត្តិ និដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា
ឧទេសសម័យ តាមរបៀបទំទៀមទម្ងាប់ ទីធ៌តាមសេចក្តីត្រូវការរបស់ជន
ជាតិនោះដែលត្រូវផ្លាស់ប្តូរដោយប្រការ ដែលក្នុងឲ្យរបញ្ញត្តិសម្រាប់សាសនា
នោះមានរបៀបផ្សេងគ្នាអំពីរបញ្ញត្តិ
របស់ពួកយកព័ស ។

របញ្ញត្តិដែលកើតឡើងនោះគឺស្រយៅសេចក្តីបែកខ្ញែកផ្សេងគ្នាជួនច្រើ
ចំនោះសាសនាគ្រិស្តមានអ្នកយកចិត្តទុកដាក់យូរយារមកហើយ តាល់តែ
មានតម្រាតែងឡើងជារឿយច្រើនបញ្ជាប់ ។ ចំណែកឯព្រះពុទ្ធសាសនាតាម
ដែលខ្ញុំបានដឹង នៅមិនសូវមានអ្នកណាយកចិត្តទុកដាក់ណាស់ សូម្បី
ក្នុងប្រទេសថៃនីដែរ ប្រទេសផ្សេង ដែលកាន់ព្រះពុទ្ធសាសនា ក៏នៅ
មិនទាន់មានតម្រាពិនិត្យនៃប្លែយបញ្ហាថែមទេនេះដែរ ដូច្នេះបើហេតុជា
ព្រោះហេតុថា អ្នកនិតិសាស្ត្រថែកយកព័សខ្លះថា ជាបញ្ហាដែលបាត់
តាមដោយព្រះវិន័យ, ចំណែកខាងព្រះសង្ឃក៏គាន់ថា ជាបញ្ហាដែលបាត់
តាមដោយបញ្ជាប់ស្រុក, ទាំងសង្ឃខាងខើបព្រះធីយកន្តើយមិនសិក្ខា
សេចក្តីពិត ឃើញថា បញ្ហាព្រះវិន័យនីដ៏ស្រុកទេសរមែងបាត់តាមគ្នា

ជាធម្មតា ភាល់តែញែកចេញពីគ្នាមិនបាន, ហេតុនេះអ្នកនិតិសាស្ត្រ
ចាំនឹងព្រះសង្ឃ ចាំនឹងយកគ្រប់សព្វយកចិត្តទុកដាក់ខ្លាំងនឹងជួយគ្នាតិចារណា
ព្រោះជាបញ្ហាដ៏សំខាន់គ្រប់ច្រកគារ ហើយជាបញ្ហាដែលរៀបរៀងមិន
បានត្រូវតែច្បាស់ច្បាង់ បើមិនថ្លែមួយក៏ថ្លែមួយ ហេតុនោះគួរពុទ្ធសាសនិក
ជនចាំនឹងរៀបរួយខ្លួយកមកពិចារណារៀបរួយល្អិតល្អន់ ដើម្បីស្វែងរក
ពាក្យវិនិច្ឆ័យ ដ៏ជាប់ដោយសេចក្តីប្រកបធម៌ គឺការពារមិនឲ្យគេតាសេចក្តី
ឆ្លាស្វែងដល់ព្រះពុទ្ធសាសនា ទំនឹងព្រះពាជអាណាចក្រ ។

ក្នុងការពិចារណានឹងរកពាក្យវិនិច្ឆ័យនេះ យើងគប្បានសេចក្តី
ដំរួយអំពីច្បាប់ត្តិសាស្ត្រ ទំនឹងការបដិបត្តិកន្លែងប្រទេសដ៏តទាន់ដែលពាក់ព័ន
ព្រះពុទ្ធសាសនាផងគ្នា គឺយើងគប្បីដឹងថា កន្លែងសម័យពុទ្ធកាល, កន្លែង
ប្រទេសឥណ្ឌាគេបានដោះស្រាយបញ្ហានេះដូចម្តេច ហើយកន្លែងសម័យ
ប៉ុណ្ណាកន្លែងប្រទេសថៃ មន ភូមា ខ្មែរ លាវ ជាដបដិបត្តិមតយ៉ាងណា
ជាគួរយ៉ាង ឲ្យយើងវិនិច្ឆ័យដ៏សមគួរដល់ប្រទេសទំនឹងសម័យ, ដើម្បីនឹង
ឲ្យលោក-អ្នកយល់រឿងនេះដោយល្អិតល្អន់ ខ្ញុំសូមលើកបញ្ហា ១ ១ មក
ពិគ្រោះផង តាមវិធីដែលខ្ញុំពោលមក គឺតាំងបញ្ហាឡើងថា : កាលបុរស
មានភរិយាហើយទៅបួសជាកិត្តកន្លែងព្រះពុទ្ធសាសនា តើការសម្ពន្ធនៃ

ស្វាមីភរិយានោះជានៅជាប់តទៅ ឬជាច់ចាកសម្ពន្ធជាស្វាមីភរិយាហើយ?

ឬគួរជាដូចម្តេចទៅវិញ ? ។

តាមបញ្ហានេះគួរសង្កេតថា តាមព្រះវិន័យមិនបញ្ញត្តិ ឬណែនាំឲ្យយើញថា គួរវិនិច្ឆ័យយ៉ាងណាទេ! បុគ្គលដែលមានសទ្ធាកង់ព្រះពុទ្ធសាសនា ខ្លាចបរិសុទ្ធដើម្បីបំភេញសមណធម៌នោះ ត្រូវលះចោលសម្បត្តិចេញទាំងអស់ខ្លួនលះកាយោគ្គវៈបុត្រចេញ តែមិនបានបង្គាប់ថាត្រូវលះចោលទ្រព្យសម្បត្តិនោះ។ ចោលចេញជាមុនសិន ខ្លួនលែងលះផ្តាច់ចំណងចាកកាយោគ្គវៈជាស្វាមីកាយោគ្គជាមុនសិន ទើបទទួលឲ្យបរិសុទ្ធបានក៏ទេដែរ ព្រោះជាមុខងារបស់ចៅបង្គាប់សម្រាប់ស្រុកដែលត្រូវមាន។ បង្គាប់ ។បង្គាប់នេះទើបអាចនឹងប្រែប្រួលទៅតាមទំនៀមទំនៀមរបស់ប្រទេសនីមួយៗសម័យ ដូចយ៉ាងគាន់ថា ការបួសនេះជាហេតុធ្វើឲ្យចំណងនៃស្វាមីកាយោចប់ចុះ ឬជាហេតុឲ្យលែងលះគ្នាបាន, តែគេអាចគាន់ថា ការបួសគ្រាន់តែជាការលះកាយោ សង្ឃធម្មតាមិនជាហេតុឲ្យការសម្ព័ន្ធចប់ចុះឡើយ គ្រាន់តែបើកឱកាសឲ្យកាយោសុំលែងលះបាន ក្នុងវេលាដែលស្វាមីចុះបង់ចោលយូរហួសកំណត់ បង្គាប់ម្ខាប់ទោះបីដូចម្តេចក៏ដោយ ក៏មិនចំរើនដល់ព្រះពុទ្ធបញ្ញត្តិកង់ព្រះវិន័យ, បុគ្គលដែលបួសជាភិក្ខុអាចនៅកង់សិក្ខាបទបដិបត្តិតាមព្រះវិន័យតទៅ; សូម្បីកាយោដែលលែងលះហើយ ចំណែកខាងស្រុកទេសនៅគាន់ថាជាកាយោ ពាំងហាមមិនឲ្យមានប្តីថ្មីទៀតបាន តែកាលមកពីត្រឹមមើលដោយល្អិតសព្វគ្រប់ហើយ បង្គាប់មិនល្អដល់ម្ល៉ោះទេ គឺមានបទដែលផ្ទុយគ្នានឹងសេចក្តី

ចំណែកក្នុងព្រះវិន័យវិតម្ពង់ សូម្បីមានបទដល់ទៅខំនាស់គ្នាក៏ពិតមែន តែមិនបានអើពើទូវការបដិបត្តិផ្លូវព្រះវិន័យក្នុងប្រការខ្លះ ដូចដែលបានឃើញតាមច្បាប់ ឬតាមប្រពៃណីផ្សេង ។ ដែលមានទៅក្នុងប្រទេសដែលកាន់ព្រះពុទ្ធសាសនា តាំងអំពីសម័យបុរាណរហូតដល់សម័យបច្ចុប្បន្ន ។

ក្នុងប្រទេសឥណ្ឌាគ្រាពុទ្ធកាល បញ្ហាដែលកំពុងវិនិច្ឆ័យនេះមិនគួរបើមានកើតឡើង ព្រោះក្នុងប្រទេសឥណ្ឌាការអាពាហ៍ពិពាហ៍មិនចេះចប់ចុះ, មិនមានការលែងលះឲ្យស្រីដែលរៀបការហើយមានស្វាមីថ្មីទៀតបាន ហេតុនោះស្វាមីគ្រាន់តែបួសជាបព្វជិតក្នុងព្រះពុទ្ធសាសនា ក៏គង់នៅជាស្វាមីការយោគទៅដោយពិត, ពិតមែនតែថា ច្បាប់ឥណ្ឌាអនុញ្ញាតឲ្យស្រីដែលស្វាមីទៅបួសជាឫសី ក្នុងលទ្ធិសាសនាព្រាហ្មណ៍យកប្តីប្រុសជាខៃទៀតបាន ដោយមានហេតុដ៏ប្រហែលគ្នាទំនងការជាស្វាមីការយោតាមច្បាប់, តែជាទីសង្ស័យថា ច្បាប់នេះប្រែពិតយ៉ាងហូរហួតដល់ការបួសជាភិក្ខុក្នុងព្រះពុទ្ធសាសនាឬទេ ? ព្រោះការបួសជាឫសីនឹងជាភិក្ខុនោះខុសគ្នាឆ្ងាយ, ហេតុឬគ្លកាលបួសជាឫសីហើយ មិនអាចត្រឡប់មកជាគហបតិវិញបាន តែគង់តាំសីលទៅក្នុងវត្តអស់ជីវិតប្រសិនបើឫសីនោះលើកលែងតាំសីល ហើយត្រឡប់មកនៅត្រកូលផ្ទះវិញ. ច្បាប់ឥណ្ឌាបង្គាប់ឲ្យធ្វើទោសយ៉ាងខ្លាំង ហើយមិនព្រមឲ្យ

ត្រឡប់មកជាគហបតីដូចដើមវិញ: តែចំណែកខាងព្រះពុទ្ធសាសនា ការ
បួសជាបព្វជិតនោះ មិនរាត្រូតឡើយ តាំងត្រឹងសំពត់កាសាវៈស្ទួរហួតជាវែក
ទេ អ្នកបួសមានសិទ្ធិនឹងសឹកបានជាដរាប ព្រោះតាមព្រះពុទ្ធសាសនា
ការបួសគ្រាន់តែបើកឧកាសឲ្យអ្នកបួសបានប្រទះឃើញតាវ្យធម៌ ហើយ
នឹងទទួលផលនៃកុសលកម្មដែលបានសាងសន្សំមកអំពីមុន អ្នកដែល
មានអភិនិហារបារមីច្រើន កាលបួសហើយក៏អាចនៅរហូតជាវែងទៅបាន
តាំងអាចបានទទួលផលរំលត់កិលេស រួចចាកសង្សារទុក្ខបានក្នុងជាតិ
នោះតែម្តង, តែបើអ្នកមានក់សនាបារមីតិចនៅអាល័យក្នុងត្រៃភពសម្បត្តិក្នុង
លោកនេះ ក៏សឹកចេញជាឃរាវាសបាន តែបានទទួលផលតិចតាម
យថាកម្មរបស់ខ្លួន, ការបួសក្នុងសាសនាព្រាហ្មណ៍ឬក្នុងសាសនាតិស្ស,
អ្នកបួសតាំងនៅបំពេញសមណធម៌ដរាបដល់អាយុក្សីយ ។

អ្នកនិតិសាស្ត្រពួកឥណ្ឌូរមែនដឹងថា ការបួសជាសង្ឃក្នុងព្រះពុទ្ធ-
សាសនាផ្សេងគ្នាអំពីការបួសជាឫសីតាមលទ្ធិសាសនាព្រាហ្មណ៍ ទើប
តួរសន្និដ្ឋានថា មិនបានតាំងយកច្បាប់ដែលចាត់ចាមដោយការបួសជា
ឫសីឥតប្រែប្រួលដូចតែងអ្នកបួសជាភិក្ខុដោយផ្លូវតែទុំលោមទេ តែងតម្កើរព្រះ
ត្រៃបិដកនឹងអដ្ឋកថាមានរឿងផ្សេង ។ ជាពិសេសរឿងដែលជាឧបករណ៍
ដ៏ល្អដែលសេចក្តីនិច្ចយនេះបានយ៉ាងល្អ ដូចយ៉ាងក្នុងអដ្ឋកថាវិនយវិភង្គ
ក្នុងខុទ្ទកវត្ថុនិទានដល់ឧបាលិវត្ថុផង ។ ដែលកាលយាសរបស់តថាគតក្តី

មកជាញយៗ ដើម្បីឲ្យស្វាមីសឹកមកចំញឹមខ្លួនគេ ដូចយ៉ាងតរ៉ាយ
របស់ព្រះបុណ្ណមាស កាលបុត្រស្លាប់ទៅហើយ គឺមកអង្វរសាមីឲ្យ
ទៅនៅជាមួយគ្នាដូចដើមវិញដោយពែ្រងថា បើគ្មានបុត្រហើយទ្រព្យ
សម្បត្តិនឹងធ្លាក់ទៅជារបស់ព្រះមហាក្សត្រ ។ តរ៉ាយព្រះបុណ្ណកាល
មានបិត្តក្លាហានជាងនេះទៅទៀត ឃុនធ្វើចុងយទំមន្តព្រះសាស្តាមក
ឯផ្ទះខ្លួន ។ ណ៎ាៈស្វាមីមកផ្ទះដើម្បីត្រួតមើលការក្រាលអាសនៈ សម្រាប់
ទទួលព្រះសាស្តាក៏នាំគ្នាមកចាប់ស្វាមីសម្រាតចីវរចេញ ឲ្យសឹកមួយ
រំពេច, តាមគួយ៉ាងអំចាលនេះចង្អុលឲ្យឃើញថា តរ៉ាយរបស់តិក្ខុបាន
ធ្វើចុងយកលទ្ធផ្សេងៗ ដើម្បីឲ្យស្វាមីសឹកមកវិញ តែមិនមានគួយ៉ាងដែល
តរ៉ាយយកស្វាមីថ្មីទៀត តាមតម្លាវិតង្គ ពោលដល់តិក្ខុដែលទៅមាន
ភរិយាទ្រព្យសម្បត្តិនឹងតរ៉ាយ ហើយប្រៀបធៀបថា

"បជាបតិ មេ អត្ថិ សា មយា ទោសេតព្វា អ-
ត្ថិ នេះទៅមានតរ៉ាយដែលត្រូវបង្ខាំចំញឹម" ។ នេះសឲ្យឃើញច្បាស់
ថា សូម្បីបានទទួលទុបសម្បទាហើយក្តីក៏នៅតាំងថា តាសមុទ្ទផ្ទះ
ស្វាមីតរ៉ាយនោះពុំទាន់ផុតទ្រព្យឡើយ ; ព្រះខន្ធនោះក៏ដូច្នេះដែរ តាល
បួសហើយទៅតែងដល់តរ៉ាយជាខ្លាំង ទាល់តែព្រះបរមសាស្តាធ្វើចុងយ
បង្ហាញឲ្យឃើញស្រីសួតិ ដែលមានរូបឆោមល្អជាងតរ៉ាយខ្លួន ទើប
បន្ទោះសេចក្តីអាល័យកង់តរ៉ាយរបស់ខ្លួនទៅបាន តាមរឿងកង់តម្ពរ

យើញថាបាន ភរិយាបស់តិក្ខុនៅវត្តចាស្វាមីដែលបួសជាទីបួ ដូច
យ៉ាងព្រះចិត្តហត្ថបួស ៦ ដង សឹក ៦ ដងក៏នៅតែត្រឡប់ទៅយើញភរិយា
ក្នុងគេងរបស់ខ្លួននៅវត្តចាំកន្លងផុតកល់ ៦ ដង ៧ ១ ទៀតតាមក្នុងគម្ពីរមិនបាន
ហៅភរិយារបស់តិក្ខុថាភរិយាថាស់ តែហៅថា បុព្វណទុតិយិកា
ប្រែថា ស្រីដែលធ្លាប់នៅជាគូគ្នាអំពីមុន ដែលតាំងឈ្មោះដោយទំនៀម
ដូច្នេះ ក៏ព្រោះសេចក្តីពិត នៅមានឈ្មោះជាភរិយាតាមបញ្ជាប់ខ្លួនវិញ
តាន់តែមិនបាននៅរួមសំវាសប៉ុណ្ណោះ ហេតុនោះនឹងហៅថា "បុព្វណ
ភរិយា" មិនបាន តោងប្រែពាក្យ ១ យ៉ាងដែលសំដៅដល់ការនៅ គឺ
ការដែលមិនបាននៅរួមគ្នា ។ ប្រការ ១ ទៀត តាមក្នុងគម្ពីរនឹងយើញ
បានថា ព្រះពុទ្ធអង្គមិនបានហាមតិក្ខុមិនឲ្យជួបនឹងភរិយាតែម្តង តាន់តែ
ហាមមិនឲ្យសេពមេថុនធម្មជួបគ្នានឹងស្ត្រីដទៃ ស្រីដែលមានចិត្តល្អ តាម
រឿងផ្សេង ។ ក្នុងគម្ពីរមិនជាឧបសគ្គដល់សទ្ធាបស់ស្វាមី មានគួយ៉ាងដ៏
សំខាន់ គឺកញ្ញាកបិលានីថេរី ភរិយាបស់ព្រះមហាកស្សបជាដើម បើមិន
ដល់ទៅបួសជាភិក្ខុនី ក៏គង់ជាឧបាសិកាកាន់សីល ធ្វើបុណ្យកុសល
យ៉ាងយកពាក់សាច់ឆ្អឹង ជាអ្នកឧបដ្ឋាកស្វាមី ចាត់ចែងរកអាហារបម្រុងឲ្យ
ទុកបែរគេងស្វាមី ក្នុងវេលាដែលមកបិណ្ឌបាត តាមរឿងព្រះថេរៈ ១
អង្គសឹងមានពោលក្នុងអដ្ឋកថាធម្មបទ សឹងត្រូវព្រះសាស្តាទ្រង់ដំទៀល
ក៏ព្រោះតិក្ខុថាស់ខោះ សំដែងអាការគាត់ចង់នឹងភរិយាហួសពេកទៅ

តែក៏មិនបានទ្រង់តេះដៀល ការដែលភរិយាជាអ្នកឧបដ្ឋាកកិច្ចជាស្វាមី ទើបជាអ្នកជួយឲ្យស្វាមីបានផលពេញតាមវាសនា ។ ច្បាប់ប្រពៃណីឥណ្ឌូ មិនបើកឱ្យភរិយា ដែលស្វាមីលែងលះដើម្បីទៅបួសនោះ យកស្វាមីថ្មី ទៀត ហេតុនោះបើភរិយាជាអ្នកមានសទ្ធា រមែងចងដៃតគ្នាផ្លូវជាមិត្តរបស់ស្វាមីជាដរាប តែបើភរិយាព្រងើយតន្តើយ ក៏គ្មានផ្លូវដទៃក្រៅអំពីនៅរង់ចាំទំពាំប៉ិសឹកមក, ចំណែកស្វាមីអ្នកបួសជាកិក្ខុ ទើបមានឧកាសពិសោធកុសលសទ្ធារបស់ខ្លួនថា ទន្ទឹងបួសរហូតទៅឬសឹកមកវិញ? តាមតំណាងចិត្តស្ងប់របស់ខ្លួន ដោយមិនចាប់ត្រែងភរិយាឥតត្បត់ទៅមានស្វាមីថ្មី បើមានសេចក្តីគាល់ឃ្លាំងកើតទៀងក៏សឹកមក តង់មានផ្លូវ-ភរិយា-បុត្រតាដើមស្រាប់ ។

តែកាលតុទ្ធសាសនាចំរើនផ្សាយទៅកន្លងនានាប្រទេស មានប្រទេសក្នុងកន្លែងប្រទេសថៃជាដើម ការនេះបានប្រព្រឹត្តទៅដូចទំនៀមកន្លែងប្រទេសឥណ្ឌូនោះក៏ទេ ព្រោះតាមទំនៀមដើមការគោរពហ៊ាតិពាហ៍កន្លែងប្រទេសនោះមិនខ្ជាប់ខ្ជួនដូចប្រទេសឥណ្ឌូ ស្វាមីភរិយាមានសិទ្ធិនឹងលែងលះគ្នាបាន ហើយបើស្វាមីមិនចង់ញ៉ឹមភរិយា មិនទៅមករកគ្នាកន្លងវេលាដែលកំណត់ទុកតាមទំនៀមការខ្ចាត់ថា មិនជាស្វាមីភរិយាគ្នាទៅទៀត, ភរិយាមានសិទ្ធិរកស្វាមីថ្មីទៀតបាន ហេតុនោះការស្វាមីបួស

ជាបព្វជិតហើយ តង់មានបញ្ហាជាគ្រាដំបូងថា នៅជាស្វាមីភរិយាគ្នាគេទៀតទេ។ នេះជាបញ្ហាដ៏ស្មុគស្មាញ ព្រោះខាងព្រះពុទ្ធសាសនា ទំនងខាងខំនៀមទម្លាប់ស្រុកទេសអំពីដើម ដើរវេរបៀចខ្សត្ត តែខាងព្រះពុទ្ធសាសនា គួរឲ្យគារវស្មគ្គនោះនៅដូចដើមតទៅ ព្រោះនៅមិនទាន់ដឹងជាច្បាកដថា អ្នកបួសជាបព្វជិតនោះគាបបៃព័ត្តព្រហ្មចរិយទៅបានយូរត្រឹមណា ហើយបើជាគាន់ថា ការបួសនោះខុកដូចជាការលែងលះ ក៏ជាការខុបសគ្គសុញគំនិតដល់អ្នកមានសទ្ធាតាំងច្បាយ ព្រោះស្វាមីរមែងមានសេចក្តីអាល័យក្នុងតរិយា បើត្រូវបង់តរិយាតាំងអំពីដំបូងដែលចេញបួសនោះតែម្តង តង់ជាមានមនុស្សជាច្រើននាក់ដែលអល់អែកមិនស្ទើគ្រចេញបួស កាលបើដូច្នេះអ្នកនោះ។ តង់មិនមានឧកាសបចេះអរិយធម៌ហូតជីវិតរបស់ខ្លួន ចំណែកឯខំនៀមទម្លាប់ក៏ទៀតងងឹតដូចដែ ១ យ៉ាងសឹងផ្ទុយគ្នាតែម្តង ឃើញថា កាលស្វាមីបួសហើយហាក់ដូចជាស្វាមីបោះបង់ចោលមិនចិញ្ចឹមតទៅ ហើយតរិយារមែងមានសិទ្ធិនឹងរកស្វាមីថ្មីតបាន នឹងបង្កាប់ឲ្យតរិយារង់ចាំស្វាមីក៏ជាការខំនាស់នឹងខំនៀមទម្លាប់ដែលតាន់មកតាំងពីបុពណាកាល ។

កាលសាសនានឹងខំនៀមទម្លាប់ដើរវេរបៀចខ្សត្តដូច្នេះ ក៏តម្រូវនឹងរកតាក្សមកនិច្ឆ័យឲ្យជាទំយុត្តិធម៌ត្រូវតាមលំអានតាំងពីផ្លូវ ដូចជាកដកថ្នក់ប្រវត្តិសាស្ត្រច្បាប់កងប្រទេសកូមានឹងប្រទេសថៃ ។ (មានត)

ឯកភាគនៃមិលិន្ទបញ្ហា

ដែលហៅថា "ឯកភាគមិលិន្ទបញ្ហា" នេះ គ្រោះជាចំណែក ផ្នែក ១ ក្នុងគម្ពីរមិលិន្ទបញ្ហារាជ៍ចុង មិនទាន់មានលោក-អ្នកឯណា ប្រែចោះពុម្ពផ្សាយជាភាសាខ្មែរនៅឡើយទេ ។ ប៉ុន្តែសេចក្តីស្រង់ទើប ប្រែចេញមកនេះ មិនបានប្រែតាមច្បាប់ចាស់ដើមទាំងមូលទេ បានតាត់ចោលពាក្យបុច្ឆា-វិស្សជ្ជនា ទើសេចក្តីផ្សេង។ ទៀតជាច្រើន ស្រង់យកតែត្រង់ៗបមានុបមេយ្យដែលចាត់ជាអង្គ។ តាំងពីមានអង្គ ១ ជាដើមទៅ ហើយប្រែរៀបរៀងជាសេចក្តីខ្លី។ ងាយយល់ងាយស្តាប់ សម្រាប់ជាផ្លូវប្រតិបត្តិរបស់សាធុជនទាំងឡាយ ។

ឯគម្ពីរមិលិន្ទបញ្ហា ដែលព្រះសង្ឃព្រះទុគ្គមមុនីជាអ្នកប្រែរៀបរៀងហើយព្រះពុទ្ធឃោសាចារ្យបានចាត់ចែងចោះពុម្ពផ្សាយ ជាវេលាយូរមកហើយនោះ មាន ២ ភាគ គឺភាគទី ១ ទើភាគទី ២ ត្រឹមប៉ុណ្ណោះមិនទាន់ចប់សព្វគ្រប់ទេ នៅមានសេចក្តីពិស្តារវែងឆ្ងាយគួរទៀតជាច្រើន ប្រហែលជា ៤-៥ ភាគទៀត ទើចប់សព្វគ្រប់តាមច្បាប់ចាស់ដើមដម្បី លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ តំពូនឲ្យចាត់ចែងប្រែទើរៀបរៀងឲ្យគ្រាតែចប់សព្វគ្រប់ ហើយគ្រសួងពុទ្ធសាសនបណ្ឌិត្យ ទើងចាប់ផ្តើមឲ្យចោះពុម្ពតាសេចក្តីពីភាគនោះតរៀងទៅទាល់តែចប់តាមច្បាប់ចាស់ដើម ។

ក្នុងទីបំផុតនេះ យើងមានសង្ឃឹមថា ការស្រង់យកអត្ថរបស់វត្ថុ
ឬសព្ទនានា មកប្រៀបធៀបនឹងអ្នកប្រតិបត្តិកន្លងព្រះពុទ្ធសាសនា ដើម្បី
ឲ្យជាយុយល់សេចក្តីនៃអាថ៌ធម៌នោះ ។ ទីឯមានប្រយោជន៍ដល់អ្នកសិក្សា
ទីឯអ្នកប្រតិបត្តិតាមបញ្ញាប់ធម៌របស់ព្រះពុទ្ធសាសនានេះឯងមិនខាន ។

ឃុនឧត្តមធម្មទ្វី ញ៉ុក-ថែម
បណ្ឌិត នៅពុទ្ធសាសនបណ្ឌិត្យ

ភ្លុកមានអង្គ ១

អង្គ ១ របស់សត្វលាៈ

មិនចេះរើសដំណោក តង់ណា ក៏ដេកបាន ហើយដេកមិនយូរពេក មិនច្រើនពេក ។

សេចក្តីនេះ ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយសេចក្តីព្យាយាម មិនរើសដំណោក មានព្យាយាមមិនប្រមាទក្នុងឈានទាំង ៤ គឺព្យាយាមមិនឲ្យចាបកើតឡើងក្នុងសន្តាន ១ ព្យាយាមលះបង់ចាបដែលកើតឡើងហើយ ១ ព្យាយាមធ្វើកុសលឲ្យកើតឡើងក្នុងសន្តាន ១ ព្យាយាមរក្សាកុសលដែលកើតឡើងហើយ មិនឲ្យសាបសូន្យទៅវិញ ១ ។

អង្គ ១ របស់កង្កែបៈ

កាលបើមានសត្រូវចូលមកជិត ក៏ភាន់កន្ទុយឲ្យធំឡើង តស៊ូសត្រូវនឹងកន្ទុយនោះ មិនថយតែគេចចេញ ។

ប្រៀបដូចអ្នកប្រតិបត្តិ កាលកិលេសកើតឡើង ក៏តប្បីចំរើនសតិប្បដ្ឋានទាំង ៤ តស៊ូច្បាំងនឹងកិលេសទាំងពួងដោយសតិប្បដ្ឋានទាំង ៤ ដូចកន្ទុយកង្កែបដូច្នោះ ។

អង្គ ១ របស់ខ្លាញី:

មានវិជ្ជូគោរតែម្តង ហើយមិនចូលទៅជិតគួរឈ្មោលតទៅទៀត ។

ប្រៀបដូចអ្នកប្រតិបត្តិ សំឡឹងមើលឃើញចុតិបដិសន្ធិ តិការឈ្មុត ទៅចាប់បដិសន្ធិថ្មីទៀត ជាដំណើរគួរខ្លាច ព្រោះប្រកួតប្រជែងទៅដោយទុក្ខវេទនាយ៉ាងពន្លឹក មានស្មុខត្រឹម ១ ដង្ហើម តោងពុក្ខជាវេលាយូរ តោងវិលវល់ដោយជាតិ ជរា ព្យាធិ មរណៈមិនចេះចប់ ទើបកងចាលមិនចង់ជួបប្រសព្វ តាំងចិត្តបំពេញយោនិសោមនសិការៈធ្វើទុកក្នុងចិត្តដោយទុច្ចរិយជ្ញា ថានឹងមិនចាប់បដិសន្ធិក្នុងកំពង់ថ្នតទៅទៀត ។

អង្គ ១ របស់ប្រុ:

អនុលោមទៅតាមផ្លូវមាត់ដែលគេទុំ សូរមិនបែកខ្ចាត់ខ្ចាយទៅទិឯទៀត ។

ប្រៀបដូចជាបុគ្គលដែលអនុលោមតាមនវង្គសត្ថុសាសនា ដែលសម្តែចព្រះសម្មាសម្ពុទ្ធជាម្ចាស់ ចានសំដែងទុកល្អហើយ ដំកល់ទុកនៅក្នុងកម្មមិនមានទោស ស្ងែរកែតែសមណធម្មប៉ុណ្ណោះ ។

អង្គ ១ របស់ឃ្មោក:

ធម្មតាឃ្មោកមែងចោះដៃទៅតោងស្មៅ ឈើស្ងួតឬស្រស់ហើយអារឡើងលើវត្ថុនោះ។ ចំរើនលួតលាស់ល្អ ។

ប្រៀបដូចអ្នកប្រតិបត្តិ ធ្វើទានធំធ្វើខ្លួនឲ្យបានចំរើនលួតលាស់ យ៉ាងនៃព្រះសង្ឃក្នុងព្រះអរហត្ត គប្បីតាំងចិត្តចាប់យកព្រះអរហត្តជាអារម្មណ៍ ឲ្យដូចជាវល្ល៍ឃ្លោកដែលមានដៃដូច្នោះ ។

អង្គ ១ របស់ជើមភ្លៅនាងៈ

ដុះឆក្ងក់នៅត្រគាមដី កាលមើចាស់ពេញទីហើយ ក៏ដុះដុះញែកបំបែកដីខ្ពើងមក ដល់ ១០០ ហត្ថក៏មាន ឬជាងនេះក៏មាន ។

ប្រៀបដូចអ្នកប្រតិបត្តិ ដែលស្វែងរកសាមញ្ញផល ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ ធំឯសមណធម៌ ក្នុងព្រៃស្ងាត់ដូច្នោះ ។

អង្គ ១ របស់សសរភ្ជោងៈ

តែងទ្រទ្រែងធំខុងនៅខ្សែរយោង រ៉ាកធំសន្ធឹកភ្ជោង ។

ប្រៀបដូចបុគ្គលប្រកបដោយសតិធំសម្បជញ្ញៈ ដឹងខ្លួនក្នុងខណៈធ្វើ ក្នុងខណៈនិយាយ ក្នុងខណៈតិតប្រចាំនៅជានិច្ច ដូច្នោះ ។

អង្គ ១ របស់អ្នកធ្វើការៈ

អ្នកធ្វើការដែលឆ្លៀតនោះ តែងគិតដូច្នេះថា អញធ្វើការគេដោយបំណងថ្លៃឈ្នួលឲ្យបានច្រើន អញមិនគួរខ្ជិលប្រអូស ធ្វេសប្រហែសការរបស់គេទេ គួរតែពិចារណាឲ្យគត់មត់ជាមុនសិនសឹមធ្វើ ទើបបានការយ៉ាងល្អ ។

ប្រៀបដូចអ្នកប្រតិបត្តិ ចំពោះការណាកាយវិវេកគេឡើង អំពី
ជាតុទាំង ៤ គឺដី ទឹក ភ្លើង ខ្យល់ ឲ្យរឿយ ។ ដោយសេចក្តីមិនប្រមាទ
មានស្មារតីខ្ជាប់ខ្ជួន រលឹកដឹងខ្លួន មានចិត្តខ្ជាប់ខ្ជួនជៀងជាត់ នៅក្នុង
អារម្មណ៍តែមួយ ក៏មិនធុតរបូតចាកកុំគួរទាំងឡាយទៅបាន ។

អង្គ ១ របស់កណ្តៀរ:

យកដីមកកសាងជំបូកតិចតួចលើ ស្រកខ្លួនតួននៅខាងក្រៅមិនស្មើ
រកអាហារមិនគ្រាន់គ្រា ។

ប្រៀបដូចអ្នកប្រតិបត្តិ ធ្វើសីលសំរេចតិចដូចជាជំបូកដាក្រឡឹង
កំបាំងកាយ បិទទ្វារតែចិត្តប្រុងស្មារតិចរង្គាត់ទៅ ក៏ទំនងធ្វេងធុតតិយាតិ
ភួងបាន ។

អង្គ ១ របស់កណ្តុរ:

កាលត្រែចរង្គាត់ទៅចំណាខ្លះមួយ តែងប៉ុនប៉ងស្វែងរកតែអាហារ
មួយយ៉ាងប៉ុណ្ណោះ ។

ប្រៀបដូចអ្នកប្រតិបត្តិ កាលត្រែចទៅកាន់ទីណាទីមួយ ក៏ប៉ុនប៉ង
ខ្ជាប់ខ្ជួនទៅតែរឿងយោនិសោមនសិការតែមួយ ទោះបីដើរមើលឆ្ងាយទៅ
ម្យ៉ាងទ្វេងខាងស្តាំ ក៏ផ្ចង់ចិត្តឲ្យខ្ជាប់នៅតែធម៌ដោយ១ចាយ ក្រែងតែ
ខាងប៉ុណ្ណោះ ។

(មានត)

កែពាក្យខុស

ក្នុងទស្សនាវដ្តី កម្ពុជសុរិយា លេខ ២ ខែកក្កដា ឆ្នាំ ១៩៦២ បន្ទាត់ ១៩ ត្រង់ឧយលក្ខណៈថា:

១. កម្ពុបុរី ឬយសោធរបុរៈ ជាទីក្រុងដែលព្រះបាទយសោវរ្ម័ន ទ្រង់សាងកាលពីឆ្នាំត្រីស័កពាជ ៩០០ (ខេបរិវេណជុំវិញ ១៤,៤០០ ម.) ។

សូមឲ្យកែជា

១. ដែលហៅថា ក្រុងយសោធរៈបុរៈ ឬកម្ពុបុរី (ក្រុងអង្គរធំចាស់) នោះព្រះបាទយសោវរ្ម័នទី ១ ទ្រង់សាងឡើងក្នុងសតវត្សរ៍ទី ១០ មានទំហំជុំវិញបរិវេណប្រមាណ ១៦ គីឡូម៉ែត្រ ។ ឯក្រុងជយបុរី (អង្គរធំថ្មីគឺអង្គរធំសព្វថ្ងៃនេះ) នោះព្រះបាទជយវរ្ម័នទី ៧ ទ្រង់កសាងឡើងខាងចុងសតវត្សរ៍ទី ១២ មានកំពែងព័ទ្ធជុំវិញប្រមាណ ១២ គីឡូម៉ែត្រ ទី ក្រុងនេះហើយដែល ចៀវ-តា-កួន បានឃើញក្នុងគ្រានោះ ។

អង្គុជសុទិយោ

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ចោះពុទ្ធផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថៃម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រែរក្ខិបញ្ញាលិង្កឹត ភៅ-សុំម អ្នាត្រួតត្រា
សិស្សនៅសោណបាលិងាន់ទុស់

បញ្ជីក្រឹង

ផ្នែកអក្សរសាស្ត្រ		ទំព័រ
កម្ពុជសុរិយា	អ្នឧពរឧទ្ទលដ្ឋាំថ្មីខ្មែរ	១៦៩
ព្រះសម្ពហ៌យោសាចារ្យ		
ឃួរ-ប៊ុណ្ណា	សុវណ្ណសាមជាតក ពាក្យកាព្យ	១៧០
លោក ហាន់-យេង	កំណួលចំសាត់ (តមក)	១៧៥
ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថៃម	ប្រឿងអង្គារ ក្នុងសតវត្សរ៍ទី ១៣ តាមសេចក្តីកត់ត្រារបស់អ្នកជំនាញរាជាតិច្ចនម្នាក់ (តមក).	១៨៩
ត្រូបត្រៀន ជាន-តេង	លោកធម្មត្ថចរិយា ពាក្យកាព្យ (តមកនឹងចប់).	១៩៦
ផ្នែកសាសនា		
ព្រះត្រៃបុរាញ្ញាណ សូរ-ហាយ. អ្នកនយកញ៉ា ទេពពិទូរ	បរិយាយសិប្បកថា	២០៩
ឈឹម-ក្រែមេ	ជាតកថា អំពីវិន័យនឹងក្បាប់ (តមកនឹងចប់).	២១៣

ឆ្នាំទី ១៦ — លេខ ៤ ខែអាវិល ១៩៦៤ — ដំណែរនាំ ១ ឆ្នាំ ១៥ រៀល ។

ស.រ.ខ. ១៨៩

KĂMPŬCHĔASŎRĬYA

Revue religieuse et littéraire éditée par l'Institut Bouddhique.
Rédacteur en chef de la partie littéraire: Luong Nibandhamantri Nhok-Thêm, Pandit à l'Institut Bouddhique.
Rédacteur en chef de la partie religieuse: Preah kru Pañnalikhito Kao-Sim, Surveillant général de l'Ecole Supérieure de Pāli.

TABLE DES MATIÈRES

Partie littéraire:

		Pages
Kămpŭchĕasŏrĭya . . .	Vieux du nouvel an cambodgien.	169
Vénérable Prĕah Samĭ-K'ósachar You-Penn..	Suvannasāmajātaka, poème. . . .	170
Monsieur Han-Yéng	Kămpul kămsăt, roman (suite)...	175
Luong nĭponmontrei Nhok-Thêm.	Angkor au 13e siècle d'après un voyageur chinois (suite).	189
Monsieur Ban-Téng	Lokadhammatthacariya, poème (suite et fin).	196

Partie religieuse:

Preah kru Suvaddhañāṇe So-Hay.	Pariyāyasippakathā	200
Oknha Tèppitur Krasém.	Pāthakathā (suite et fin) . . .	213

16e année — N° 4. Avril 1941 — Abonnement: un an 15$00

ផ្ទះពរ

ចូលឆ្នាំថ្មីខែត្រ

នៅទូរាសព្វាស់ឆ្នាំថាស់គឺឆ្នាំមមែបញ្ចស័ក ដើម្បីចូលឆ្នាំថ្មី គឺឆ្នាំវកធស័ក កំណត់នៅថ្ងៃព្រហស្បតិ៍ ៥ កេចខែចេត្រ ពុទ្ធសករាជ ២៤៨៦ ត្រូវនឹងថ្ងៃ ១៣ អាវិល ១៩៤៤ នេះ

កម្ពុជសុរិយា សូមជូនពរសព្វសាធុការជល់លោក-អ្នក មើលទស្សនាផ្ដែរចេស់យើងត្រមាំងទេមរជាតិកម្ពុជ សូមឲ្យនិកសយ្ហាតចាកទុក្ខសោកភេតភ័យគាំពួង ជួបប្រទះតែនឹងសេចក្ដីសុខក្សេមក្សាន្តត្រប់ទំព័កគ្រី ដោយអានុភាពព្រះរតន-ត្រ័យគឺ: ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ កុំបីឃ្លាតឡើយ ។

កម្ពុជសុរិយា

ព្រះសម្ពុទ្ធវង្សាចារ្យ យ្បូរ-ប៉ុណ្ណ (ពីន្ទសុរិយោ)

ក្នុងដំណើរព្រះវិនៃតបិដក នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

បទព្រហ្មគីតិ

ខ្ញុំសូមក្រាបបង្គំ ទូរបង្គំព្រះគតេនា ជាកែវដ៏ថ្លៃថ្លា ដោយសិរសានេះជាអាទិ៍ ។ គ្រានេះនឹងពណ៌នា ព្រះកេតុមាលុនាម៍ កាលខ្លះ
សោយព្រះជាតិ ទំរ៉ឹងឃ្លាតសាងកុសល ។ ទើបខ្លះគ្រាស់ដំណើរ ព្រះពុទ្ធសត្តាកុំឲ្យឆ្ងល់ កាលនៅមានកង្វល់ មិនជាន់ដល់ជាសាស្តា ។
ខ្លះគ្រាន់ព្រឹទ្ធចំពោះ គឺគុណោះអ្នកវគ្ស ទូរមាតាបិតា ដោយមេត្តាដ៏លើសលន់ ។ សរម្រែចនិយាយថ្លែ នៅកន្លែងវត្តផេតពន សំដែងនាំរឿងជន មានគុណធ្ងន់ជាអនេក ។ ម្ចាលគំកុំតាំងឡាយ ស្តាប់ចរិយាយដែលចំណែក មានប្លែកមួយយ៉ាងឯក បំរើប្លែកជាគន្លាវ្យ ។ កាលនោះគថាគត កើតរលត់កន្លងសង្ខ្យា ប្រែកបដោយសន្ធារ អស់ប្រយោរកប់មិនចាន ។ កើតកន្លែងកូលជាតិ ខាយនេះមានតាំងពីរប្លែក ជាប់មកតាមលំដាន ពីបុរាណចាស់ព្រៃនាយ ។ អតីតេកន្ធង់ហើយ តតិកុរើយយូរវែងឆ្ងាយ មានដែនមួយសម្បាយ ជនតាំងឡាយហៅកាសិ ។ មានន័យថាតព័ន្ធាក់ ចិត្តស្មោះស្ម័គ្រដោយមេត្តិ នៅជិត

ពាក្យណាស៊ី ញាតិប្រុសស្រីកាប់គាទគ្នា ។ គាស្រ័យនៅមាត់ស្ទឹង
ជាពំនឹងនៃអាត្មា បានប្តេជ្ញាគ្នាថា បើអ្នកណាមួយមានបុត្រ ។ ចោះ
ប្រុសឬមួយស្រី កុំគប្បីយើងឲ្យផុត ផ្សំដុំឲ្យបរិសុទ្ធ ធ្វើជាបុត្រ
យើងវិញគ្នា ។ នេសាទគ្រីយមានឈ្មោះ មិនវែងឆ្ងាយបានធីតា
ឲ្យឈ្មោះនាងចាវកោ ដូចច្បាប់ចិត្តប៉ុនប៉ង ។ នេសាទគ្រីយមានឈ្មោះ
បានសប្បាយតាមបំណង មានបុត្រមួយជាប្រុស ល្អកន្ទុំមានលក្ខណា ។
មាតាបិតានោះ បានឲ្យឈ្មោះបុត្រថា ខុកូលកុមារ ចិត្តស្នេហា
ពេញចំណង់ ។ សំឡាញ់ចាំងពីរនាក់ រៀបចុងជាប់ដោយដួងចិត្តផ្ងន់
ខ្លួនបុត្រចាំងពីពែងឬ មិនលះបង់ពាក្យប្តេជ្ញា ។ បានធ្វើកិច្ចមង្គល បុត្រ
និមួលស្រែចគាលណា ឲ្យទៅជាកស្តា ទំនឹកវិយោគន៍ពេលនោះ ។
ខុកូលជាស្វាមី គ្មានសេចក្តីស្រឡាញ់សោះ តាំងពីនៅតំណែះ
តែមិនឈ្លោះទាស់រវែង ។ ឯនាងចាវកោ មិនច្បាច្បាចនឹងឲ្យឃ្លាត
ក្បែរកេរ្តិ៍មារយោង មិនឲ្យញាតិគេនិន្ទា ។ ទំនឹកិច្ចការគន៍ផ្ទះ ចោល
ស្រឡះមិនធ្វើតនា ចិត្តបង់តែបព្វជ្ជា លះគ្រហាទៅនៅព្រៃ ។ រីឯ
ជនតាំងនោះ មិនវែលសោះមានតម្រៃ ធ្វើបាបគាត្រកំព្រៃ ដោយ
ដើងវៃដឲ្យសៅហ្មង ។ ទើបក្រាបបង្គំលា នូវមាតាបិតាផង តាំង
ពីត្រាច់ត្រសង ដើរកាត់ទ្វង់ស្រុកភូមិហាន ។ ទៅដល់មាត់ស្ទឹងមួយ
មិនមានព្រួយកង្វល់សន្ធាន ជាទីរហាហាន គួរសម្រាន្តធ្វើបព្វជ្ជា ។

ព្រះអង្គាធិរាជ នាទីអំណាចដាច់ខាតក្តី តំរែកខ្លួនរស់ ចេញនៅ
ឃើញបំពោះ ។ ខ្លួនស្មោះមិនរំលោ ចរលីលាផលស្លឹងខោះ ចិត្តចង់ផ្តួយ
សារគ្នាវ ដោយស្នេហ៍ស្មោះសាទរគ្រែ ។ ទើបប្រើរាស្ត្រមន្ត្រី សាង
គាស្រមះឥតឯណា ប្រមូលអ្នកថ្នាក់ថ្នែ នាំគោលថ្ងៃនេះតុំខាង ។ រីទេវ-
បុត្រនោះឯង មកចាត់ចែងឆ្លើយទាំងទន្ទេ ដើម្បីដំណើរប្រាណ នៅសុខ
សាន្តបានយូរយោង ។ ខ្ញុំម្ចាស់ត្រឹងអ្នកឫស មិនឲ្យហួសល្មមប្រើការ
បំពេញបុណ្យស្មារ ឲ្យអស្ចារ្យគេឥតស្មើ ។ ឯជនអ្នកត្រូវការ
ឃើញជាក្តារមានថ្នើ ។ អរណាស់ទំហួតខ្ញុំ ទើបស្រដីប្រាប់នេះថា ។
ពើហ្នាអាស្រមនេះ ល្អអំរែះតែនណា មកនៅជៀតក្បែ ប្តូរខ្លួនខ្ញុំម្ចាស់
ពុក ។ ឲ្យផល់អ្នកដំណើរ ដ៏ប្រសើរជ្រាជ្ញាសុខ ចំរើនជម្រើតមុខ
លះក្តីរុតតន់សង្សារ ។ ឥឡូវយើងមកផល់ ហើយបានយល់ត្រឹងចរិក្ខារ
សុទ្ធតែអ្នកត្រូវការ បុណ្យស្មារសោនជារមិ ។ ទើបតាំងអង្គាសន
ចិត្តស្មោះស្មានប្រឆ័ស្មារតី ឫសជាគេឥតស្មើ ពាំងប្រុសស្រីគេលានោះឯង ។
បឹករនៅតន់តាស្រមៃ ឥតជាម្ភៃត្រួយចម្រៃរ
ទឹមួយនៅម្ខាត់ឯង ទំប្រឹនវែបង ជាយសុចរិត ។ ភ្នំស្រីយតែផ្លែ
ឈេ ជាអំពើត្រូវប្រែក្រឹត្ត ស្មែរនេះបានតាមចិត្ត មិនខុសគ្រឹតឫបាប
រំខ័យ ។ ឥសីពាំងព័ទ្ធអង្គ ចិត្តស្មោះត្រង់ក្នុងហឫទ័យ មិនមានក្តីសង្ស័យ
ឥតអាល័យចំពោះកាម ។ គ្រានោះស្តេចទេព្តា ពិចារណាឃើញ

ផ្ទះស្នាម រៀបនេះដាប់តាម អ្នកលះតាមតាំងពីនោក ។ អំណើះតទៅមុខ
តែងមានទុក្ខធ្ងន់ឥតអាត់ មានតែកសុទ្ធតែខ្វាក់ ឥតមានអ្នកចាំរក្សា ។
ដូច្នេះគួរអញ្ជើទៅ កាន់លំនៅពាន្យល់ថា ឲ្យរួមសង្វាសគ្នា កុំដាច់ស្រោ
នេះកុំខាន ។ លុះគិតយ៉ាងនេះហើយ មិនយូរឡើយមកដល់ភ្នំ
និយាយឲ្យលោកបាន រួចរួមថ្កាណាតាំងពីអង្គ ។ បពិត្រព្រះឥសី
សូមមេត្តាតាមចំណង់ កិច្ចនេះកុំលះបង់ ចំពោះត្រង់មេឧទ្ទម ។
លោកម្ចាស់ទន់ដាច់បុត្រ ល្អបំផុតចេះគួរសម ដឹងគុណជាបឋម គួរ
និយមរំពឹងបាន ។ ព្រោះដល់ពេលខាងមុខ ខ្ញុំឃើញទុក្ខលោកពីរ
ថ្កាណោ លំបាកឥតស្រាកស្រាន្ត ឲ្យរំភើនភាំងពីរអង្គ ។ ឥសីតប
ទៅថា ខ្លួនអាត្មាគ្មានទឹកចង់ មេឌុនបុនលះបង់ ចិត្តស្មោះត្រង់តែ
កុសល ។ មិនធ្វើឲ្យជាប់ស៊ីល ដាមទ្ធិលខូចមគ្គផល គឺផ្ទួរនាំឲ្យដល់
បាននរកទ្រល់ទ្រក់ក្នុងចិត្ត ។ ព្រះឥន្ទអង្វរហា បើតុណាមិនស្នេហ៍ស្និទ្ធ
ត្រាន់តែអង្អែលផ្ទៃត ឥសីស្រែឈោះបាវិកា ។ កិច្ចនេះមិនខុសគ្នាឯ
តាមរំនងគួរប្រាថ្នា ទឹងកើតបានបុត្រា ពេញស្នេហាល្អថ្លៃឯណា ។
ឥសីតបទៅថា កិច្ចនេះណាទើបធ្វើបាន បើត្រាន់តែស្តាបប្រាណ មិន
ឲ្យមានតាមចំណង ។ សម្តេចឥន្ទកោសីយ ត្រឡប់ទៅផ្ទះផ្ទាល់
លៃលកតាមទំនង មិនរំលងបុរសត្រី ។ ទៅអាពាធនា ដោយពាក្យ
ថាយើងសន្ទុត ឲ្យលោកទៅប្រាកដ ដល់កំណត់ពេលវេលា ។

ទៅចាប់ជាតិកន្លឹតតិ [illegible] ចំពោះខ្លួន [illegible] ឲ្យ
បាស់ក្លាបុណ្យបារមី ។ ពោធិសត្តខ្លួន [illegible] ស្រែស្រួលគាន់តាម
ថ្មី មិនមានប្រែតែអ្វី ដោយមេត្តាចរិតសាធ ។ ទើបខ្លួនតបវិញ
ថា ខ្ញុំតបុណ្ណានធីអនោធ ទៅកើតតាមសំណង ជាអ្នកតាធ្វើបវរក្សា ។
លុះបានទទួលហើយ ពុំយូរឡើយចុះសូន្យ ឋិតនៅកន្លឹតព្រៃ ខាង
បារិតានោះជ្រោតជ ។ ឯនាងឥសិនី [illegible] ស្លុះ
ដល់ត្រង់កំណត់ នៃដប់ខែត់ប្រសូតគ្រឹះ ។ រីឯបុត្រនោះណា មាន
រូបឆ្នូរត្រៃតអរ ទើបបានឲ្យនាមករ ដោយស្មោះសរឈ្មោះសោមា[1] ។
ឥសីពាំងពីអង្គ ចិត្តត្រៃតត្រង់ឆ្ពោះបុត្រា ខំមើលថែរក្សា រកផលា
នេះជាគាំ ។ តាំងពីនៅតូចស្មោះ ដល់កំឡោះរូបកាន់ស្អាត មិន
មានខាស់ខូចខាត ទំនៀមតាសើក្សា ។ មានកាលថ្ងៃមួយនោះ
[illegible] រាស់លាបម្តុំយ៉ា ចរយោគាំរែកត្រឡប់ ។
មកដល់ត្រណាលផ្លូវ ឥស់សត្វមែកប្រសព្វ [illegible]
ចូលស្ងួតអើលអង្គ ។ [illegible] មានទេវតាឯធីតបត់ ខ្លឹត
ដើរកាន់ដោយក្រអឺ តាមចិត្តចង់នោះពុំជួន ។ ទើបវែកសារបា
[illegible] កាន់ដៃគ្នាដើរស្មោន [illegible]
តន៍ជីវ៉ា ។ (មានត)

---

๑ ឯក្នុងកាលព្រឹត្តនៃរៀបថាសុមៈ ឬសុមក្ខណកោនៈ ដែលមកក្នុងថ្មីនេះ ប្រើឈ្មោះម្តងៗ
ដដែលៗពាក្យកាន ។

លោកហ៊ាន – យើង នៃនឹងរឿងរឿង

(ភាគ)

បទទី ៥

រត្នាវីនិវាសជាកប្តីស្អប់ញ៉ែ

ចាប់ពីថ្ងៃនោះមក ជីវិតគាំនឹងប្តីខ្លាននៅតែសម្បុកនោះតែមែន ប្រែប្រួលតាំងអស់ ខ្ញុំកំដរបាវតែតែកើតក្តៅត្រហាយត្រជាក់ប្រមូ ដោយសារខាងសុវណ្ណប្តូរប្រែសិត្តិដាមេផ្ទះពេញទី ហើយតែងតែហៅហែត្រួតត្រាលើតែ ៗ ថ្ងៃ ខ្លះគាំមិនបានក៏សម្រេចឈប់រៀងត្រឡប់ទៅទីលំនៅវិញ អ្នកជិតខាងក៏មានចិត្តអាក់អន់ ដែនទស្សាហ៍ដើរមកលេងផ្ទះនោះទៀត ម្ចាស់ហ៊ាយក៏ស្ងាត់ច្រឹបសួរឈឺឆ្អាលួរឱ្យស្រែកយំត្រដែកលើសលន់ គេនឹកស្មានថាគ្មានមនុស្សនៅតាស្រែង ៗ ពួកសូវតែមាត់ជើងចក់តុកតែយរឿយ ៗ យ៉ាងស្រណោះ ព្រោះសត្វតាំងនោះនឹកខ្លោចចិត្តតាណាតែដល់ត្រង់វែលកំពុងដេកយំលើពួក មានកង្កែកយស្ទាំងស្គម មានឆ្មាស្រែនោន មានទឹកមុខព្រួយមិនស្រស់ញញឹមដូចពីដើម ដូចកែកដែលក្តុះផ្តក់ស្រអ៊ីពួចុះ មណ្ឌលមុខដែលពេញចរិយាណាគួរជាទីស្នេហា ក៏ស្ងួតស្រនោនត្រឡប់ជាផ្ងន់ខ្សោយឆ្អិនឆ្អៃខ្ទុងអស់ ផ្តន់ជាច្រែនកាតស្បែកថ្ងាស់ជ្រួញជាស្នាមជាន់ច្រ គួរឱ្យសង្វែតដល់អាការរបស់ក្តីនៃមនុស្សលោកលើស

លែង ។ គួរឱ្យអាសូរដល់សុភិន្ទ្រ កាលណៃពីសាលាមកវិញ កុមារ
តែងចូលទៅរកមាតា នាំគ្នាថ្វែងទុក្ខសុខទៅវិញទៅមក តែពីរោត់ម្តាយ
ទើបកូន គួរឱ្យអាសូរណាស់លោកអើយ! រួមគេប្តូរប្រយើងពាល់គ្នា ដែលកុំពុងតែបានសោយសម្បត្តិសុខ ។ ស្រាប់តែមានជាបកម្ចប់លមកវៃផ្តាច
ដៀត ឱ្យធ្លាក់ខ្លួនត្រឡប់ទៅរកសោយទុក្ខវេទនាវិញ ក៏មិនវៃកគ្នាប៉ុន្មាន
ទេលោក, ទឹកភ្នែករបស់អ្នកទាំងពីរនាក់កន្លងពេលដែលសន្ទនាគ្នា ហើយ
ស្រក់ចុះមកមិនដឹងគណនាគ្រាប់បានទេ ។

តាមច្បាប់ចក្រពត្តិនេះ រួមណាដែលចំរើនទុង្ហរឿងហើយ ក៏តែ
តែស្លុកស្តុកគ្នាទៅទៀត ចំណែកអ្នកដែលបណ្តាយឱ្យដោតកំណាប
ត្រប់ត្រងហើយ មិនអាចនឹងលាស់ខ្លួនបាត្រណាកម្មនោះឱ្យឃ្លាតបាក
ខន្ធសន្តានបានដោយងាយ តែងវង្វេងទុក្ខវេទនាយ៉ាងសហ័ស ដែល
តែងអន្ទោលតាមត្រប់ៗជំហាន ព្រោះហេតុនេះបានជាពីរតបស់យើង
មានទុក្ខព្រួយ ដល់បាននៅចក្តីសុខសប្បាយភ្លើតភ្លើនចិត្ត ត្រឡប់
ប្តូរគ្នា តែតាមដោយមេត្តាមើលទៅឃើញថាទុក្ខព្រួយច្រើនជាង
សុខ ។ ចុបន្ទុស្សលោកនេះជាទីគួរខ្លឹយណាយណាស់ទេតើ តុំគួរបើ
ប៉ះប៉ិនាល់គ្នានោះតែជំពាក់ជិត្តនឹងវិញ្ញុតិ្តដូច្នេះសោះ បែរជាទៅយល់ឃើញ
"តន់ច្រែងដែលតែងទាស់ទាស់ថាជាមកុដ ត្រឿងឥន្ទរទៅវិញ" ។

កន្ទួលមកមិនយូរប៉ុន្មាន មនុស្សដែលនៅតូចផ្ទះក៏នាំគ្នាចេញលែងនៅតែរៀងខ្លួន នៅសេសតែតាសីពាបើនាក់ប៉ុណ្ណោះ ដែលជាអ្នកមានចិត្តស្មោះត្រង់ចំពោះម្ចាស់ស្រែចម្ការខ្លួន ស៊ូតែអត់ធ្មត់នៅចំរើតបស្នងសងគុណ មេសុរិណ្ណបុរីដូចជាមិនហ៊ានដូច្នោះ ក៏ញុះញង់ប្តូរឲ្យបណ្តេញជាវស្រីពាំងបីនាក់នោះចេញ ។ ដល់គ្មានអ្នកឯណាជាណ្តាំស្ទូ រត្នាវ័ក្ត្រក៏ត្រូវបន្ទំឲ្យចូលដើរតែនរៀបគោជនាហារ ទំនិញចោសជាស់ផ្ទះសម្បែងឲ្យស្អាតបាត នាងរៀបមូបចាយចំណីជាក់ឲ្យគេហើយថយចេញទៅដល់គេស៊ីរួចទើបចូលមកលើកចានក្បាន យកទៅបរិភោគដែលគេ រួចបានរៀបចំលាងសំអាតទុកជាក់ ចួនក៏បានកូនមកចូលជាមួយដង ហើយដួយធ្វើការងារជំនួយម្តាយ តែនាយសោតតូចនៅមិនទាមសុតន្តែមិនឲ្យមូបាយជាមួយទេនាងផង ថ្ងៃនោះឯងនាងលេបាយបណ្តើរលេបទឹកភ្នែកបណ្តើរ ។

មានថ្ងៃមួយ ក្មេងបង្អ្ករាក់ចុះមកដោកជាំ ក៏ទឹកទុសអស់គ្មានសល់ នាងបង្ហាត់ក្មេងជាំបាយក្រនេះហុយតែផ្សែងមកលើមុខ ចូលក្អែកហើមពោរពេញ បាយក៏ឆ្អែមពុំសូវឆ្អែខ្លះដោយគ្មានរដើកទឹកដូច ហួសពេល សុរិណ្ណបុរីឃ្លានភ្លាំងក៏រៀសកឲ្យនាងរៀបបាយនាប់ ។ ដល់ដឹងថាបាយធុំក្លិនមិនល្អហើយដុប ។ ចង ក៏រៀសកច្រេះគ្នាឡើង សោកភតក៏កាន់ដើងតន្ត្រែការម៉ាន់ដេរនាងតេនាវីថា " ហានឯងសមតែកក្បាល

ខ្ញុំឯងនឹង ដេកតែស៊ី គ្រាន់តែដាំបាយប៉ុណ្ណឹងមិនកើត ធ្វើស្រីបានជាការអ្វី" ។

"ចាំ! ម៉េចក្មេងទុកខុសអស់ ឲ្យខ្ញុំធ្វើជួចម្តេច? គ្មានវាសនា ។ ! យើ! ហ៊ានធ្វើយកតែប្តីអញផង" សុវណ្ណបុប្ផាស្រែកសន្ធាប់ ។ សោកតទឹងណាស់ គ្រាកអ្នឹងទៅកន្ត្រាក់ដំបងមកទឹងកាយ ចែតន្ទេដើម យារវែងអស់ទំហឹងសំពង់ចុះ តែគ្រាន់ល្អណាស់ មានកែមួយយ៉ាងខ្លាំងចាប់ដំបងនោះជាប់ ហើយមានសំឡេងលាន់ខ្សឹងថា "ឈប់សិន ។" ។

សោកតដាកទៅក៏ឃើញបុរសម្នាក់កាងមាំ ឫកពាសុភាពជាអ្នកមានត្រកូល សំលៀកបំពាក់ជាអ្នកក្រុង ទើបពោលដល់ក្មេងនោះដោយសំដីខ្លាំង ។ ថា "ចុះគាត់ឯងមកពីណាមក ហ៊ានហៅតាំងអញចុះពីលើផ្ទះអញឲ្យទាប់ ។ ទៅ" ។

"ឈប់ ។ អ្នកឯងកុំព្រហើនពេក កែក្មេងគ្រាន់ប្លាត់ឆ្ងាត់ដល់ខ្លួនអ្នកវិញ ចុះរឿងហេតុអ្វីបានជាអ្នកឯងឃាត់យកយូ? ហេតុអ្វីបានជាអ្នកឯងហ៊ានខម្លាក់ខុសជាប់រើអ្នកឯង? តើអ្នកចង់ព្រឹត្តទម្លាប់អាណាចក្រប្រទេសណា? អ្នកនិយាយឲ្យខ្ញុំស្តាប់ផងមើល" ។

ទៅពេលនោះ ក្មេងវ័យក្មេងឃើញថាបាបសំខ្លួន ខ្លាចក៏ប្តូរមកជួបសាកសួរដំណឹង "នេះលោកមានវេបន្ទដ៏អញ្ជើញមកពីណាបាន

ជាខ្ញុំផ្ញើសំបុត្រទៅមិនឃើញតបមកវិញសោះ តាំងតែលោកអ្នកដ៏មានគុណអនិច្ចកម្មទៅ" ។

"កូយអើយ! ពូត្រូវទៅរៀនឯស្រុកចាក់ឯណោះ ទើបខឹងប្រឡងបានជាធម្មសាស្ត្រឆ្នាំនេះឯង ដល់ពូវិលមកវិញបានឃើញសំបុត្រកូយ ហើយមានសេះសរសៃសំបុត្រ ១ ច្បាប់ផ្ញើមកសម្ងាញ់ទៅស្រុកនេះ សោកស្តាយដំណឹងអំពីសុខទុក្ខរបស់កូយ តែជាកូយលំបាកគោកយ៉ាកបានជាបើកឡានមកស្តាប់ ណ្ហើយចុះកូយរៀបចំអីវ៉ាន់ទៅនៅជាមួយនឹងមាទៅ" រួចបែរទៅរកសោភ័ត "អ្នកឯងឯណោះត្រូវឡើងទៅសាលាជំបូងជាមួយនឹងខ្ញុំ" ។

លុះទៅក្រមាតស្រេចក្តី ត្រូវលែងលះគ្នាតាមច្បាប់ ចែកទ្រព្យសម្បត្តិគ្នាពាក់កណ្តាលម្នាក់ហើយ មានឯកូយកំទាំគ្នាឡើងឡានវិលទៅឯស្រុកភ្នំពេញវិញ ចំណែកសុភ័ន្តក៏យំសោកថ្នាក់ខ្លួនថ្នាក់ថ្នមណាស់រន្ធត់ទ្រូង ព្រោះព្រាត់ប្តូរសឃ្មាតចាកមាតាជាទីស្រឡាញ់ ដោយសារឪពុកមិនត្រូវឲ្យកូនទៅតាមម្តាយ ចំណែកមាតាក៏ពុំត្រូវជាចង់ចិត្តចេញទៅ ស៊ូអត់ទ្រាំនៅលំបាកឲ្យតែបានជួបដុំទឹងកូនស្នងតែមាពុំត្រូវកំលាកូនចេញទៅ ចេញទៅទាំងសេចក្តីរាក់ចិត្ត ស្រយាកស្រយុតស៊ើរទឹងផុតដង្ហើមនាវេលាខោះ ។ ឃ្លាតឆ្ងើយឃ្លាតភ្នាយពីកូនស្នង តែលតែនឹកបងប្អូនរាល់វេលា ពីរ្យមែកព្រាត់ចាកឃ្លាតឃ្លា តែលតែងប្រែប្រួលតាមកែវតម្រា ។

ខុសជាមានទុក្ខក្រៃដើមខ្លួនអម្បាលម៉ាន ឥតែបុត្រមកជិតក៏សោយ
ក្ដៅអស់ មកដល់ឥឡូវបែរជាទាសាកបុត្រគ្នាដូច្នេះ ។ ឱពុទ្ធោអើយ!
កន់ឮនវិលមួយដុំក៏កាន់តែឆ្ងាយពីកូនបន្តិចៗ ។ តុលាលុះហើយនឹង
ជួបគ្នាវិញ គួរឲ្យម្ចាស់ម្ចាញ់ណាស់មេតាអើយ! ជាតិមុនខ្ញុំច្រឡំគ្នា
បែបណាក៏ជួនជាមកតាត់ធ្វើសាកកូនសំឡាញ់យ៉ាងនេះ ក៏កន្លងជាតិ-
នេះ ដែលខ្ញុំជួនកសាងកុសលផលបុណ្យច្រើនជាអនេក ក៏សូមឲ្យជួន
រដោះអស់កម្មវាត្រង់ ឈោយជាតិពីរបីខ្ញុំទៅដកចេញទៅជាតិខាងមុខ
ទៀត ហើយខ្ញុំសូមឲ្យជួនចួបនឹងកូនសម្លាញ់របស់ខ្ញុំ ឲ្យជួនប្រកប
ដោយសេចក្ដីសុខក្សេមក្សាន្តកុំបីឃ្លាតឡើយ ។

នាងឆាកមើលក្រោយ ក៏ឃើញបុត្រស្រយុតចិត្តខំសង្ឃឹមមើល
ឲ្យច្បាស់ ព្រោះក្អែកនាងស្រអាំងទៅដោយឥតក្អែក អង្វរមាឲ្យបើក
វង្សន្តិចៗ សន្សឹមៗ ឃើញពួកអ្នកស្រុកនាំគ្នាឈរមើលមានឥកមុខ
សៅហ្មងរាល់ៗគ្នា ខ្លះបក់ដៃហៅ ខ្លះហុចដៃទាំងពីរមកកាក ហាក់ដូច
ជាខ្លាំងប្រែគ្នាយដើមខ្លួន នាងចំមើលឃើញត្រឹមៗ ទាល់តែរលុបរបូ
ឆាត់មើលតុំយល់ ទើបលាស្រុកកំពង់ធំជាជាន់ក្រោយបំផុត លាម្ចាស់
ណោះលែងណាទៀត ព្រោះអស់សង្ឃឹមថានឹងបានត្រឡប់មកវិញ ។

នៅវេលានោះ គេហដ្ឋានទីដ៏ត្រកាលតាវល្ងិ ហាក់ដូចជាមានវិញ្ញាណចេះនិយាយស្តី ចំពោះស្ងើចរវៃចរាសញ្ញាណគ្នា ហើយហាក់ដូចជាខំបំអើតឲ្យខ្ពស់ឡើង ដើម្បីនឹងឲ្យមើលនាងឲ្យបានឃើញវែងឆ្ងាយ នាំឲ្យនាងសោកស្តាយក្រអួមតរៀបជជងពុំបាន ទំយកដៃខ្ចប់មុខយំស្រណោះស្រណោក រហូតដល់លែងឃើញភាពស្រុកកំណើតរបស់នាងទៀត បុងបំផុតនាងបានលើកដៃឡើងប្រណម្យបួងសួងដល់អស់ទេវតាឲ្យជួយថែរក្សាបុត្រនាងឲ្យផង ។

លុះថេយន្តព័ណ៌ទៀរលុបបាត់ទៅហើយ អ្នកស្រុកក៏នាំគ្នាដួតទឹកភ្នែកតែរៀងពាល់ខ្លួន មើលមុខគ្នាទៅវិញទៅមកសំដែងទឹកចិត្តនាគ្រានោះថា «ឧយើងពាល់គ្នាប្រាសចាកអ្នកដ៏មានគុណចោយទេតើ អ្នកខ្វាល់ត្រូវបាននរណាទីងខ្វាតទៅទៀត អ្នកមានផ្ទាំបានអ្នកឯណាថែរក្សា ពិតមែនជាមានមន្ទីរសុខាភិបាល តែអ្នកពាក្យបាលនោះមានឫកអក្រអឺតក្រទមណាស់ បានតែអ្នកមាននោះទើបគេកាប់រកព្រោះប្រាថ្នាលាភ ចំណែកពួកយើងអ្នកខ្ទុគ្គតគេពុំឃើញឡាលផងទេ ឧអ្នកដែលចាកទៅនេះ ដូចជាមាតាយើងបង្កើតមែនពិត សូមឲ្យអ្នកបានសេចក្តីចំរើនដរាបទៅ តែគួរឲ្យអាសូរដល់សុភ័ន្តន៍ម៉្លេះទេ នាងស្រឡាញ់ម្តាយណាស់ ចែកតែពេលទៅរៀនប៉ុណ្ណោះ សមនាងទីងកើតខ្ទុគ្គជាច្រើនមិនលែងទេ ព្រោះទៅកន្លែងណាបានតែខ្វាក់ណាច ” ។

ហើយអ្នកចាំងអស់ខោះ ក៏ចែកគ្នាទៅគាន់ចិលំនៅតែរៀងខ្លួនចិ-
ន្តៃ តែមានចិត្តអន្ទះអន្ទែងស្រែកគោនស្រែកតន់ជាទុក្ខគ្រប់ៗ គ្នា ។

បឋមី ៩

កុមារកំព្រាជាទុក្ខខ្លោចបង្ហូ

គួរឲ្យអាណិតអាសូរដល់សុភំន្តូកុមារពាន់ពោក គាលបើអ្នកឃើញ
មាភាឡើងឮគាន់ចរចេញទៅហើយ ស្ងូតដើងដួលចុះអង្គុយលុតជង្គង់
ទៅកែរវេចងូរ លើកដៃទាំងពីរសំពះម្តាយ ឲ្យអ្នកវិលត្រឡប់មកវិញ
ទឹកភ្នែកហូរស្រស្រាក់ឥតអាក់សោះ ណែនដើមទ្រូងដកដង្ហើមស្ទើរមិន
កើត មានបេះដូងដូចជាគេច្រចាច់ឈ្វេចឈ្វើហើយ ចុមួយមានត្រួញ
ដ៏មុតចាក់ដោតហើយឈឺគៀបខ្លោចផ្សា វិស័យដូចជាប៉ះទង្គិចតបទ្រព្យ
ដ៏ក្លាខ្លាំង ។

លុះបេយ្យខ្ពុចាត់ស្រមោលទៅហើយ កុមារក៏ចោយដៃទាំងពីរទៅ
ទាងមុខ ជម្រាយហៅអ្នកមេថា "អ្នកខ្ញុំអើយអ្នកវិលមកវិញ កុំបោល
កូនឲ្យនៅតែឯង សមកូនទើងស្ងាប់ពុំខាន កូនជាប់ឃើញមុខអ្នករៀង
រាល់ថ្ងៃ មកឥឡូវនេះបាត់មុខអ្នកទៅ កូនគ្មានប់រមអាហារជាមួយទើង
ក្រុក ឥឡូវបានណា គ្មានទើងតំដាកូនទៅ នុអ្នកខ្ញុំអើយ សម្លាញ់យើង
ពិត្រាប់ពីរម្នាំ កូនស្ទើរខ្លែងរលេះរលួយថ្ងៃមួយមាត់ទៅហើយ នុអ្នក

នេះខ្ញុំនេះអម្បាញ់មិញទេតើ ម្តេចឡើយមកនិកសៅ ម្តេចកំប្រិតគ្នៅយ៉ាងនេះហ្ន ទុព្វន្តា ! ពុទ្ធោអើយ !!

ដល់គ្រង់នេះសុភិទ្ធក៏ដួលសន្លប់ផ្តាត់ស្មាតើ បិតាឃើញដូច្នោះក៏មិនវាល់នាំសុវណ្ណបុប្ផាចូលទៅកន្លឹងផ្នូរ ឋកណ្ណាយឲ្យក្មួនដេកលើដែនដីផ្ទាល់ហុយទ្រលោមគ្រហស្ថខ្លួនឯង ហាក់ដូចជាសត្វតិរច្ឆានឥតអ្នកថែរក្សា គួរឲ្យអាសូរអើម្ល៉ះ គាត់ថ្នាប់ដេកលើភួកខ្នាល់ទៀយ ឆ្នាប់មានគេថែតាំតែណាតើយ ឥឡូវមែរកើយប្រឹថព្យាង់នេះ អ្នកឯណាមួយយើញហើយ មិនកើតសង្វេគកន្ធំចិត្តអាណិតដល់រូបកុមារនោះ សឹងតែរីករាលត្រង់គាត់ទាំងពុំហ៊ានចូលទៅបបោសអង្អែល ដោយខ្លាចអំណាចអ្នកម្ចាស់ផ្ទះនៃពេក ។

ចុះសេចក្តីវេទនាតាំងប៉ុណ្ណេះបណ្តាលឡើងដោយហេតុអ្វី ? តាំងនេះមានដើមចមបណ្តាលឡើង តែអំពីតាមគុណតែម្យ៉ាងប៉ុណ្ណោះ រួចណាតែបណ្តោយឲ្យលុះកន្លងផុតពីលដ៏លាមកនេះហើយ មុះជានឹងវង្វេងភ្លេចស្មារតីលែងស្គាល់ខុសត្រូវគុណទោស នឹងច្រាសចាកធម្មសញ្ញាផ្តាត់ខ្លួនជាសត្វធាតុ គិតទៅគួរឲ្យធុញច្រាន់ណាស់ មិនគួរបើនឹងច្រំព្រាត់ច្រាសវង្វេងគួរឲ្យសុនដូច្នេះរឿយ ។ សោះ គួរតែនឹកដល់ការដ៏ពិកៃចាប់ចិត្តរបស់ព្រះឧត្តមមុនី អ៊ុំ - ស៊ូ ដែលមានព្រះពុទ្ធដីកាក្នុងអសោនកិច្ចរបស់លោកថា « អ្នកវាល់នឹងស៊ីបុណ្យផឹកកាម ដេកចណ្តែតខ្លួនទៅ

តាមវិធីកំណត់ឥណ្ណា សត្វចំពូកនេះឯង ដែលជាសត្វរកសោរចប់ រក
ត្រីយកតាន់ភ្នាន ដូចជាសំណាត់មួយអណ្តែតលឿនលយទៅក្នុងសង្ឃរ
វដ្ត" ។

ឯការនិពន្ធសាកបុត្រនីងមាតានេះ មានទៀងត្រង់សោកិតក្សត់
ចិត្តកំយោកក៏មែនហើយ តែថាតាមដែលយើងបានសង្កេតមក និស្ស័យ
អ្នកនេះ មិនមែនជាអ្នកគាចរហូតដល់ធ្វើបាបប្រពន្ធដល់ថ្នាក់នេះឡើយ
តែបានជាលើកដើងខាត់កូន លើកដំបងវាយប្រពន្ធតើត ក៏ពីត្រង់ត្រូវ
ស្នេហ៍ជោកជាំនោះឯង ឯតំហុសអស់នេះឲ្យតាលើតាចាមទាំងអស់ ខ្លួរ
ណាស់តែស្ងាតបំបាត់ពួកបំផ្លាញត្រកូលអស់នេះឲ្យផុតពីដែនខ្មែរចេញ
ត្រង់លោមនុស្សលោកអន់ពុតត្បុតបានខ្លះ ទុកជាត្រូលយ៉ាងណាក៏មិន
ខ្លាំងក្លាដូចត្រូវនឹងស្នេហ៍ដែរ ឯនីងបំបាត់តាមតណ្ហាឲ្យផុតពីខ្លួ
សន្ធានទោះឃើញថាគ្រប់ណាស់ ត្រង់ជាជម្ងឺប្រចាំលោកនេះឯង ប៉ុ-
ណែកឯត្រូវស្នេហ៍វិញ តាលណាបើបានដឹងរឿងរ៉ាវអស់នេះច្បាស់លាស់
ហើយ ខ្លួនឹតតាស្ងាត់ដើម ត្រូវដូចគ្នាផង កុំសន្ធឹតម្ចាស់ពៀរពេក
ប៉ុន្តែណាស់អាស្រ័យពាក្យសាទឹតតាងទៅលួងជាង ។

លុះត្រឹកត្រាងស្ងាត់ខ្លឹង សាខ្លួមក្លាក់ចុះមកស្រោចស្រង់ខ្លួន
សុតខ្លួនឡើង ក៏ឃាត់ត្រជាក់ក្លាក្លាត់ខ្លួនខ្លឹង ទំនើបឈរដើរផងរំណាង
ទៀងទៅលើផ្ទះ អស់កំឡាំងណាស់ក៏អង្គុយទៅលើតាំងណើរ លុះនឹក

ដល់ហេតុគេទាល់តែតាមរឿងនោះ ក៏ចាំបាច់ថាមានមិនខៅ សុភ័ន្ត
ចាប់យំសាផាថ្មីទៀត រៀបចាប់សព្វគ្រប់ខៅត្រង់ណោះ ឮដល់សុវណ្ណ-
បុប្ផាបើកទ្វារចេញមកស្តីថា: "ឯងជាក់មាត់ឲ្យឈឺងខៅ តែទំយឹមុខជា
អញ្ជាក់យឲ្យថែកខ្នងមិនខានទេ ឆាប់ៗ ខ្ញើងមក រកបង្កាត់ភ្លើងដាំបបរ
ឲ្យយើងស៊ី" ។

ឮសូរសំដីតំរេះតំរើយដាលើកជម្ងឺបង្អួស សុភ័ន្តសង្វើរស្ទឹក
គ្រចៀកអស់កំឡាំងខន់ខ្លួន តែទំជួនស្មារតីឲ្យទំងន្ធួនបង្អួសដើងចូលខៅ
ក្នុងផ្ទះចាយ សុថ់សៅលៃងសប្បាយជួបគ្រាមុន ។ ដោយមិនឆ្ងាប់ពីបាក
អ្នកពុះទសគ្រចែកមុតដៃសាំអស់ ថែមទាំងគ្នាទកំឡាំងផង ទម្រាំ
ទំងបង្កាត់ភ្លើងនេះគ្រហមក្អែកអស់ រះសះរះសោះដៃដើងលើកអ្វីមិនចង់
រួច លុះបបរឆ្អិនហើយរួបសុភ័ន្តក៏ប្រឡាក់ប្រឡូសខៅរោយធ្លុងឆ្នាំង
មាមដៃក៏ផ្សាគ្រប់ម្រាម ដោយកកិតនឹងទសរលាកភ្លើង ។

កាលបើរៀបចំខ្ទុកដាក់ឆ្នាំងអម្បែងស្រួលបួលហើយ ក៏ហួស
ពេលខៅសាលា លុះដល់ថ្នាក់រៀនក៏ទុនមុខចូលខៅកាន់កន្ទែងខ្លួន ប្រុង
ចាំស្តាប់តាក្យបន្ទោសអំពីអាចារ្យ តែគ្រូជំងើដើមហេតុក៏សន្ទោសឲ្យមិន
ទំយាយស្តីថាអ្វី ព្រោះសុភ័ន្តជាសិស្សឡាតក់ងំវៃជាងសិស្សឯទៀត
មានតំនិតមានហោទស្រគត់ស្រគំដាំទំដាខុតតិដល់កុមារឯទៀតៗ អ្នករៀន
ផងគ្នាក៏ពប់អានតោរពបូជា ព្រោះសុភ័ន្តជាកេងចិត្តបុណ្យ តែងជួយ

អ្នកដទៃ អ្នកខ្លះយកដួយពន្យល់ឲ្យភ្លឺកែឡើង អ្នកណាត្រូវបបួលទៅ
ទិញចំណីវិលគ្នាបាត់គោត ។

តែចំត្តមនុស្សគ្រប់ត្រកំវិលណាស់ កាលបើយើងមានក៏ចូលមកក្លើជាញាតិមិត្តសម្លាញ់ត្រមគ្នា លុះដល់យើងចុះក្រដុនដាបហើយ កំគ្មានអ្នកឯណាមួយដួយចំនុកបំរុងឡើយ តែដើរជិតគេក៏មិនចង់ដើរជិតត្រែងគាប់មុខ ។ ឯសុគតិទ្ធកុមារដល់នូវសេចក្តីខ្ចាល់ក្រហើយ ទើបអ្នកចុះស្លៀកពាក់ទោអាវខេសអែក រហែកមុខក្រាយគុំពូលតាពាន់ពោតណាស់ ទោះទៅផ្ទះក្តី ទោះទៅសាលារៀនក្តី ទោះទៅពេលលេងក្តី តែងអែបភ្លាមម្ខាងឯងឥតគេកប់ គេនាំគ្នាទិញចំណីស៊ីប្រឡែមទៅមុខកុមារ គេតែងជ្រមុំគ្នានិយាយដើមលើចលេង ឬនក៏និយាយឡកឡឺយចំអកចំអន់ឲ្យ ។

សុគតិទ្ធទំអត់សង្កត់ចិត្តលេចសេចក្តីកាម៉ាសមុខទុក្ខកន្ធគោះ ឬនក៏អត់ខាំពុំជាឧបាទើកភ្នែកបេញត្រួតៗមក ពួកក្មេងក៏កេះគ្នាស្រែកឡើងថា "កនយើងមានត្រកាំផ្ទាស់មុជទឹកទេ ក្មេងមកហើយសោះទ័ងក្តៅ" ។

កុមារឈឺណាស់ប្រមុខបេញព័នោះទៅ ទើបនឹកកន្ធគោះថា "ណ្ហើយបុះ អញត្រាអត់សង្កត់ចិត្តតែមួយនាំនេះទៀត ខ្លាំងឬឡើយកបដិញ្ញាណាថ្ងាន (ស្រែកដំហ្មីយោះ) ត្រើមួចឯងឥតកំត្រា មានទុក្ខ

ក៏ដូចជាគ្នាន ត្រូវតែតាមកម្មៅចុះ ខំឯរៀនសរសេរឲ្យណាក៏ពុំផុតដែរ'' ។

ពេលរៀលត្រឡប់មកផ្ទះវិញ តែងគ្រៀងចូលទៅផ្សារទិញត្រីខ្ចីឯបន្ទៃ ជាន់អ្នកលក់ម្ចាស់មានចិត្តសប្បុរសជួយទិញផ្លូវឲ្យស្រួច តាលាបើសុកិន្ទូរទៅដល់គេក៏ប្រគល់មុកឲ្យតែរៀងរាល់ថ្ងៃ ។ លុះដល់ទៅផ្ទះដោក់សៀវភៅសឹងតែមិនខាន់ តែបញ្ចប់ប្រញាប់ចូលដើរគ្រានជាយរៀនដណ្តើសូត្រប់មុខ តែងតែត្រូវពាក់ទឹងស្តីបន្ទោសជារាល់ថ្ងៃរាល់ពេលព្រោះម្ហូបមិនឆ្ងាញ់ពិសា ក៏ខំប្រឹងផ្សំគ្រឿងគ្រប់តែត្រូវ ទើបចំណានខាងសម្លម្ជូរបង់គ្រឿងការី ៣ មុខ ការីគ្រអូប ១ ចុង ការីផ្លែ ១ មុខ ការីហឹរ ១ មុខ បើខាងភ្លាលវិញក៏ចំណាន ទៅចេះធ្វើទំក៏ច្រើនមុខម្ហូបជាកំឯក៏គ្រាន់បើដែរ ចេះច្រើនក្រសាំងជាបដំនួសសាច្បាត់បាន ។

ពេលយប់គោងរៀនដេរបំរះហួតដល់ម៉ោង ៩ កាលុះបើផុតម៉ោងហើយចង្កៀងក៏ត្រូវពន្លត់ គ្មានអនុញ្ញាតឲ្យប្រើការរៀនសូត្រតទៅទៀត ទ្វាំរហើយសុកិន្ទូរកពេលទន្ទេញមេសូត្រ ទំរាំបំពេញកណ្តាលយកិច្ចមិនបាន ទើបលបបើកគ្រាប់ក្រាយចុះទៅលេងផ្ទះអ្នកជិតខាងម៉ើលសាស្តាឲ្យគេស្តាប់ចំនួន ១ ម៉ោង ព្រោះកុមារបានសំឡឹងពីកេះហើយចេះបទបែបច្រើនយ៉ាង ទើបគេចាប់ចិត្តនឹងស្តាប់រាល់យប់ ហើយគេឲ្យតានមួយកាក់ពីរកាក់ខ្លះគ្រាន់ទិញគ្រឿង ១ បតរណ៍រៀនសូត្រ

ពីមៅដ ១០ ខ ល់តណ្តាលអធ្រាត្រ គេខុតភ្លើងឲ្យមើលរៀនសូត្រវេរ ។
ទើបសុភិន្ទ្រចេះតែតូកែងាប់គេបានលេខ ដកបក្នុងថ្នាក់ ។

ពេលព្រឹកសុភិន្ទ្រភ្ញាក់ខ្លើងពីមាន់រងាវ ដាំទឹកក្តៅរួចដាំបបរ
ទៀត ដល់បបរឆ្អិនគឹដុតតែរងៀត ដួសបបរដាក់ចានស្រាក់យួរយក
ទៅឯវៃស្ងណោះ ព្រោះតាំងពីមានរឿងមក សោភិតតែងចេញទៅ
ក្រៅតែរាល់ពេលព្រលឹម ។ លុះវិលមកវិញឃ្លាតណាស់ សុភិន្ទ្រ
ខ្លាចចូលទៅវត្តបេះផ្លែតែថែកអស្រយ៉ងគេញ្ញោះ ប្អូនក៏លោក
សម្លឹងមើលប្អូន លោកក៏ដាក់ចានឲ្យបរិភោគខ្លះមក ទៅថ្ងៃបន្ទាប់ប្អូនបានជាយ
កក ប្អូនក៏អត់ទៅ រួចពីកុមារកើតខ្លះៗតែមស្រោនចុះទៅតែស្បែក
ន៍ដ៏ឆ្ងាញ់ ជ្រងមុខខ្លួនក្លែកអស់ ឈាមក៏មិនបំព្រងដូចមុនទៀតឡើយ ។

ខុកជាវែនាយ៉ាងណា កុមារកើតទៅតែខិតខំរៀនសូត្របានចំរើន
កើនឡើងជាលំដាប់ តែដល់ថ្ងៃមួយ សុវណ្ណបុប្ផាចាស់ថ្ងៃចង់សម្លាល
កូនខាយប់អធ្រាត្រ ក៏ស្រែកយំ ។ តែម្នាក់ឯងគ្មានសាក្សីត្រូវគ្នា ហៅ
ស្តាមីឲ្យជួយយកអាយុផង សោភិតនើបទៅដើមម្តាចូលទៅជាស់កូន
ដៃលេខើមនិលក់ទៅបានមួយស្របក់ សុភិន្ទ្រភ្ញាក់ខ្លើងញ័ររន្ធត់ដើម
ខ្លួន ដោយតុំធ្លាប់មានខណាជាស់ពេលខ្លះតំពុនចិត្តស្រួល យក
ដៃញ៉ីក្តែកសួរទៅពុកអំតើហេតុអាសន្នអន់ក្រៃលីមិនបាន ត្រូវសោភិត
កន្ត្រាក់ដៃចេញពីវ៉ែត បង្គំឲ្យត្រលប់ទៅហើយយើមមកឲ្យនាប់ ។

(មានត)

តាមសេចក្តីកត់ត្រារបស់អ្នកដំណើរដោតីដ៏ខ្មាក់ (តមក)

ប្រសិនបើជាវ៉ាគេចរត់នាំយកភាំងកូនចៅវ៉ាទៅផង (បើគេចាប់បាន) គេសាក់ថ្នាំខៀវនៅមុខវ៉ា ។ ប្តូនតាលគេដាក់ប្រវ៉ាក់ដែលនៅកវ៉ាក់ មិនដូច្នោះទេគេដាក់ប្រវ៉ាក់ដៃនឹងដើនវ៉ា ។

អំពីសំដីភាសា - ប្រទេសនេះមានភាសាមួយដោយខ្លួន ពុកជាមានសូរសំឡេងប្រហែលៗគ្នា (នឹងភាសាដើមរបស់ខ្លួន) តែពួកចាមនឹងសៀមស្តាប់ភាសានេះមិនបានទេ ។

ឯពាក្យខ្មែរបុកណាដែលលោកចៀវ-តាកូន បានកត់ពុតមកខ្លះ កន្លះកក្សរចិនខោះដូច្នេះ :

ពាក្យខ្មែរបុកណា	ពាក្យខ្មែរថ្មី	ពាក្យខ្មែរបុកណា	ពាក្យខ្មែរថ្មី
មី	មួយ (១)	ប៉ា-តូ	ឪពុកធំខាងឪពុក
ពៀ	ពីរ (២)	មី	ម្តាយបង្កើត
ប៊ី	បី (៣)		ឬម្តាយមីងខាង
ប៉ាន	បួន (៤)		ឪពុកឬខាងម្តាយ
ប៊ី-ពៀន	ប្រាំ (៥)	ប៊ង	បងប្រុសឬបងស្រី
ប៊ី-ពៀន-មី	ប្រាំមួយ (៦)	ប៊ី-ប៊ើន	ប្អូនប្រុស
ប៊ី-ពៀន-ពៀ	ប្រាំពីរ (៧)	ពេ-ខ្ញៀ	មាខាងម្តាយ
ប៊ី-ពៀន-ប៊ី	ប្រាំបី (៨)		ឬប្តីរបស់មីង
ប៊ី-ពៀន ប៉ាន	ប្រាំបួន (៩)		ខាងឪពុក
ត (ឬ) ក់	ដប់ (១០)		
ប៉ា-តូ	ឪពុកបង្កើត		

តាមធម្មតាគួរសើចខ្លាំង គេប្រកាសផ្ទួយគ្នាដូច្នេះ : យើងនិយាយ
ថា នេះជា ចាង-សាន ប្អូនប្រុស គេនិយាយថា ប្អូនប្រុសចាង-សាន
នោះជា លី-ស៊ី អាពួកធំខាងម្ខាយ គេថា អាពួកធំខាងម្ខាយលី-ស៊ី
សើរៀង ។ ម្យ៉ាងទៀតដូចហៅចិនថា ប៊ុ-ហេ, មន្ត្រីថា ចាំ-ចិង, ឡេត្រែ
ថា ចាំង-គឺ ។ កាលបើគេនិយាយទង់ងមន្ត្រីចិន គេមិននិយាយថា ប៊ុ-ហេ
ចាំ-ចិងទេ ថែរជាថា ចាំ-ចិង ប៊ុ-ហេ សើរៀង ។ ប៉ុន្តែនិយាយទង់ងឡេត្រែ
ចិន គេមិននិយាយថា ប៊ុ-ហេ ចាំង-គឺ ទេ ថែរជាថា ចាំង-គឺ ប៊ុ-ហេ សើ
រៀង តែងតែដូច្នេះឯងពាំងអស់ ។ ពួកមន្ត្រីក៏មានរបៀបពាក្យសម្រាប់
មន្ត្រីនិយាយគ្នា ។ ពួកឡេត្រែក៏មានចំណេះបេះដង្ហិតបត់ខាងឡេ-
ត្រែ ។ ពួកលោកសង្ឃទង់តៅអ៊ីស្ត៍ ក៏មានតាសារបស់លោកសង្ឃ
ទង់តៅអ៊ីស្ត៍ ។ របៀបនិយាយនៅគ្រង ទង់នៅភូមិក៏ផ្សេង ៗ គ្នា ។
នេះមានតំនង់ដូចរបៀបនៅស្រុកចិនដែរ ។

អ៊ីពីពួកមនុស្សព្រៃ : មានមនុស្សព្រៃពីរពួក ។ ពួកដំបូងជា
បនុស្សព្រៃដែលចេះកាសាសំដីអ្នកស្រុក ពួកនេះហើយដែលគេចាប់
យកមកលក់នៅទីក្រុងពុកធ្លូជាច្រើន ។ មួយពួកទៀត ជាពួកមនុស្សព្រៃ
(ព្នង) ដែលមិនត្រមកាន់តាមស៊ីវិល័យចំនើបថ្នូ ទង់មិនចេះតាសាគេ
ផង ។ ពួកនេះមិនត្រមនៅផ្ទះទេ ទៅតាមត្រមគ្រសាចេះតែដើរផ្លាស
ប្តូរទៅកន្លែងកំពុង ខ្លួសញាងដំ ១ ផង ។ ប្រសិនបើជួបប្រទះទង់សត្វព្រៃ

កំប្លាញ់ទឹងធ្ងន់ស្មា ចេះរាយថ្នឲ្យគេតក្លើនខ្លួន សម្រាប់ដុតចំអិនសាច់ ហើយសុំជាមួយគ្នា រួចលើកគ្នាចេញទៅខៀត ។ ពួកនេះមានទិស្សយេកាច ហើយវាមានថ្នាំពុលខ្លាំងណាស់ ។ នៅក្នុងចំណោមពួកគ្នាវា ចេះតែនិយាយគ្នាជារឿយៗ ។ ក្នុងមនុស្សពួកនេះ មានចេះរាំត្រាញទឹងកបស្ម ហើយចេះត្បាញសំពត់អម្បោះខ្លះដែរ តែសំពត់នោះសាច់គ្រាតគ្រាត ហើយមានគំនូរមិនមានរបៀបរៀបរយទេ ។

អំពីរបៀបសរសេរអក្សរ - តាមធម្មតា របៀបសរសេរជាសេចក្តីតាមផ្លូវការ គេសរសេរលើស្បែកក្តាន់ឬស្បែកមាំង ទឹងវត្ថុដែលត់ព័ណ៌ខ្មៅដងែខៀត ។ ឯខ្មាតចំហិចទឹងបណ្តាយគេកាត់តាមត្រកោរ ហើយគេយកមេក្យាមួយយ៉ាង មេក្យានោះដូចដំព័ណិសនៅស្រុកចិន គេយកមេក្យានោះលាយធ្វើជាកំណាត់មូលវែងតូចៗ ហៅថា សូរ (ដីសពង) ។ គេចាប់ដុំមេក្យានេះសរសេរលើស្បែកនោះ អក្សរក៏ដិតមិនរលុបទេ ។ កាលណាគេសរសេរចប់ហើយ ក៏យកសូរមកសៀតត្រចៀក ។ អក្សរនោះគេអាចសំគាល់ដឹងដល់ដៃអ្នកសរសេរផង ។ ប្រសិនបើគេយកកំណាត់ខ្មៅកទៅលុប អក្សរនោះក៏រលុបអស់ទៅ ។ តាមធម្មតាគេសរសេរពីឆ្វេងទៅស្តាំជាទំនៀម មិនសរសេរពីលើមកក្រោមទេ ។ ឡុកបានឮគេនិយាយថា នៅ យេ-សៀន-ហៃ-យ៉ា នោះអក្សរបស់គេបញ្ចេញសូរសំឡេង ប្រហែល ។ ទឹងពួកម៉ុងកុល មានតួ

តាមបែបប៉ុណ្ណោះទេដែលមិនត្រូវគ្នា ។ ឯការតែងពាក្យប្តីដ៏នោះ គេមានច្បាប់ផ្ទៃងសម្រាប់អ្នកតែងពាក្យ ឬអ្នកជួលសរសេរពាក្យបណ្តឹង ។

អំពីប្បែបប្រពៃណីជាតិរបស់ខ្មែរ.. គេតែងរើសយកថ្ងៃទី ១ ត្រូវនឹងថ្ងៃទី ១០ ចន ។ ឯថ្ងៃទី ១ នោះ គេហៅថា សៀ-គូ (1) ។ នៅខាងមុខព្រះពុទ្ធរូបធំ គេធ្វើអង្គចន្ទ ១ ធំចំណុះមនុស្សជាងពាន់ឡើងទៅ ហើយគេយកគោមនំធ្លាផ្សេង ។ ប្រជាប់ប្រជាពាសពេញ ។ នៅខាងមុខ (អង្គចន្ទ) ប្រវែង ២០ ហត្ថ គេយកឈើត្រនំ ។ រៃ ។ មកផ្គុំគ្នាបន្តឡើងទៅលើ មានទំនងដូចសសរក្តោង សម្រាប់សាងជាស្តូបហើយមានកំពស់ដល់ ២០ ហត្ថ ។ ពស់ៗយប់ គេតសាងបានដល់ ៣-៤ ឬ ៥-៦ ក៏មាន ។ នៅត្រង់កំពូលនោះ គេដាក់គាំជ្រចន្ទីងារ ។ ឯការចំណាយធនធានទោះនៅលើតួកម្លាំងទេ ទំងពួកអ្នកមានត្រកូលខ្ពង់ខ្ពស់ ។ ដល់វេលាយប់គេតាបខ្លួលអាភ្លើញព្រះមហាក្សត្រ ឲ្យស្តេចយាងមកប្រជុំពុទ្ធរូបនៃត្រង់ ។ ទើបគេអុជគាំជ្រចន្ទីងារឡើង ឯគាំជ្រចនោះមានរយៈប្រមាណជាង ៣០ ស ដាវនោះដុំធំដូចកាំភ្លើងធំសម័យបុរាណ ហើយអុជណាន់ឬទ្រូវភ្លើងទៅឆាំត្រូវ ។ ពួកម្ចាស់ទ្រង់ពួកអ្នកមានត្រកូលខ្ពស់ ក៏នាំគ្នាគាន់ទៅនំ ។ ចូលមកគាន់បុណ្យនេះ ការចំណាយតាមបុណ្យនេះអស់ច្រើនណាស់ ។ ព្រះមហាក្សត្រត្រង់ភ្លើញភ្លឺជាងគេ

---

1 — កត្តិក (Octobre-Novembre) ។

មានប្រទេស ឲ្យមកមើលបុណ្យនេះផងដែរ ។ បុណ្យនេះគេធ្វើរាវណា ១៩ ថ្ងៃទើបឈប់ ។

កន្លងខែមួយ ។ តែងមានបុណ្យមួយ ។ ដែរ ។ នៅខែទី ៤ គេបោះបិណ្ឌ(១) ។ ខែទី ៨ បុណ្យយ៉ាលិ ។ នេះ គេប្រដុំបណ្តាក្រុងតាំងអស់ក្នុងវត្តនច្ចូលមកក្នុងក្រុងហើយហៅ (ភាហាន ?) ដើរតាត់មុខភ្លើង ។ ខែទី ៩ គេនាំគ្នាទៅរតនចេតិកព្រះពុទ្ធ គឺប្រដុំព្រះពុទ្ធរូបតាំងអស់ក្នុងស្រុក ហើយយកទឹកមកហើយគេនាំគ្នាលាងព្រះពុទ្ធរូបអស់នោះ ទៅចំរោះព្រះភក្ត្រព្រះមហាក្សត្រ ។ ខែទី ៧ គេដុតស្រែ គឺពេលដែលស្រែរាំទើបទំនំខុំ គេនាំគ្នាចេញទៅកេស្រែនៅខាងត្រែងភ្នំរតនៈ ហើយគេដុតថ្វាយព្រះពុទ្ធជាម្ចាស់ ។ ពួកស្រី ។ តាប់មិនអស់នាំគ្នាជំរេះ ប្តូរដីរមកធ្វើពិធីបុណ្យនេះ ប៉ុន្តែព្រះមហាក្សត្រមិនស្តេចចេញទេ ។ ខែទី ៨ បុណ្យឆៀ-ឡាន ។ គឺរថាំកំរែក គេរើសរកយកពួកអ្នកភ្លេងដែលត្អូកែ ។ ដែលនាំគ្នាមកចូលកំនែតពស់ ។ ថ្ងៃ ដើម្បីបុណ្យឆៀ-ឡាន ។ កន្លងបុណ្យនេះមានប្រដាល់ជ្រុតនឹងប្រដាល់ដំរីផង ។ ព្រះមហាក្សត្រ បានអញ្ជើញពួកភាជនូតប្រទេសត្រៃមកមើលផង ។ បុណ្យនេះគេធ្វើ ១០ ថ្ងៃ ។ ខ្ញុំចាំមិនបានច្បាស់អំពីពិធីបុណ្យ ដែលជាប់ខាក់ខន់ខំនឹងខែឯទៀត ។ ទេ ។

១— ភាត់សី ? ឬបោលត្រាប់កាំភ្លើង ? ។

ក្នុងប្រទេសនេះ មានមនុស្សចេះភ្នែនហោរាសាស្ត្រ ហើយអាច់ ព្យាករណ៍អំពីចន្លូគ្រាសន៍ដ៏សូរ្យគ្រាសបានផង ។ ប៉ុន្តែរបៀបនៃវែនន៍ដ៏ខ្លីមានរបៀបខុសពីយើង ។ ពួកនេះមានឆ្នាំដែលត្រឹមតែ ១២ ខែដូចជាយើងដែរ ប៉ុន្តែគេកាច់បន្ថែមត្រង់ខែទី ៨ ទៅវិញ ឯខ្ញុំមិនដឹងរបៀបគេទេ។ ក្នុង ១ យប់ ១ នោះចែកចេញជា ៤ យាមប៉ុណ្ណោះ ក្នុង ៧ ថ្ងៃជាមួយនាទិត្យ របៀបនេះដូចជាមិនហៅថា "តៃ-ពី-កៀន-ប៊ូ" ។ ពួកមនុស្សគ្រស់នេះ មិនមានឈ្មោះត្រកូលទំនឹងឈ្មោះខ្លួនទេ ហើយមិនកាច់ថ្ងៃកំណើតផង ប៉ុន្តែឈ្មោះខ្លួនដោយច្រើននោះ គេតាំងតាមថ្ងៃដែលគេកើត ។ ពួកនេះមានទំនៀមប្រកាន់ថ្ងៃល្អ- អាក្រក់ (លិច-អណ្តែត) សូម្បីតែគេដើរទៅទិសខាងកើតឬខាងលិច ក៏មានកាច់ថ្ងៃលិច-អណ្តែតដែរ ឯរបៀបនេះស្រីៗក៏ចេះដែរ ។ ក្នុង ១ ឆ្នាំមានសត្វ ១២ ដូចជាចិនដែរ តែឈ្មោះហៅខុសគ្នា ដូចជា សេះ ហៅថា ពួ-សៃ មាន់ថា លូ-អាន ជ្រូកថា ចេ-លូ គោថា គោ ..... ។

ប្លាប់ជង្រ្កែ - ដំណោះគាស់ទៃនរបស់បណ្តាកស្ត្រ ខុកជាមិនមែនជារឿងសំខាន់ ក៏ច្រើនតែទៅដល់ព្រះមហាក្សត្រ ។ ពីដើមមក នោះមិនមានឆ្នើគោសក់យដំណេ គេនិយាយថ្លាប់ខ្ញុំថា មានតែឆ្នើគោសតិន័យដោយថ្លាក់គាសប៉ុណ្ណោះ ។ ក្នុងការដែលមានគោសជាន់ម្ខាងណាស់នោះ គេមិនសម្លាប់ដោយអាវុធឬច្រចាច់កសម្លាប់ទេ ដ្បិតនៅ

ខាងក្រៅភូវគិសខាងលិច គេដឹកវណ្ណមួយសម្រាប់ជាកំមន្ទុស្សគោស
១ក្បែរ ហើយគេកាយដីលុបសន្ធឹកថ្នឹ (ឲ្យស្ងាប់ទៅ) គោសបន្ទាប់
មកត្រូវកាត់ម្រាមជើងនឹងម្រាមដៃឬកាត់ដើមដៃចេញ ។

គេមានវិធីវិសេសសម្រាំងទៀត គឺបើសិនបើអ្នកណាមួយ មាន
ប្រាត់បេះអ្វីមួយ ហើយមានសេចក្តីសង្ស័យទៅលើអ្នកដទៃទៀតនោះ
គេយកប្រេងដាំក្នុងឆ្នាំងមួយឲ្យពុះឡើង ។ អ្នកដែលគេសង្ស័យត្រូវ
ដែលក់ដៃទៅក្នុងឆ្នាំងប្រេងនោះ ។ បើសិនជាចោរមែន ក៏នេះខ្ចោចដៃ
ទៅ បើមិនមែនជាចោរទេ សាច់ស្បែកដៃនៅដដែល នេះជួចជាវិធី
បេះពួកមនុស្សពៃ ។

ប៉ើសិនប្រើគ្រួលពីរកេតឈ្មោះខាស់ខែងគ្នា មិនដឹងជាខាងណា
ខុសខាងណាត្រូវទេ ។ ទៅខាងមុខវិញ មានប្រាសាទថ្មតូច ១ ៦ ខ្នង
ត្រូវគួសត្រូវពាំងពីនោក ចូលទៅអង្គុយក្នុងប្រាសាទមួយម្នាក់ ។ ទៅ
ខាងក្រោមប្រាសាទពាំងពីរ ត្រូវគ្រួលពាំងពីរចាំគ្រួតគ្រាថែរក្សាគ្នា
ទៅវិញទៅមក ។ លុះ ១-៦ ឬ ៣-៤ ថ្ងៃតមក អ្នកដែលធ្វើខុស
ខឹងមានអាការប្លែកប្រាកដឡើង គឺមានតម្រាមាស់ប្តូរផ្លាស់យកគ្រួនដៃអ្វី
ខិមួយកេតឡើង ។ ឯអ្នកឥតខុសឥតមានដឹងដឹងគាត់អ្វីឡើយ ។ គេ
ក៏ដម្រែកាត់គោសខុស-ត្រូវទៅ ។ វិធីនេះហើយដែលហៅថា "ដម្រែ
កាត់គោសបេះហ៊ានសួគ៌" ។ (មានត)

លោកគន្ថន្តរិយា ពាក្យកាព្យ

របស់

គ្រូបង្រៀន បាន-តែង

(តមក)

ផ្លូវលោកនេះហើយជាដើមហេតុ កុំបដិសេធមិនត្រេកអរ ចល-
សគ្គាវញ្ជាប់ញ៉ែរ បំផ្ញើសផ្លូវធម៌ច្រឡំចល់ ។ មើលចុះគ្រប់ជាតិគ្រប់
ភាសា ដ៏ដែនហាខណាតាំងសាគល ប្រែផ្លូវលោកិយមានតង្គល់ តែ
ដល់ផ្លូវធម៌ថយអំណាច ។ មនុស្សយើងត្រូវការប្រែកម្លាំង បើរូបស្គម
ស្គាំងតើតរកគាប ឯាមនុស្សពិការមុខគួរខ្មាច មិនអាចធ្វើការបរិហារ
កាយ ។ សូម្បីដ្ឋាសារតើ អាចឈើរើរៃពងតាំងឡាយ តន់តែ
ត្រូវការកម្លាំងកាយ ដ៏តគាស់ឈូសឆាយឬចូកចាំង ។

ដើមិនថ្នមរូបឲ្យសប្បាយ ការណាកងកាយមានកម្លាំង អាង
តែការនាយប្រាំ ឆ្នាំដ៏តតអង្គុះប្រែកមួយគ្រាប់ ។

៥ — ដាប់ផ្លែប្រែក្លាក់ភក្ត្រស្រែស់ស្រាយ សូមអធិប្បាយ
ឲ្យប្រមុខប្រាប់ ចាន់ដែលដាំដុះដែលមិនចង់ដាប់ ត្រូវប្រាស្រោះសោកគង់
លោក ។ ត្រែកមានខ្លឹងតាមដែលតើតស្ងាប់ តែមានឈ្មោះថាប់ឆាប់រាគ
ដូចដែនចិនស្ងួត ចង្កាគ្មានណាយក្លាយទឹយ ។ ទឹយមានលោតី

យ៉ាងតែតែងតែទុក្ខ ចង់សុខតែសោកកេងជួយដែ ទុក្ខវែងពេលក្រាន
ប្រាណលំ រលើងពាំងតុម្ពកាយរលើង ។

ផ្លុំចំណងចងសារ- រះនោះមានបាដូចចាប់ធ្លាង គ្រែកកដូចដែលគ្នាត់ដួលកើង កាយដើងទន្ទឹមធ្លាងគ្មានសល់ ។ ចំណងមួយគឺកូនប្រុសស្រី បេតីតេញតីពីតូចធល់ ធំឡើងគង់នៅតែទ្វាយទូល់ រកផលប្រយោជន៍ឲ្យគ្រប់យ៉ាង ។ ចំណងពីរគឺឃើ ពេញជាស្នេហ៍ស្និទ្ធជិតជិតខាង ឋណ្ដោយភាមចិត្តឯងស្និតស្នាង តុបតែងគ្រប់យ៉ាងសំអាងប្រាណ ។ ចំណងខ្លាំបីសម្បត្តិទៃព្យ គិតជាប់ជានិច្ចក្នុងមិនបានសូម្បីជីវិតជិតចាកប្រាណ សន្ធានទៅផ្ទះហួងនន្ទាន ។ ប្រសិនជាមានដើងបំណុល ឥតយោកឥតយល់គ្នាឥត់ហ្នាន គិតដើមគិតការគោងបំពាន ចង់មានទាំងពេកវេកមិនលត់ ។

ប្រមូលបានៈច្រើនជាងម៉ឺនសែន មិនទាន់ដល់កេណ្ឌចិត្តលាមក
គេលយប់ងងុយអង្គុយងក់ ពុំហ៊ានដេកលក់ខ្លាចចោរលួច ។ ភ្លាំងហើយហៅជាប់ដួលចែកត់ អង្វាក់នេះគាញពិបាកវែង វិតក្តីតតាយវិតកែងស្ពឹក ក្រែបួចកែមាត់ជាអត់ភ័យ ។

វិធីនេះធម៌កុំច្រឡំ បើចិត្តយើងមាំខ្លាំបម្រៃ ព្រះពុទ្ធគ្រាស់សម្តែយ គ្រប់លែតំនិតគិតមើលផង ។ បើបានជាចេះឲ្យដល់ចេះ កុំរែកគ្រងនូនតែខ្លួង ប្រយោជន៍ក្នុងលោកឈ្មោកមើលផង ប្រឡងម្តេចបាន

ឧត្តមមិត្តនេះ ។ ក្រែងតែមកជាធម្មតា គួរណែនាំមិនដើរទៅមានៈ លោកមួលស្រួលមិត្តមិនគិតខ្វះ ចណ្តាយឲ្យខ្លះៗភ្ញាសជាតិ ។

ប្រតិកម្មព័ត៌មានគារធ៌ បន្ទុំដ្ឋានភ្លឺព្រោងព្រាត ប្រយោជន៍ឲ្យរៀនមានមារយាទ អាណិតជល់ជាតិឲ្យចេះដឹងធំ ។ បើចេះតែអាងលះនៅឡើយមិនរមិលគុណហើយបើម្តុំធំ។ ចំណងចាំធំបីស្តីថាតឹង សម្ងំធំមើលទៅទៅតែចាស់ ។ នរណាខំធំដឹងថាស្ងាប់ស្អែក ឧត្តមគាលប្រតែកគិតលោស់ ប៉ើរូបនាមរស់នៅស្រស់។ ស្តានឲ្យចេះបានអ៊ីស៊ី ។

តែងឲ្យតែធំពនប្រតន្តកូន ជាតែឯងសណ្តូនធួនតន្ទឹយ តែងំរោះវាឃ្លានស្តានអ៊ីស៊ី ចរប្រែបំសព្វទិសុំបានគេ ។ នេះព្រោះតែខ្វាត់អត់ចំណេះ មិនចេះផ្លូវលោកមិនកើតទេ ត្រូវតែឲ្យបាន់សម័យគេគិតរៀនទៅតែក្តីចំរើន ។

៦- គួរខ្វាបខ្នងក្មាយជាក្តៀវក្លា បញ្ហាថាចិត្តវង្វែនច្រែនពាក់ព័ន្ធនឹងសេចក្តីចំរើន ខន្ធើនកេរ្តិ៍សម្តីគ្នាម្នេណ៍ ។ ហ៊ានបាញ់ចាក់កាប់ជាប់ប្រមាទ ព្យាបាទមនុស្សសត្វឥតច្រឡំ ហ៊ានជាល់ហ៊ានតប់ហ៊ានវាយដំ សន្សំសាងកម្មពុំមេត្តា ។ សត្វស្រុកសត្វព្រៃរំពៃចាប់សម្លាប់ស៊ីលេងតាមចេតនា នេះហើយគួរខ្វាបខ្នងក្តៀវក្លា ប្រាថ្នាឥតស្តាប់ជាប់ជាទិច្ច ។

ដ៏វែងឆ្ងល់ខ្លួនៗខ្លាចស្លាប់ ត្រង់សត្វសម្លាប់មិនចេះតែង មិនយល់ពោសថ្ងាណាជាន់ជាលិច ខន្ធិចលើកុក្កុមុះកែកយ ។ ត្រូវតែត្រូវការដៃខ្លារឆក់ សម្លក់ក្អែកតឹងស្លឹងឥន្ទាយ ទុកាសណាស្រួលខំនួលដាយ ខំលាយសុខគេមិនឲ្យសល់ ។ ពោះបុត្រកំយោលោកអ្នកណា ស្រកាំងនេត្រាស្រាវដល់ បញ្ឆោតកូតកូរហ៊ានជាយកល់ ស្លឹងផលប្រយោជន៍ខ្មោចលែងខ្លាស ។ ប្រសិនជាចិត្តឥតចេះខឹង ចែកខំកសែវែងតឹងអុខគាស់ ចំពុលរបងាយសប្បាយណាស់ នៃនាសថ្ងាក់កាសកំមិនថា ។ ថ្ងាដូច្នាបថាផ្លូវនេះត្រូវលេះ វែប្រាមានះចិត្តក្លៀវក្លា បើសប្បុរសដំពូកណា ដែះថ្ងាកន្ធមប្រព្រឹត្តត្រូវ ។ ដនណាចិត្តលោកល្មោកលោកយ តែស្តីបៃបនោះវាងុសផ្លូវ សម័យនំយមយើងឥឡូវលោកត្រូវការប្រើវិទ្យាសាស្ត្រ ។

ប្រសិនជាមិនចង់ចាំចេះ ចំណេះវាខ្វត់អត់ខ្វាំងណាស់ តែទំប្រមាទាតថ្ងាក់កាស វាខ្លាសកូនក្មេងលេងកាលណា ។ កុំគាលអាងលះវែកងមិនលុះ តែរៀងដំពុះតុះថ្ងាថ្ម ខាន់មានកម្លាំងតាំងចិត្តា សិក្សារៀនសូត្រសិល្បៈ ។ រមស់គួរខ្លាចកូនលោកយ គប្បីចៀសវាងចិញ្ចាំ[1] ឲ្យគេញៀនឥន្ធិលៈ នៅត្រង់ខណៈចិត្តយើងផង ។

---

១ អ្វី ។ ត្រង់យ៉ាងត្រង់ចង់ពួក (ពាក្យថៃ) ។

តីកុំពាហានបំភាន់ឲ្យប្រាប់ សណ្តាប់អ្នកស្រុកតើតស៊ៅហ្នង ពាជការ
មានគុណគួរតបស្នង ត្រូវសែរដោយកតវេទី ។

គួរដឹងឲ្យដល់ជាវិញ្ញា ដែលបេះពាល់គ្នាមានរកស៊ី មានស័ក្តិមាន
យសខ្ពស់ឥន្ទ្រិយ មកពីពាជការលោកអាណិត ។ បើមានចំណេះបេះ
អស្ចារ្យ ប៉ុន្តែពាជការលោកមិនស្និត មុខជាត្រូវត្រៀមត្រៀបត
ព្រោះចិត្តច្រមាទទាត្រូវយោធន៍ ។ ជីវិតដើរដិតតែដុំលោក កុំឲ្យល់គួរ
ឈ្លោកវាកចាមោជ្ឈ គោះឆ្ងាយគោះជិតតិតឲ្យភ្ញាប ត្រូវឃុកច្រវាយោធន៍
ត្រូវប្រយ័ត្ន ។ មួយព្រះបរមសម្ភារ ព្រះទ័យសាធារណ៍វិសេសក្តាត់
បមបក្រព័ត្រមហាក្សត្រ ឆ្នើមកម្ពុជរដ្ឋពាជប្បវ័ ។ ព្រះអង្គជាមូលប់ស្រប់
ត្រជាក់ ពស្តុងតំនាក់ជ្រកកេស៊ី ត្រូវមកក្លាន្តដោយបុណ្យព្រះចារមី
ផែនដីសុខុមចំរើនជល ។ នេះគួរកុំភ្លេចឆ្នេចក្តែកដិត ត្រូវតិតព្រះគុណ
ជាប់តមល ពេលយប់គោរពំលឹកដល់ ព្រះគុណដំកល់លើកេសា ។
ឲ្យពេញជាកស្តេដែលកត្តី ទ័ងម្ចាស់សីរីនៃអាត្មា. យើងជាប់ជ្រកបុណ្យតីដូនតា ចាំងពូជពង្សាសាប់សន្ធាន ។ ប្រព្រឹត្តទៅបាននេះទើប
អ្នកប្រាជ្ញ ហៅថាបេះខ្លាចមិនក្លាហាន ទៅអនាគតតង់តែឃ្លាន សម្បត្តិ
ស្ទុះសាន្តសំពន្ធចិត្ត ។

ពី- រីឯដែងផ្លែមិនស្ងួតណា ចាន់ដល់ចណ្តាញ់លក្ខតែ រីឯ
ពាណិជ្ជបេះមិនស្ងួត ប្រយ័ត្នតបកូតអួតឥតប្រាជ្ញ ។ មិនបាច់តែតិតាប់

ស្តាប់ទុក្ខ អាងទ្រាតអួតឈ្មោះគ្រែគោះកាច មោហ៍មុខឡូដ្រុលចិត្ត
ឥតចេះខ្លាច ប្រើប្រាស់ព្រៃស្មោះមិនអស់ព្រៃល ។ ពុទ្ធាធិប្បាយបីកញ្ចឹ
ត្រង់ធ្វើត្រូវពិតគ្មានតិតមើល ពោលធម៌ការលោភជាតង់ឆើល ហៅ
ព្រៃលហួសប្រាប់ប្រាស់ចាកផ្លូវ ។ មនុស្សដើរវង្វេងមិនលេងទេ មិន
សួរនាំគេណានឹងត្រូវ តង់ឃ្លាតចំណងខ្លួនឥឡូវ រកផ្លូវមួយជាតិមិន
ចេះចំ ។ សូម្បីលោកយដ៏ផែនខ្មែរ យើងដែលយាងដើរកុំច្រឡំ
តែក្លាត់ល្បត់ផ្លូវមិនសូវសម លែងចំមួយជាតិឃ្លាតវិញ ។

លោកថាប្រមាទជាត់បុណ្យ ចិត្តដួសរវាងនគ្មានសង្ឃ មានះ
ជាត់មិត្តឥតឥន្ទ្រីគា វិជ្ជានឹងចេះមកពីចិត្ត ។ បើមិនរៀនសូត្រឬសិក្សា
ប្រាជ្ញក៏អាប់ចាប់មិនស្អិត ធ្វើខ្លួនមិនខ្លាចខ្លាមិនស្បែត ហៅមិនអាណិត
អាសូរគេយ ។ លោកថានៅស្រែកស្រាសបន្ទាំ អាសាច់ជួនខ្លាកុំខ្លាច
ស្តាយ វិជ្ជានឹងតើតមកពីកាយ កុំណាយខ្លាចនឿយគិតឲ្យយល់ ។

๘ - ឥតឹងបច្ចុតិតអារ្ទ្រ ទុតនេះពុទ្ធមង្គល សូមពណ៌នា
ភាក្យពន្យល់ ថាតីបុគ្គលមានតណ្ហា ។ ប៉ារេចសមិនចង់ត្រង់ឈឺ
ចាប់ មិនចង់ចាស់ស្លាប់ចាកធម្មតា ប៉ុន្តែមិនរកគ្រឿងសង្ក្រា តនឹង
បច្ចាមច្ចុរាជ ។ រៀលរៀងនឹងនឹងរូបទាម ទង្វាមត្រែតនឹកតាំងព្រឹក
កន្លងផ្តាច់សូន្យឈឹងដោយឋុទ្ធិរបស់ខ្លាំង គ្មានដូចជាព្រះគោតមត្បូរផែលអស្ចារ្យតែម្តងឡើយ ។ បុរសកំសត់ជោកទុក្ខនោយសោកស្តើរតែនឹងសន្លប់ផ្តាំស្មារតី ដោយការតាន់តឹងក្នុងទ្រូងដ៏ហួសប្រមាណ ។ ក្នុងពេលផែលជនទាំង ៣ នាក់ចែកគ្នានោះ ជារពេលថ្ងៃល្ងាចតឹងក្តុំស្រទំនន់តាបរៀបនឹងអស្តង្គតរលត់ផ្តាត់ភ្នែ, មានសេចក្តីអស្ចារ្យប្លែក, ពៃព្រាំងមួលក៏ហាក់ដូចជាបញ្ចេញសូរសំឡេងលាន់ឮអូរខ្ទេកនឹងពេង, ដើមឈើតូចធំក៏ហាក់ដូចជាមានស្មារតីស្រទោនញេមគ្រែមគ្រែ ជួយការនាំទុក្ខជួយព្រួយដាមួយនឹងជនទាំងនោះឯង មុខតួឱ្យស្រណោះអាណោចអាធ័មគេកក្តាត់ ។ ឯស្លាមីសង្រែងនឹងសង្រែរៀបកាប់មួយសន្ទុះ ទើបពកួនលែតឡប់មកកាន់ផ្ទះវិញ; ចាប់ដើមតាំងអំពីថ្ងៃនោះមក, បុរសកំសត់មួយអន្ទេះដោយកួនតួច តែនឹងដើរទៅអង្គុយយំសោកត្រកាមគល់ឈើនោះហើយស្រែកដង្ហើយក្តៅនឹង ហៅឋុជាតិតែងឱ្យនាងត្រឡប់វិញ, ធ្វើយ៉ាងនេះរៀងរាល់ថ្ងៃមិនដែលខាន តាល់តែស្លាំងស្តូមអស់ពាងក្រាណាប៉ុន្តែមិនអាចហៅនាងឱ្យត្រឡប់វិញបានឡើយ, ទឹងឡើងទៅតាន់យកផ្តាំនោះក៏មិនបានដោយឋុទ្ធិរបស់ខេតកញ្ញា; សំឡេងដែលស្រែកហៅអង្វរពេលថ្ងៃនោះគ្រាន់តែឃ្លាតចេញអំពីមាត់ប៉ុណ្ណោះ ហើយសាត់រលាតទៅតាមខ្យល់ផ្តាត់សូន្យឈឹងឥតច្រះយោជន៍ ។

រួបរួមសេចក្តីផាតតិយាំងនេះ

អតិថ្លាបុរសក្រែកំសត់ ... គោកយ៉ាកទុំតតពេកកខ្វក់
ជាខន្ធបរិនស្រីស្រែស្រស់ខួនល្អត ... សែនគាប់ចំណង់ឥតអ្វីផ្ទឹម ។
ភ្លេចនឹកដល់ធម៌ទិវេរៀងខាត់ ... តិតតែឯកព័ទ្ធហាញញឹម
ភ្លើតភ្លើសក្បាលព្រោះសង្សឹម ... បុប្ផាខួនឆ្ងីមតាំរើត ។
លុះដល់នាងងាកណាកលះចោល ... ទ្រុងដូចគេហោលធ្វើភ្លែកស្ងើត
តិតធ្វើដូចម្តេចក៏មិនកើត ... យំស្តាយនោមដើតស្តួមអាត្មា ។
ហេតុនេះព្រះពុទ្ធទើបប្រទាន ... ឲ្យដំបូន្មានយ៉ាងនេះថា
សត្វសត្វដៃលហែលសង្សារ ... កុំឈ្លក់កាមាហួសប្រមាណ ។
បើជាខសេចក្តីចំរើនហើយ ... កុំធ្វើកន្តើយគួរតិតអាន
ដំណាវវិនាសទៀតកុំខាន ... ដើម្បីទប់ប្រាណឲ្យតំនិតត្បៀ ។
ព្រោះធម៌តាំងនេះតិតមិត្រមួល ... មួយចេញមួយចូលតាមវេនពិត
បើធ្វើយ៉ាងនេះទើបក្សាន្តចិត្ត ... ដិលទុក្ខដើញក៏តិមិនវិលខ្លរ ។

លោកហាន់-យេង តែងនឹងរៀបរៀង

(តមក)

កាលៈបំនឹងបែកឃ្លាតគ្នាយូរអំពីនាងសាលីហើយ យើងគិតមើលចុះតើសុភនិន្ទនឹងគិតយ៉ាងណា ហើយយើងក៏មិនចង់ឲ្យសុភនិន្ទនឹកសាចាកគ្នាដែរ តែថាកម្មនេះមានមកដល់សុភនិន្ទយើង អនិច្ចាអើយ គឺដោយហេតុនេះដូចមានខាងក្រោមនេះ ។

ថ្ងៃមួយក្មេងកំព្រាខាំងពីកំពុងដើរលេងក្នុងសួនបន្លែ សុភនិន្ទឃើញខ្លែងដែលស្រាប់តែមួយស្រាប់តែ ពាក់មន្ទោចដ៏ខ្លាំងប្លែកឡាក់អាវអស់ធុមកុំនស្ទុយពេញខ្លួន ក៏ឡើងមកលើដុះស្រោចទឹកលាងដុះពាក់ហើយ កំដាក់ឲ្យអង្គុយយ៉ាងស្រួល ដើម្បីនឹងជុសលាងអាវខ្លួន ពេលនោះមានសត្វខ្លាដើរមកដល់នោះ កូនខ្លែយើញហើយលោតចាប់ ភ្លាត់ចំណាប់ជួលនឹងស្រែកយំខ្លាំង នាងសុវណ្ណបុប្ផាឮសំរែកយើញដូច្នោះ ក៏លើកកូនខ្លែដ៏ចិត្តនឹងសុភនិន្ទភ្លាំងណាស់ក៏ខ្ជាក់ដំបងមកនឹងក្រយ នាងសាលីលុតជង្គង់ចុះលើកដៃសំពះអង្វរថា : " សូមមានគោសអ្នកម៉ែ សុភនិន្ទឥតពុំសេច តើខ្ញុំនេះប៉ែរហែសជាក់កូនអ្នកម៉ែរចោលបានជាក់ជួលទៅ អ្នកម៉ែរក្រយខ្ញុំវិញចុះ" ។

សុវណ្ណបុប្ផាស្រែកតំហកឡើង " នាងឯងពីថ្ងៃនេះទៅលែងឡើងផ្ទះអញទៀត ព្រោះតែឯងហើយបានជាកូនអញក៏ជួល បែរមកវាយ

សុភិន្ទ ឯងនេះច្រើយ័តខ្លួនកុំទៅលេងជាមួយនឹងនាងនេះទៀត ច្រើឲ្យ
មើលប៉ុណ្ណឹងមើលមិនកើត ឲ្យក់ដួលក្បែកបង្ហើយអស់ ចាំមើលតែ
ស្អែកវាហៀរសំបោរហើយ រួចអញថែកូនណាស់មិនដួចម៉ែឯងទេ កុំ
ច្រលែសស្តាប់ចុងទេ" ថាហើយក៏ពកូនចូលទៅក្នុង ។

ចន្ថីបួនចាំងពីនាក់ ក៏នុចគ្នាយំនិយាយលាគ្នា នាងសាលីដើរ
ចេញទៅហើយចូលមកវិញសុំទៅនុចបង "បងអើយ តម្អូរយើងមក
បែកគ្នាដូច្នេះ ណ្តើយចុះបង យើងគង់នឹងឃើញមុខគ្នាពាក់ថ្ងៃទេ កុំកើត
ទុក្ខអី" ។

"អូនអើយ . . . . បង . . . . បងស្មើនឹងបែកខ្លួនស្លាប់ទៅ
ហើយ រួចក៏បែកគ្នាទីឆៃ។ ទៅ នាងសាលីចុះជណ្តើរផ្ទះទៅសឹងមិន
បង់ដុច ដើរមួយ។ ទឹកភ្នែកយំដៃលនាងគ្នាប់លេងជាមួយនឹងបងចាញ់ម
នាងនឹកស្រណោះគ្រប់ច្រកកន្លែងសង្វែងសង្វៃតាមផ្លូវទៅដល់ផ្ទះហើយ
នាងក៏មិនចុងញ៉ាំអាហារ ចូលក្នុងបន្ទប់គេងទៅចាំងសោកសៅ ។

ចំណែកខាងសុភិន្ទកុមារវិញ លុះច្រាស្ងាតកន្លួនសម្លាញ់ហើយ
ក៏ពុំស្បើយសោកទុក្ខណាស់ជ្រាបមុខមិនសប្បាយ ហួសនឹកដល់ម្តាយដែល
ខានឃើញមុខយូរណាស់មកហើយ ហួសនឹកដល់ឪពុកដែលជាបេះដូង
ខ្លួន ហួសនឹកដល់អនាគតមិនទៀង ក៏ណែនណាន់តានតឹងដើមទ្រូង
ខ្លោចផ្សាក្តៅក្រហាយ ទំនេីកាឲ្យហើយៈស្រងោយសំរក់ទឹកភ្នែក

បណ្តើរ បំតេញការណាឱយគិច្ចប្តូរហើយ ចូលតាន់ដំណេកភ្លាម ដោយ
អស់កំលាំងតេតកំលក់ទៅ ។

ដល់ឱប់ជ្រៃ ត្រូវខ្យល់ផាត់តាមបង្អួចចំហរចូលមក សុភិន្ទ
កើតជាក់ត្រាក់ខ្លើងរើបឈរត្រដឹបដួចនោះ ឃើញមេឃដឹតមើលទិស
តំបន់ពុំឃើញ ក៏ទំាងដល់ភាក្យដែលខ្លួនបានទិយាយថ្កាច់ថានឹងសាលីទៅ
ខាត់ដឹក សុភិន្ទក៏ស្រែកដឹកភ្នែកដោតដៃពាំងពីរ តិតថា "នុដ៏រតនភ្ញា
អញ្ញាខេះដូចជាខឹកហ្អប់ចុះមិនដែលខ្លើងរាំញ ទំាងត្រាំពុតម្ចោមម្នេញតទៅ
ឃើញតិជាកណាស់ តួរតែលះបង់ជីវិតខេះចោលចេញ ព័ត្រោះមនុស្ស
លោកត្រប់រូប តែងស្ងែងកសេចក្តីសុខពាល់គ្នា ព័ត្រោះពាក្យពាំរ
ម៉ាត់ថា "មិនកើត" នេះ ប្រយ័ត្នអស់ពាំងពុតត្រប់ប្រភារ តិតែងតែកន្ធក់
កន្ទេញកុំរៃជាចម្ងាស ឃើញថាខាទីវេសមនុស្សទៅក្នុងលោកក៏ផុតអស់
ក់រះប៉ុណ្ណឹងហើយ ។ មុខម្តាយក៏ពុំបានឃលជាខនាងសាលីមកត្រាន់
ទំាងឆ្ងាខ្លួន ឥឡូវត្រែវជ្រាសចាកខាងទៅខ្លៀត សុភិន្ទទឹកអណ្តែត
ដល់ខ្លួនតាន់ពោក តម្អូរហ្ន៎! មកវេទនាដូចេះ នុដើមខ្លួនអើយបើតានតំំង
យ៉ាងនេះ មុខជាន់ងវិចកខ្លាយជាពុំខាន នុសាលី ឯងទៅជាសុខចុះ
បងលាហើយ នុអ្នកម្តាយរបស់ក្មួន ក្មួនខានឃើញមុខអ្នកតីថ្ងៃនេះទៅ
ហើយ ធ្វើម្តេច អ្នកនឹងបានជំងឺដំណឹងក្មួនអេះអ្នកមេ ! ។

ថាផុតព័ទាត់ហើយក៏លោតចុះពីលើផ្ទះ ចំរុងនឹងសម្ងាប់ខ្លួនឱ្យស្លាប់លាន់សូរក្តុក រួចសូរសំឡេងថ្លាលាន់ឡើងយ៉ាងខ្លាំងពាក្យលាត្រដាស្ងាត់តមកឮសូរដូចជាបម្រែនេខៀលប្រុសធ្វាសមួយសន្ទុះ ហើយស្ងាត់ឈឹងទៅ ឯងឹតមើលអ្វីពុំឃើញសំឡឹងមើលពុំជាក់ មួយស្របក់ក្រោយមកមានខ្លែងស្រោកស្រែកច្រឡំហើរកាត់ទៅ លាន់ក្រឡុងដល់គ្រប់ក្បាលដាំសាលំ នាងភ្ញាក់ឡើងរួញខ្លួនញាប់ញ័រចំប្រប់ពុំដឹងដោយហេតុអ្វីនាងហួសនឹកដល់ចងចិញ្ចឹម ហើយក៏យំខាំងក្បាលយប់ ។

*

* *

បទទី ៩

ប្លែងអំពីរ័ត្នគារ

អ្នកផងតែងនិយមថា កាលបើយ៉ាតចេញចាកគ្នាឆ្ងាយខ្លែងហើយកាលបើចាត់មុខចាត់មាត់លែងឃើញជាយូរវែងថ្ងៃ ចិត្តក៏រសាយឆ្ងាយពីគ្នាដែរ ភ្លេចលែងនឹកនាតទៅទៀត ហាក់ដូចជាខ្ញុំបានដែលខ្លួនបានផ្តាច់ពីកាលមុនសោះសូន្យចាត់ចង់ទៅហើយ ព្រោះមិត្តភាពនឹងតែងគ្រងបាន ក៏ពីព្រោះការពាក់ព័ន្ធគ្នាទៅវិញទៅមក ការជួយកិច្ចធុរៈថ្ងៃយប់នឹងអំណោយទៅវិញទៅមក សេចក្តីឃើលនេះក៏ត្រូវពាំងអស់គ្រប់ហ្នឹងនាំឱ្យយើងនឹកឃើញថា ចិត្តមនុស្សលោកតែងវិលប្រែប្រួលមិនទៀងទាត់

ប៉ាដូចជាផ្ទៃនៃមហាសមុទ្រ ពុកជាមានអ្នកខ្វះសន្យាថានឹងមិនភ្លេចគ្នាទេ
សេចក្តីស្លាប់ដូចម្តេចក្តី តាលេប៉ាហ្នាតគ្នាហើយ ចិត្តក៏គ្រាតចេញពីគ្នា
ទៅវិញ ក្រែណាស់ដែលចិត្តនឹងមានសំវែងសេចក្តីតិតតែមួយ ។

មិនត្រឹមតែមិត្តភាពដម្នាក់ទេ សូម្បីតែកូនបង្កើត តាលេប៉ាចាក
ចេញទៅយូរតិចនៅដែលខ្លួនបានឃើញ ពន្ធុ ព្រះអាទិត្យហើយក៏នឹងតែ
ភ្លេចនឹកឥតពុកម្តាយបងប្អូនដែរ បើដាច់នឹកក៏នឹកយ៉ាងធំយ៉ាង ចំណែកចិត្ត
មាតាដែលស្រឡាញ់បុត្រវិញ ពុកជាចាត់មុខកូនអស់កំណត់ច្រើនទៅទៀត
ក្រៃពេក ក៏នឹងតែនឹករលឹកដល់កូនជានិច្ចមិនដែលលោះមានថ្ងៃណាមួយ
បេះតែត្រយ៉ាចវៃក្រែងកូនអត់ឃ្លានឬឈឺចាប់ តែងចាម្តៃក្រែងមាន
គ្រោះថ្នាក់ធ្លាក់ដល់កូន ឬទុកាលអ្នកក៏មានទឹកភ្នែករលេងរលោងដោរ
ដល់ឡើង ពុកជាកូនពេញរូបពេញភក្ត្រពេញត្រចៀកមុំកំឡោះក្តី កំភ្លាយទៅ
តែពុកដូចជាកូនតូច ដែលអ្នកនៅឋបោសអង្អែលនៅឡើយ ។

ឧបាទិត្តមាតា តែងប្រកបដោយសេចក្តីករុណាជាគារ្ភាភាព សាយ
ទូលាយវែងឆ្ងាយដូចក្រសែទឹកដែលហូរមិនចេះដាច់ ហើយដែល
ត្រជាក់ស្មើនៃបំផ្លូវ! តែងប្រាថ្នាឲ្យកូនបានចេះបុត្រមិនចេះអស់! ចិត្តនេះ
ប្រសើរនៃលែង តែងដ្បាយទូវព្រហ្មវិហារធម៌ចំពោះបុត្រឥតឈប់ឈាន
ហើយគ្មានសង្ឃឹមអ្វីអំពីកូន ក្រៅពីសេចក្តីសុខរបស់កូនប៉ុណ្ណោះ ហើយ
តែងអង់ធ្លត់សន្ធោសនៃប់ភាល ចិត្តនេះធំលើសលុបជាងនៃតភព ឧដ្ឋិតកេ

ពាក្យជាការសាមមនុស្សសរសើរទូរគុណសម្បត្តិនៃចិត្តនោះមិនបាន ព្រោះចិត្តនេះល្អដ៏ល្អើយឥតកោះត្រើយ ហើយសំដីមនុស្សលោកមិនអាចតាមដល់ តួរតែបាវីកំជាអក្សរមាសលើផែនថ្មមឬ ពុកជាបូជនីយវត្ថុជាខ័ណ្ឌពេកប់អាននៃបុត្រតាំងឡាយ ទឹកភ្នែកគួរឲ្យស្តាយឥតខំពេកណាស់ដោយស្មារបាំកំកាមិនអាចទំនងសរសេរត្រាប់បាន ពិតរហ័យជាចិត្តបានខ្ពស់ដុតខ្ពស់ដ៏ទឹងប្រកាំមិនបានឈោងមិនដល់ ស្រាប់តែដ៏ងាខ្លៅត្រប់តំបន់ប៉ុណ្ណោះ ។

តាមសេចក្តីនេះ យើងក៏អាចនឹងថ្លឹងទូរទុក្ខរបស់ព្រះនាងវិ ដែលតែងនឹកឃើញកដល់បុត្រត្រប់ៗ អាទិ ទឹកភ្នែកតែងហូរស្រោចជោកខ្នងល់ខ្នើយ នាងមិនចេះបានរស្យើយតែងសោយសោកខ្នត់អស់អង្គខំផ្ទួនស្មារតើទូរពេលដែលមានភ្ញៀវខ្សឹងជូន ព្រោះនាងនៅសំណាក់ជូនមារបស់នាង ហើយអ្នកទាំងអស់គ្នាក៏ថ្នមនាងមិនឲ្យអាក់អន់ចិត្តពុកជានាងបានរសេចក្តីសុខត្រប់ចំពូក នាងក៏នៅតែមិនស្រស់ស្រាយសប្បាយចិត្តឯកាយរបស់នាងក៏ទ្រុឌទ្រោមទៅជាលំដាប់ ហើយទាំងក៏មានជម្ងឺឈឺកុំរៃតែប្រមល់ពន់ពេក ។

នាងបានសរសេរសំបុត្រពីរច្បាប់ផ្ញើទៅឲ្យកូន តែគ្មានឃើញកូនតបមកវិញដល់ម្តង នាងក៏បេះតែខន្ធឹងមើលថ្ងូរ ក៏គិតថា នេះប្រាស់ជាសុំណាប្អូនបាត់យកសាក់ហើយមើលទៅ តកូនសម្លាញ់ឱ្យអើយ

សមកូនលំបាកណាស់ហើយមើលទៅ សមខ្លាចបុន្មានឯងនេះធ្វើបាបកូន
ទៅទ្រែនេះហ៎ាយ តុកូនមាសស្អាយ តើកូនទៅរៀនទៅខ្វែយប្តូរម្តេចទៅ
បានជាទៅមិនឲ្យដំណឹងម្តាយបានដឹងផង ទឹកភ្នែកក៏បេះតែហូរមកឥត
ឈប់ បិត្តនាងក៏កណ្តែនដកឥតត្រាក តុកាលណាខ្វែយទំនិងបាន
សុខ្វែយកូនអេះ មិនគួរសោះខ្វែយសុំណាប្តូរ ឥឡូវនេះទំនិងទំនងក៏ពុំ
កើត នេះគឺកម្មពៀរពេកបង់នាងពីព្រែងនាយតាមមកទាន់ ។

ខែមនាងខែកចាយសម្បត្តិបង់នាងជាក់ខានធ្វើបុណ្យមិនចំពោះ
ម្តុំ ហើយសង្ឃអធិដ្ឋានឲ្យបានបួបមុខកូន នាងក៏សមាទានចោសឥ-
សីលមិនដែលខាន តែងមានចិត្តសង្វាជ្រះថ្លាជួយសង្គ្រោះអ្នកទីលាល់
គ្រមានខ្លួនព្រួយ ហើយនាងតែងថ្នាក់ថ្នមកេងដូចជាកូននាងបង្កើត
អំបាលអើយ កាលណានាងក្រែកឡែកឃើញកូនគេល្អ។ ក៏ចូលទៅជិត
លើកមកបីបម្រាក់ថ្នមត ហើយនាងទៅតែទឹកឃើញថា នាងមានកូន
សំឡាញ់មួយដែរ ឥឡូវកូនសំឡាញ់នោះភ្លាត់ឆ្ងាយពីដើមទ្រូងនាង
ទៅហើយ ។ . . . . . ។

ចំណែកឯមាបង់នាង កាលបើឃើញកូនព្រួយចិត្ត ក៏នាំនាងទៅ
មើលវាំងកុនត្រែបសព្វ ទឹងនាំនាងដើរដំណើរទៅលេងមាត់សមុទ្រហើយ
តែងនាំមកលេងផ្ទះដើម្បីឲ្យនាងក្តេបខ្លួនខ្លះ កាលមានគេមកនិយាយ

ដុំៗ ពីនេះពីនោះ នាងក៏ឱនស្បៃយកទុក្ខខ្លះ តែគេមើលអស់មើល នាងរឹងតែចម្រៀងចិត្តលើសដើម សោកស្តាយមិនគួរបណ្តោយចិត្តឲ្យសប្បាយសោះ តែងណាដែលកូនតំពូងរងទុក្ខធ្ងន់ ទើបមានបន្ទាន់ចែកគំនិតមួយជាថ្មីទៀត បើមិនអាចនឹងបំបាត់ទុក្ខនោះបានទេ គួរតែបណ្តោយទៅចុះ ហើយនឹងគិតលៃលកឲ្យនាងមានទឹកចិត្តថ្មី តិតិតរកប្តីឲ្យគួរសមដល់នាង ។

បណ្តាក្បែរដែលទស្សាហ៍មកលេងផ្ទះនោះ មានបុរសកណ្តាលអាយុខ្នាក់ មានឋានៈជាចៅក្រមសាលាដំបូង មានកិរិយាស្រគត់ស្រគំរមនមល្អ គួរឲ្យផ្ញើរត្នាត់បាន ហើយចៅក្រមនោះក៏ស្រឡាញ់នាងយ៉ាងខ្លាំង តែងយកចិត្តទុកដាក់ធ្វើឲ្យនាងសប្បាយ ទុកជានាងព្រងើយកន្តើយយ៉ាងណាក៏មិនណាយចិត្តដែរ ថ្ងៃមួយអត់ទាំពុំបាន ក៏ថ្ងៃនេះចក្តីនោះច្បាប់ដល់មាឃស់នាង មាឃស់នាងគិតមួយស្របក់ក៏និយាយឡើងថា: "លោក! ខ្ញុំសព្វថ្ងៃក៏គិតទុកដាក់កុងដែរ តែដួចលោកជាបស្រាប់ហើយ កុងខ្ញុំវាកើតទុក្ខណាស់សព្វថ្ងៃនេះ បានជាខ្ញុំមិនប្រគល់ដល់ដៃអ្នកដែលខ្ញុំមិនទុកចិត្ត បើបានទៅលោកនោះខ្ញុំមានចិត្តត្រេកអរណាស់ដោយសង្ឃឹមថា លោកនឹងធ្វើឲ្យនាងបានសប្បាយ បើដូច្នេះខ្ញុំសូមប្រគល់នាងដល់លោក តែគោរលោកសន្យាថា មិនធ្វើឲ្យនាងអាក់អន់ចិត្តដល់ថ្ងៃក្រោយ" ។ (មានត)

អារម្ភកថា

អស់លោក-អ្នកជាធំក្នុង ឃើញថាបច្ចាស់ថាបច្ចាប់ក្រមនេះសុទ្ធ
សឹងជាសុភាសិតល្អៗទាំងអស់ ជាដំបូន្មានដែលបុព្វាចារ្យបានរៀ
បរៀងតាមដោយគន្ថន៍ធម៌ផង តាមដោយគន្ថន៍បច្ចាប់ប្រពៃណី
ផង ដើម្បីទុកឱ្យយើងកាលក្នុង យកជាដំបៅប្រដៅខ្លួនឱ្យបានល្អក្នុងលោក
នេះ នឹងបានលោកខាងមុខ នឹងប្រយោជន៍ដ៏ប្រសើរតែពុំខានឡើយ. តែភាគ
ច្រើនលោកជាធំអម្បាលម៉ានៗ ខ្លះគឺជាយល្មមស្គាល់ច្បាប់ ខ្លះសោតជាបញ្ហា
ឱ្យហើងត្រែរិះគិតរកវិធីណា តាមរបៀបលំនៅទើបយល់ក្តី ។

ហេតុដូច្នេះខ្ញុំយកបច្ចាប់ក្រមនេះ មកកែស្រាយតាមរបៀបជាសេចក្តី
បកប្រែ ហៅថា "បច្ចាប់ក្រមបកប្រែ" ដើម្បីឱ្យយុវជន ដែលនៅខ្វះ
សេចក្តី ជាយស្គាល់ច្បាប់ច្បាស់ចិត្ត ។

អ្នករៀបរៀង ញឹក-ឆ្ង (ត្រួតពិនិត្យ)

ចប្បាប់ក្រែមចរំយាយ

លោកញ៉ែក-នួ ក្រូបង្រៀនជំនួយ

នៅវិទ្យាល័យស៊ីសុវត្ថិ

ទី-១ ២ នេះគឺចប្បាប់ក្រែម ប្រសើរឧត្តម ទូន្មាន អ្នកជន ប្រើដិនល់នោន កុំបីមានឆ្គង ទ្រាជាបុណ្យ ជន កើតដោយប្រតិបត្តិ ។

ជានសេចក្តីថា ចប្បាប់ក្រមនេះជាសុភាសិត មានខ្លឹមសារដ៏ប្រ-សើរវិសេសវិសាល លោកមានមេត្តាករុណាចំពោះ ឯក្រោយ ចង់ឲ្យមានប្រាជ្ញាទន់ជានបុណ្យ ដូច្នេះហើយ ទើបលោកពោលជាបញ្ញាឧកមកឲ្យ ជានជាដំបូងថា "ប្រើដនល់នោន កុំបីមានឆ្គង ប្រាជ្ញាបុណ្យជន កើតដោយប្រតិបត្តិ" នេះជាពាក្យសំខាន់, គឺថា បើចង់ជានប្រាជ្ញា ទន់ជានបុណ្យ ចូរអ្នកចាំតួនខំធ្វើតិច្ចការ: ប្រតិបត្តិឲ្យសុភាពរៀបរយ កុំគប្បីឲ្យឆ្គង, ព្រោះលោកឃើញថា ប្រាជ្ញាទន់បុណ្យ កើតឡើងជាន ដោយសេចក្តីប្រតិបត្តិ តែយើងត្រូវស្គាល់ថាអ្វីជាប្រាជ្ញា? អ្វីជាបុណ្យ? អ្វីជាសេចក្តីប្រតិបត្តិ?

"ប្រាជ្ញា" គឺដឹងខ្លួនឯង យល់ដាក់ច្បាស់ដោយញាណខ្លួនតិច្ចការ ចាំនតួន ល្អទន់អាក្រក់ ពិតទន់មិនពិត ។

"បុណ្យ" គឺសេចក្តីសុខ, កុសល, អំពើល្អ ។ មួយយ៉ាងទៀត ដូចជាពាក្យថា "បុណ្យសម្តី" គឺសម្តីយ៉ាងណាដែលសម្តែងឲ្យសត្វនៅក្នុងទុក្ខមានសេចក្តីសុខ ឬមានការងារដែលបរិសុទ្ធ ។

"ប្រតិបត្តិបុបដិបត្តិ" គឺការប្រតិបត្តិតាម, ការធ្វើតាមគន្ថធម៌ឬបច្ចាប់ ។

បើនិយមន័យបញ្ជាក់ប្រមូលសេចក្តីពាក្យយ៉ាងដូច្នេះយើញថា ការដែលប្រតិបត្តិធ្វើតាមនេះ ជាបុគ្គលាគល់ពាក្យឲ្យជុះប្រាជ្ញា ឲ្យបានបុណ្យសម្តី ទើបបុណ្យកុសល, សេចក្តីប្រតិបត្តិនេះ ជាហេតុឲ្យខ្ពើមរអើមក្នុងលោកនេះ ខំឆ្លៀតលោកខាងមុខ, តែគេបដិបត្តិ ធ្វើតាមអ្នកឯណា? ធ្វើតាមយ៉ាងណា? ថាត្រូវបដិបត្តិធ្វើតាមពាក្យសុភាសិតដែលជាឧត្តមល្អ គឺពាក្យប្រដៅរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ក្តី ទេវតាលោកអ្នកប្រាជ្ញក្តី ។

សុភាសិតនេះត្រូវគាំទ្រជាងៗ អាណាចក្រក៏ត្រូវ ផ្ទះគ្រួសារក៏ត្រូវ ។

ចំណែកអាណាចក្រ យើងកាលគ្មានបានយើញច្បាស់ខ្លឹមក្នុងទេសយើង តុំចាំបាច់ទៅសួរដល់អ្នកណាទៀតឡើយ, យើងយើញហើយបណ្តាសេនាបតីអាមាត្យមុខមន្ត្រីធំតូច នៅក្នុងប្រទេសនានា សុទ្ធសឹង

តែលោកអ្នកប្រតិបត្តិដោយយសស័ក្តិ ដោយបញ្ញាមុតថ្លាវាងវៃឈ្លាសក្នុងការដែលលោកធ្វើ ជាប្រយោជន៍ដល់ផែនដី ។

ចុះអំពើល្អទាំងនេះ ដែលគេតែងឡើងដល់លោក តើមកពីហេតុអ្វី? ជាមកពីសេចក្តីប្រតិបត្តិធ្វើតាមគតិតាមច្បាប់ដែលគាប្បីលោក ដែលគាលលោកបានបួលឲ្យគាន់សំណាក់អស្រ័យសុំរៀនចំណេះវិជ្ជា ។

លោកខំសង្កាត់ចំពែកវិជ្ជាប្រាជ្ញាដោយការរៀនសូត្រការស្តាប់ត្រាប់តែងធ្វើតាម ហើយកត់សំគាល់ខុតតរៀងមក ដោយការគិតតាមយោបល់ឲ្យយល់ច្បាស់ក្នុងកិច្ចការផ្សេង ។ កាលលោកនៅជាសិស្សសោលកំពុងរកវិជ្ជាជាក់ខ្លួននេះជាហេតុ, ដល់បានជាឫកជការហើយ លោកក៏មានចិត្ត ប្រតិបត្តិច្បាប់ខ្ជាប់ខ្ជួនរបស់ស្រុងនគរ ធ្វើតាមពាក្យបង្គាប់ខ្ជួនរបស់នាយចៅហ្វាយ លុះត្រាតែលោកបានឡើងយសស័ក្តិដ៏ធ្ងន់ខ្ពស់នេះជាផល ។

ដូច្នេះយើញថា បុណ្យបានមកពីបញ្ញា គឺចំណេះវិជ្ជា ។ បានមកពីរៀន ប្រព្រឹត្តធ្វើតាមគ្រូអាចារ្យ បង្ហាត់បង្ហាញបង្រៀនប្រៀនប្រដៅមក ខំធ្វើតាមចៅហ្វាយនាយបង្គាប់បញ្ជា ក្នុងមុខក្រសួងការងារ ។

ឯមានពុទ្ធចរិកវិញក៏ដូចគ្នា តែត្រង់នេះត្រូវប្រែពាក្យ «បុណ្យ» ជាមុនសិន ក្នុងព្រះពុទ្ធសាសនាសំដៅយកសេចក្តីសុខ ។

ចុះយ៉ាងណាមិញ ? ថាជនដែលគោរពប្រតិបត្តិព្រះពុទ្ធសាសនា មានព្រះពុទ្ធសមណគោតម ជាព្រះបរមគ្រូដ៏ឧត្តមជាងព្រះធម៌ជ្រាសសត្វ ដោយទ្រង់មានព្រះហឫទ័យប្រកបដោយមេត្តាចម្រើនសត្វ កាត់ផ្តាច់ឱ្យរួចស្រឡះចេញពីគ្រឿងតឹងត្រឹងនិព្វាន ជាឋានបរមសុខ, នោះចេះតែសត្វណាស្តាប់ត្រាប់តាម ប្រតិបត្តិតាម តឹកសាងធ្វើបុណ្យឱ្យទានរៀនធម៌រក្សាសីល ចម្រើនកំណើតជាប ចេះតែបានអំពើជាប ចេះតែបានបុណ្យកុសល តើសេចក្តីសុខគ្មានទីបំផុតគ្មានដល់អ្នកនោះឯងពុំមាន ។

ទីបំផុតភាក្យលោកថា "ជ្រាជ្រាបុណ្យធំ កើតដោយប្រតិបត្តិ" នេះជាពាក្យដំបូន្មានល្អ គួរយើងកាលគ្មានស្តាប់ធ្វើតាម, ដើម្បីយកបុណ្យសំភ្លក្ខដ៏លោកនេះផង យកបុណ្យកុសលទៅបរលោកនាយផង ។

ទី ២- ឯអ្នកណា នោះយកអាត្មា ឬលសាសន៍ពុទ្ធរ័ត្ន ក្លាវក្លៀវឲ្យត្រង់ ដោយខ្លួនបង្គាត់ ហៅស្វែងសម្បត្តិ យកផ្លែនិព្វាន ។

អធិប្បាយថា មនុស្សឯណា ទើបនាំខ្លួនទៅបួសក្នុងពុទ្ធសាសន៍ដែលជាសាសនាល្អប្រពៃនេះ នោះត្រូវធ្វើឲ្យត្រង់ដោយខ្លួនបង្គាត់គឺវិន័យ ទើបបានឈ្មោះហៅថាជាអ្នកស្វែងរកសម្បត្តិព្រះនិព្វាន នេះពោលយ៉ាងនេះ ។

តទៅទំនើស្រាយឲ្យត្រចះត្រចង់ងាយស្តាប់ ឃានបន្តិចទៅទៀត ព្រោះលោកបង្គាប់ថា បើបុគ្គលឯណា ឃានចូលសាសន៍ព្រះពុទ្ធជាម្ចាស់ហើយ "ចូរឆ្លើងឲ្យត្រង់ដោយន័យវិបត្តនា" ។

ចុះមនុស្សដំពូកណា ដែលហៅថាចូលសាសន៍ព្រះពុទ្ធ? គឺអ្នកចូលទៅកាន់ព្រះពុទ្ធសាសនា តាំងខ្លួនជាពុទ្ធមាមក: ដឿកុងគុណព្រះរតនត្រ័យ តតសន្ធឹះសង្ឃ័យនូវពុទ្ធវិបទ: ហើយថ្វាយខ្លួនជាឧបាសក ឃកព្រះពុទ្ធព្រះធម៌ព្រះសង្ឃ ជាទីពឹងទំរង្វក ពុកស្មៅដោយដំរិត ឆ្នូកតាំងកម្សាលមាន់នេះ ពុំរើសមុខថាជាជាតិទ្វីរឡើយ ភ្លុំថាប្រុសថាស្រីពុំថាកុងឋាចាស់ ឲ្យតែមានចិត្តសទ្ធា ដឿជាកំកុងព្រះបវរពុទ្ធសាសនាប៉ុណ្ណោះឯង តើដឿសេចក្តីត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ដឿកម្ម-ផល ដឿចុះបទឹងបុណ្យ ហើយថ្វាយខ្លួនកុងព្រះពុទ្ធសាសនា, ខ្លះក៏សូមបព្វជ្ជាជាតិក្ខុ-សាមណេរ ខ្លះថ្វាយខ្លួនជាឧបាសក ជាឧបាសិកា, ហើយបុគ្គលទាំងនេះ ក៏ត្រូវប្រតិបត្តតាមកូមិរបស់ខ្លួន ឲ្យត្រឹមត្រង់តាមពុទ្ធបញ្ញត្តិ, តែចំណែកអ្នកបួស មានវិន័យសិក្ខាបទ ទឹងសីលសមាធិបញ្ញាជាបន្ទាត់ ឯត្រហស្ថវិញ មានកម្មបថ ១០ ប្រការ សីល ៥ ខ្លួវ សីល ៨ ជាបន្ទាត់ ។ តែហេតុដូចម្តេច ឃានជាលោកខ្លួនថាត្រូវធ្វើឲ្យត្រង់ខ្លៅនេះ ព្រោះដោយមនុស្សខ្លះ ឃានចូលទៅកាន់សំណាក់ព្រះពុទ្ធសាសនាហើយ តែពុំធ្វើកាយវាចាចិត្តឲ្យត្រង់ត្រូវតាមពុទ្ធឧវាទ,

ខ្ញុំប្រព្រឹត្តធ្វើសីលពុំបានជូនធំល្អបរិសុទ្ធឡើយ ខ្ញុំនឹងតាន់ត្រណម តមភាវបំភាមព្រះពុទ្ធពុំបាន ម្ល៉ោះហើយ ក៏បន្ទរបន្ទាយខ្លួនឯងដ៏ថា វិន័យ នេះតឹងតោក យើងធ្វើតែប៉ុណ្ណោះក៏បានដែរ បុគ្គលដំពូកនេះលោកពុំសរសើរឡើយ ។

"បើនរណាធ្វើកាយវាចាចិត្ត ជាន់ល្អត្រង់តាមបន្ទាត់ គឺសិក្ខាវិន័យ ដែលព្រះពុទ្ធអង្គត្រង់ប្រាប្តីប្តុគមកនោះ អ្នកនោះឯងឲ្យឈ្មោះថាជាអ្នកស្វែងរកសម្បត្តិ យកដួងព្រះនិព្វាន" ដែលជាហានបរមសុខ រំលត់ទុក្ខបាំងឆ្ងាយ, ដូច្នេះទើបលោកខ្ជាន់ឲ្យយើង "ចូលសាសន៍ពុទ្ធវត្តន៍" ហើយគោរពឲ្យត្រង់តាមធម៌វិន័យ ដែលជាបន្ទាត់ ទើបជាន់ដល់ត្រើយម្ខាង គឺព្រះនិព្វាននោះ ។

ទី ๓- ឯអ្នកកាន់ ដោះនឹងយល់ហោង ចិត្តដោះ ឮមិញ បំពេញព្រះធម្មសួ ដោយព្រះទុទ្ធាន ក្នុងទ្វើ ឈ្មោះហោង ដោយចិត្តអង្គារាល ។

អ្នកដឹងគាំងឆ្ងាយ ដើម្បីអ្នកដឹងពិតថា "ចូលសាសន៍ពុទ្ធវត្តន៍" នេះជាដំណើរល្អប្រពៃ ហើយយល់ជាក់ជាមាគ៌ាដោយសុគតិ ទើងព្រះនិព្វានបាន ដោយដំបូន្មានរបស់ព្រះពុទ្ធជាម្ចាស់នេះហើយ នោះបុរេអ្នកតាំងចិត្តឲ្យក្លាហានហ៊ានបំពេញជួស បួសជាសាមណេរឬជាភិក្ខុ កុំគប្បីធ្វើឆ្ពោះឆ្ពាសដោយចិត្តពាល នេះពោលដោយសង្ខេប ។ (មានន)

ហ្វូងនិពន្ធមន្ត្រី ញ៉ុក-ថែម

រៀបរៀង (ឥឡូវ)

អក្សរ ន

១ អ្នកមានមិនដែល ៣ គ អ្នកក្រមិនដែល ៣ ជាតិ ។

១ អ្នកដឹងដប់ មិនស្មើអ្នកប្រសប់មួយ ។

១ អ្នកដង្កុំគ្មើដែក អ្នកប្រមឹកកុំឆ្មើស្រា ។

១ អ្នកមានកុំអាលអរ អ្នកក្រកុំអាលភ័យ ។

១ អ្នកមានរក្សាខ្យាត់ ដូចសំពត់ព័ទ្ធតិក្រៅ ។

១ អ្នកមុនកំសោយ អ្នកក្រោយមានលាភ ។

១ អ្នកយោងគាន់ក្រោះតាមពាសី ចៅក្រមកាត់ក្តីតាមពាក្យបណ្តឹង។

១ អ្នកឡើងបានតែបេះ អ្នកចុះខ្សេរមិនបានស៊ុ ។

១ អ្នកហាលស្បែកដាច អ្នកភ្ញាចស្បែកជា ។

១ អ្នកដេកនាប់លក់ ដ្បិតឥតបើគិត ។

១ នាងគូទធំអ្នក មេទាតលក្ខណ៍គូទធំអាក់ជាក់ខន្សោ, ក្បត្តិគូទធំក្បត្តិ, ស្រីទេពកញ្ញាគូទធំមហាក្បត្តិ ។

១ នាងតីស្មាតាង ស៊ុះរសង់ខាងមិនឲ្យអន់ចិត្ត ។

៧ និយាយក្តីឲ្យមើលមាត្រា និយាយការឲ្យមើលទំនង ។

៨ និយាយច្រើនតែតុំស្តាប់ អប្បត្រជ្ញា ។

៩ និយាយយប់ផ្ទប់ព្រៃ និយាយថ្ងៃព្រៃមានត្រចៀក ។

១០ និយាយយប់ប្រទប់ព្រៃ និយាយថ្ងៃៗ មានត្រចៀក ។

១១ ទឹកសុំម្នេញ ទឹងកុំខ្ទេញ ស្អប់កុំញាប់ខ្ញាច ។

១២ ទំពាសតម្លែង ខ្លុកតម្លែង វែងកុំចន្ទែង មឹតកុំបណ្តេញ ។

១៣ ទឹងលេចវាស្ងាក់ ទឹងខ្លាក់ពាស្មែង ។

១៤ ទឹងដួញចេញគិតក្រោយ ពោះខ្ទឹងឲ្យៗមើលមុខ ។

១៥ ទឹងលើរឆ្កើក្រោម ។

១៦ ទឹងស៊ីចង់តីសា ខ្លិលចំការឲ្យក្អែតហ្នង ។

១៧ នៅផ្ទះម្តាយទីថៃ នៅព្រៃម្តាយដាមួយ ។

១៨ នំមិនដែលធំដាងនាឡៃ ។

១៩ ទៀយណាស់កុំឲ្យដេក យកប្រពន្ធឲ្យមើលម្តាយក្មេក ប្តូលដំណេកកុំឲ្យនិយាយនឹងប្រពន្ធ ។

អក្សរ ប

១ បងំចោយមិនមើលច្រណា, ដាំដើងគ្រានមិនប្រមាណផ្នាំង ។

២ បញ្ចើខុសស្ទើចំណុល ។

៣ ប័ស្តុកប័ស្តា អ្នកមានច្រើយថ្ងៃក្រែណាទឹងអ្នកមានកំពូ ។

๑ បន់ព្រះទៅសំពះឯចាំយ៉ាច, បន់ចាវភូមហាច្រាសាទទៅទៅ
ព្រៃស្នួសាន, បន់ពាក្យសមណព្រាហ្មណ៍ទៅយកឯពាក្យពាល ។

๑ ចានតែចាបមិនឆ្លាចមាត់ ។

๑ ចានតិតែកួតវែកតទៅតាអ៊ី ។

๑ ចានមកថាតួចរួចទៅថាធំ ។

๑ ចានមាសហើយ, ត្រូវត្រជាសរវេច ។

๑ ចានស្វាយ ណាយក្រូច ។

๑ ចាយកកក៏ចាយ, មេម៉ាយក៏ស្រី ។

๑ ចាយសង្ឃាដទៅប្រមាទឯតន្លោងចំ ។

๑ បុណ្យចាត់ជ្រុតចាប, លាតចាត់ជ្រុតយោរ ។

๑ បុណ្យក៏ធ្វើ, ឈើក៏តាប់, សត្វក៏សម្លាប់, ឫសាប់ក៏តាន់ ។

๑ ប៉ុនត្រែចកឆ្នូតជាំធំ ។

๑ ប្លុញមាត់បត់ដុំដៃ ។

๑ ប្លុសដោយវត្ត ចិត្តរដោយខ្លួន ។

๑ ប្លុសមិនរៀនបន្ទោសថាខ្លៅ ។

๑ បើជំពប់ដើងត្រាន់ចំ តែជំពប់មាត់បង់ច្រក ។

๑ បើដុះចាប់អីឡាំ, បើខ្វាន់ឆ្នាំងចាប់អីនឹងបួលរៃ ។

๑ បើចង់ពិសាឲ្យរកអន្លក់, បើចង់ស្រែណាកុងឲ្យនឿយ ។ (មានត)

ជំនាន់រឿងព្រៃឆ្នែរខ្មែរ

រឿងបៀកាំបិតបង្គោះ

(តទៅទំព័រ៣)

អាមាត្យទូលថា ត្រូវវេនមហាសេដ្ឋី ហើយស្តេចឲ្យទៅហៅមហាសេដ្ឋី ។ អាមាត្យទៅដល់ហៅថា លោកមហាសេដ្ឋីស្តេចមានព្រះរាជបន្ទូលឲ្យទៅជាឆាប់ ឯមហាសេដ្ឋីក៏ទៅជាមួយនឹងអាមាត្យទៅ ចៅកាំបិតបង្គោះជាមួយដែរ តែដំបូងជាអាពុកស្តេចឲ្យមកហៅទេ មហាសេដ្ឋីដើរទៅជាមួយនឹងអាមាត្យ ដល់ភាក់កណ្តាលផ្លូវ អាមាត្យសួរមហាសេដ្ឋីថា លោក។ ឬអ្នកណាដែរចាំកំដរយប់មិញនេះ មហាសេដ្ឋីថាកូនខ្ញុំទេ អ្នកអាមាត្យ ហើយអាមាត្យថ្កុំប់ថា ឥឡូវសត្រូវកាប់ចុងព្រះរាជវាំងរលំអស់ ចាន់ជាស្តេចឲ្យមកហៅលោកទៅ ឯមហាសេដ្ឋីឮអាមាត្យថ្កុំប់ដូច្នោះ ក៏មានសេចក្តីតក់ស្លុតថា នុកូនអើយ សូមខ្ញុំមកដែរចាំកំដរជួសអាពុកខ្លះចាន់ជាឲ្យឆ្ងាយសេចក្តីសុខ ឥឡូវសត្រូវចូលកាប់ចុងព្រះរាជវាំងអស់ តើមហាសេដ្ឋីថប់ចាប្រមូលតិតក័យគ្រែងស្ទាប់ ។

លុះដើរចូលទៅដល់ទីចុងព្រះរាជវាំង ឃើញចុងព្រះរាជវាំងរលំអស់ រឹងតែតិតក័យជាច្រើនទៀត អាមាត្យទាំមហាសេដ្ឋីទៅដល់ស្តេចទ្រង់សួរថា មហាសេដ្ឋីត្រូវវេនណាយប់មិញ មហាសេដ្ឋីក្រាបទូលថា ត្រូវវេនខ្ញុំលុះចង្អឹជាខ្ញុំ ស្តេចមានបន្ទូលថាឯណាដែរចាំកំដរ

សេដ្ឋីខូលថា កូនខូលបន្ទិចាខ្ញុំដេកចាំកំង ហើយស្តេចមានជខ្ញុំលថា មហាសេដ្ឋី ខ្លួនអ្នកឯងមានកូនប្រុសតិចាលណា ក្រែងអ្នកឯងមានតែកូនស្រីទេតើ មហាសេដ្ឋីក៏ចខ្ញុំលថាសូមទ្រង់ព្រះមេត្តាប្រទាន ឯកូនខ្ញុំលបន្ទិចាខ្ញុំនេះ កំព្រាមិនដឹងជាមកពីណា ខ្ញុំលបន្ទិចាខ្ញុំយកញាក់ព្រាសុំជាកូន ដ្បិតគ្មានកូនប្រុសឲ្យសោះ ។

ស្តេចមានចខ្ញុំលថា បើដូច្នោះឲ្យទៅហៅក់មក អាមាត្យក៏រត់ទៅហៅចៅតាំបិតបង្ខោះជង់មួយ ឯសេដ្ឋីវិនិតក៏យខ្លួនតថា នកូនអើយសមស្លាប់ជាមួយទន្លឹងអាពុកថ្ងៃនេះជាប្រាកដពុំលែង លុះអាមាត្យទៅដល់ប្រាប់ប្រពន្ធមហាសេដ្ឋីថា អ្នកស្រីស្តេចឲ្យមកហៅកូនប្រុសអ្នក នាងជាប្រពន្ធមហាសេដ្ឋីថា នុអ្នកអាមាត្យអើយ ឥឡូវខ្លួនជំណេកទៅហើយ យប់មិញនោះទៅដេកចាំកំង អត់ងងុយពាល់ត្រឹក អាមាត្យថា ទេអ្នកបើពុំជាអត់ងងុយក៏ជាស់ឡើង ដ្បិតស្តេចឲ្យហៅជាប្រញាប់ ឯប្រពន្ធមហាសេដ្ឋីប្រណីអាណិតកូន ទើបប្រើឲ្យកូនស្រីជាប្អូនចូលទៅជាស់ថាឯង៎ទៅជាស់បងឯង៎ឡើង ឯនាងកូនស្រីប្រកែកថាទេមែ៎ខ្ញុំមិនហ៊ានទៅជាស់ទេ ដ្បិតគាត់ទើបនឹងសម្រាន្តអម្បាញ់មិញនេះឯង ចៅតាំបិតបង្ខោះជង់មួយឮគេមាត់តរឭកឡើងចេញទៅក្រៅ ឃើញកូនរឭកប្រាប់កូនថា ស្តេចឲ្យមកហៅកូនទៅ តែឥឡូវកដំបូម៊ែរគេអត់ងងុយតែចាំ

ទៅគាំបិតបង្ហោះកិលុបមុខសិតសក់ខ្ទុះកញ្ជក់ស្បែកសំតត់រួចហើយក៏ចុះ
ដើរទៅជាមួយនឹងគាមាគ្យ ៧ដល់ឡើងតាល់ស្តេច ។

ស្តេចមានព្រះបន្ទូលសួរថា ទឹងហើយឯកូនអ្នកឯងមហាសេដ្ឋី
ឯមហាសេដ្ឋីទូលថា សូមទ្រង់ព្រះមេត្តាជ្រាបទឹងហើយកូនខ្ញុំបង្គំ
ជាខ្ញុំ ហើយស្តេចសួរទៅទៀតាំបិតបង្ហោះដងមួយថា ឯងប្តូនណាដេក
ពាក់ទឹងយប់មិញ ទៅគាំបិតបង្ហោះដងមួយគ្រាបទូលថាទូលបង្គំជាខ្ញុំទូល
ព្រះពុទ្ធានុដំណាកយប់ម្សិលខ្ញុំមែន សូមទ្រង់ព្រះមេត្តាជ្រាស ។
ស្តេចទ្រង់ព្រះសណ្តាប់ហើយស្តេចបន្ទូលទៅនឹងមហាសេដ្ឋីថា មហា-
សេដ្ឋី ឯវិញ្ញុងព្រះភវកេងអញ្ជើដែលឃាត់ខ្ញុំរលំអស់នេះអញពុំមានចិត្ត
ទឹងទេ ធ្លើឡើងជាថ្មីទៀតបាន តែរើសាកមនុស្សឱ្យដូចកូនអ្នកឯង
នេះមិនបានទេ នេះហើយដែលគេហៅថាជាមនុស្ស ហើយស្តេចត្រាស់
សួរថាទៅឯងឈ្មោះអ្វី ឯទៅគាំបិតបង្ហោះដងមួយក៏គ្រាបទូលថាទូល
បង្គំជាខ្ញុំឧរឈ្មោះទៅគាំបិតបង្ហោះដងមួយ ស្តេចមានបន្ទូលថា ទៅ
គាំបិតបង្ហោះយប់មិញដែលឯងដេញគាប់អញគ្រើគាប់ទឹងអ្វី ទៅគាំបិត
បង្ហោះដងមួយគ្រាបទូលស្តេចថា ទូលបង្គំជាខ្ញុំគាប់ទឹងគាំបិតបង្ហោះ ព្រះ
មហាក្សត្រិតភ្ញៅទៀតាំបិតបង្ហោះដងមួយគ្រាបទូលដូច្នោះ ស្តេចបន្ទូលថា
ឯងយកគាំបិតបង្ហោះមកមើល បើឯងថាគាប់ទឹងគាំបិតបង្ហោះនោះមែន
ទៅគាំបិតបង្ហោះដងមួយគ្រាបទូលស្តេចថា សូមទ្រង់ព្រះមេត្តាជ្រាស

បើខ្ញុំធំចង់ជាបជាគាំប៉ិតបង្ហោះនេះមុតឬមិនមុត ខ្ញុំឲ្យយកក្តារមកដាក់ដម្អែតឲ្យបាន ๗ ដាន ខ្លួលបង្គំដាំខ្ញុំគ្រាន់តែអូសថ្នាយទៅក្តារក៏ដាច់ចាំងអស់ ស្តេចពុំជឿបង្គាប់អាមាត្យឲ្យយកក្តារមកត្រែតដម្អែតគ្នា ๗ ដាន ហើយស្តេចឲ្យចៅគាំប៉ិតបង្ហោះដងមួយ យកគាំប៉ិតបង្ហោះទៅអូសស្តេចខ្ញុំឯង ឯចៅគាំប៉ិតបង្ហោះដងមួយក៏យកគាំប៉ិតបង្ហោះទៅអូសខ្ញុំឯក្តារចាំង ๗ តម្អែត ស្តេចគ្រាស់សួរថាហ្នឹងជាច់ហើយឬនៅ ចៅគាំប៉ិតបង្ហោះដងមួយក្រាបទូលថា ក្រាបទូលជាច់អស់ហើយ ស្តេចមានព្រះបន្ទូលថាបើជាច់ម្តេចក៏គ្មានស្នាម ចៅគាំប៉ិតបង្ហោះដងមួយក្រាបទូលទៅស្តេចវិញថា សូមខ្ញុំធំព្រះមេត្តាព្រះបាសបើខ្ញុំពុំជឿ សូមឲ្យមនុស្សពាញចុងដើមម៉ែលទើបដងជាជាច់ឬមិនជាច់ ស្តេចឮចៅគាំប៉ិតបង្ហោះដងមួយក្រាបទូលដូច្នោះ ស្តេចឲ្យអាមាត្យចាប់ចុងដើមពាញក៏ជាច់ចេញពីគ្នាដូចគេកាត់ ស្តេចទតទៅឃើញក្តារជាប់ពីគ្នាដូច្នោះ ស្តេចមានសេចក្តីកិតក្ល័យជាក្រៃឃ ទឹកកន្ធត្រែងយំយ៉ាថា ឃប់មិញ បើប្រសិនជាអាដែងចៅគាំប៉ិតបង្ហោះដងមួយនេះ ក៏គាប់ត្រូវអញសមអញស្វាប់ បងំអស្សារឥតការគ្មានន័យណាសមធំងអញសោះ ចាំងនេះចាំងនោះហេតុតែបុណ្យអញមានច្រើនជាមិនស្លាប់ ។

ព្រះមហាក្សត្រស្តេចទតឃើញដូច្នោះហើយ ទើបមានព្រះបន្ទូលច្រាប់ទៅមហាសេដ្ឋីថា ឯកូនអ្នកឯងនេះទើបហៅជាមនុស្សចេះក្បា

ទំនៅក្បាដ៏ធ្លោមន្ត្រីក្បាស្តេចបាន មន្ត្រីអញទាំងអស់ដែលអញឲ្យសម្លាប់
ចៅនោះគ្មានអាណាមួយទំដេះដើមឲ្យឃើញខុសត្រូវ រក្សាទំពក់ដ៏ក្បាស
ស្តេច អាល្អសអញឲ្យដេកចាំ ទំពន្ធឹងអញក់ហ៊ានដេក ចំណីអញក់ហ៊ាន
ស៊ី គ្រាន់តែចំណីទំងដំណេកអញក់ហ៊ានម្ល៉ៃយ៉ាងនេះ បើព្រះមិនជាអញ
ម៉ិនទៅ ម៉ិលចៅចិត្តគាដែងទាមុំនដែលអញសម្លាប់នេះក៏ឲ្យដែកទំង
ប្រពន្ធខ្លឹងកូនអញម៉ិនលែងវ្រាយ ។ លោយស្តេចបង្គាប់មហាសេដ្ឋីថា
មហាសេដ្ឋី ឯកូនស្រីអ្នកឯង ។ រៀបផ្សំផ្គុំឲ្យចៅគាំចិតបន្ទោះដងមួយចៅ
ឯមហាសេដ្ឋីទំងចៅគាំចិតបន្ទោះដងមួយ ក៏ថ្វាយបង្គំលាស្តេចវិលមកផ្ទះ
វិញ ដើបមហាសេដ្ឋីឲ្យរៀបធ្វើពេងទាន់ស្ងា រៀបការចៅគាំចិតបន្ទោះ
ដងមួយទំងកូនស្រីយកគ្នាជាប្តីប្រពន្ធ មហាសេដ្ឋីឲ្យហៅអស់អ្នកមុខអ្នក
ការ ខេត្តីយ៉ា ពញ្ញា ព្រះ ស៊ីវ៉ា ម្ចាង ខុនណាងញាតិស្តេចជិតវាង
ល្អះជ្រួតបូកូរការគោលល្អក៏រៀបមង្គលការផ្សំផ្គុំប្តីទំងចៅគាំចិតបន្ទោះ
ដងមួយស្រែចបរបួណានោះជាសុខសប្បាយតរៀងទៅ ។

ឯចៅគាំចិតបន្ទោះតាំងអំពីមានប្រពន្ធកាលណា ក៏ពុំខានខ្លិលតែង
ចៅតាល់បម្រើស្តេចតែសព្វថ្ងៃរៀងទៅ ឯស្តេចនោះក៏កាន់តែចាស់ជក
ក៏ទំពក្តងព្រះចិត្តថា អញចាស់ជកហើយទំងកេបុត្រាគ្មានមានតែបុត្រ
ស្លូវតែអំណោះអត់អំពីអញទៅខនតអញទំងសាបសូន្យ គ្មានកូនណាទំង
សោយរាជ្យស្នងអញនេះទេឬយ ស្លូវចៅគាំចិតបន្ទោះនេះ ក៏មានចំណេះ

ច្រើញកំរ័យោមារយោខល្អម្ល៉ះ ដូច្នេះអញនឹងផ្សំផ្គុំបុត្រអញឲ្យទៅវាឲ្យវា
សោយរាជ្យស្នងត្រង់រក្សាអស់គាណា ប្រជាទុក្ខស្ដេរនេះតរៀងទៅ ស្ដេច
ទ្រង់នឹកក្នុងព្រះចិត្តរាតម្ល៉ះ ស្ដេចទ្រង់បង្គាប់ឲ្យសង់ពេងមង្គលការអា-
ពាហ៍ពិពាហ៍ ឲ្យហោរនេន្តូវរកឫក្សការស្ដេចនឹងផ្សំព្រះកជប្រុត្រនឹងនាង
កាំបិតបន្ទោះដងមួយ ដល់បានឧក្សការគេលាល្អទើបស្ដេចឲ្យមហា-
សេដ្ឋីនាំចៅកាំបិតបន្ទោះដងមួយទៅឲ្យស្ដេច ។ ទើងរៀបមង្គលការចងដៃ
ប្រុតប្រុតផ្សំផ្គុំគ្នារួចអតិរេតឲ្យសោយរាជសម្បត្តិស្រួចបរិបូណ៌រក្សា
អស់អាណាប្រជាទុក្ខស្ដេចសុខសប្បាយតរៀងទៅ ។

ឯនាងកំរ័យាជាកូនស្រីមហាសេដ្ឋី ក៏មហាក្សត្រីស្ដេចឲ្យយកមក
ទៅជាមួយគ្នា ស្ដេចកាំបិតបន្ទោះដងមួយក៏តាំងមហាសេដ្ឋីឲ្យធ្វើជាអគ្គ-
មហាសេនាជាធំសម្រាប់រាជការរក្សាព្រះនគរស្នងព្រះនេត្រ - ព្រះកាណ
ឯមហាក្សត្រីជា ព្រះវរពោធិសត្វមាតាក៏ចាស់ជរាទន្ទឹងតអស់ទៅ ស្ដេចកាំ-
បិតបន្ទោះដងមួយឲ្យសង់ព្រះមេរុប្រាសាទស្ថិតស្ថានស្ថានរៀបចូជាព្រះ
សពព្រះវរបិតាព្រះវរមាតាធ្វើបុណ្យទេសនាសង្ឃយានាស្រួចបរិបូណ៌
ទើបឲ្យធ្វើព្រះចេតិយជាក់ព្រះធាតុទាំងពីរព្រះអង្គរួចការបុណ្យជាស្រេច
ស្ដេចកាំបិតបន្ទោះដងមួយក៏តង់ទៅជាសុខឥតទុក្ខគ្មានព្យាធិព្រះពេតាមក
បៀតបៀនព្រះអង្គទៀយ ។

សម័យថ្ងៃមួយ ស្តេចនឹកក្តុកចង់ទៅថ្វាយបង្គំស្តេចដែលធ្លាក់ចិតបន្ទោះព្រះពុទ្ធទឹង ក៏លទៅជាហៅបុរសកំសត់ទៅឡើយ ទើបស្តេចឲ្យមន្ត្រីរៀបកណ្តាលថ្មើរជើង រៀបទ័ន្ធជាងអង្គរជេន្ទ្រទ័ន្ធអស្សាចាន់ល្អុះរៀបចុះស្រេច ស្តេចផ្តាំអគ្គមហាសេនាឲ្យមើលថែទាំព្រះពុទ្ធទាំងឆ្លើយឲ្យមើលថែក្បួរអគ្គមហាសេនាទាំងពីរ ហើយស្តេចយាងឡើងទៅលើព្រះទ័ន្ធជាងអង្គរជេន្ទ្រ ចរចេញទៅ ៣ ថ្ងៃទើបបានដល់ទៅខែត្រដែនខោះ ស្តេចឲ្យភាមាត្យចូលទៅគាបសួរថា ស្តេចគាំចិតបន្ទោះដងមួយចូលមកថ្វាយបង្គំឬទេ ភាលតាដើមបានថ្វាយខ្សែបដាំបាំងកាយឯង ឆ្នាំងគ្នំនឯងទំនែវជ្រកដើរលេបទឹក ហើយស្តេចធ្វើគាំចិតបន្ទោះដងមួយព្រះពុទ្ធទឹង ឥឡូវបានសោយពុទ្ធជាស្តេចហើយ។ ចូលមកថ្វាយបង្គំភាមាត្យទាំងពួកព្រះបណ្តាំចុះហើយ ថ្វាយបង្គំលាទៅ ដល់ហើយក៏ចូលទៅចូលស្តេចនោះតាមព្រះមហាក្សត្រឆ្លាំ ស្តេចនោះទ្រង់ជ្រាបហើយទើបឲ្យរៀបទាំងពួក ភាមាត្យក៏វិលទៅទូលស្តេចគាំចិតបន្ទោះវិញថា ស្តេចជាចៅនគរអញ្ជើញស្តេចយាងចូលទៅជាធាប់ ដ្បិតទ្រង់នឹកឮកណាស់។

ឯស្តេចគាំចិតបន្ទោះដងមួយ ក៏ឲ្យអស់ពួកពលសកលយោធារៀបដំណើរចូលទៅ ដល់ហើយស្តេចចៅនគរ ជាន់តយើញស្តេចគាំចិតបន្ទោះនោះថ្លែក ស្ទើរតុំស្គាល់ក៏ស្តេចចុះពីចុងព្រះពុទ្ធទេងមកទូលថាប់ព្រះហស្តទាំងឡើងទៅ ហើយស្តេចឲ្យរៀបដង្ហែលៀងអស់ពួកពលនាម៉ឺន

សព្វមុខមន្ត្រីធំតូចឲ្យស៊ុនឹកសប្បាយចាំដរាស់ ទើបស្តេចចៅខតរតែកក្នុង
ព្រះទ័យថាអញនេះចាស់ហើយគ្មានបុត្រាធំដោះសោយកផ្សងសោះ ឯ
ស្តេចកាំចិតបន្ទោះនេះមានបុណ្យណាស់ ឥឡូវនេះបានសោយកផ្សា
ស្តេច ឯអញមានបុត្រមួយនេះមិនដឹងនឹងឲ្យទៅអ្នកឯណាទេ ស្តេចខ្វល់
តែដូច្នោះហើយ ក៏ស្តេចបង្គាប់អស់នាម៉ឺនឲ្យធ្វើកេរណ្តាប់អាពាហ៍-
ពិពាហ៍ ចាំនពេលាល្អហើយស្តេចឲ្យបុកេហិតរៀបចំផ្សំផ្គុំព្រះកដ-
បុត្រាបុត្រី ឲ្យសោយកដសម្បត្តិស្រែចបរបូណ៌ ឯខ្សែបន្ត ដំបងភ្លុយ
ឯង ឆ្នាំងឆ្នុំនឹងឯងនឹងកែវជ្រក ស្តេចជាព្រះវរបិតាក៏លើកប្រគល់ឲ្យ
ស្តេចជាព្រះកដបុត្រប្រសាចាំដរាស់ ។

ឯស្តេចកាំចិតបន្ទោះ លុះចាំនសោយកផ្សនតរាល់ហើយក៏ខ្វល់ខ្វាយ
ដល់បងនៅឯស្រែកបន្ទោះ ក៏ប្រើបម្រើឲ្យទៅហៅយកមកធ្វើជាអគ្គ-
មហាសេនាជាធំបង្អស់ ឯស្តេចកាំចិតបន្ទោះក៏ថ្វាយបង្គំលាព្រះវរបិតា
មាតា ហើយឆ្ពាំបងឲ្យមើលកដការក្សាព្រះខតរ ទើបស្តេចកាំចិតបន្ទោះ
យាងវិលទៅព្រះខតរដើមវិញ តែងតែយាងទៅយាងមក រក្សាអស់
នាណាប្រជានុកស្តេចសុកម្មការជាសុខសប្បាយតរៀងទៅ ។

រឿងចៅកាំចិតបន្ទោះឯបបរិបូណ៌តែប៉ុណ្ណេះ ។

ព្រះសមុហ៍យោសាចារ្យ យ្ហូរ-ប៉ុណ្ណា

ក្រុមដំទុំព្រះវិត្រជិដការនៅវត្តមហាសន្ទចណ្ឌិត្យរៀបរៀង

(ភាគ៧)

ពិសោធទុក្ខលបណ្ឌិត និងនាងបារិកា

ភាក្យ ៧

ទុក្ខនិស្ស័យគ្នាយ៉ាពុតអើយ បើម្ល៉ះទៅហើយបានឧណា ខ្ញុំដែនៅជាប់ជែរក្បា សមអ្នកតំគ្រាទៅម្ខាក់ឯង ។ ពីដើមបានយើងទៅពុករលួយ ផ្ទៃឈើនាំមកជល់តន្ទែង ម៉ិនមានខ្លះខាតទំស្ងួនស្ងែង ឋានជាក់ពេញជែងទាំងពុំខ្វះ ។ ថ្ងៃនេះខ្លួនយើងមានវេក ចូលមកឆ្ពោះឥតប្រណី សរបង់មគ្គលទ្បើអប្រិយ ពិញ្ញាណាស្មារតើក៏ក្ងេចភ្លាំង ។ ទាំងការព្យាយាមកំសាបសូន្យ ឥតញាតិឯងជួនជួយកំភ្លាំង មានកម្មវេរមកបិទជាំង ម៉ិនឱ្យយើងតាំងដោយសុចរិត ។ បើចាំជល់ចាស់បច្ចិចក៍ សឹមខ្លាក់នេត្រាចុះម៉ិនតិត ស្តាយតែបុត្រនោះនៅតូចពិត ប្រឹងរំលែកព្រឹត្តការសិក្បា ។ ម៉ិនខាន់ជាន់ជើងការកក់ក្រែវ ខ្ញុំដែនាំដើរទៅកេងលាយកមកចិញ្ចឹមយើងពស់ត្នា ម៉ិនខាន់ភ្ញៀវក្បែរដោយម៉ាមួន ។ ឥឡូវបើអតីតយើងហើយ ឋានឧណាទៀយខ្ញុំដែនៅថ្មុន ម្ល៉ើលការទុស្សត្រដែលល់

កូនស្ងួន ចាន់ត្រៃប់ចំនួនដូចកាលថ្ងៃ ។ ថ្ងាៃនេះអ្នកនៅចាំអាស្រែម
មានព្រួយចារម្ភគិតមមៃ ចាំមើលផ្លូវយើងមកពីព្រៃ ចាន់ឃើញអារ៉ែក
រត់ខ្លួល ។ រៈសៀលសុរិយោចាបណាស់ហើយ ទុកូនស្ងួនអើយម៉្លេះ
ក្តៅក្តួល ក្នុងខ្ទមស្ទើរប្រែរេះធាបធួល សមអ្នកដកដួលទំណាងដឹង ។
ឬមួយអ្នកកេសពុកម្តាយ ទៅគាន់ផ្លូវឆ្ងាយព្រៃស្រោងស្រឹង ឬអ្នកទៅ
លេងជិតមាត់ស្ទឹង មិនដឹងដំណឹងការនេះជាក់ ។ អ៊ីចាសាមអើយប្រុស
ពន្លក កូនអើយអ្នកមកជាពំនាក់ នាំយកសពុកម្តាយទៅជាក់ ដល់ទំ
សំណាក់អាស្រមបង ។ គ្រានោះរឹងសាមបណ្តូត អ្នកចាន់ដឹងពិត
តាមកំណត់ ពាក្យចិតាមកច្រាកដ មិនខុសកំណត់ពេលវេលា ។ ទើប
តែថ្ងៃនេះមិនឃើញមក ប៉ុមួយទំរកអស់ផលា មិនខាន់ចាន់ត្រៃប់គ្រាន់
កាលណា ទំបង្ហោគ្រាកឲ្យចាន ។ ប្តូរលោកមានភ័យហេតុណាមួយ
ធ្វើឲ្យមានព្រួយក្នុងសន្ធាន ឬពួកសត្វមើនចិត្តក្លាហាន ធ្វើឲ្យលោក
ខានមកទេដឹង ។ ទើបទំដើរកេសពុកខ្លែង កន្លងព្រៃម្ខាក់ឯងចិត្តគាន់ឆឹង
ឆឹងទំដែលលោកធ្លាប់ទៅសឹង មិនឃើញទំប្រឹងស្រែកហៅរក ។ ឆឹ
លោកមាតាបិតាអើយ ថ្ងៃនេះម្តេចឡើយលោកមិនមក ចាស់ថ្ងាៃនេះ
ហើយម្តេចនៅរក ឲ្យកូនពន្លកនៅម្នាក់ឯង ។ អ៊ីលោកគាំងពីរដើមាន
គុណ ម្តេចខុសពេលមុនទំស្ទុះស្ទែង ឲ្យកូនទៅចាំទីកខ្លែង រឹងព្រួយ
ចម្រែងឥតមានគ្នា ។ អ៊ីលោកសពុកម្តាយខ្ញុំអើយ ម្តេចលោកមិនឆ្លើយ

តបបុត្រា ក្នុងខ្លែងកូននេះស្ទើរខ្ចោចផ្សា សូមលោកមេត្តាកូនកំសត់ ។ ស្រែកហៅម៉ែមកមិនឈប់ឡើយ ឮសូរមាត់ឆ្លើយច្បាស់ច្រាកដ ស្គាល់ជាឪពុកម្តាយទើបត់ ដល់ហើយមិនអត់សូរទៅថា ។ បពិត្រលោកអ្នកមានគុណធ្ងន់ ច្រើរលើសាលន់ឥតចេះមា ម្តេចលោកមិនទៅនៅដល់ណា រសៀលសុរិយោតបណាស់ហើយ ។ ឥសីតាំងពីច្រាប់ដល់ប្តូរ ក្នុងចិត្តស្រយុតទុក្ខឥតស្ទើយ ថាឧមាសម្លាយឪពុកអើយ ក្លែកភ្លាត់អស់ហើយទៅមិនបាន ។ ទើបជនតាំងនោះយំរៀបរាប់ ដល់ទីផែលស្លាប់ធ្លាក់ច្រាណា តាំងពីថ្ងៃនេះនឹងអាក់ខាន បានសុខសប្បាយតទៅទៀត ។

បទព្រហ្មគីតិ

គ្រានោះគោធិសត្វ ឮសំរែកចិត្តមេត្តា ព្រះទ័យតាំងច្រាថ្នា យកច្រាប្បរគោជាញាណ ។ គោះកើតក្នុងដំណា ទំនុកប៉ាច្រើសិលាខាន ដឹងគុណជាប្រធាន តែងខ្នាននសត្វសត្តា ។ គោះប្រុសឬមួយស្រី ដោយសេចក្តីករុណា ឲ្យបានកើតសុខា ដោយច្រាជ្ញាដ៏ប្រពៃ ។ ប្រព្រឹត្តធម៌ខ្ពង់ខ្ពស់ មានកិត្តិយសចេះរាងវៃ ច្រើរើសសាច្រៃ អ្នកដទៃមិនស្មើឡើយ ។ បានឮលោកច្រាប់ថា មានគ្រោងភ្លាត់អស់ហើយ ទួញយំឥតឈ្លោះល្ហើយ ទុក្ខគ្មានស្ទើយក្នុងសន្តាន ។ យំច្រៃសើចក្អាកក្អាយ ខឹកសម្បុយពន់ច្រមាណ តំពូនេះភ្លាត់លើច្រាណ ធ្វើឲ្យបានពេញចំណាន់ ។

ទើបតបទៅវិញថា ខ្ញុំកុណាមិនលះបង់ ខ្លួរលោកតាំងពីអង្គ ចិត្ត
ស្មោះត្រង់មិនភ្លេច ។ ដល់វេនលើកូនហើយ សូមស្រាកស្បែយ
ពាកខ្លួកា ខ្ញុំនឹងថែរក្សា រកផលាដូចសព្វដង ។ ប្តេជ្ញាហើយនាំទៅ
ទីលំនៅឥតស្មៅហ្នង មិនហ៊ានឲ្យកន្ទុង តាមបំណងចិត្តថ្លា ។ តាំង
ពីថ្ងៃនេះឯង ខំស្រុះស្រែងរកផលា ដើម្បីនឹងរក្សា ខ្លួរបព្វជ្ជាកេងឥសី ។
បំរើតាំងថ្ងៃយប់ មិនឈរឈប់ដោយមេត្តា ចាយតែអត្តិនិចណា
ព្រឹកល្ងាចក្តីមិនលោះលះ ។ ពេលថ្ងៃរកផ្លែឈើ ពេលយប់ផ្លុំក្តួង
គ្រឹហា តក់ក្រែចាប់ចាគា កល់វេលាមិនដែលខាន ។ អស់តាំងពួក
ខេត្តា តែងស្នេហាចិត្តពប់អាន ។ សូម្បីពួកអ្នកប្លាន ចិត្តស្មោះស្មាន
ត្រប់ៗគ្នា ។ ឥតមានសត្វណាមួយ ធ្វើឲ្យព្រួយដល់ចិត្តា សុទ្ធតែ
ដួយរក្សា ចានសុខាតាំងយប់ព្រឹក ។ មានកាលថ្ងៃមួយនោះ លោក
គ្រាច់ឆ្ពោះទៅដងទឹក មានពួកក្អែងសត្វខ្មែគ ទៅភ្លក់ភ្លឹកហែត្រសង ។
ទៅដល់មាត់តំពង់ មិនពរដើរចុះទៅដង វិលមកតាមបំណង ពួកសត្វ
ដងដួយរក្សា ។ ពេលនោះស្តេចបិលយក្ស ពួនលបលាក់ក្នុងគ្រឹក្សា
ចេញបដោយរមេហា ដាក្សត្រាដែនកាសី ។ លុះឃើញសាមកុមារ
ថ្លែកអស្ចារ្យលើដែនដី ឃើតឆ្ងល់ញាំទៅខ្លី ឥតប្រែណាដូលតិចឡើយ ។
សុវណ្ណសាមនោះណា ត្រូវក្សត្រាចាញ់ដូលហើយ ឃើចាប់ចុកឥត
សេរ្យី ដួលដេកកើយលើផ្ទៃខ្សាច់ ។ (មានត)

(តមក)

ដោយហេតុ ពីព្រោះខ្លួនក្សោយទាំងព្រលឹងរបស់កូនក្មេងនោះវាខ្លាំងជាងខ្លួនឯងក្សោយ លុះព្រលឹងមាតាជ្ញាស្មារតីរបស់កូនក្មេង ។

ទី ៦ - កាលកុមារកុមារីមានវ័យនៅក្មេងវាងឆាយុ ៦ ឬ ៧ ឆ្នាំ ប៉ុណ្ណោះជាក្មេងមិនទាន់ពេញកំឡាំងនៅឡើយ, មាតាបិតាមិនត្រូវប្រើការឲ្យធ្វើការធ្ងន់ ។ មានវែកសែងជាដើមទេ ។

ទី ៧ - មិនត្រូវដើរទាំងបណ្តាយឲ្យកូនក្មេងចេះដើរប្រទេចបុរោណភាក្យទៅរោះបោះបោក ។

ទី ៨ - ត្រូវថែរក្សាញ៉ាំឲ្យមកូនក្មេងដោយទុក្ខយដ៏ល្អ ត្រូវចែងឲ្យមានគំនិតស្មារតីដ៏ប៉ិនឲ្យមានបុគមាយោគសណ្តាប់ធ្នាប់ថ្លៃថ្នូ ឲ្យមានភាក្យសំដីនិយាយចំពោះអ្នកផងតិចតួច ផ្ទែមល្ហែម, ទាំងការបរិភោគអាហារចំណីក៏ត្រូវឲ្យមានកំណត់ពេលវេលា, ត្រូវទុកស្បៀងសំអាតឲ្យគ្រាន់ដំរេចខ្លួនឯងប្រាណនឹងត្រឹងស្មៀកពាក់ទឹកថ្នេងដេកនៅដើម្បីបង្ការរោគ, ត្រូវបំប៉ោនកូនក្មេងឲ្យមានសាច់ធំជាត់កុំឲ្យស្គាំងស្គម, ត្រូវ

ឋង្ហាត់ឲ្យចេះស្ងាត់ក្នុង ការគោរពកោតខ្លែងចំពោះត្រកូលឪអ្នកឯទៀត
ដែលគួរគោរព, មិនត្រូវបណ្តាយតាមអំពើចិត្តរបស់ពាល ។

ទី ៥ ត្រូវបៀនកូនក្មេងឲ្យចេះពាប់ចំនួនរបស់អ៊ីផ្សេង ។ ឲ្យចេះគិត
ការញ៉ាំគ្នេរតាំងពីរបស់ ๓ ឬ ๔ ឡើងទៅ ឲ្យចេះពាប់លេខពាយលេខឬក
ដោយមាត់ខេ, ឲ្យចេះថែរក្សាផ្ទះសម្បែងខ្លួនឲ្យសមត្ថភាពដឹងជាតំនាំ
វិនាសចំរើនខាតចំណេញឬបណ្តោះអាសន្នឬបណ្តើរតាំងពីក្មេង ។

ទី ៦ មាតាបិតាត្រូវតាំងខ្លួនឲ្យមានមារយាទសុចរិតឬកតាថ្លៃថ្នូរល្អ
ឲ្យសមស័ក្តិថាជាមាតាបិតា គួរជាទីគោរពជាតម្រាប់ដ៏ល្អរបស់បុត្តធីតា,
ដើម្បីឲ្យបុត្តធីតា ចម្លងយកបែបបទចរិតដ៏ល្អនោះតទៅ; បុគ្គលជា
មាតាបិតា ត្រូវចំណាត់ខិតខំសិក្សាឲ្យសមក្នុងក្មេងឲ្យរឿយ ។ ដើម្បីឲ្យ
ស្គាល់ពុតត្បុតដំណើរលំនាំទើបងាយទំនងប្រដៅឬតម្រែតម្រង់ការជុះដល់ក
ក្នុងកាលដែលវាមានវ័យចំរើនឡើង ។

ទី ៧ ត្រូវបង្ហាត់បុត្តធីតា ឲ្យមានការយោគក្នុងតីឲ្យចេះគោរព សំពះ
ដំរាបសួរញាតិសន្ថានឬបុគ្គលចាស់ព្រឹទ្ធាចារ្យក្នុងកាលដែលខ្លួនជួបលើ
រកឬគេជួបមករកខ្លួន ឲ្យចេះស្ងាត់ក្នុងការធ្វើបដិសណ្ឋារៈតាមសមគួរ
ដល់គុណសម្បត្តិរបស់ភ្ញៀវដែលជួបមករក ព្រោះជាបុត្តធីតា ក្នុងត្រ-
កូលខ្លះស្រុកខ្លះមានការគ្នាដែលមិនចេះសំដែងសេចក្តីគួរសមចំពោះ
អ្នកណាសោះ សូម្បីតែមាតាបិតារបស់ខ្លួន ក៏មិនដែលឃើញនូវលំនាំខ

សោះ មនុស្សខ្លះធ្ងន់កាយយ៉ាងនេះតាំងពីក្មេងរហូតចាស់តែខ្លួនចាស់ស្លាប់ចាត់ទៅវិញ មិនដែលបានគោរពសំពះមាតាបិតា អស់មួយជីវិតមនុស្សបែបនេះក៏មានច្រើនណាស់ដែរ ។ បុត្តធីតាធ្ងន់កាយបែបនេះនឹងឲ្យខុសពៅលើកូនក៏មិនបាន ព្រោះតែមាតាបិតាមានអាការខ្ជិលខ្ជាតតាប់ទម្លាប់បានជាបុត្តធីតាក៏មានកិរិយាធ្ងន់បែបនោះដែរ សមដូចបុរាណាចារ្យតថា "ដំងឹងធ្ងន់ព្រោះដង កូនធ្ងន់ព្រោះម្តាយ ប្តូរចេញពីម្តាយ សាយដល់កូន" ។ ដំណើរនេះច្រើនតែភ្ញាក់ពោសពៅលើមាតា ព្រោះហេតុនេះស្តែងជាមាតាចេះបុត្តធីតា តួរប្រយ័ត្នបង្ហាត់កូនឲ្យមានសណ្តាប់ធ្នាប់ល្អ កុំឲ្យធ្ងន់បែបនោះ តើមុនដំបូងត្រូវមានបង្ហាត់កូនឲ្យចេះសំពះបិតា ទើបឯបិតាក៏ត្រូវបង្ហាត់កូនឲ្យសំពះមាតា, ។ សព្វថ្ងៃបង្ហាត់បណ្តាក់គ្នាទៅវិញទៅមកវឿយៗ យ៉ាងនេះទៅគង់ធំធាត់បានបទបាត់ធ្ងន់ពុំខាន ។ បើមាតាបិតា ពន្យល់កូនឲ្យសំពះខ្លួនឯងក៏ហាក់ដូចជាមិនត្រូវទំនង ។ មួយទៀតអាមាតាបិតាត្រូវ។ សព្វថ្ងៃនិយាយរឿងអ្វីផ្សេង។ ដែលខ្លួនចេះចាំឲ្យកូនចៅស្តាប់ ដើម្បីឲ្យកូនចេះពាក្យពេចន៍ហើយឲ្យរៀនឱ្យយល់តាមជាហេតុនឹងឲ្យកូនក្មេងចេះពាក្យសំដីល្អ មនុស្សជាន់មុននេះបន្តិចម៉្លេះតែគ្រប់ស្រុកច្រើនតែនាំកូនក្មេងឲ្យចេះសូត្រពាក្យថា "ចាក់ចឹកដូនមេឡូនមេរា កន្ទុយត្រីឆ្លាសៅខាងអុក កន្ទុយត្រីដូកសៅខាងកែវ អកកំបោរបញ្ចាំងដំ បំពងបុស្សប្រមាញ់កែក ក្បាលទំពែកក្អែកជុះងាប់ប៉ិត" អ្នកខ្លះ

ឲ្យសូត្រថា "ចាក់ទឹកដូងមេឰងមេលៀប ចាន់ត្រពៀចពាក់អាវត្រែតើ ទឹកនៅលើត្រពើនៅត្រោម" ប៉ុណ្ណោះដោយ ខាងបុងដូចគ្នា; មួយបែបទៀតថា "រើកៗដង្វរ, ស្ពឺនៅផ្លូវ ក្តាម, ស្រមេមស្រមាម បង្កង, (๑)ដំពង់ត្រីរស់, ទាំតប់ ស្ពារ, ស៊ីបន្លា រមាស, មានខ្មាស ពន្លែល" ប៉ុណ្ណោះដោយ ។

ការបង្រៀនកូនក្មេងឲ្យចេះចាំពាក្យទាំងនេះដោយហេតុឲ្យកូនក្មេងចេះពាក្យសំដីច្រើនរឿងក៏ជាការល្អមួយដែរហើយ តែមិនសូវមានប្រយោជន៍ផ្ទាល់ខ្លួន គួរបង្រៀនកូនក្មេងឲ្យចេះរាប់អក្សរពីមួយដល់ដប់ឲ្យស្ទាត់ជាមុនសិន ... ក ខ ... អាទិត្យចន្ទ ... មិគសិរ បុស្យ ... ជូត ឆ្នូរ ... ហោរាសី ។ តើត្រូវចោទសួរកូនក្មេងអំពីថ្ងៃខែឆ្នាំ ហើយនិយាយប្រាប់ឲ្យស្គាល់ថ្ងៃតើមានប៉ុន្មាន? ថ្ងៃណាជាដើម? ក្នុងមួយឆ្នាំៗតើមានប៉ុន្មានខែ? ខែណាជាដើម? ឆ្នាំតើត្រូវរាប់យកឆ្នាំណាជាដើម? ការបង្រៀនកូនក្មេងឲ្យចេះរាប់ឲ្យស្គាល់បែបនេះឯង ជាការមានប្រយោជន៍ច្រើនជាងការសូត្រពាក្យចាក់ទឹកដូងជាដើម ។

ការប្រែប្រួលកូនក្មេងឲ្យមានសណ្តាប់ធ្នាប់ល្អ ជាការបណ្តោះអាសន្នដូចសំដែងមកប៉ុណ្ណោះនេះ ជាការបណ្តុះផ្ទាំក្រាញ្ញាស្មារតីឲ្យមានប៉ុនប៉ងខ្ពស់ចំរើនឡើងផង ដើម្បីឲ្យស្រួលដល់ការបង្រៀនរបស់គ្រូផងជាការងាយការបង្រៀនផង ។

๑- ខ្លះថា: ពុកស្រមាម បង្កង ។

លុះក្មេងក្នេងមានអាយុ៦ឬ៧ឆ្នាំ ហើយត្រូវនាំយកទៅទុកដាក់ក្នុងសំណាក់ ត្រូវរៀនសូត្រវិជ្ជាគណ្យ។ រីឯលេខនព្វន្តមិនត្រូវបណ្តោយទុកឲ្យទៅចំនេះ។ កុំគាលទុកក្មេងគ្មានអ្វីសោយឯកតំឡាំងប្រើប្រាស់ ព្រោះថាក្មេងតំណាលប៉ុណ្ណេះ កាលបើប្រែក្បាញ់ញ៉ាំឲ្យហាត់ទើយភ្លាំងតេកប្រែរួលកំដៅថ្ងៃភ្លាំងជាហេតុឲ្យបាត់តំឡាំងខួបខាតស្មារតីបង់ក្មេងខ្លីងសិក្សាវិជ្ជាអ្វីមិនសូវអង់អាចក្លៀវក្លា ព្រោះហេតុនោះ បុគ្គលជាមាតាបិតាដែលមានបុត្តប្រុសស្រីបម្រើឲ្យទទួលធុរៈការសិក្សា គួរថ្នមតំឡាំងកាយកេរុបាយបណ្តុះប្រាជ្ញាស្មារតីបង់ក្មេង ហើយត្រូវសំរៀងរៀនឲ្យសម្បត្តិសម្រាប់ជួយបំពេញកិច្ចសិក្សាសិល្បសាស្ត្រដល់បុត្តធីតាបង់ទួន។ ដើម្បីធ្វើដំណើរនៃការចេះដឹងឲ្យជឿនលឿនឡើងទៅតាមកាលសម័យ ។

សិល្បសាស្ត្រក្នុងលោកនេះមានច្រើនយ៉ាងជាគនេក ។ ពាក្យថាសិល្បសាស្ត្រនេះច្រើនតែគេប្លែចិត្តថា "ជាន់ដល់មន្តអាគមសម្រាប់ផ្ទុំស្មោះត្រង់ប្រុសប្រសិទ្ធិឲ្យតែមានអាប់មិនមុតជុតមិនចេះជាដើម" តែពាក្យថា "សិល្បសាស្ត្រ" ក្នុងទីនេះមិនសំដៅយកដូច្នោះទេ ។ ឯពាក្យថា "សិល្បៈឬសិប្ប" នេះ ប្រែថា សេចក្តីឆ្លៀវឆ្លាសតិវិជ្ជាដែលស្ទាត់ពលវារៈ កុងតម្លាមន្តលត្ថទិដ្ឋិ ជាជាន់ដល់ហត្ថកោសល្យ ប្រែថា "សេចក្តីឆ្លៀវឆ្លាសដោយដៃ" ឬហត្ថកម្មតីការដែលស្ទាត់ដោយដៃ ។

ពាក្យថា "សាស្ត្រ" ប្រែថាគម្ពីរ, ក្បួនច្បាប់, តម្រា ឬ សៀវភៅ ។ យក
សិល្បៈមករួមបទជាមួយគ្នាហៅថា "សិល្បសាស្ត្រ" គឺគម្ពីរដែលសំដែង
អំពីសិល្បៈផ្សេងៗ មានច្រើនប្រភេទដូចសេចក្តីដែលត្រូវសំដែងតទៅ ។

សិល្បៈនេះបើនិយាយរួមរួមមានតំណាងដោយសង្ខេបមាន ២ យ៉ាងគឺ

ទី ១ អនាគារិយសិប្បៈ សិល្បៈចេះសង់ប្រាសាទ ដូចយ៉ាងព្រះ
អាទន្ធូរត្ថេរមានប្រាជ្ញាស្មារតីឈ្លេងយល់កន្លងការហែក, កាត់, ដេរ, តក់,
ដែលតក់ស្បង់ចីពរសង្ឃាដិឲ្យមានខណ្ឌមានមណ្ឌល មានភ្នាតបន្ទាត់ត្រូវ
តាមនៃយោនុញ្ញាតរបស់ព្រះសម្មាសម្ពុទ្ធ ។

ទី ២ អាគារិយសិប្បៈ សិល្បៈចេះគ្រហស្ថដែលគេចេះស្ងួតក
ក្នុងរៃកន្លងសិល្បៈផ្សេងៗ មានធនុសិប្បៈ ពាសុសិប្បៈ ស្ងួតកន្លងរៃកន្លងការ
ជាញ់ធ្វើ, ស្ងួតកន្លងការជាងឈើជាដើម ។

កន្លងទីនេះនឹងសំដែងអំពីសិល្បៈចេះគ្រហស្ថដូចមានសេចក្តីតទៅ

សិល្បៈ ដែលអ្នកស្រុកមជ្ឈិមប្រទេសកន្លងសម័យបុពណាតាំងពី
មុនពុទ្ធកាលរហូតដល់មកក្នុងសម័យពុទ្ធកាល, គេតែងនិយមកាន់អាន
សិក្សាខ្លះមានច្រើនយ៉ាង តាមៗចាយប្រាជ្ញាប្រសប់អ្នកប្រាជ្ញក្នុងដំណាក់
ខ្លះចំណែកសាខាវិជ្ជាទៅជាច្រើនចំណែកណាស់ តែដែលប្រាកដមក
ក្នុងគម្ពីរៗមានខន្ធវគ្គខ្លះកន្លងកាយ កាប់គោលសិល្បៈធំៗ ហៅថាមហា-
សិល្បៈមាន ១៨ យ៉ាងគឺ (មានត)

ពិធីបុណ្យបញ្ចុះខណ្ឌសីមា

នៅវត្តសាំងសាម៉ (ព្រៃវែង)

កាលពីថ្ងៃពុធ ១១ កើតខែពិសាខឆ្នាំវក ឆស័ក ព. ស. ២៤៧៧ ត្រូវនឹងថ្ងៃទី៣ ខែមិថុនា ១៩៣៤ ថ្ងៃនោះសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ នឹងពួកព្រះកជាគណៈហានុក្រម ជាមួយនឹងព្រះភិក្ខុសង្ឃច្រើនអង្គ ព្រមទាំងអ្នកមុខអ្នកការជាច្រើនគ្នាទៀត បានទៅមកក្នុងនឹងអញ្ជើញទៅរៀបចំចាត់ការពិធីបុណ្យបញ្ចុះខណ្ឌសីមាដ៏ឧឡារិក នៅវត្តសាំងសាម៉ (ព្រៃវែង) ។

ឯភូមិបរិវេណវត្តនេះ តែខ្ទុះក៏មានចំនួនច្រើនណាក់ គេបែងគ្នាជា ៨ ក្រុម តម្រូវឲ្យតាន់តាប់យ៉ាមត្រប់ទាំង ៨ ទិស រួមនឹងក្រុមទិសតែងកណ្តាលមួយទៀតផងក៏ត្រូវជា ៩ ក្រុម ។ បណ្តាបរិវេណទាំង ៩ ក្រុមខ្ទុះក្តី ក្រុមទីមួយ។ គេនិមន្តភ្ញៀវសង្ឃ ១០ ឬ ១១ អង្គឲ្យគង់នៅប្រចាំការក្នុងកេរដែលគេចែងត្រៃចនានោះយ៉ាងត្រឹមប្រមាប់ត្រប់ទិស ។ ឯទីវាងក្រៅជុំវិញព្រះវិហារ គេតាក់តែងដោយយកដីតំនឹងដីធ្វើជាគូបជុំៗ ទៅទាំងកន្លែងមានរៀបតាក់តែងក្តីផ្កាជារង្វឹងសក្ការបូជាដល់ព្រះរតនត្រ័យ ។ លុះវេលាម៉ោង ៩ យប់នោះ គេប្រជុំអស់គ្នាគង់តែងដង្ហែយកបូសសីមាដ៏ស័ក្តិសិទ្ធដើរប្រទក្សិណ ៣ ជុំហើយ ក៏ចូលទៅរៀបតែងដល់ដំណុំសង្ឃ មានអង្គសម្តេចព្រះមហាសុមេធាធិបតីជាប្រធាន ដែល

តន់ខៅរៀបរយខាងក្នុងព្រះវិហារ ។ ខណៈនោះព្រះភិក្ខុសង្ឃចំរើនព្រះបរិត្ត លុះចប់ហើយទើបគេនិមន្តលោកគ្រូព្រះអរិយធម្មមុនី ឲ្យសំដែងធម្មទេសនាអំពីសេចក្តីគោរព ៧ ប្រការនិងអានិសង្សសីមាគាថា ខៀត ។ លុះដល់ថ្ងៃព្រហស្បត៍ ១៦ កើតខែផ្នាំដដែលនេះ ខៅវេលាថ្ងៃរសៀល ក្រុមអ្នកគាន់ទំសង៍ឯស់នោះគេនិមន្តធម្មកថិកាចារ្យជាច្រើនអង្គ ឲ្យសំដែងធម៌ទេសនាផ្សេងៗគ្នា គឺពេលក្នុងទំសន៍មួយៗមានធម្មកថិកទេសនាជាតកមួយៗ ឯខាងក្នុងព្រះវិហារទេសនាពីជាតក, កំប្លែងនេះគេហៅថាទេសនាទេសជាតក៍ ។ ដល់វេលាយប់ទៅម៉ោង ៩ គេនិមន្តព្រះសង្ឃចំរើនព្រះបរិត្តចប់ហើយ ទើបអាចនានាលោកគ្រូព្រះជ្ឈាន់តេនមុនីវង្សចៅអធិការវត្តនោះឲ្យសំដែងធម្មទេសនា ក្នុងរឿងបឋមត្រាស់ (បឋមសម្ពោធិ) ។ ខៅពេលចប់គ្នានោះ គេរៀបចំកំប្លុងពុទ្ធាភិសេក គឺអភិសេកព្រះពុទ្ធរូបបដិមាការជាច្រើនអង្គ ។ ឯព្រះអង្គដែលធំបណ្តាប់ជាងគេនោះ គឺជារបស់ដែលសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ចាន់តសាង់លាយចម្រុះដោយលោហធាតុនឹងរតនវត្ថុច្រើនយ៉ាងគឺ: ស្ពាន់-លង្ហិន-ទង់ដែង-ទង់ហ្វាំ-ច្រាក់-មាសដែលជាងរិចិត្រវចនាឲ្យមានសម្បុរលើបលែង ហាក់ដូចបញ្ចេញរស្មី ៦ ព័ណ៌ ។

លុះដល់ថ្ងៃ ๑๓ កើត គេក៏នាំគ្នាដង្ហែរលោកសីមាគ្រប់ទិសទាំងអស់ជាមាន់កន្ត ព្រះវិហារ ហើយគេចងប្រចាក់ទៀនអម្បោះសមន្តរាត្រីជុំវិញជាប់គោលរាត្រីម៉ោង ๙ យប់ គេក៏ទំមន្តព្រះសង្ឃឲ្យសូត្រព្រះបរិត្តផ្សេងៗគ្នាទៅតាមសីមាទាំង ๙ រៀងគ្នា មិនឲ្យសូត្រមន្តដូចលោកមុន ។ ទៀយ ។ លុះរួចស្រេចកិច្ចនោះហើយ ទើបជំនុំសង្ឃទាំង ๑๗๑ អង្គ មានសម្តេចព្រះមហាសុមេធាធិបតីជាប្រធាន ក៏រៀបចំធ្វើកិច្ចសង្ឃកម្មតទៅ ។ លោះនោះពួកព្រះសង្ឃសមណសក្តិពីរជាគណៈ ហានាខុតមក គឺ; ព្រះសមាធិធម្ម ๑ ព្រះធម្មវង្ស ๑ ព្រះគ្រូបញ្ញាចរិយាបិដក ๑ ព្រះវិបស្សនា ๑ ជាអ្នកសូត្រដក សូរនិមិត្ត, ញត្តិសន្ទុតសីមាគ្រប់ទិសទាំងអស់ ព្រះពុទ្ធឃោសាចារ្យចារឹហ្វាង៣ សាលាជាលីជាន់ខ្ពស់ ๑ ព្រះសាក្យវង្សអធិបតីតែមជុំទុំព្រះវិនៃបិដក ๑ ព្រះអរិយធម្មមុនី ๑ ព្រះវជិរមេធា ๑ និងហានាខុតមកប្រទានអង្គខៀត ជាអ្នកជួយរៀបចំកិច្ចាខុកិច្ចសព្វគ្រប់ ឯសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកវត្តសាកវ័នទំនឹងព្រះសុធម្មាធិបតី សង្ឃនាយកវត្តបទុមវតី ជាប្រធានាធិបតីឲ្យសម្រេចកិច្ចសង្ឃកម្ម បញ្ចុះឈ្មោះសីមាកន្លងវេលាយប់នោះឯង ។

លុះព្រឹកឡើងតិថ្ងៃសៅរ៍ ๑๔ កើត ត្រូវនឹងថ្ងៃ ๖ ខែមេសា ๑๙๔๖ នេះ នៅវេលាម៉ោង ๗ ព្រឹក ព្រះសង្ឃទាំងអម្បាលនោះមានសម្តេចព្រះមហាសុមេធាធិបតីជាប្រមុខ បានទំមន្តចូលទៅដួបជុំនៅខាង

ក្នុងព្រះវិហារដើម្បីចាំទទួលព្រះករុណាជាអម្ចាស់ដ៏វិសេសលើសត្ត្វ ។ ចំ-
ណែកខាងអស់លោកពុជការក្នុងវែងត្រនោះ ក៏ចាត់រៀបចំតាក់តែងព្រះ
ពន្ធាមួយដ៏វិចិត្រវេចនា គួរជាទីទស្សនាការឧឡារៈដោតចង់ទន់ដ៏ឃ្លាំ-ភ្លូច
ជាជួរវៀងកាយ អមសងខាងផ្លូវនៅចំមុខព្រះវិហារនោះ ។ ឯកាសនោះ
ជាទីប្រជុំនៃអស់លោកនាម៉ឺនធំ - តូច ព្រមទាំងភពួកប្រជាជនក្នុងវែង ត្រ
នោះសឹងតែឈប់ឈរណែនណាន់តាន់តាប់ នៅរង់ចាំទទួលព្រះករុណា
ជាអម្ចាស់ដ៏វិសេសត្ត្វនៃវែរ ។

លុះដល់វេលាម៉ោង ៩ ព្រះករុណាជាអម្ចាស់ដ៏វិសេសត្ត្វ, លោក
អ្នកឧកញ៉ា អគ្គមហាសេនា សេនាបតី, លោកឡីវេស៊ុដន៏រួមវែងត្រនោះ
លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ, លោកអ្នកឧកញ៉ាខាងឯបតី
ចៅហ្វាយវែងត្រ, លោកអ្នកឧកញ៉ាស្រីធម្មាធិបតី, លោកអ្នកឧកញ៉ា
សុន្ទរកថាធិបតី ទាំងលោកចៅហ្វាយស្រុក ព្រមទាំងអស់លោកអ្នកពុជ-
ការក្នុងវែងត្រនោះជាច្រើននាក់ទៀត ស្តេចយាងអញ្ជើញទៅដួចដុំព្រម
ក្នុងទីនោះដើម្បីជាអធិបតីក្នុងវិធីការតំឡូសបន្លើយកិច្ចបញ្ចុះទណ្ឌសីមា ។

ឯការកាត់ផ្តាច់ឫសសីមានោះ គឺព្រះករុណាជាអម្ចាស់ដ៏វិសេសត្ត្វ
ស្តេចទ្រង់ព្រះទម្រង់ផ្ទាល់ដាក់ផ្តងលើខ្សែអម្បោះ ដែលរុំស្រោចដុំសិលា
នៅចំកណ្តាលព្រះវិហារនោះ លោកឡីវេស៊ុដន៏រួមវែងត្រចាប់គាន់អន្លង
លើកឡើង ការបើកឫសទួលញាណដោយតេជៈយេតន៏ត្រប់ ៣ ជន់ហើយ

លោកឡើងស៊ើជងត់នោះ ព្រះទម្រង់ក៏សើដោយអន្ទងដែលកាន់នោះ ឯឫស
សីមាក៏ជាប់ភ្នាក់ចុះក្នុងរណ្តៅនោះភ្លាម នៅពេលដំណាលគ្នាចាំងអស់ ។
លុះរួចកាលកំប្លុងនោះហើយ ព្រះគុណជាអម្ចាស់ដ៏វិតលើគ្រួងព្រមចាំង
វដ្តមន្ទីចាំងអម្បាលនោះ ក៏ស្តេចយាងអញ្ជើញវិលត្រឡប់ទៅវិញ
ដោយមានសេចក្តីសោមនស្សរីករាយចំពោះបុណ្យនោះយ៉ាងក្រៃលែង ។

ពីដើមបុណ្យបញ្ចុះទណ្ឌសីមាដ៏ធ្ងន់ធ្ងរភ័យយ៉ាងនេះ ដែលកើតជារុង
រឿងខ្ចប់ខ្ចើង សុទ្ធសឹមក្បាច់ខ្ពស់ទៅបាន ក៏ដោយសារតែគុណបុណ្យព្រះ
ចារ្យព្រះគុណជាអម្ចាស់ដ៏វិតលើគ្រួង ទំនឹងគុណកដការអាណា-
ត្យាចុលបានជួយទបគ្គម្ភះដោយមុឺងម៉ាត់ផង ហើយជាកិច្ចបុណ្យសមតាម
បំណងរបស់សម្តេចព្រះមហាសុមេធាធិបតី ដែលមានប្រាថ្នាចង់ឲ្យបាន
សេចក្តីសុខសេចក្តីចំរើនកែងក្បាយធំរូលាយ ខ្លួនៅដល់សង្ឃរួមណ្តុលក្នុង
តម្កល់ដង្ហែចាំងមូល បានដាច់ការទំមន្តព្រះសង្ឃគ្រប់ភូតគ្រប់គណៈឲ្យ
ប្រមែប្រមូលធ្វើសង្ឃកម្មក្នុងវិដាមួយគ្នា បានសេចក្តីសុខស្រួលឥតមាន
សៅហ្មងអ្វីសោះឡើយ ។ សេចក្តីចំណង់ល្អដ៏សំខាន់របស់សម្តេចព្រះ
មហាសុមេធាធិបតីនោះក៏ត្រូវតាមខ្នងនៃពុទ្ធកាសិតដែលទ្រង់ត្រាស់ថា:
"សុខា សង្ឃស្ស សាមគ្គី សេចក្តីព្រមព្រៀងគ្នាទើបបាន"
សេចក្តីសុខ ដូច្នេះពិតមែនហោង ។

ព្រះគ្រិស្តសាសនារឿង គុយ-សូត្រ

ដែលបានដំណើរការបោះពុម្ពផ្សាយ ។

អំពីចៅអធិការនៃធម្មត្តិសង្ឃ

ដែលទើបតាំងថ្មីក្នុងឆ្នាំទៃម៉ោ ១៩៤៤

១ — សញ្ញាប័ត្រលេខ ១២ ចុះថ្ងៃ ១៧-៩-៤៤ តាំងគ្រូសូត្រ ខូ-ពិន កើតឆ្នាំខាល អាយុ ៤២ វស្សា ២១ នាមឆាយា អនុ្ញជោត-ត្ថេរ ជាចៅអធិការ វត្តព្រះកមវេរ្ញ ឃុំដៃជ្រុក ស្រុកវលាជ្រៃ (កំពង់ឆ្នាំង) ។

២-សញ្ញាប័ត្រលេខ ១៣ ចុះថ្ងៃ ១៧-៩-៤៤ តាំងគ្រូសូត្រ ប៉ែន-ហ៊ុន កើតឆ្នាំរោះ អាយុ ៥៤ វស្សា ៣២ នាមឆាយា សុជម្ប-ញ្ញា ជាចៅអធិការ វត្តសន្ទៃ ឃុំអណ្តូងស្នាយ ស្រុកវលាជ្រៃ (កំពង់ឆ្នាំង) ។

៣-សញ្ញាប័ត្រលេខ ១៤ ចុះថ្ងៃ ១៧-៩-៤៤ តាំងគ្រូសូត្រ ជេត-ស៊ី កើតឆ្នាំរោះ អាយុ ៤៤ វស្សា ២៤ នាមឆាយា សុនន្ទាភ-ត្ថេរ ជាចៅអធិការ វត្តអង្គស្រែផែ ឃុំរលាំងគ្រៃល ស្រុកសំរោងទង (កំពង់ស្ពឺ) ។

៤-សញ្ញាប័ត្រលេខ ១៥ ចុះថ្ងៃ ១៧-៩-៤៤ តាំងគ្រូសូត្រ សុខ-ប៊ុន កើតឆ្នាំខាល អាយុ ៣០ វស្សា ៩ នាមឆាយា ឋិណ្ណត្ថេរ ជា-ចៅអធិការ វត្តស្រែតាចាន់ ឃុំសែនដី ស្រុកសំរោងទង (កំពង់ស្ពឺ) ។

៥- សញ្ញាប័ត្រលេខ ១៦ ចុះថ្ងៃ ១៧-៩-៦៤ តាំងត្រួសត្រួស-ច្រែស កើតឆ្នាំច អាយុ ៣៤ វស្សា ១៤ នាមនាយា សុវណ្ណ-ប្បញ្ញា ជាចៅអធិការ វត្តស្រែស្រែង ឃុំសែនដី ស្រុកសំពោធិ៍ខ្ពស់ (កំពង់ស្ពឺ) ។

៦- សញ្ញាប័ត្រលេខ ១៧ ចុះថ្ងៃ ១៧-៩-៦៤ តាំងត្រួសត្រួស-សាម-រឹម កើតឆ្នាំពេង អាយុ ២៩ វស្សា ៧ នាមនាយា សុវ័ណ្ណនេរ ជាចៅអធិការ វត្តទឹកហូត ឃុំទឹកហូត ស្រុកលោងប្អូរ (កំពង់ឆ្នាំង) ។

៧- សញ្ញាប័ត្រលេខ ១៨ ចុះថ្ងៃ ១៧-៩-៦៤ តាំងត្រួសត្រួស-ម៉ៅ-ស៊ីម កើតឆ្នាំមមែ អាយុ ២៩ វស្សា ៩ នាមនាយា ឥន្ទ្រជោត ជាចៅអធិការ វត្តសាលាមុខវង្ស ឃុំទឹកហូត ស្រុកលោងប្អូរ (កំពង់ឆ្នាំង) ។

៨- សញ្ញាប័ត្រលេខ ១៩ ចុះថ្ងៃ ២០-៩-៦៤ តាំងត្រួសត្រួស-រស់-ខឹម កើតឆ្នាំឆ្លូវ អាយុ ៥៩ វស្សា ៣៩ នាមនាយា ឥន្ទ្រសារ ជាចៅអធិការ វត្តទុតិ្តមានជ័យ ឃុំត្រៃញាតិ ស្រុកគងពិសី (កំពង់ស្ពឺ) ។

៩- សញ្ញាប័ត្រលេខ ២០ ចុះថ្ងៃ ២០-៩-៦៤ តាំងតិក្ខមាស-កុល កើតឆ្នាំឆ្លូវ អាយុ ៥៩ វស្សា ៣៦ នាមនាយា សុវណ្ណនេរ ជាចៅអធិការ វត្តគគណាភម ឃុំព្រៃឯកឯក ស្រុកត្រែងកក់ (តាកែវ) ។

កែពាក្យខុស

កន្លែងមួយសុរិយោះលេខ ៥ ខែឃ្លាំង ១៨៦៤ [តែងចំព័រ ៤៧២ បន្ទាត់ ១០ ។

តែងពាក្យថា: "អង្គ ១ បេស់ក្អែត" ឲ្យកែជា "អង្គ ១ បេស់ក្អែប" ដូច្នេះវិញ ។